ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- គណៈប្រធានរដ្ឋកម្ពុជាប្រជាធិបតេយ្យ
- គណៈកម្មការស្វែងរកការពិត

លេខ៧ ខែកក្កដា ឆ្នាំ២០០០

# ស្វែងរកការពិត

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ៧ ខែកក្កដា ឆ្នាំ២០០០


## មាតិកា


- សំបុត្រៈ ខៀវ សំផន........................................ ១

**ផ្នែកឯកសារ**

- ចិនៈ ភូមា និងរបបខ្មែរក្រហម........................................ ២
- ប្រវត្តិរូប ដួន ប្រាសិទ្ធ........................................ ៦
- ប្រជុំគណៈរដ្ឋមន្ត្រីលើកទី១........................................ ៨
- រណ្ដៅសាកសពប្រល័យពូជសាសន៍ខេត្តបន្ទាយមានជ័យ......... ១២
- ញត្តិរបស់ប្រជាជន........................................ ១៥
- ជួបជាមួយសិស្ស និងមិត្តភក្តិជំនិត របស់សមមិត្ត ឌុច........... ១៦
- វាលពិឃាតចម្ការស្វាយចន្ទី........................................ ២០
- ប្រវត្តិរូបបដិវត្តន៍សមមិត្ត គង់........................................ ២៤
- ការរៀបចំឯកសារទាក់ទងនឹងអំពើប្រល័យពូជសាសន៍........... ២៨

**ផ្នែកប្រវត្តិសាស្ត្រ**

- សោកនាដកម្មនៅភូមិកោះផល........................................ ២៩
- សម្ភេទពីមន្ទីរស-២១........................................ ៣២

**ផ្នែកច្បាប់**

- គំរូមួយនៃភ័ស្តុតាងឯកសារ........................................ ៣៦
- កម្ពុជា និង រ៉្វាន់ដា........................................ ៤០

**វេទិកាពិភាក្សាសាធារណៈ**

- ការវិវត្តថ្មីៗជុំវិញច្បាប់ជំនុំជម្រះក្ដី........................................ ៤៤
- វត្ថុអស្ចារ្យពីរប្រភេទ........................................ ៤៦
- ការទាមទារប្រវត្តិសាស្ត្រកម្ពុជាមកវិញ........................................ ៥០

**ធំព័រស្រាវជ្រាវរកគ្រួសារ**

- ប្រវត្តិរណ្ដៅសាកសពក្រោយគុកទួលស្លែង........................ ៥៤
- ជីវិតពិតរបស់ខ្ញុំក្នុងរបបកម្ពុជាប្រជាធិបតេយ្យ.................. ៥៨

**សិល្បៈខ្មែរក្រហម**

- **ចម្រៀងខ្មែរក្រហមៈ** រដូវវស្សាហើយយើងប្រមូល.......... ក្របក្រោយ




ណេរីន



ខៀវ សំផន



អៀង សារី



ខៀវ សំផន នាទសវត្សរ៍ឆ្នាំ៦០


## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា



អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ០២៩១ពម៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**វាគ្មិនលេខនេះ៖** ចាយ៉ា វ៉ាមជី, ហេឡែន ហ្វារីស, ដេវីត ឆេនដល័រ, ស៊ីវ ហេង៉ែរ, ស៊ូសាន់យុក, ប៊ីរធីល លីណឺរ, ឆាំង សុង **អ្នកនិពន្ធនិងស្រាវជ្រាវៈ** សាន់ កល្យាណ, លី សុផល, ដួង សុភារិទ្ធ **ជំនួយការនិពន្ធនាយកៈ** អែម សុខឃីម **និពន្ធនាយករងទី១ៈ** ផាត កុសល **និពន្ធនាយករងទី២ៈ** សឹម សុរិយ៉ា **អ្នកបកប្រែៈ** សួ ប៊ុនស៊ូ **និពន្ធនាយកទូទៅៈ** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ឹម សុភ័ក្រ្ត, **គ្រប់គ្រងការចែកផ្សាយៈ** ទ្រី សុភក្តិ

*សំបុត្រ*

# ខៀវ សំផន

កាលខ្ញុំនៅរៀនឯមហាវិទ្យាល័យ ខ្ញុំបានបកប្រែនិក្ខេបបទរបស់ ខៀវ សំផន ដែលមានចំណងជើងថា វឌ្ឍនកម្មនៃសេដ្ឋកិច្ចនិងឧស្សាហកម្មកម្ពុជា ។ មុនពេលបកប្រែនិក្ខេបបទនេះ ខ្ញុំក៏ប្រហែលជាមិនខុសពីយុវជន យុវនារីបច្ចុប្បន្នមួយចំនួនសព្វថ្ងៃនេះទេដែលតែងតែគិតថា ខៀវ សំផន គឺជា «បញ្ញាជន» ជាអ្នកស្អាតស្អំនិងមិនពុករលួយ ។



ធាតុពិត និក្ខេបបទរបស់ ខៀវ សំផន គឺគ្រាន់តែជានិក្ខេបបទចាស់គំរឹលមួយសរសេរជាភាសាបារាំងនៅមហាវិទ្យាល័យប៉ារីសក្នុងឆ្នាំ១៩៥៩ ហើយដែលប្រើប្រាស់មិនកើត ក្រៅពីឆ្លុះបញ្ចាំងឲ្យឃើញត្រឹមតែភាពមិនប្រាកដនិយម របស់ ខៀវ សំផន តែប៉ុណ្ណោះ ។ ខៀវ សំផន ដែលមានតំណែងជាគណៈប្រធានរដ្ឋនៃរបបខ្មែរក្រហម បានរុញច្រានសេដ្ឋកិច្ចកម្ពុជាឲ្យនៅក្រោមសូន្យ ហើយបង្កឲ្យប្រជាជនរាប់សែននាក់ស្លាប់ដោយខ្វះស្បៀងអាហារ ។ នៅក្នុងសន្និសីទកំពូលលើកទី៥នៃប្រទេសមិនចូលបក្សសម្ព័ន្ធនាទីក្រុងកូឡុំបូ ប្រទេសស្រីលង្កា (ថ្ងៃទី១៦-១៩ ខែសីហា ឆ្នាំ១៩៧៦) ខៀវ សំផន បានថ្លែងសុន្ទរកថាក្នុងឋានៈជាគណៈប្រធានរដ្ឋកម្ពុជាប្រជាធិបតេយ្យថាៈ...ដើម្បីយើងខ្ញុំផ្តើមបានឯករាជ្យសេដ្ឋកិច្ចឲ្យបានបរិសុទ្ធយើងខ្ញុំត្រូវប្រឹងដោយឈរលើជំហរឯករាជ្យម្ចាស់ការ ហើយទាល់តែសេដ្ឋកិច្ចយើងខ្ញុំមានឯករាជ្យបរិសុទ្ធទើបធានាដល់ឯករាជ្យនយោបាយរបស់យើងខ្ញុំឲ្យរក្សាភាពបរិសុទ្ធបាន...។ ភាពបរិសុទ្ធដែល ខៀវ សំផន ដឹកនាំរបបខ្មែរក្រហម បានកំណត់យកជាគោលការណ៍កសាងសង្គមមហាលោតផ្លោះ មហាអស្ចារ្យ១ហ៊ិកតា៣តោននោះ គឺកម្ចាត់ចោលនូវអ្វីៗទាំងអស់ដែលមានពីមុនមក រួមទាំងរូបិយវត្ថុ និងទីផ្សារដែលជាមូលដ្ឋានមួយនៃការពង្រីក និងដោះដូរសេដ្ឋកិច្ច ។

ជាបញ្ញវន្ត ខៀវ សំផន គ្រាន់តែជាមនុស្សម្នាក់បានសិក្សានៅបរទេសនៅក្នុងអតីតកាល ។ បច្ចុប្បន្ននេះ មានយុវជន យុវនារី ខ្មែររាប់ម៉ឺនសែននាក់ដែលមានការយល់ដឹងខ្ពង់ខ្ពស់ ច្រើនរាប់មិនអស់ ហើយគ្មាននរណាម្នាក់បានបង្កឲ្យមានទុរ្ភិក្សនៅកម្ពុជាដូច ខៀវ សំផន នោះទេ ។ យើងមិនត្រូវភ័ន្តច្រឡំ អតីតកាលនិងបច្ចុប្បន្ន ។ ការសិក្សារបស់ ខៀវ សំផន ឬ និក្ខេបបទរបស់ ខៀវ សំផន មិនបានជួយដល់ជាតិនិងប្រជាជនកម្ពុជាសោះឡើយ ផ្ទុយទៅវិញបានរួមចំណែកបង្កឲ្យមានការស្លាប់មនុស្សជាង១លាននាក់នៅក្នុងរបបខ្មែរក្រហម ។

**ឆាំង យុ**

# ចិនៈ ភូមា និងរបបខ្មែរក្រហម

ចុងខែវិច្ឆិកា ឆ្នាំ១៩៧៧ ឧត្តមសេនីយ៍ ណេ វីន ដែលជាមេដឹកនាំយោធាផ្តាច់ការនៃប្រទេសភូមា និងជាប្រមុខរដ្ឋដំបូងគេបំផុត ហើយក៏ជាប្រមុខរដ្ឋតែមួយគត់នៃប្រទេសមិនមែនកុម្មុយនិស្តបានមកទស្សនកិច្ចនៅប្រទេសកម្ពុជា នៅពេលដែលរបបខ្មែរក្រហមកំពុងតែកាន់អំណាចនៅឡើយ ។ ណេ វីន បានចំណាយពេលអស់ជាច្រើនថ្ងៃនៅក្នុងប្រទេសកម្ពុជាក្នុងដំណើរទស្សនកិច្ចមួយដែលទទួលស្វាគមន៍ដោយ ខៀវ សំផន និងមេដឹកនាំខ្មែរក្រហមដទៃទៀត ។ ណេ វីន ត្រូវបានអញ្ជើញទៅទស្សនាប្រាសាទអង្គរវត្ត និងអាងក្រពើនៅក្រុងសៀមរាប ។ ឧត្តមសេនីយ៍ ណេ វីន ក៏បានធ្វើដំណើរទស្សនកិច្ចនៅក្រុងភ្នំពេញ ដែលក្នុងពេលនោះស្ទើរតែត្រូវបានបោះបង់ចោលទាំងស្រុង ។

នៅក្នុងសុន្ទរកថាមួយដែលធ្វើឡើងនៅរាជធានីភ្នំពេញ នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ១៩៧៧ ឧត្តមសេនីយ៍ ណេ វីន បានថ្លែងថា «ថ្ងៃ១៧ ខែមេសា គឺជាថ្ងៃប្រវត្តិសាស្ត្រមួយសម្រាប់ប្រជាជនកម្ពុជា យើងខ្ញុំមានសេចក្តីរីករាយឥតឧបមា ដែលប្រជាជនកម្ពុជាបានទទួលជ័យជម្នះដ៏ឯកច្ឆ័ន្ទនៅក្នុងការតស៊ូដើម្បីស្វែងរកឯករាជ្យសម្រាប់ប្រទេសនិងប្រជាជនរបស់ខ្លួន» ។ មេដឹកនាំភូមារូបនេះបានបញ្ជាក់ជាថ្មីអំពីការគាំទ្ររបស់ខ្លួនចំពោះបដិវត្តន៍កម្ពុជា នៅក្នុងសុន្ទរកថាលើកទី២ នាពិធីជប់លៀងលាគ្នាដែលរៀបចំឡើងជាការផ្តល់កិត្តិយសដល់ឧត្តមសេនីយ៍ ណេ វីន នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៧៧ ថា «កម្ពុជាបានទទួលឯករាជ្យទើបតែក្នុងពេលថ្មីៗនេះប៉ុណ្ណោះ ក៏ប៉ុន្តែនៅក្នុងរយៈពេលដ៏ខ្លីនេះបានស្តែងយ៉ាងច្បាស់ក្រឡែតថា ប្រជាជនកម្ពុជាទាំងមូលក្នុងស្មារតីម្ចាស់ការសម្រេចបាននូវសមិទ្ធផលដ៏គួរឲ្យកត់សម្គាល់ នៅក្នុងការតស៊ូដើម្បីកសាងប្រទេសជាតិឡើងវិញ» ។ ទោះបីជាមានភាពសុក្រឹតផ្នែកការទូត ក៏ដូចជាការបញ្ចេញការលើកសរសើរជាសាធារណៈបែបនេះក៏ដោយ ក៏ចិនប្រាកដជាប្រទេសនៅពីក្រោយដំណើរទស្សនកិច្ចខុសពីធម្មតាបែបនេះ ដោយចិនសង្ឃឹមថានឹងស្រោចស្រង់របបខ្មែរក្រហមឲ្យរួចផុតពីភាពឯកោផ្នែកការទូត ។ ណេ វីន ក៏បានបង្ហាញឥរិយាបថសម្របទៅនឹងការចង់បានបែបនេះដែរ ដោយរដ្ឋាភិបាលភូមារបស់គាត់សង្ឃឹមថាក្រុងប៉េកាំងនឹងកាត់បន្ថយការគាំទ្ររបស់ខ្លួនចំពោះបក្សកុម្មុយនិស្តភូមាដែលបានប្រយុទ្ធប្រឆាំងនឹងរដ្ឋាភិបាលភូមាស្ទើរតែចាប់តាំងពីពេលទទួលបានឯករាជ្យពីប្រទេសអង់គ្លេសនៅក្នុងឆ្នាំ១៩៤៨ មកម្ល៉េះ ហើយប្រទេសចិនបានផ្តល់ជំនួយដ៏ច្រើនសន្ធឹកសន្ធាប់ចាប់តាំងពីឆ្នាំ១៩៦៨ ដល់ចលនាបក្សកុម្មុយនិស្តភូមា ។ ប្រទេសចិនបានបង្ហូរចូលនូវសព្វាវុធដ៏ច្រើនសន្ធឹកសន្ធាប់រួមមានទាំងអាវុធយុទ្ធភណ្ឌ គ្រាប់រំសេវ និងជំនួយដទៃទៀតរួមទាំងទីប្រឹក្សាយោធានិង «អ្នកស្ម័គ្រចិត្ត» ដល់បក្សកុម្មុយនិស្តភូមាក្នុងបរិមាណច្រើនជាងដែលប្រទេសចិនបានផ្តល់ដល់ចលនាកុម្មុយនិស្តដទៃទៀតក្នុងទ្វីបអាស៊ីក្រៅតែពីប្រទេសនៅឥណ្ឌូចិន ។


ណេវីន

បក្សកុម្មុយនិស្តភូមាមានលក្ខណៈដូចគ្នាជាច្រើនទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យ ។ មេមនោគមន៍វិជ្ជារបស់បក្សកុម្មុយនិស្តភូមាឈ្មោះ ឃិន ម៉ូងជី បានសិក្សានៅក្នុងបណ្ឌិតសភាវិទ្យាសាស្ត្រសង្គមនៅទីក្រុងម៉ូស្គូ នៅចន្លោះឆ្នាំ១៩៥៧ និងឆ្នាំ១៩៦០ ហើយបន្ទាប់មកគាត់បានសរសេរនិក្ខេបបទមួយស្តីអំពីបញ្ហាកសិកម្មនៅក្នុងប្រទេសភូមាដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងនិក្ខេបបទរបស់ខៀវ សំផន ស្តីពីបញ្ហាដូចគ្នានេះនៅក្នុងប្រទេសកម្ពុជា ក្នុងលក្ខណៈគួរឲ្យភ្ញាក់ផ្អើល ។ បន្ទាប់អំពីការបែកបាក់នៃចលនាកុម្មុយនិស្តអន្តរជាតិនៅចុងទសវត្សរ៍ឆ្នាំ៥០ និងដើមទសវត្សរ៍ឆ្នាំ៦០


កម្មាភិបាលខ្មែរក្រហមអបអរសាទរគណៈប្រតិភូប្រទេសភូមា



ពួកកុម្មុយនិស្តភូមាបានប្រកាន់ជំហររបស់ខ្លួនជាសម្ព័ន្ធមិត្តជាមួយនឹងប្រទេសចិន ហើយតំណាងពួកកុម្មុយនិស្តទាំងនេះដែលនៅក្រុងម៉ូស្គូរួមមានឃិន ម៉ូងជី ត្រូវបានបង្ខំឲ្យចាកចេញពីសហភាពសូវៀតនៅក្នុងឆ្នាំ១៩៦៣ ។ ក្នុងឆ្នាំ១៩៦៨ ប្រទេសចិនសម្រេចផ្តល់ការគាំទ្រទាំងស្រុងដល់ «ចលនាតស៊ូបដិវត្តន៍» របស់បក្សកុម្មុយនិស្តភូមា ហើយនៅក្នុងរយៈពេលប្រមាណ២-៣ឆ្នាំប៉ុណ្ណោះ «តំបន់រំដោះ» មួយដែលមានទំហំផ្ទៃដីប្រមាណ២០០០០ម៉ែត្រក្រឡា ត្រូវបានបង្កើតឡើងនៅភាគឦសាននៃប្រទេសភូមាដែលជាទីតាំងដ៏អំណោយផលងាយស្រួលនៅតាមព្រំដែននៃខេត្តយូណាននៃប្រទេសចិន ។

បក្សកុម្មុយនិស្តភូមាដែលត្រូវបានចិនទទួលស្គាល់ថាជាបក្សកុម្មុយនិស្ត «ភាតរភាព» មួយ បានធ្វើទំនាក់ទំនងជាមួយនឹង ខាំង សឹង ប្រធានទីភ្នាក់ងារសម្ងាត់ដ៏កំណាច ។ នាយកដ្ឋានទំនាក់ទំនងអន្តរជាតិរបស់បក្សកុម្មុយនិស្តចិន ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ខាំង សឹង ។ នាយកដ្ឋានទំនាក់ទំនងអន្តរជាតិនេះបានធ្វើរបាយការណ៍ដោយផ្ទាល់ជូនគណៈកម្មាធិការមជ្ឈិម ដូចដែលអ្នកស្រាវជ្រាវជនជាតិអូស្ត្រាលីចន ប៊ីរ៉ន និង រ៉ូបឺត ភែក បានថ្លែងថា «នាយកដ្ឋានទំនាក់ទំនងនេះមានសិទ្ធអំណាចស្មើរតែឥតព្រំដែននៅក្នុងកិច្ចការក្រៅប្រទេសនៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ៥០ និង៦០ ដោយបានពង្រីកឥទ្ធិពលដ៏មហិមាជាងរដ្ឋាភិបាលនិងក្រសួងការបរទេសរបស់ប្រទេសចិនទៅទៀត ។ នៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ៧០ ទីស្នាក់ការធំរបស់បក្សកុម្មុយនិស្តភូមានៅឯខេត្តប៉ាងសាងនៅក្បែរព្រំដែនខេត្តយូណាននៃប្រទេសចិនដែលពុំមែនជាមូលដ្ឋានធំតែមួយគត់សម្រាប់បក្សកុម្មុយនិស្តភូមានោះទេ មានតំណាងបក្សកុម្មុយនិស្តថៃមួយចំនួនតូច និងកម្មាភិបាលជាងម្ភៃរូបមកពីបក្សកុម្មុយនិស្តឥណ្ឌូនេស៊ីរួមមានទាំងកូនស្រីពីរនាក់របស់លោកប្រធាន អាយឌីត ដ៏មានអំណាចនៃបក្សកុម្មុយនិស្តឥណ្ឌូនេស៊ីនាពេលនោះ ។ វិទ្យុ «សម្លេងបដិវត្តន៍ម៉ាឡេស៊ី» របស់បក្សកុម្មុយនិស្តម៉ាឡេ បានផ្សព្វផ្សាយពត៌មានពីហេងយ៉ាង ភាគខាងត្បូងនៃចាងសា នៅក្នុងខេត្តហ៊ូណានប្រទេសចិន ។

មិនតែប៉ុណ្ណោះ «បក្សកុម្មុយនិស្តភាតរភាព» ទាំងអស់មានការិយាល័យជាច្រើនទៀតនៅគួនមីង ក៏ដូចជានៅក្នុងការិយាល័យការទូតធំនៅក្រុងប៉េកាំង ។ ខាំង សឹង មានផែនការដ៏ធំ ហើយមូលដ្ឋានរបស់បក្សកុម្មុយនិស្តភូមាដែលមានទីតាំងនៅតាមព្រំដែនខេត្តយូណានគឺជាឈ្នាន់ដែល ខាំង សឹង សង្ឃឹមថានឹងប្រើប្រាស់ដើម្បីលោតទៅពង្រីកឥទ្ធិពលលទ្ធិកុម្មុយនិស្តទៅកាន់បណ្តាប្រទេសនៅអាស៊ីភាគអគ្នេយ៍ ។ ក៏ប៉ុន្តែបន្ទាប់មក ខាំង សឹង ដែលជាអ្នកផ្តល់ដំបូន្មាននៃបក្សកុម្មុយនិស្តភូមា បានស្លាប់នៅក្នុងក្រុងប៉េកាំងនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៧៥ នៅក្នុងអាយុ៧៧ឆ្នាំ ។ មិនដល់មួយខែ

ក្រោយមកដែលគឺនៅថ្ងៃទី៨ ខែមករា ឆ្នាំ១៩៧៦ ជូ អេនឡាយ (ដែលជានាយករដ្ឋមន្ត្រីប្រទេសចិន) បានស្លាប់ដោយរោគមហារីកតម្រងនោម ។ មជ្ឈដ្ឋានជាច្រើនបានជឿជាទូទៅថា ជូ អេនឡាយ មានគោលបំណងប្រគល់មុខតំណែងនេះទៅឲ្យ តេង ស៊ាវពីង ដែលជាមេដឹកនាំមានភាព «ប្រាកដនិយម» ខ្ពស់ជាង ដើម្បីគ្រប់គ្រងរដ្ឋាភិបាល ។ ដោយ ខាំង សឹង បានលាចាកលោកទៅ មេដឹកនាំកុម្មុយនិស្តក្បាលរឹងភូមាទាំងនោះមានអារម្មណ៍ថា ឥទ្ធិពលរបស់ពួកខ្លួនស្ថិតនៅក្នុងគ្រោះថ្នាក់នៃការវាយកម្ទាត់គ្រប់ពេលវេលា ។ ភរិយារបស់ ម៉ៅ សេទុង ឈ្មោះ ចាងឈីញ ដែលជាអតីតតួកុនដ៏ស្រស់ស្អាត បានធ្វើយុទ្ធនាការដ៏សាហាវឃោរឃៅមួយក្នុងគោលបំណងកម្ទាត់ តេង ស៊ាវពីង និងមន្ត្រីដទៃទៀតដែលនិយមកណ្តាល ។

ការតស៊ូដណ្តើមអំណាចបានពុះកញ្ជ្រោលយ៉ាងខ្លាំងឡើងរហូតដល់ខែមេសា ឆ្នាំ១៩៧៦ ដែលនៅពេលនោះពួកឆ្វេងនិយមរបស់ប្រទេសចិនព្យាយាមជ្រៀតខ្លួនចូលទៅក្នុងអំណាចហើយបណ្តេញ តេង ស៊ាវពីង ពីមុខតំណែង ។ បក្សកុម្មុយនិស្តភូមាមិនដូចជាបក្សកុម្មុយនិស្តដទៃទៀតនៅក្នុងតំបន់ឡើយ ។ បក្សនេះបាន «ប្រព្រឹត្តនូវកំហុសដ៏ធំ» នៅក្នុងការប្រកាសយ៉ាងខ្វះខ្វារគាំទ្រពួកជ្រុលនិយមក្បាលរឹងនៃប្រទេសចិនៈ នៅក្នុងខែមិថុនា ឆ្នាំ១៩៧៦ បក្សកុម្មុយនិស្តភូមាបានថ្លែងនៅក្នុងសារលិខិតអបអរសាទរមួយនៅក្នុងទិវាបុណ្យ ខួបទី៥៥ នៃបក្សកុម្មុយនិស្តចិនថា «ក្រុមពួកសេរីរើដែលមានការពាក់ព័ន្ធជាមួយនឹង តេង ស៊ាវពីង ដឹកនាំដោយ លាវ សាវគី ត្រូវបានវាយឲ្យបរាជ័យ» ។ សារលិខិតនោះបន្តទៀតថា «ចលនាដើម្បីវាយបំបាក់ការប៉ុនប៉ងរបស់ពួកសេរីរើខាងស្តាំដើម្បីបង្វិលបញ្ច្រាសទិសនូវមាគ៌ាត្រឹមត្រូវ និងសេចក្តីសម្រេចរបស់គណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនិស្តចិនស្តីពីវិធានការប្រឆាំងនឹងលោកប្រធានពួកស្តាំនិយម តេង ស៊ាវពីង គឺស្របគ្នាយ៉ាងពេញលេញជាមួយនឹងលទ្ធិម៉ាក្ស-លេនីនដែល ម៉ៅ សេទុង បានគិតទុកជាមុន ។»

ប៉ុន្តែបន្ទាប់មក ម៉ៅ សេទុង បានស្លាប់នៅថ្ងៃទី៩ ខែកញ្ញា ឆ្នាំ១៩៧៦ដដែលនោះ ។ បក្សកុម្មុយនិស្តភូមាបានថ្លែងនៅក្នុងសារលិខិតចូលរួមមរណទុក្ខចំពោះមរណភាពរបស់លោកប្រធានដែលមានវ័យចំណាស់នេះថា «ក្រោមមគ្គុទ្ទេសក៍ដ៏ភ្លឺស្វាងនៃមាគ៌ាបដិវត្តន៍វណ្ណៈកម្មកររបស់លោកប្រធាន ម៉ៅ សេទុង ប្រជាជនចិនបានទទួលជ័យជម្នះដ៏មហិមានៅក្នុងការកសាងសង្គមនិយម និងបដិវត្តន៍សង្គមនិយមនៅក្នុងមហាបដិវត្តន៍វប្បធម៌របស់វណ្ណៈកម្មករទទួលបានជោគជ័យនៅក្នុងការរិះគន់ដល់មាគ៌ាពួកសេរីរើប្រឆាំងនឹងបដិវត្តន៍របស់ លាវ សាវគី ទទួលជោគជ័យក្នុងការរិះគន់ លីន ពៀវ និងក្នុងការរិះគន់ តេង ស៊ាវពីង និងវាយឲ្យបរាជ័យនូវពួកសេរីរើស្តាំនិយមដែលប៉ុនប៉ងអនុវត្តបញ្ច្រាសនឹងមាគ៌ាត្រឹមត្រូវ និងពង្រឹងផ្តាច់ការវណ្ណៈកម្មករ ដោយធ្វើដូច្នេះពង្រឹងបាននូវសាធារណរដ្ឋប្រជាមានិតចិនដែលជាខែលនៃបដិវត្តន៍កម្មករទូទាំងពិភពលោកដែលគួរឲ្យជឿទុកចិត្តបាន» ។

បក្សកុម្មុយនិស្តភូមាមានហេតុផលក្នុងការធ្វើការវាយតម្លៃឡើងវិញ និងដាក់សំណួរចំពោះភាពអាចពឹងពាក់បាននៃខែលនេះនៅពេលដែលលោកប្រធាន តេង ស៊ាវពីង បានឡើងកាន់អំណាចជាថ្មីម្តងទៀតនៅក្នុងសមាជនៃគណៈកម្មាធិការមជ្ឈិមមួយនៅក្រុងប៉េកាំងកាលពីខែកក្កដា ឆ្នាំ១៩៧៧ ។ ខាំង សឹង បានទទួលមរណភាព ហើយបន្ទាប់មកប្រធាន ម៉ៅ បានធ្វើឲ្យទស្សនាវដ្តី «ប៉េជីង រីវយូ» និងប្រព័ន្ធផ្សព្វផ្សាយពត៌មានជាផ្លូវការដទៃទៀតរបស់ប្រទេសចិនដែលធ្លាប់បានផ្សព្វផ្សាយពត៌មានពីសមរភូមិនិងឯកសាររបស់បក្សកុម្មុយនិស្តភូមា បានបញ្ឈប់ការបោះពុម្ពផ្សាយនូវអ្វីទាំងអស់ដែលទាក់ទងទៅនឹងការតស៊ូបដិវត្តន៍នៅក្នុងប្រទេសភូមា ។ ឈ្មោះបក្សកុម្មុយនិស្តភូមាត្រូវបាននិយាយជាលើកចុងក្រោយនៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៦ នៅពេលដែលប្រធានបក្សកុម្មុយនិស្តភូមាឈ្មោះ តាក់គីន បាធានទីន និងអនុប្រធាន តាក់គីន ប៉េទីន បានធ្វើដំណើរទៅកាន់ទីក្រុងប៉េកាំងដើម្បីចូលសួរសុខទុក្ខទាយាទ (អ្នកស្នង) របស់លោកប្រធាន ម៉ៅ ឈ្មោះ ហួ គួហ្វេង ដែលមិនយូរប៉ុន្មានបន្ទាប់នោះក៏បានបាត់បង់អំណាចធ្លាក់ទៅក្នុងដៃ តេង ស៊ាវពីង ។ នៅក្នុងបរិបទនេះហើយដែលរដ្ឋាភិបាលយោធារបស់ប្រទេសភូមាដឹកនាំដោយឧត្តមសេនីយ៍ ណេ វីន ប្រញាប់ប្រញាល់ឲ្យបានឆាប់បំផុតនៅក្នុងការប្រើប្រាស់ក្បួននេះដោយបង្កើតជាទំនាក់ទំនងល្អជាមួយនឹងប្រទេសចិនតាមរយៈប្រទេសកម្ពុជាដោយក្នុងពេលនោះបង្កើនការផ្តោតការយកចិត្តទុកដាក់របស់ខ្លួនទៅលើការចាប់អារម្មណ៍និងការព្រួយបារម្ភរបស់ប្រទេសចិនចេះតែកើនឡើងចំពោះភាពឡើងចាងរបស់ប្រទេសវៀតណាមក្នុងការគ្រប់គ្រងប្រទេសជិតខាងនៅក្នុងឥណ្ឌូចិនទាំងមូល ។ កងកម្លាំង

កុម្មុយនិស្តទទួលបានជោគជ័យនៅក្នុងបណ្តាប្រទេសឥណ្ឌូចិនទាំងបី ហើយក៏ស្រាប់តែបែកបាក់គ្នាអស់មួយរំពេចទៅវិញដោយប្រទេសចិនគាំទ្ររបបខ្មែរក្រហមនៅក្នុងប្រទេសកម្ពុជា ហើយសហភាពសូវៀតគាំទ្រវៀតណាម និងឡាវ ។ដំណើរទស្សនកិច្ចរបស់ឧត្តមសេនីយ៍ ណេ វីន មកកាន់ក្រុងភ្នំពេញពិតជាទទួលប្រយោជន៍តបវិញដូច្នោះមែន ។ នៅក្នុងឆ្នាំ១៩៧៨ ការិយាល័យមជ្ឈិមរបស់បក្សកុម្មុយនិស្តភូមាដែលស្ថិតនៅក្នុងប្រទេសចិនទាំងមូល រួមបញ្ចូលទាំងស្ថានីយ៍ «វិទ្យុផ្សាយសម្លេងរបស់ប្រជាជនភូមា» ត្រូវបានចាប់បង្ខំឲ្យត្រឡប់មកតំបន់ប៉ាងសាងនៃប្រទេសភូមាវិញ ។ «អ្នកស្ម័គ្រចិត្ត» ជនជាតិចិនក៏ត្រូវបានហៅឲ្យវិលត្រឡប់មកប្រទេសចិនវិញដែរ ។ទំនាក់ទំនងរវាងរដ្ឋាភិបាលក្រុងប៉េកាំងនិងរដ្ឋាភិបាលក្រុងរ៉ង់ហ្គូនពេលនោះបង្ហាញនូវសញ្ញានៃភាពរឹងមាំប្រាកដប្រជាអស់រយៈកាលជាច្រើនទសវត្សរ៍បន្ទាប់មក ។ តេង ស៊ាវពីង បានប្រកាសក្នុងពេលដំណាលគ្នានេះនៅក្នុងប្រទេសម៉ាឡេស៊ីដោយសារភាពថា ទំនាក់ទំនងរវាង «រដ្ឋាភិបាលនិងរដ្ឋាភិបាល» គឺខុសពីទំនាក់ទំនងរវាង «បក្សនិងបក្ស» ក្នុងន័យបង្កប់ថា ការគាំទ្ររបស់ចិនចំពោះបក្សកុម្មុយនិស្តភូមា និងចលនាបះបោរកុម្មុយនិស្តស្រដៀងគ្នានេះនៅក្នុងតំបន់នឹងនៅតែបន្ត ។ ក៏ប៉ុន្តែ សំណេរបែបនេះសរសេរថាអ្នកទាំងអស់ដែលនៅក្រោមការគាំទ្ររបស់ពួកមន្ត្រីចិនដែលគាំទ្រ បាធានទីន និងបក្សកុម្មុយនិស្តភូមា មុខជានឹងស្លាប់ឬក៏អស់អំណាច... ។ តេង ស៊ាវពីងមានគម្រោងដទៃទៀតសម្រាប់ការពង្រីកឥទ្ធិពលរបស់ប្រទេសចិននៅក្នុងតំបន់អាស៊ីអគ្នេយ៍លើសពីការគ្រាន់តែផ្តល់អាវុធដល់ពួកបដិវត្តន៍កុម្មុយនិស្ត ។ ដោយប្រឈមមុខជាមួយនឹងស្ថានការណ៍ថ្មីបែបនេះ គណៈកម្មាធិការមជ្ឈិមរបស់បក្សកុម្មុយនិស្តភូមាបានជួបប្រជុំជាបន្ទាន់និងជាហូរហែចាប់តាំងពីខែវិច្ឆិកា ឆ្នាំ១៩៧៨ រហូតដល់ខែមិថុនា ឆ្នាំ១៩៧៩ ហើយបុណ្យខួបទី៤០នៃបក្សកុម្មុយនិស្តភូមានៅថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៩ ត្រូវបានចុះថយស្ងាត់ទៅវិញ ។ នៅក្នុងសុន្ទរកថាដ៏វែងមួយទៅកាន់កម្មាភិបាលដែលអស់កម្លាំងចិត្តរបស់គាត់ បាធានទីន បញ្ជាក់ថា បក្សត្រូវតែ «ម្ចាស់ការលើខ្លួនឯង» ហើយលោកប្រធាន បាធានទីន មានប្រសាសន៍ដោយមិនបញ្ជាក់ច្បាស់ថា បក្សកុម្មុយនិស្តភូមា «បានប្រព្រឹត្តកំហុសជាច្រើន» នៅក្នុងប្រវត្តិសាស្ត្ររបស់ខ្លួនដែលមានរយៈពេល៤០ឆ្នាំ «ការមិនជឿតជ្រែកគ្នាទៅវិញទៅមកត្រូវបានប្រកាសថាជាទិដ្ឋភាពមួយដ៏ធំនៃទំនាក់ទំនងរវាងបក្សកុម្មុយនិស្តភូមាជាមួយនឹងបក្សកុម្មុយនិស្តភាតរភាពដទៃទៀត» ។ បក្សកុម្មុយនិស្តភូមាបានបន្តការតស៊ូរបស់ខ្លួនអស់រយៈពេល១០ឆ្នាំទៀត ប៉ុន្តែក្នុងឆ្នាំ១៩៧៩ ចលនាប្រឆាំងក្នុងចំណោមកងទ័ពដែលជាពួកកុលសម្ព័ន្ធនៅក្នុងយោធារបស់បក្សដែលមានចំនួនប្រមាណ៩០ភាគរយនៃកងកម្លាំងប្រដាប់អាវុធ បានវាយរុញច្រានមេដឹកនាំរបស់ប្រទេសភូមាដែលដើរតាមគន្លងរបស់ប្រធាន ម៉ៅ ឲ្យគេចខ្លួនទៅរស់នៅប្រទេសចិន ។ សព្វថ្ងៃនេះ មេដឹកនាំដ៏មានវ័យចំណាស់ទាំងនោះបន្តរស់នៅក្នុងប្រទេសចិននៅឡើយ ។ យោធាបក្សកុម្មុយនិស្តភូមាចាស់ក៏បានបែកខ្ញែកទៅតាមក្រុមកុលសម្ព័ន្ធនានាទៅជាចលនាយោធា៤ក្រុមតស៊ូតាមតំបន់ខុសៗគ្នាដែលមិនយូរប៉ុន្មានក្រោយមកក៏បានធ្វើកិច្ចព្រមព្រៀងឈប់បាញ់ជាមួយនឹងរដ្ឋាភិបាលនៃក្រុងរ៉ង់ហ្គូន ។ អតីតយោធាពួកខ្ទាមដែលមានអំណាចជាងគេបំផុតដែលកើតចេញមកពីយោធាបង្រួបបង្រួម «វ៉ាសេត» សព្វថ្ងៃនេះគឺជាអង្គការរត់ពន្ធគ្រឿងញៀន ប្រដាប់អាវុធដ៏ធំមួយនៅអាស៊ីភាគអគ្នេយ៍ ។ ជាតិហេរ៉ូអ៊ីននិងបណ្តាថ្នាំញៀនដទៃទៀតបានហូរចេញពីតំបន់ក្រោមការគ្រប់គ្រងរបស់កងទ័ពខ្ទាមនេះ ហើយអាចហូរចូលមកប្រទេសកម្ពុជាទៀតផង ។ ដំណើរទស្សនកិច្ចរបស់ឧត្តមសេនីយ៍ ណេ វីន ក្នុងឆ្នាំ១៩៧៧ អាចជួយសង្គ្រោះប្រទេសភូមាកុំឲ្យបក្សកុម្មុយនិស្តភូមាដណ្តើមអំណាចបាន ។ មិនតែប៉ុណ្ណោះប្រទេសចិនបានធ្វើការសម្រេចចិត្តកាត់បន្ថយការគាំទ្ររបស់ខ្លួនចំពោះពួកកុម្មុយនិស្តដើរតាមលទ្ធិម៉ៅរបស់ប្រទេសភូមា ក៏ប៉ុន្តែបញ្ហានយោបាយរបស់ប្រទេសមហាអំណាចនៅក្នុងតំបន់បានជំរុញសូម្បីតែមេដឹកនាំចិន តេង ស៊ាវពីង ដែលជាមេដឹកនាំ «និយមកណ្តាល» ឲ្យបន្តការគាំទ្ររបស់គាត់ចំពោះរបបខ្មែរក្រហមនៅក្នុងប្រទេសកម្ពុជារហូតដល់ទសវត្សរ៍ឆ្នាំ៩០ ។

**បឺរធីល លីណឺរ**

## សេចក្តីកែតម្រូវ

ទស្សនាវដ្តីស្វែងរកការពិតលេខ៦ ទំព័រទី១៤ នៅត្រង់កូឡោនថ្ងៃកម្ទេចចោល លេខរៀងទី៦ ដែលសរសេរថា «ថ្ងៃ១៤-១០-៧៦» សូមកែតម្រូវមកជា «ថ្ងៃ១៤-១០-៧៨» ។ សូមអរគុណ

# ប្រវត្តិរូប ជួន ប្រាសិទ្ធ

## (កត់ត្រាតាមសំណេរដើមទាំងស្រុង)

## (តចប់)

### ៦) សរុប

នៅក្នុងរយៈពេលជាង៩ឆ្នាំនេះ ខ្ញុំមានសេចក្តីរីករាយដោយបានបម្រើដោយស្មោះអស់ពីកម្លាំងចិត្តកម្លាំងកាយ បក្សបដិវត្តន៍ ប្រជាជនយើង ជារយៈកាលមួយក្នុងជីវិតខ្ញុំដែលមានខ្លឹមសារយ៉ាងធំដោយបានចូលរួមក្នុងសកម្មភាពលើកអត្ថិភាពបក្សបដិវត្តន៍ប្រជាជនយើងនៅលើឆាកអន្តរជាតិ ចូលរួមបម្រើបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យរហូតដល់បានជ័យជម្នះទាំងស្រុង ។ ខ្ញុំមានការរីករាយដោយបានជួបហើយជាប់នឹងបក្សវិញ ។


ជួន ប្រាសិទ្ធ

តែដោយបានទទួលឥទ្ធិពលពីសង្គមនាយទុនបារាំងច្រើន ពិសេសនៅក្នុងរយៈពេលខ្ញុំដាច់ពីបក្ស គឺពីឆ្នាំ១៩៦៣ ដល់ឆ្នាំ១៩៧០ កម្ពែលនេះរារាំងសកម្មភាពខ្ញុំមិនឲ្យខ្ញុំកសាងខ្លួនឲ្យបានរហ័សដូចចិត្តខ្ញុំចង់បាន ។ បញ្ហាកម្មសិទ្ធិឯកជនគ្រួសារក៏បានស្ថិតនៅច្រើនដែរពេលនោះ ។ ម្យ៉ាងទៀតជារួមបើខ្ញុំភ្ជាប់មាគ៌ានយោបាយទស្សនៈនិងគោលជំហរបក្សបានខ្ញុំភ្ជាប់មិនទាន់បានល្អិតដែរ ពិសេសក្នុងការច្នៃប្រឌិតក្នុងការអនុវត្តមាគ៌ានយោបាយបរទេស ។ សភាពខ្វះខាតនេះបានចេញច្បាស់នៅពេលខ្ញុំត្រឡប់មកក្នុងប្រទេសវិញនៅចុងឆ្នាំ១៩៧៩ ។

### VII. ឆ្នាំ១៩៧៦នេះ

១) ចប់សង្គ្រាម ក្រោយជ័យជម្នះដ៏មហាអស្ចារ្យជាប្រវត្តិសាស្ត្រ ខ្ញុំបាននៅបន្តសកម្មភាពក្នុងរណសិរ្សរហូតដល់ចុងខែសីហា ឆ្នាំ១៩៧៥ ។ ចាប់តាំងពីពេលនោះ បក្សឲ្យខ្ញុំទៅបំពេញភារកិច្ចនៅលើឆាកអន្តរជាតិ ពិសេសចូលរួមក្នុងគណៈប្រតិភូកម្ពុជាយើងនៅសន្និសីទរដ្ឋមន្ត្រីការបរទេសនៃប្រទេសមិនចូលបក្សសម្ព័ន្ធនៅក្រុងលីម៉ា ហើយទៅអង្គការសហប្រជាជាតិ ។ ខ្ញុំអស់ធ្វើសកម្មភាពជាមួយអង្គការមហាជនដែលជារួមជាអង្គការដែលពួកសេរីរើកាន់កាប់ ។

ចាប់តាំងពីពេលនោះមក សកម្មភាពខ្ញុំខ្លាំងទៅជាមួយប្រទេសលោកទី៣ និងប្រទេសមិនចូលបក្សសម្ព័ន្ធ ។ នៅអង្គការសហប្រជាជាតិឃើញច្បាស់ថែមទៀតសកម្មភាពនិងឧបាយកលចក្រពត្តិនិងពួកសេរីរើ ។ ពួកទាំង២នេះទន្ទ្រានរាក់ទាក់នឹងគណៈប្រតិភូកម្ពុជាណាស់ ។ ពួកចក្រពត្តិអាមេរិកវាមកទាក់ទងផ្ទាល់ ។ ពួកសេរីរើសូវៀតវាទំទាក់ទងតាមកូនចៅវាគឺ ប៊ីយេឡូរុស្ស៊ី ដែលអង្គុយជាប់នឹងគណៈប្រតិភូកម្ពុជា ជាមាគ៌ាដំណើរការដែលខ្ញុំភ្ជាប់បានខ្ញុំក៏មិនធ្វើអ្វីឲ្យបរិយាកាសអាប់អួរជាមួយពួកទាំងសងខាងនេះ តែប្រុងប្រយ័ត្នជាប់ ។ តែក្រោយមកខ្ញុំបានពិនិត្យមើលខ្លួនខ្ញុំ ខ្ញុំឃើញថា ស្មារតីប្រុងប្រយ័ត្ននេះខ្លាំងចំពោះចក្រពត្តិអាមេរិកជាងចំពោះសេរីរើ ។ នេះដោយវាយកម្រិតគ្រោះថ្នាក់ចក្រពត្តិចំពោះយើងធំជាងសេរីរើ ។ ព្រឹត្តិការណ៍ក្បត់ថ្មីៗនេះឲ្យខ្ញុំចាប់អារម្មណ៍ដល់កម្រិតនូវគ្រោះថ្នាក់សេរីរើចំពោះបដិវត្តន៍យើង ។ ចំពោះប្រទេសលោកទី៣ ខ្ញុំក៏ខំរឹតចំណងសាមគ្គីភាពនិងមិត្តភាពជាមួយគេ ពិសេសប្រទេសណាដែលបានជួយគាំទ្រយើងក្នុងពេលសង្គ្រាម ។ ដោយប្រទេសទាំងអស់នេះមានបញ្ហាស្មុគស្មាញ ខ្ញុំក៏បានខំចៀសវាងធ្វើយ៉ាងណាកុំឲ្យចូលទៅស្មុគស្មាញជាមួយគេ ហើយធ្វើយ៉ាងណាឲ្យគេភ្ញាក់រឭកអំពីការចាំបាច់តស៊ូប្រឆាំងទាំងចក្រពត្តិ ទាំងសេរីរើ ដើម្បីពង្រឹងពង្រីកសាមគ្គីភាពរវាងប្រទេសលោកទី៣ទាំងអស់ និងដោះស្រាយបញ្ហាផ្ទៃក្នុងប្រទេសមួយដោយឯករាជ្យម្ចាស់ការ ។

ក្នុងឆ្នាំ១៩៧៦នេះ ក្នុងសកម្មភាពខ្ញុំនៅអង្គការសហប្រជាជាតិ នៅពេលសន្និសីទច្បាប់សមុទ្រ នៅពេលទស្សនកិច្ចនៅប្រទេសអាហ្វ្រិកមួយចំនួន នៅសន្និសីទកំពូលប្រទេសមិនចូលបក្សសម្ព័ន្ធនៅកូឡុំបូ ខ្ញុំក៏បានចូលរួមក្នុងការបំពេញភារកិច្ចអនុវត្តមាគ៌ាបក្ស ពង្រឹងពង្រីកមិត្ត ឯកោខ្មាំងលើសកលលោក ។ ក្នុងទស្សនកិច្ចប្រទេសមួយចំនួន សុំកត់សម្គាល់ថា ប្រទេសគុយបា និងប្រទេសហ្គីណេមិនបានទទួលគណៈប្រតិភូដែលបក្សឲ្យខ្ញុំដឹកនាំនេះឲ្យបានរាក់ទាក់ទេ ។ អ្នកដឹកនាំធំៗគេមិនបានទទួលគណៈប្រតិភូទេ ។ នៅគុយបា គេលើកវៀតណាមយ៉ាងខ្លាំងក្លា ។

## ២) អំពីបដិវត្តន៍សង្គមនិយមនៅកម្ពុជា

មុននឹងបានចូលមកក្នុងប្រទេសចុងឆ្នាំ១៩៧៥នេះ ខ្ញុំមិនបានចាប់អារម្មណ៍ច្បាស់លាស់ថា ថ្ងៃ១៧ មេសា ១៩៧៥ ជាថ្ងៃបញ្ចប់បដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យទាំងស្រុងទេ នៅស្មានថាបដិវត្តន៍នេះត្រូវបន្តមួយរយៈពេលទៀត ។ ឯវិធានការធំៗដូចជា ជកប្រជាជន មិនចាយលុយ ខ្ញុំក៏ចាប់អារម្មណ៍មិនដល់កម្រិត ដោយមិនឃើញថាវិធានការនេះជាវិធានការចាំបាច់ដែលសភាពក្រោយសង្គ្រាមវិនាសកម្មទាមទារឲ្យយក ដូច្នេះហើយជាវិធានការបណ្តោះអាសន្នទេ ។ ការយល់ស្មានបែបនេះគឺមកពីគំនិតនិយមមិនជាក់ស្តែងដាច់ពីចលនាក្នុងប្រទេស គិតគូរតាមតែសៀវភៅដែលខ្ញុំបានមើល ។ ក្រោយពីបានរៀនសូត្រជាបន្តបន្ទាប់មក ខ្ញុំបានយល់ហើយគាំទ្រពេញទីវិធានការដែលបក្សបានយកដើម្បីបន្តបដិវត្តន៍សង្គមនិយមនិងកសាងសង្គមនិយម ។ នៅក្នុងប្រវត្តិបដិវត្តន៍សង្គមនិយមសកលលោកគឺមានកាលបរិច្ឆេទ៣ គឺខែតុលា ឆ្នាំ១៩១៧ បដិវត្តន៍សង្គមនិយមទី១ នៅរុស្ស៊ីដឹកនាំដោយលេនីន, ថ្ងៃ១ ខែតុលា ឆ្នាំ១៩៤៩ បដិវត្តន៍សង្គមនិយមចិន និងថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ បដិវត្តន៍នៅកម្ពុជា ។ វិធានការដែលបក្សបានយកដើម្បីបន្តបដិវត្តន៍សង្គមនិយមនេះមិនដែលមានទេ ។ ហើយខ្ញុំមានជំនឿជាក់ថា បើមិនបានយកវិធានការនេះប្រទេសកម្ពុជាយើងប្រាកដជាស្ថិតនៅក្នុងសភាពស្មុគស្មាញ ហើយក៏មានលទ្ធភាពបាត់បង់ឯករាជ្យជាតិនិងអធិបតេយ្យភាពបូរណភាពដែនដីរបស់ខ្លួនផង ។ ឈាមរបស់ប្រជាជនយើងជាង១លាននាក់នឹងត្រូវបង្ហូរចោលទទេ ។ បើបក្សមិនបានដាច់ខាតយកវិធានការដូច្នេះ ពួកយួនចូលមកដះដាន់ទឹកដីយើងទៅហើយ ។ យើងបានយកវិធានការប៉ុណ្ណឹង ហើយវានៅមកចូលលួចទឹកដីយើងទៀត ។ ចុះបើយើងមិនបានយកវិធានការដាច់ខាតដូច្នេះ តើទៅយ៉ាងណាទៅ ។

ឥឡូវសភាពការណ៍បដិវត្តន៍សង្គមនិយមយើងល្អប្រសើរល្អជាងនៅយួននិងឡាវឆ្ងាយណាស់ ។ ក្នុងតែរយៈ១ឆ្នាំ យើងដោះស្រាយបញ្ហាមូលដ្ឋានគឺបញ្ហាស្បៀងបាន ។ នេះមិនដែលមានទេ ។ ក្រោយពីសង្គ្រាមរំដោះជាតិរំដោះប្រជាជន យើងសម្រេចបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យបានភ្លាម ហើយឈានទៅកសាងសង្គមនិយមបន្តបដិវត្តន៍សង្គមនិយម ។ នេះក៏មិនដែលមានដែរ ។ មិនតែប៉ុណ្ណោះនៅប្រទេសយើងមិនចាយលុយ សភាពដែលមិនដែលមានក្នុងប្រវត្តិសាស្ត្រ ហើយឲ្យខ្ញុំមានមោទនភាពនឹងបន្តធ្វើបដិវត្តន៍សង្គមនិយមក្នុងជួរបក្ស ។ ក្រោមការដឹកនាំដ៏ភ្លឺស្វាងរបស់បក្ស ។

ម្យ៉ាងទៀតចលនាកម្ចាត់កម្មសិទ្ធិឯកជនក្នុងសតិអារម្មណ៍ម្នាក់ៗ ចលនាជ្រៅបំផុត ហើយត្រូវបំផុតដើម្បីផ្តាច់ឫសសើរើក្នុងជួរបដិវត្តន៍ ។ ចលនានេះឲ្យខ្លួនខ្ញុំចាប់អារម្មណ៍យ៉ាងខ្លាំងថា ខ្លួនឯងដែលចេញពីវណ្ណៈជិះជាន់ ជាកម្មវត្ថុនៃបដិវត្តន៍សង្គមនិយម គឺត្រូវតស៊ូវណ្ណៈក្នុងខ្លួនឲ្យដាច់ខាត កម្ចាត់កម្មសិទ្ធិឯកជនឲ្យអស់ ហើយកសាងកម្មសិទ្ធិសមូហភាព ។ ការតស៊ូវណ្ណៈក្នុងខ្លួនខ្ញុំនេះខ្លាំងក្លាដែរ ។ ការជម្រុះកម្មសិទ្ធិឯកជនបានជាបន្តបន្ទាប់ ។ នេះធ្វើឲ្យខ្ញុំមានការរីករាយជាបន្តបន្ទាប់ ។ តែការតស៊ូនេះនៅយូរអង្វែង ត្រូវតែខ្ញុំខំប្រឹងប្រែងថែមទៀត ។

កម្មសិទ្ធិគ្រួសារនៅដើរតួនៅឡើយ ពិសេសមនោសញ្ចេតនាចំពោះកូន ។ តែបើប្រៀបធៀបពីដើមឆ្នាំគឺមានសភាពធូរស្រាលនឹងនជាងមុន ។ តែទោះជាមានការលំបាកយ៉ាងណាក៏ដោយ ខ្ញុំដាច់ខាតមិនចាកចេញពីជួរបដិវត្តន៍ ពីជួរបក្សទេ ។ បក្សបានអប់រំខ្ញុំជាបន្តបន្ទាប់ ហើយមានការទុកចិត្តចំពោះខ្ញុំជាបន្តបន្ទាប់ ។ នេះខ្ញុំមិនភ្លេចទេ ។ ពេលរដ្ឋប្រហារឆ្នាំ១៩៧០ បក្សបានគិតដល់ខ្ញុំ ហៅខ្ញុំចូលក្នុងជួរវិញភ្លាម ។ ខ្ញុំទុកនេះជាវិធានការសង្គ្រោះខ្ញុំមួយធំ ។ ដោយការអប់រំនិងការទុកចិត្តពីបក្ស ខ្ញុំបានដើរក្នុងជួរបដិវត្តន៍រហូតដល់បានជ័យជម្នះបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ ហើយបានទាំងចូលរួមបន្តបដិវត្តន៍សង្គមនិយមកសាងសង្គមនិយមលើទឹកដីកម្ពុជា ។ ក្នុងជីវិតខ្ញុំ បើខ្ញុំមិនបានជួបនឹងបក្ស ខ្ញុំមិនដឹងទៅជាស្អីទៅហើយទេ ។ គុណនេះខ្ញុំមិនអាចភ្លេចទេ ហើយធ្វើឲ្យខ្ញុំខំបន្តកសាងខ្លួនទៀត ជាប់នឹងបក្សនិងបដិវត្តន៍ បន្តបម្រើដាច់ខាត បក្ស បដិវត្តន៍ និងប្រជាជនដោយស្មោះអស់ពីចិត្ត អស់កម្លាំងកាយ បន្តធ្វើយ៉ាងណាឲ្យជីវិតខ្ញុំមានខ្លឹមសារយ៉ាងជ្រាលជ្រៅតទៅទៀត ។

ប្រវត្តិរូបនេះមិនបានល្អិតលើគ្រប់ផ្នែកនិងគ្រប់រយៈកាលនៃជីវិតខ្ញុំទេ ។ ខ្ញុំរីករាយនឹងបញ្ជាក់បក្សអំពីចំណុចណា ឬរយៈកាលនៃជីវិតខ្ញុំណាដែលខ្ញុំមិនបាននឹកដល់ ហើយដែលបក្សឃើញថាមានសារៈសំខាន់ ។ ២៥ ធ្នូ ១៩៧៦ **(ចប់)**

# ប្រជុំគណៈរដ្ឋមន្ត្រីលើកទី១

## បទឧទ្ទេសនាមរបស់សមមិត្តលេខាក្នុងសម័យប្រជុំគណៈរដ្ឋមន្ត្រីលើកទី១ ថ្ងៃទី២២ មេសា ១៩៧៦



***(តពីលេខទី៤)*** *នៅក្នុងសកលលោក ទិសវិវឌ្ឍន៍គឺទៅឯករាជ្យ ទោះប្រទេសខ្លះគ្មានបក្សដឹកនាំក៏ដោយ ។ ប៉ុន្តែលទ្ធភាពច្រើនជាងគេគឺអាស៊ី-អាហ្វ្រិក ព្រោះអាស៊ី-អាហ្វ្រិកមានបក្សដឹកនាំហើយប្រយុទ្ធ ។ បើអាស៊ី-អាហ្វ្រិកឯករាជ្យហើយជះឥទ្ធិពលទៅសកលលោកសម្បើមណាស់ ។ អាល់ហ្សេរី សេណេហ្គាល់ អេហ្ស៊ីប ។ល ។ សុទ្ធតែចង់បានឯករាជ្យ តែទៅមិនរួចព្រោះត្រូវមានបក្ស ប្រជាជន និងកងទ័ព ។*

*នៅក្នុងសកលលោក ប្រទេសជាច្រើនត្រូវការយើងណាស់ ហើយមួយថ្ងៃៗគេរឹតតែត្រូវការយើងទៀត ។ ដូច្នោះយើងត្រូវខំ ។ ដើម្បីឲ្យក្រៅប្រទេសខ្លាំងលុះត្រាតែក្នុងប្រទេសខ្លាំង លុះត្រាតែការពារប្រទេសកសាងប្រទេសខ្លាំង លុះត្រាតែប្រព័ន្ធភ្លឺនិងផលស្រូវបានសម្រេចតាមសំណូមពររបស់បក្ស ។*

*សរុបមកវិញ យើងមានលទ្ធភាពរក្សាឯករាជ្យបានពេញទី ។ ខ្មាំងសត្រូវវាយយើងពីក្រៅអត់បានទេ ។ ទិសវាគឺវាយក្បាលម៉ាស៊ីនដឹកនាំតាមផ្លូវងងឹត ។ ដូច្នោះត្រូវលើកកម្ពស់ស្មារតីប្រុងប្រយ័ត្នបដិវត្តន៍ថែមទៀត ។*

### III. ភារកិច្ចរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ

#### ១) ប្រភេទភារកិច្ចរួមៈ

*គឺភារកិច្ច៤ជំពូកដែលបានចេញច្បាស់ក្នុងសេចក្តីប្រកាសណែនាំរបស់សភាតំណាងប្រជាជនកម្ពុជាចំពោះគណៈប្រធានរដ្ឋ រដ្ឋាភិបាល និងគណៈកម្មាធិការតុលាការ កាលពីថ្ងៃទី១៤ ខែមេសា ឆ្នាំ១៩៧៦ ។*

*-ទី១ៈ អនុវត្តរដ្ឋធម្មនុញ្ញយើង បំផុសអប់រំឲ្យប្រជាជននិងកងទ័ពបដិវត្តន៍យើងជ្រួតជ្រាប ពេញចិត្ត ហើយការពាររបបរបស់គេ ។*

*-ទី២ៈ ការពារប្រទេស ការពាររដ្ឋអំណាចបដិវត្តន៍លទ្ធផលបដិវត្តន៍ ការពារបក្ស ប្រជាជន កងទ័ព ឯករាជ្យ អធិបតេយ្យភាព ។ល ។ តាមគ្រប់រូបភាពដែលខ្មាំងធ្វើសកម្មភាពទាំងចំហទាំងសម្ងាត់ ។ យើងត្រូវប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់ជានិច្ច ត្រូវម្ចាស់ការជានិច្ច ។ ដើម្បីម្ចាស់ការទាល់តែបំពាក់បំប៉នមហាជននៅគ្រប់ក្រសួងមន្ទីរនៅក្នុងកងទ័ព នៅក្នុងសហករណ៍ សហជីព ។ល ។ ដូច្នោះកុំគិតតែគណៈកម្មាធិការ ទាល់តែមហាជនទាំងមូលជ្រួតជ្រាបទាល់តែយកមហាជនធ្វើជាភ្នែកជាច្រមុះទើបអាចការពារបានទើបម្ចាស់ការបាន ។ ដូច្នោះប្រជុំជាប់ វគ្គសិក្សាជាប់ ដកពិសោធន៍ជាប់ ។*

*-ទី៣ៈ កសាងប្រទេសគ្រប់ផ្នែក សេដ្ឋកិច្ច កសិកម្ម ឧស្សាហកម្ម គមនាគមន៍ សង្គមកិច្ច សុខាភិបាល ។ល ។ តាមសន្ទុះក់និងតាមសំណូមពររបស់បក្ស ធ្វើយ៉ាងម៉េចឲ្យក្រសួងមួយៗ មន្ទីរមួយៗ អង្គភាពមួយៗ បំពេញភារកិច្ចបានល្អ បានច្រើនតាមសន្ទុះមហាលោតផ្លោះមហាអស្ចារ្យ ។*

*-ទី៤ៈ ប្រមូលកម្លាំងមិត្តនៅលើសកលលោកឲ្យបានកាន់តែច្រើនរៀងរាល់ថ្ងៃ ពង្រីងពង្រីកមិត្តជិតឆ្ងាយទាំងអស់ឲ្យបានជាអតិបរមា កុំឲ្យមារសត្រូវយើងទាំងខាងលិច ទាំងខាងកើតវាឯកោយើងបាន ។ ឥឡូវវាឯកោយើងមិនបានទេ ។ មកពីយើង*

មានជំហរច្បាស់លាស់ ។ ជំហរនេះក៏មានចែងក្នុងរដ្ឋធម្មនុញ្ញ ។ មកពីយើងប្រកាន់យកជំហរនេះហើយទើបសកលលោកវិនិច្ឆ័យថាយើងត្រឹមត្រូវ ។

យើងអនុវត្តនយោបាយក្រៅប្រទេសរបស់យើងបានជាអតិបរមា ។ យើងមិនភ្លេចក្អេងអំពីបដិវត្តន៍ ។ យើងមិននិយាយអំពីសង្គមនិយម ។ សំខាន់គឺខ្លឹមសារអនុវត្តន៍ ឯពាក្យមិនសំខាន់អីទេ ។ បើយើងមិននិយាយអំពីចិន តើគេថាយើងបដិវត្តន៍ឬមិនបដិវត្តន៍? តាមមើលសកលលោកគេថាយើងបដិវត្តន៍ខ្លាំងក្លាជាងគេ ។ ខ្មាំងក៏ថា ។ ឯមិត្តយើងក៏ដឹងយ៉ាងនេះ ។ គេដឹងពីរយ៉ាងៈ ម្យ៉ាងយើងខំធ្វើបដិវត្តន៍ខ្លួនឯងឲ្យបានល្អឲ្យបានខ្លាំងក្លា ហើយតាមរយៈនេះរួមចំណែកជួយបដិវត្តន៍សកលលោក ។ តែបើយើងខ្សោយខ្លួនឯងខ្លាំងមកយកទឹកដីឯលិចផង ឯកើតផង សេដ្ឋកិច្ចក៏លំបាក យើងជួយបដិវត្តន៍សកលលោកអត់បានទេ ។ បញ្ហានេះគេយល់ច្បាស់ ។ ម្យ៉ាងទៀតគេជឿជាក់ ហើយជាក់ស្តែងគេឃើញថាយើងជួយបដិវត្តន៍សកលលោកច្រើនណាស់ ។

-ពិសោធន៍នយោបាយក្រៅប្រទេសមិនមែនក្រសួងការបរទេសធ្វើម្នាក់ឯងទេ ។ គឺទាំងអស់គ្នាធ្វើ ។ ដូច្នោះយើងនិយាយអីកុំនិយាយឲ្យហួសក្របខ័ណ្ឌនៃរដ្ឋធម្មនុញ្ញយើង ក្របខ័ណ្ឌនៃសេចក្តីថ្លែងការណ៍របស់សភាយើង ។ ដូច្នោះមិនបាច់ឃោសនាពីកុម្មុយនិស្ត ។ បក្សយើងមិនទាន់ចេញចំហ ។ បើចេញមានតែខាតអត់ចំណេញទេ ។ នៅក្នុងកាលៈទេសៈដែលសកលលោកកំពុងប្រគោងប្រទាញ និងកំពុងស្មុគស្មាញ ។ នយោបាយយើងគឺពង្រីកមិត្ត ។ បើមិនបានពង្រីកក៏យើងមិនបង្រួញនិងបង្កើនសត្រូវដែរ ។

-ពិសោធន៍មួយទៀតអាកប្បកិរិយាក្នុងការប្រាស្រ័យទាក់ទងជាមួយបរទេស ។ យើងជាម្ចាស់ផ្ទះ ទទួលភ្ញៀវយើងរាក់ទាក់គួរសម សមរម្យ កក់ក្តៅ នឹងនរ ត្រឹមត្រូវ មិនល្មេចល្មាច ។ បើធ្វើយ៉ាងនេះបាននរណាក៏ពេញចិត្ត ។ ទោះបីយើងក្រនៅខ្វះខាតក៏ដោយ បើយើងមានអាកប្បកិរិយាយ៉ាងនេះនរណាក៏ពេញចិត្ត ។ កុំស្តាប់ក្រឡានឹងពិធីការរបស់នាយទុន ។ ដូច្នោះត្រូវរាក់ទាក់ជិតស្និទ្ធ តែត្រូវប្រុងប្រយ័ត្នជានិច្ច ។

ជាមួយខ្មាំងសត្រូវយើងមិនទាក់ទងអីទេ ។ ក្នុងអង្គការសហប្រជាជាតិក្តី យើងមិនដេរវាផ្តេសផ្តាស ។ យើងដេរវាក្នុងក្របខ័ណ្ឌយើង ។

នេះមិនមែនជាការថោកទាបទេគឺដើម្បីបម្រើផលប្រយោជន៍បដិវត្តន៍ ។ ដូច្នោះអ្វីជាផលប្រយោជន៍បដិវត្តន៍អ្វីដែលបម្រើបក្សបដិវត្តន៍ យើងអត់ខ្លាចញញើត យើងហ៊ានលូកដៃចាប់ ។ យើងដាក់ខ្លួនបន្តិចអត់អីទេ ។ ពិសោធន៍នេះមានប្រសិទ្ធភាពណាស់ ។

## ៧) ប្រភេទភារកិច្ចជាក់ស្តែងតាមក្រសួងនីមួយៗៈ

-ភារកិច្ចជាក់ស្តែងជាមូលដ្ឋាននៅតាមក្រសួងគឺជាភារកិច្ចដឹកនាំ មិនមែនជាបញ្ហាបច្ចេកទេសទេ ។ ដឹកនាំគឺដឹកនាំនយោបាយសតិអារម្មណ៍ និងចាត់តាំងតាមគោលជំហរប្រជាធិបតេយ្យប្រមូលផ្តុំសមូហភាពដឹកនាំ ដោយឡែកទទួលខុសត្រូវ ។

-ដឹកនាំជាអប់រំតាមវគ្គសាលាជាផ្នែកណាមួយទេ ។ សំខាន់គឺដឹកនាំប្រចាំថ្ងៃ ។ ដឹកនាំមហាជនឲ្យបំពេញភារកិច្ចអ្វីមួយត្រូវពន្យល់គេឲ្យជ្រួតជ្រាប ឲ្យជ្រះស្រឡះ ឲ្យគេក្តាប់ភារកិច្ចបាន ហើយពេញចិត្តនឹងបំពេញភារកិច្ចនោះ ។

ដូច្នោះ ទោះជាមានខបសគ្គខ្លះក៏ដោយ ឲ្យតែដោះស្រាយតាមនេះពិតជាដំណើរការទៅបាន ។ ចំពោះបញ្ហានេះបក្សយើងមានពិសោធន៍ច្បាស់ណាស់ ។

-ដើម្បីកុំឲ្យកម្មាភិបាលកប់មានតែអនុវត្តប្រជាធិបតេយ្យប្រមូលផ្តុំ ។ ឲ្យគេអនុវត្តទៅកុំខ្លាចខុស ។ ធ្វើហើយយកមកពិនិត្យដកពិសោធន៍កែម្រែតម្រង់ជាបន្តបន្ទាប់ ។ ខុសហើយកែម្រែតម្រង់ទៀតកសាងទៀត ១ឆ្នាំ ២ឆ្នាំ ៣ឆ្នាំ យើងកសាងបាន ។ ក្នុងក្រសួងមួយៗមានមហាជនយ៉ាងតិច១០០នាក់ ។បើកម្រើកទាំង១០០នាក់ក្នុងមួយឆ្នាំ យ៉ាងម៉េចក៏យកកម្លាំងល្អបាន១០នាក់ដែរ ។ យើងមើលសង្គ្រាមប្រជាជន ។ ដល់បក្សបំផុសប្រជាជន មហាជន ឲ្យធ្វើសង្គ្រាមបាន យើងមានកងទ័ព មានកម្មាភិបាលជាវរសេនាតូច ជាវរសេនាធំ ជាកងពល ។ កុំខ្លាចបំផុសមហាជន កុំខ្លាចប្រគល់ភារៈ ។ សំណូមពររបស់យុវជន-យុវនារីយើងគឺចង់ចេះចង់ដឹងណាស់ ។ ខាងពេទ្យ ខាងកាសែតអ្នកនិពន្ធ ខាងវប្បធម៌ ឃោសនាការ វិទ្យុ ។ល ។ ត្រូវមានផែនការកសាងកម្លាំង១ឆ្នាំបានប៉ុន្មានកម្រិតណា ។ ដូច្នេះត្រូវបំផុសទាំងកម្លាំងចាស់ទាំងកម្លាំងថ្មី ។ កម្លាំងចាស់ច្បាស់ជាមួយចំនួនមិន

លឿន តែមួយចំនួនលឿន ។ កម្លាំងថ្មីក៏ដូច្នោះ ។ យើងកុំរើសចោះ យើងបំផុសឲ្យមហាជនដើរតួ គេរៀបជួរខ្លួនគេ ។ ដល់ដើរតួទៅទើបដឹងថានរណាលេងល្អ នរណាមិនល្អ ។ នេះជាវិធីវិភាគវិធីកសាងកម្លាំងមហាជន ។

-មួយផ្នែកទៀតគណៈកម្មាធិការត្រូវចុះជាប់មូលដ្ឋានត្រូវជាក់ស្តែងដើម្បីយល់ការលំបាក ការស្រួល និងដោះស្រាយឧបសគ្គទាន់ពេលវេលា ឧបសគ្គជាសម្ភារក្តី ជាសតិអារម្មណ៍ក្តី ។ បងប្អូនយើងខាងក្រោមគ្មានពិសោធន៍ ជួនណាមានស្មារតីល្អនឹងបំពេញភារកិច្ចតែជួបឧបសគ្គខ្លះ គេដោះស្រាយពុំបាន ។ ទាល់តែកម្មាភិបាលទទួលខុសត្រូវចុះជាប់គ្រប់ថ្នាក់ ទើបជំរុញការបំពេញភារកិច្ចល្អ និងឆាប់រហ័ស ។ ដូច្នោះលុះត្រាតែចុះជាប់មូលដ្ឋាន ចុះជាប់មហាជន ទើបដឹកនាំបានពិស្តារនិងមានប្រសិទ្ធភាព ។


ប៉ុល ពត

-ន័យអនុវត្តន៍មួយទៀត គណៈកម្មាធិការក្រសួងនីមួយៗត្រូវខិតខំខ្លួនឯងជាអតិបរមាដើម្បីឲ្យអចិន្ត្រៃយ៍មានពេលចុះទៅមូលដ្ឋានមិនជាប់រវល់តែក្រសួងនៅភ្នំពេញ ។ បើអចិន្ត្រៃយ៍ តែបញ្ហាក្រសួងយើងធ្វើការមិនចំទិសទេ ។ ទិសរបស់យើងគឺសម្រេចភ្លឺឲ្យបាន៣០ភាគរយនិងផលស្រូវ៣តោនក្នុង១ហិកតា ក្នុងឆ្នាំ១៩៧៦ ។ ដូច្នោះអចិន្ត្រៃយ៍ ត្រូវចុះខាងស្រែឲ្យបានញឹកញាប់ យ៉ាងតិចឲ្យបាន១៥ថ្ងៃក្នុង១ខែ ។ នេះជាវិធីដំណើរការរបស់យើងក្នុងពេលបច្ចុប្បន្ននិងទៅអនាគត ។

## IV. របបនិងខ្លឹមសារប្រជុំរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ

### ១) ចំពោះរដ្ឋាភិបាលៈ

-ជាមធ្យមប្រជុំរដ្ឋាភិបាល១ដងក្នុង១ខែ ហើយប្រជុំ១ថ្ងៃ

-យើងជួបជុំគ្នាដើម្បីផ្សព្វផ្សាយអំពីសភាពការណ៍របស់បដិវត្តន៍យើងលើគ្រប់ទិដ្ឋភាពដែលកើតមាននៅក្នុងប្រទេសយើង ។ សំណូមពរគឺឲ្យយើងឯកភាពគ្នាលើទស្សនៈរួមរបស់បក្ស ហើយដើម្បីក្រសួងនីមួយៗជំរុញការងារឲ្យបានកាន់តែខ្លាំងក្លាថែមទៀត ។

-ម្យ៉ាងទៀតកាលបើយើងឯកភាពគ្នាលើទស្សនៈរួមរបស់បក្សហើយ យើងក៏មានគោលជំហរច្បាស់លាស់ក្នុងការប្រាស្រ័យទាក់ទងជាមួយបរទេស ។ បញ្ហាអីត្រូវនិយាយមិនត្រូវនិយាយ បញ្ហាអីត្រូវឆ្លើយមិនត្រូវឆ្លើយ យើងម្ចាស់ការ ។

-ការប្រជុំនេះក៏ដើម្បីលើកស្ទួយការចេះដឹងរបស់យើងលើសភាពការណ៍ លើនយោបាយសតិអារម្មណ៍ ចាត់តាំង ដើម្បីយើងម្ចាស់ការលើបដិវត្តន៍យើងតទៅទៀតដែរ ។

### ២) ចំពោះក្រសួងនីមួយៗៈ

-យើងធ្វើតាមរបបចាស់របស់យើង ។ ឧទាហរណ៍ខាងផ្នែករទេះភ្លើងស្ថិតនៅក្នុងក្របខ័ណ្ឌឧស្សាហកម្មដដែល ។ ប៉ុន្តែបើមានសន្និបាតឬប្រជុំក្តី អចិន្ត្រៃយ៍នឹងចុះផ្ទាល់ ។ ខាងពាណិជ្ជកម្មក៏ដូច្នោះ ។

-យើងធ្វើយ៉ាងនេះគឺយើងចង់ចូលល្អិតជាក់ស្តែងក្នុងក្រសួងនីមួយៗ ។ នៅក្នុងពេលប្រជុំរដ្ឋាភិបាលយើងយកបញ្ហាល្អិតមកដោះស្រាយទៅពុំរួចទេ ។ យើងខាតពេលច្រើនណាស់ ។

## V. គោលជំហរនិងអាកប្បកិរិយាក្នុងការទាក់ទងជាមួយបរទេស

បរទេសនៅក្នុងសកលលោកនិងបរទេសនៅក្នុងប្រទេស យើងត្រូវការទាក់ទងយើងដើម្បីវិនិច្ឆ័យយើង និងវាយតម្លៃយើង ។ ដោយឈរលើសភាពការណ៍នេះបានជាបក្សចង់បញ្ជាក់ជាថ្មីម្តងទៀតអំពីគោលជំហរនិងអាកប្បកិរិយារបស់យើងក្នុងការទាក់ទងជាមួយបរទេស ។

**១) ប្រភេទបរទេសគឺមានចម្រុះគ្នាៈ**

-មានមិត្តដែលមានលក្ខណៈត្រឹមត្រូវល្អជាងគេ ។

-មានមិត្តត្រឹមត្រូវថ្នាក់លេខ៨ លេខ៧ លេខ៦ លេខ៥ លេខ៤ លេខ៣ ។ល ។

-តទៅមុខមានអ្នកខ្លះមិនមែនជាមិត្តទៀត ។ ពួកនេះក៏ចង់មកប្រទេសយើងដែរ ។ គេចង់ទាក់ទងយើងខាងនយោបាយ សេដ្ឋកិច្ច ហើយព្រមជាមួយនោះធ្វើចារកម្មផង ។

**២) បេសកកម្មការទូតនៅក្នុងប្រទេសយើងៈ**

-ជាការធម្មតា បេសកកម្មការទូតមួយៗគឺសម្រាប់តែពិនិត្យការណ៍ ។ យើងមិនថាស៊ើបការណ៍ទេ ។ ឧទាហរណ៍ គេចង់ដឹងកម្មាភិបាលយើងម្នាក់ៗធ្វើអី កម្មាភិបាលថ្នាក់ដឹកនាំយើងមានជំហរយ៉ាងម៉េច? អាកប្បកិរិយាយ៉ាងម៉េច? ចំណុចខ្សោយ-ខ្លាំងយ៉ាងម៉េច?...។ គេចង់ដឹងយ៉ាងនេះដើម្បីវិភាគវិនិច្ឆ័យ ហើយធ្វើសកម្មភាពបម្រើផលប្រយោជន៍ឲ្យគេ ។ ប៉ុន្តែ ជួនណាគេធ្វើសកម្មភាពបំផ្លាញយើង ឬធ្វើឲ្យយើងលំបាក ឲ្យយើងស្មុគស្មាញក្នុងករណីដែលគេមិនពេញចិត្តយើងក៏មានដែរ ។ ដូច្នេះគេពិនិត្យរួមផង គេពិនិត្យសកម្មភាពរបស់បុគ្គលយើងម្នាក់ៗផង ។ កម្មាភិបាលថ្នាក់ដឹកនាំក៏គេសួរ ។ កម្មាភិបាលធម្មតាក៏គេសួរ ។ យុទ្ធជនយុទ្ធនារីក៏គេសួរ ។ តាមរយៈនេះគេវិភាគបក្សយើង និងវិភាគបដិវត្តន៍យើង ។

-ប៉ុន្តែបញ្ហានេះគេធ្វើល្មមៗទេ ព្រោះគេជាមិត្តយើង ។ ក្នុងឋានៈជាអង្គការបក្សគេ រដ្ឋាភិបាលគេ គេមិនស៊ើបការណ៍ពីយើងទេ ។ ប៉ុន្តែមនុស្សខ្លះរបស់ប្រទេសហ្នឹងជាមនុស្សខូច ។ ប្រទេសជាសត្រូវយើងវាទិញអ្នកហ្នឹងឲ្យមកស៊ើបការណ៍ពីយើង ។ ដូច្នេះបានជាភ្នាក់ងារទូតរបស់ប្រទេសខ្លះជាភ្នាក់ងាររបស់សេ-អ៊ី-អា ។ អាមេរិកចាត់តាំងស៊ើបការណ៍នៅក្នុងទូតសូវៀតដូចសូវៀតចាត់តាំងភ្នាក់ងារនៅក្នុងអាមេរិកដែរ ។ ដល់ពួកអាធំៗវាប្រើគ្រប់មធ្យោបាយដើម្បីស៊ើបការណ៍មានប្រើម៉ាស៊ីនអាស្សាណូជាដើម ។

៣-ក្នុងការទាក់ទងជាមួយបរទេសយើងត្រូវប្រុងប្រយ័ត្នឲ្យមែនទែនៈ

-រាក់ទាក់ ជិតស្និទ្ធ គួរសម តែឆ្លាត ។ ស្វាត់ជាការប្រុងប្រយ័ត្នមូលដ្ឋាន ។

-សុំរៀនសូត្រពីគេឲ្យច្រើនជាងបង្រៀនគេ ។ យើងមិនសួរគេទេ សួរគេហាក់ដូចជាចង់ស៊ើបពីគេ ។ យើងសុំរៀនសូត្រពីគេព្រោះក្រោយសង្គ្រាមយើងខ្វះពិសោធន៍ ។ នេះបញ្ជាក់នូវលក្ខណៈសុភាពរាបសាររបស់យើងផង បញ្ជាក់នូវការវាយសម្រុករបស់យើងផង ។

-យើងឲ្យគេនិយាយច្រើនជាងយើង យើងចាំតែស្តាប់ ។ កុំនិយាយមុនគេច្រើន បើនិយាយមុខតែមានភ្លាត់ ។ មិនមែនត្រឹមតែទូតទេ ។ ទោះបីជាមួយអ្នកដឹកនាំគេ ថ្នាក់ប្រមុខរដ្ឋគេក៏ដូច្នោះដែរ ។

-ដល់យើងនិយាយវិញ យើងនិយាយតែចំណុចណាដែលត្រូវនិយាយ ។ ជាធម្មតាយើងមិនចង់ឲ្យគេដឹង បើគេដឹងគេវិនិច្ឆ័យភ្លាម ។ បើគេមិនដឹងគេវាយយើងមិនត្រូវ ។ បញ្ហានេះស័ក្តិសិទ្ធិណាស់ ។ ក្នុងសង្គ្រាមក៏ដូច្នោះ ។ ការទូតក៏ដូច្នោះ ។ ក្នុងកិច្ចចរចាខាងទូតបើគេមិនដឹងយើងគេមិនម្ចាស់ការទេ ។ បើគេដឹងយើងមុនគេច្បាស់ជាមានវិធានការ ។ ដល់ចូលចរចាគ្នា គេសង្កត់យើងលើបញ្ហាអ៊ីមួយមិនខាន ដើម្បីយកប្រៀបលើយើងភ្លាម ។ ជាមួយមិត្តក៏ដូច្នោះ មិត្តបរទេសក៏ដូច្នោះ ។

**មតិសរុបៈ**

យើងលើកបញ្ហាមួយចំនួនខាងលើនេះទុកជាលំនាំមូលដ្ឋានសម្រាប់កិច្ចដំណើរការរបស់រដ្ឋាភិបាលយើង ។ តាមពិតនេះជាការងាររបស់បក្សយើង ។

ឯការដាក់ស្តែង ការងារល្អិតរបស់ក្រសួងនីមួយៗ ក្រសួងមានផែនការរបស់ខ្លួនហើយ ។ យើងដំណើរការតាមផែនការតាមការចាត់តាំងនៅក្នុងក្រសួង ហើយដកពិសោធន៍តាមផ្នែករបស់ខ្លួនចុះ ។ ដូច្នោះយើងត្រូវជំរុញវាយសម្រុកបំពេញភារកិច្ចទាំងក្នុងក្របខ័ណ្ឌរដ្ឋាភិបាល ទាំងក្នុងក្របខ័ណ្ឌក្រសួង ។

**(តទៅទំព័រទី១៨)**

# រណ្តៅសាកសពប្រល័យពូជសាសន៍ ខេត្តបន្ទាយមានជ័យ

## ១) ចម្ការខ្មុរ

ចម្ការខ្មុរជាទីតាំងគុកសន្តិសុខ និងកន្លែងសម្លាប់ «ខ្មាំង» របស់របបកម្ពុជាប្រជាធិបតេយ្យស្ថិតនៅចម្ងាយប្រមាណ២ គីឡូម៉ែត្រ ភាគខាងលិចសាលាស្រុកសេរីសោភ័ណ ។ វាលពិឃាត ចម្ការខ្មុរ បច្ចុប្បន្នស្ថិតនៅក្នុងភូមិអូរអំបិល ឃុំអូរអំបិល ស្រុកស៊ីសុផុន ខេត្តបន្ទាយមានជ័យ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ទីតាំងនេះស្ថិតក្នុងតំបន់៥ ភូមិភាគពាយ័ព្យ យោងតាមផែនទីកម្ពុជាប្រជាធិបតេយ្យ «ផែនទីនយោបាយ» បោះពុម្ពផ្សាយដោយក្រសួងសិក្សាធិការ ឆ្នាំ១៩៧៦ ខ្នាត១,២០០០,០០០ ។ ការធ្វើដំណើរទៅកាន់ទីតាំងប្រល័យពូជសាសន៍អាចធ្វើដំណើរបានដោយរថយន្តគ្រប់រដូវ ។ ក្រុមស្រាវជ្រាវចាប់ផ្តើមធ្វើផែនទីរណ្តៅប្រល័យពូជសាសន៍នៅម៉ោង១១ព្រឹក ថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៩៧ ដែលនេះជាការចុះស្រាវជ្រាវលើកដំបូងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ទៅកាន់ស្រុកសេរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។ ទីតាំងនេះស្ថិតនៅក្នុងចំណុចប្រសព្វរវាង ខ្សែស្រប ១៣° ៣៥' ៣០៨៧" និងខ្សែទទឹង ១០២° ៥៧' ២៦៨៩" តាមរយៈប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្រពិភពលោក ជាភាសាអង់គ្លេសហៅថា (Global Positioning System) ។

ទិន្នន័យចំណុចទីតាំងភូមិសាស្ត្រនៃទីតាំងប្រល័យពូជសាសន៍នេះ ត្រូវបានថតទុកក្នុងឧបករណ៍អេឡិចត្រូនិកកំណត់ទីតាំងភូមិសាស្ត្រក្នុងឯកសារលេខ០៤២៩០3A សម្រាប់ធ្វើការបំប្លែងទៅជាចំណុចទីតាំងលើផែនទីប្រទេសកម្ពុជាទាំងមូល ដែលតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារ, នៅសកលវិទ្យាល័យញូវសៅវែល ក្រុងស៊ីដនី ប្រទេសអូស្ត្រាលី និងសកលវិទ្យាល័យយ៉េល សហរដ្ឋអាមេរិក ដើម្បីរក្សាសុវត្ថិភាព ។ ជាគោលដៅ តាមរយៈទិន្នន័យដែលក្រុមស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាកត់ត្រាយកតាមប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្រពិភពលោក នៅគ្រប់ទីតាំងនីមួយៗ នឹងបង្កើតបានជាផែនទីរណ្តៅប្រល័យពូជសាសន៍ក្រោមរបបកម្ពុជាប្រជាធិបតេយ្យចន្លោះឆ្នាំ១៩៧៥-៧៩ នៅទូទាំងប្រទេស ។ ហើយចំណុចនីមួយៗនៅលើផែនទីមានផ្ទុកពត៌មានសង្ខេបអំពីចំនួនជនរងគ្រោះតាមរយៈកសិណសាក្សី ឬចំនួនរណ្តៅជាដើម ។ល ។

ការចុះពិនិត្យផ្ទាល់ក្នុងខែមេសា ឆ្នាំ១៩៩៧ បង្ហាញឲ្យឃើញថា ទីតាំងនេះស្ថិតនៅក្នុងចម្ការខ្មុរ (បច្ចុប្បន្នជាចម្ការដំណាំរបស់អ្នកស្រុក) មានផ្ទៃដីមួយហិកតា រាងការេ នៅចន្លោះភ្នំកូនខ្លា ភ្នំស្វាយ និងភ្នំជញ្ជាំង ។

លោកតា សារ៉េង អាយុ៦៥ឆ្នាំ ជាជនរងគ្រោះម្នាក់ដែលត្រូវបានពួកខ្មែរក្រហមជម្លៀសមកនៅក្នុងភូមិអូរអំបិលនេះ ហើយក៏ជាអ្នកធ្លាប់បានចូលរួមជីកគាស់រណ្តៅសាកសពនៅចម្ការខ្មុរនេះក្នុងចន្លោះឆ្នាំ១៩៨៣ និង១៩៨៤ ជាមួយក្រុមស្រាវជ្រាវឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា បានបញ្ជាក់ប្រាប់ថា នាពេលនោះគាត់សង្កេតឃើញរណ្តៅមានប្រមាណ១០០រណ្តៅ ។ រណ្តៅធំមានទទឹង ៥ទៅ៦ម៉ែត្រ បណ្តោយពី៦ទៅ១០ម៉ែត្រ ជម្រៅពី១,៥ទៅ២ម៉ែត្រ និងរណ្តៅតូចជាច្រើន ។ អដ្ឋិធាតុមួយចំនួនដែលគាស់ចេញពីរណ្តៅទាំងនោះត្រូវបានយកទៅតម្កល់ទុកនៅស្តូបតូចមួយក្នុងវត្តសុភមង្គល សម្រាប់ធ្វើបុណ្យផ្សេងៗដូចជាទិវា «ចងកំហឹង» ជាដើម ។ ទាក់ទងនឹងការជីករណ្តៅនេះ លោកតា មានអាយុ៦៨ឆ្នាំ ជាអាចារ្យវត្តសុភមង្គលបានបញ្ជាក់ថា កាលណោះលោកតាជាប្រធានអាចារ្យក្នុងស្រុកទាំងមូល បានលៃលកយកប្រាក់បច្ច័យវត្តទៅជួលឲ្យគេគាស់យកឆ្អឹងពីរណ្តៅទាំងនេះក្នុងតម្លៃមួយបាវ២០បាត (ប្រាក់ថៃ) តាំងពីឆ្នាំ១៩៧៩ ហើយការជីកនៅក្នុងឆ្នាំ១៩៨៣ នោះពុំអាចថាជីករណ្តៅបានទាំងអស់ឡើយ រណ្តៅមួយចំនួនទៀតនៅមានអដ្ឋិធាតុជនរងគ្រោះរហូតដល់បច្ចុប្បន្ននេះ ។

លោកអាចារ្យ សាយ ជាអតីតគ្រូសូត្រថ្នាំបុរាណមុនរបបខ្មែរកហម ត្រូវបានឈ្លបពួកខ្មែរក្រហមចាប់ដាក់គុកនិងសន្តិសុខ




ចម្ការខ្មុរអស់រយៈពេល ២ទៅ៣ខែ នាចុងឆ្នាំ ១៩៧៨។ អាចារ្យ សាយ បានឃើញផ្ទាល់ភ្នែក មានពេលមួយ នោះរថយន្តធំៗចំនួន២០ដឹកមនុស្សពេញ បានបរចូលមកក្នុងទីធ្លាមន្ទីរសន្តិសុខចម្ការខ្មុរនេះ។ ពួកខ្មែរក្រហមប្រាប់ប្រជាជនទាំងនេះថា «ដឹកជម្លៀសទៅព្រំដែនប្រទេសថៃ» ក៏ប៉ុន្តែតាមពិតប្រជាជនទាំងនេះត្រូវបានសម្លាប់ចោលទាំងអស់នៅក្នុងចម្ការខ្មុរនេះ។


សាយ

លោកអាចារ្យ សាយ បានបន្តការអះអាងរបស់អាចារ្យ មានថា ជនរងគ្រោះចម្រុះជាទាហាន មន្ត្រីរាជការ សិស្ស និស្សិត គ្រូ បង្រៀន ប៉ូលិស ប៉េអឹម នៃរបបសាធារណរដ្ឋខ្មែររួមទាំងគ្រួសារ ចិន យួន យកមកសម្លាប់ផ្ដាច់តែម្ដងនៅចុងឆ្នាំ១៩៧៨នេះ។ អាចារ្យ សាយ សន្និដ្ឋានថាមនុស្សប្រហែល ២០,០០០ នាក់ត្រូវបានពួកខ្មែរក្រហមផ្ដាច់ជីវិតនៅចម្ការខ្មុរនេះ។

សព្វថ្ងៃអដ្ឋិធាតុជនរងគ្រោះត្រូវបានរក្សាទុកជាភស្តុតាងក្នុងបូជនីយដ្ឋាន នៅក្នុងវត្តសុភមង្គល។

## ២) ល្អាងភ្នំគួយយំ និងគុកភូមិធំ

ល្អាងភ្នំគួយយំគឺជាគុកនិងកន្លែងពួកខ្មែរក្រហមសម្លាប់មនុស្សដ៏ធំមួយកន្លែងទៀតនៅខាងក្រោយអនុវិទ្យាល័យអូរប្រាសាទ ក្នុងភូមិភ្នំជីត្បូង ឃុំភ្នំតូច ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ។ ទីតាំងនេះស្ថិតនៅក្នុងតំបន់៣ ភូមិភាគពាយ័ព្យ យោងតាមផែនទីនយោបាយរបបកម្ពុជាប្រជាធិបតេយ្យឆ្នាំ១៩៧៦។ ទីតាំងនេះស្ថិតនៅចម្ងាយប្រមាណ៥គីឡូម៉ែត្រពីសាលាស្រុកមង្គលបុរី នៅក្បែរជើងភ្នំ និងក្រោយសាលារៀន (អនុវិទ្យាល័យអូរប្រាសាទ) តែម្ដង។ ការធ្វើដំណើរដោយរថយន្តអាចចូលទៅដល់ទីនេះបានស្រួលនៅរដូវប្រាំង ក៏ប៉ុន្តែរអិលបន្តិចនៅរដូវវស្សា។ ក្រុមស្រាវជ្រាវនិងធ្វើផែនទីរណ្ដៅប្រល័យពូជសាសន៍នៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានទៅដល់ទីតាំងសម្លាប់ល្អាងភ្នំគួយយំនេះនៅម៉ោង៣ៈ៤៥រសៀល ថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៩៧។

ទីតាំងនេះស្ថិតនៅក្នុងចំណុចប្រសព្វរវាងខ្សែស្រប ១៣° ២៥' ៥៦៦៤" និងខ្សែទទឹង ១០៣° ០០' ៤៣៣០" តាមរយៈប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្រពិភពលោក។ ទិន្នន័យចំណុចទីតាំងភូមិសាស្ត្រនៃទីតាំងប្រល័យពូជសាសន៍នេះត្រូវបានថតចម្លងទុកក្នុងឧបករណ៍អេឡិចត្រូនិកកំណត់ទីតាំងភូមិសាស្ត្រក្នុងឯកសារលេខ ០៤២៩០៨A។

លោក នុត អាយុ៦១ឆ្នាំ សព្វថ្ងៃរស់នៅភូមិធំឃុំអូរប្រាសាទនេះតែម្ដង ធ្លាប់ជាអ្នកទោសនៅក្នុងគុកភូមិធំដែល

គ្រប់គ្រងដោយគណៈស្រុកខ្មែរក្រហមឈ្មោះ មិត្ត បូ និង គណៈឃុំឈ្មោះមិត្ត ញឹម ដោយពួកខ្មែរក្រហមចោទគាត់ថាមាន កំហុសក្នុងការបង្គាប់ឲ្យកូនក្មេងសម្លាប់ជ្រូកយកសាច់ហូប ។ មុនពេលចាប់ខ្លួន នុត ជាប្រធានរោងបាយនៃសហករណ៍ភូមិធំ ។



លោក នុត បន្តរៀបរាប់ថា អ្នកជាប់គុកជាមួយគាត់នៅគុក ភូមិធំមានប្រភេទទោសធ្ងន់និង ទោសស្រាល ។ អ្នកទោសធ្ងន់ ត្រូវបានដាក់ខ្នោះជើងជាប់ រហូតមិនបញ្ចេញឲ្យទៅធ្វើការ ទេ ក៏ប៉ុន្តែអ្នកទោសកម្រិត ស្រាលត្រូវបានបណ្តើរបញ្ចេញ ទៅធ្វើការជារៀងរាល់ថ្ងៃ។ លោក នុត ប្រាប់ថា អ្នកទោស ស្ទើរតែទាំងអស់ត្រូវបានសម្លាប់នៅចុងឆ្នាំ១៩៧៨ ក៏ប៉ុន្តែមួយ ចំនួនតូចរួមទាំងរូបគាត់ពុំត្រូវបានសម្លាប់ទាន់ដោយទ័ពរំដោះចូល មកកៀកទៅហើយ ។ នុត បានប៉ាន់ស្មានថាជនរងគ្រោះនៅទីនេះ មានចំនួនប្រហែលជាជាង២ម៉ឺននាក់ ។



លោក អុល វុស អាយុ ៤០ឆ្នាំ ជាកម្មករវាយថ្មភ្នំឲ្យ ពួកខ្មែរក្រហម ។ គាត់ត្រូវបាន ពួកខ្មែរក្រហមចាប់ដាក់គុកភូមិ ធំនេះចន្លោះឆ្នាំ១៩៧៨ និង ១៩៧៩ គឺដល់ថ្ងៃរំដោះតែ ម្តង ។ គាត់ប្រាប់ថា គាត់ធ្លាប់ បានឃើញឡាន១ ឬ២ ដឹក មនុស្សចូលគុកនេះជារឿយៗ ។ គាត់បញ្ជាក់ទៀតថា ល្អាង គួយឃំមានជម្រៅ១០ម៉ែត្រ ហើយអ្នកទោសប្រហែលជា ១០០ ទៅ២០០នាក់ត្រូវបានបណ្តើរយកពីគុកភូមិធំទៅសម្លាប់ នៅតាមរណ្តៅនាជើងភ្នំក្រោយអនុវិទ្យាល័យអូរប្រាសាទនា ពេលបច្ចុប្បន្ន ។

អដ្ឋិធាតុនៅល្អាងគួយឃំ និងនៅតាមរណ្តៅក្រោយ អនុវិទ្យាល័យអូរប្រាសាទ ពុំមានភ័ស្តុតាងបញ្ជាក់ថាត្រូវបាន គាស់យកអដ្ឋិធាតុមកតម្កល់នៅឡើយទេមកទល់ពេលបច្ចុប្បន្ន នេះ អាចដោយសារថាតំបន់នេះនៅមានអសន្តិសុខ ជាពិសេស ក្នុងទសវត្សរ៍ឆ្នាំ៨០ ។

**ផាត កុសល**

**(តមកពីទំព័រទី១១)** ផ្នែកនីមួយៗត្រូវមានទិសច្បាស់លាស់ ត្រូវរៀបចំចំពោះមុខផង និងយូរអង្វែងផងៗ បើរៀបចំយ៉ាង នេះទាំងចំពោះមុខក៏យើងដំណើរការបាន ទាំងយូរអង្វែងក៏យើង ដំណើរការបាន ហើយយើងដំណើរការដោយម្ចាស់ការទៀត ព្រោះយើងដំណើរការជាខ្សែសន្ទាក់មិនច្របូកច្របល់ ។ឧទាហរណ៍ ខាងសុខាភិបាលត្រូវមានផ្ទះពេទ្យប៉ុន្មាន? មនុស្សជាពេទ្យប៉ុន្មាន? ថ្នាំពេទ្យប៉ុន្មាន? ប្រភេទអ្វីខ្លះ?

ការរៀបចំរបស់យើងមិនមែនរៀបចំតែមួយថ្ងៃទេ ។ យើងមានទិសហើយយើងរៀបចំវាជាបណ្តើរៗ គ្រប់ផ្នែក គ្រប់ក្រសួងត្រូវធ្វើយ៉ាងនេះ ។ តទៅមុខជីវភាពប្រជាជនយើង កាន់តែបានធូរ ។ សម្លៀកបំពាក់ក៏កាន់តែគ្រប់គ្រាន់ ។ ស្បៀង អាហារ ជីវភាពរស់នៅក៏កាន់តែមានកម្រិតខ្ពស់ ។ យើងច្បាស់ ជាឈ្នះគេ ទាំងចំនួនអង្ករហូប ទាំងចំនួនសាច់ហូប ទាំងផ្ទះនៅ ខ្យល់អាកាសដកដង្ហើម ។ល ។

តាមទិសនេះតែ៣ឆ្នាំទៀតយើងច្បាស់ជាដើរតួនាទីយ៉ាង សំខាន់នៅក្នុងសកលលោក ពិសេសនៅក្នុងបញ្ហាប្រទេសមិនចូល បក្សសម្ព័ន្ធ ។ ដល់ពេលនោះតិចលោកគ្មានទូតតែមានស្រូវ ។ ដូច្នោះត្រូវកសាង ។ ការបរទេស កសិកម្ម ឧស្សាហកម្ម ។ល ។ ត្រូវកសាងទាំងចំពោះមុខទាំងយូរអង្វែង ។បើកសាងយ៉ាងនេះ តែ១០ឆ្នាំទៀតច្បាស់ជាអគ្គិសនីយកម្មទូទាំងប្រទេសហើយ ។

**(ឯកសារលេខ D៦៩៥)**

## ពាក្យស្លោកខ្មែរក្រហម

- ◆ អង្គការម្ចាស់ទឹកម្ចាស់ដី!
- ◆ អង្គការមហាត្រឹមត្រូវ មហាភ្លឺស្វាង មហាអស្ចារ្យ!
- ◆ ត្រូវស្មោះត្រង់ និងស្រលាញ់អង្គការ!
- ◆ ត្រូវតែស្រលាញ់អង្គការដោយគ្មានព្រំដែន!

## ញត្តិមួយក្នុងចំណោមញត្តិ ១,២៥០សន្លឹក ចុះហត្ថលេខាដោយប្រជាជនកម្ពុជាចំនួន ១,១៦៦,៣០៧នាក់ ប្តឹងដល់អង្គការសហប្រជាជាតិឱ្យមានការកាត់ទោសរបបកម្ពុជាប្រជាធិបតេយ្យ ◆ ខាងក្រោមគឺជាញត្តិរបស់ប្រជាជនភូមិទី៤មាត់ព្រៃ ឃុំកំពង់ពោធិ៍ ស្រុកក្រគរ ខេត្តពោធិសាត់

ដោយឃើញញត្តិរបស់ក្រុមប្រឹក្សាទូទាំងប្រទេស រណសិរ្សការពារនិងកសាងមាតុភូមិកម្ពុជា លេខ១.០៥២.៨៣ ក.រ.ស ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ១៩៨៣ ស្តីអំពីឧក្រិដ្ឋកម្មរបស់វាតទីនិយមចិនប៉េកាំង និងប៉ុលពត អៀង សារី ខៀវ សំផន ជាបរិវារ ក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៨ មកលើប្រជាជនកម្ពុជាយើងអស់ចំនួន៣ ៣១៤ ៧៦៨នាក់ ដោយនៅខ្វះខេត្តមួយ និងស្រុកដប់ទៀតមិនទាន់បានទទួលរបាយការណ៍នៅឡើយ ។

ដោយបានឃើញលិខិតចំហរបស់បញ្ញាជននិងបព្វជិតកម្ពុជាផ្ញើជូនបញ្ញាជនបព្វជិតអង្គការអន្តរជាតិ និងប្រជាជននៅលើសកលលោក ស្តីពីបញ្ញាជននិងបព្វជិតកម្ពុជា ដោយមិនអាចចៀសវាងផុតពីការធ្វើទារុណកម្មយ៉ាងខ្លោចផ្សានោះដែលមានព្រះសង្ឃចំនួន ២៥ ១៦៧អង្គ វេជ្ជបណ្ឌិត ឱសថការីជាន់ខ្ពស់និងទន្តពេទ្យ ៥៩៤រូប អ្នកកាសែត១៩១រូប សិល្បករ១១២០រូប ត្រូវបានទទួលការកាប់សម្លាប់ពីពួកវាតាមគ្រប់រូបភាពនិងយង់ឃ្នងបំផុត ។ បញ្ញាជនចំនួន១០០០នាក់ ដែលមកពីបរទេសក្នុងអំឡុងឆ្នាំ១៩៧៥-៧៨ ដោយមានគោលបំណងចង់ចូលរួមកសាងមាតុភូមិក្រោយពីដណ្តើមបានឯករាជ្យ ក៏ត្រូវពួក ប៉ុល ពត អៀង សារី ខៀវ សំផន កាប់សម្លាប់ជិតអស់ នៅសល់តែ៨៥រូបតែប៉ុណ្ណោះ ។ ដោយឡែកគ្រាន់តែសាលារៀនទួលស្លែងភ្នំពេញដែលពួកប៉ុល ពត ប្រែក្លាយទៅជាទីឃុំឃាំងសម្រាប់ធ្វើទារុណកម្ម ពួកវាបានកាប់សម្លាប់សាស្ត្រាចារ្យ២០៦រូប គ្រូបង្រៀន១១៣រូប វេជ្ជបណ្ឌិត និងឱសថការីជាន់ខ្ពស់អស់៥៦រូប វិស្វករអស់៦១រូប ។ ដោយបានឃើញកំណត់ហេតុសម័យប្រជុំលើកទី៥ នីតិកាលទី១ របស់រដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជាពីថ្ងៃទី១៥ ដល់ថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៨៣ ស្តីពីទោសឧក្រិដ្ឋកម្មរបស់ពួក ប៉ុល ពត អៀង សារី ខៀវ សំផន មកលើប្រជាជនកម្ពុជាក្នុងអំឡុងឆ្នាំ១៩៧៥-៧៨ ពួកវាបានកាប់សម្លាប់ប្រជាជនស្លូតត្រង់អស់ ៣ ៣១៤ ៧៦៨នាក់ បន្សល់ទុកជនពិការបាក់កម្លាំង ១៤១ ៨៤៨នាក់ កុមារជាង ២០០ ០០០នាក់ត្រូវកំព្រាឪពុកម្តាយទាំងពីរ នារីរាប់សែននាក់បានក្លាយទៅជានារីមេម៉ាយ នេះមិនគិតចំនួនអាណិកជនរាប់ម៉ឺននាក់ទៀតផង ដែលត្រូវពួកវាកាប់សម្លាប់យ៉ាងសែនឃោរឃៅ សាលារៀនចំនួន៥ ៨៥៧ មន្ទីរពេទ្យនិងមន្ទីរពិសោធន៍ ៧៩៦ វត្តអារាម ១ ៩៦៨ ព្រះវិហារឥស្លាម១០៨ ហើយនិងរោងសិល្បៈជាច្រើនទៀតត្រូវបំផ្លិចបំផ្លាញ ។ ជាងនេះទៅទៀត រាល់សកម្មភាពអប់រំ សាសនា វប្បធម៌ សិល្បៈ សង្គមកិច្ច ការធ្វើជំនួញដូរប្រែផ្សេងៗ ប្រាក់កាស ផ្សារផ្សាត្រូវបំបាត់ចោល ។ នៅក្រោមរបបប៉ុលពត ប្រទេសយើងត្រូវរងនូវការអត់ឃ្លាន និងភាពក្រីក្ររហេមរហាមជាខ្លាំង ជនកម្ពុជាម្នាក់ៗនៅសល់តែស្បែកដណ្តប់ឆ្អឹងតែប៉ុណ្ណោះទេ ហើយទាំងយប់ថ្ងៃគិតខ្លួនត្រូវស្លាប់ ។ ការតស៊ូបុគ្គលគ្រប់រូប គ្រប់កន្លែង សុទ្ធតែពួកវាបង្ក្រាបយ៉ាងសាហាវព្រៃផ្សៃជាទីបំផុត ។ ជាមួយនេះដែរ យើងខ្ញុំជាប្រធានភូមិទី៤មាត់ព្រៃ ឃុំកំពង់ពោធិ៍ មានការសប្បាយរីករាយជាខ្លាំងដោយឃើញការរលំរលាយទៅនៃរបបប្រល័យពូជសាសន៍ដ៏គ្រោះថ្នាក់នេះ ហើយថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ បានបើកនូវទំព័រប្រវត្តិសាស្ត្រថ្មីរបស់សង្គមកម្ពុជាតាមការដឹកនាំដ៏ឈ្លាសវៃនិងភ្លឺស្វាងរបស់បក្សប្រជាជនបដិវត្តន៍កម្ពុជាក្រោមទង់ប្រាសាទកំពូលប្រាំដ៏ថ្លៃថារបស់មាតុភូមិយើង ប្រជាជនគ្រប់ស្រទាប់វណ្ណៈរួមសាមគ្គីទាំងកម្លាំងកាយ ទាំងកម្លាំងចិត្ត ជុំវិញរណសិរ្សជ្រោងទង់ខ្ពស់ ទង់ប្រយុទ្ធ ដើម្បីការរស់នៅដ៏ត្រឹមត្រូវ ការសាងជីវភាពថ្មីឡើងវិញដោយមានការជួយឧបត្ថម្ភពីកងទ័ព និងប្រជាជនវៀតណាមពីសហភាពសូវៀតនិងប្រទេសសង្គមនិយម ព្រមទាំងពីកម្លាំងជឿនលឿនលើពិភពលោកជាងបួនឆ្នាំកន្លងមកនេះ បដិវត្តន៍កម្ពុជាបានដណ្តើមបាននូវជ័យជម្នះយ៉ាងធំធេងនិងគ្រប់គ្រងលើគ្រប់វិស័យ ស្លាកស្នាមខ្លោចផ្សា ឈឺចាប់ជូរចត់ បានរលំរលាយទៅជាបន្តបន្ទាប់ ជីវភាពដ៏ស្រស់បំព្រងបានរស់ឡើងវិញនៅទូទាំងប្រទេស ចំណងមិត្តភាពសង្គមនិយមជាមួយមិត្តវៀតណាមនិងប្រជាជនចំរើនបានត្រូវពង្រីកនិងពង្រឹងជាលំដាប់ ។ ប៉ុន្តែទន្ទឹមនឹងការរីកចំរើនរបស់បដិវត្តន៍កម្ពុជា ពួកពង្រីកទឹកដីវាតទីនិយមចិនប៉េកាំង និងចក្រពត្តិអាមេរិកនៅតែចចេសរិះរកឧបាយកលពិសពុល ឈ្លានពានទឹកដីយើង បង្កលក្ខណៈឲ្យរបបប្រល័យពូជសាសន៍ប៉ុលពតត្រឡប់មកវិញ ។ ថ្មីៗនេះ ក្នុងស្ថានភាពផ្សងសំណាងចុងក្រោយបង្អស់ពួកវាបានបង្កើតរដ្ឋាភិបាលចម្រុះត្រីភាគី កម្ពុជាប្រជាធិបតេយ្យរបស់សីហនុ សឺន សាន ខៀវ សំផន ដែលធាតុពិតសុទ្ធជាបរិវារដាច់ថ្លៃរបស់ពួកវាតទីអនុត្តរភាពចិនប៉េកាំង ។ ចំពោះឧបាយកលដ៏ខ្មៅងងឹតទាំងនេះ ប្រជាជនភូមិទី៤យើងខ្ញុំទាំងចាស់ទាំងក្មេង ស្រីប្រុស គ្រប់ជាន់ថ្នាក់ គ្រប់ជនជាតិ ព្រះសង្ឃ បញ្ញវន្ត ត្រូវតែភ្ញាក់រឭក ចងកំហឹងក្តៅក្នុងបេះដូង ចំពោះឧក្រិដ្ឋកម្មរបស់បនប៉ុលពតនិងចៅហ្វាយរបស់ពួកវាគឺបនវាតទីអនុត្តរភាពនិយមចិនប៉េកាំង បង្កើនជំនឿជាក់លើការដឹកនាំរបស់បក្ស ស្វាហាប់ អនុវត្តនូវចលនាបដិវត្តទាំងបីដើម្បីការពារនិងកសាងមាតុភូមិសម្បូរសប្បាយជូនប្រជាជន កសាងលូនូវចំណងមិត្តភាពសាមគ្គីភាព និងសហប្រតិបត្តិការរឹងមាំជាមួយបណ្តាប្រជាជាតិបងប្អូន ។ ចំពោះមុខឧក្រិដ្ឋកម្មរបស់បនប៉ុលពតបរិវារអនុត្តរភាពវាតទីនិយមចិនប៉េកាំងនេះ កម្មាភិបាលនិងប្រជាជនក្នុងភូមិទី៤ មាត់ព្រៃទាំងអស់ក្នុងភូមិទី៤ ឃុំកំពង់ពោធិ៍ ស្រុកក្រគរ ខេត្តពោធិសាត់ មានការឈឺចាប់យ៉ាងក្រៃលែង ហើយចងកំហឹងក្តៅងំចំពោះរបបប៉ុលពតជាបរិវាររបស់អនុវត្តភាពវាតទីនិយមចិនប៉េកាំង ។ ក្នុងនាមជនរងគ្រោះដែលសល់ពីការកាប់សម្លាប់ ដោយសារភាពផ្ទាល់ឈ្មោះបន្ទំខ្លួនធ្វើជាគរ ជាថ្នង់ ហើយដោយបានឃើញដោយផ្ទាល់ភ្នែកនូវវិនាសកម្មដ៏សែនខ្លោចផ្សាបំផុតរបស់ជនជាតិខ្លួនក្នុងរបបប៉ុលពត ។ យើងខ្ញុំជាកម្មាភិបាលនិងសេនាជនប្រជាជនក្នុងភូមិមាត់ព្រៃទាំងអស់ ក្នុងឃុំកំពង់ពោធិ៍ទាំងមូល សូមឯកភាពនិងគាំទ្រទាំងស្រុងលើសេចក្តីសម្រេចចិត្តរបស់រដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ សូមជូនភ្ជាប់មកនូវបញ្ជីរាយនាម និងហត្ថលេខាស្នាមមេដៃប្រជាជនក្នុងភូមិមាត់ព្រៃ ឃុំកំពង់ពោធិ៍ ដែលមានចំនួន២០៦នាក់ ។

ធ្វើនៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៨៣ ជ.គណៈកម្មការភូមិទី៤មាត់ព្រៃ

អនុប្រធាន សមមិត្ត មក់ ម៉ូវ

# ជួបជាមួយសិស្ស និងមិត្តភក្តិជំនិតរបស់សមមិត្ត ឌុច នៅខេត្តកំពង់ធំ

**(តពីលេខមុន)**

**កុសល:** នៅពេលដែលលោកគ្រូបានដឹងថា ឌុច ហ្នឹងជាប្រធានមន្ទីរស-២១ទួលស្លែង តើគ្រូមានអារម្មណ៍យ៉ាងម៉េចដែរ?

**សារុន:** ខ្ញុំមិនទាន់យល់ថាគុកទួលស្លែងយ៉ាងម៉េចទេក្នុងរបបប៉ុលពត ទាល់តែក្រោយឆ្នាំ១៩៧៩ បានដឹងថាគុកទួលស្លែងយ៉ាងម៉េច.. ស្គាល់ កាំង ហ្កិចអៀវ, ម៉ម ណៃ ហៅ ចាន់, ទង់ សេងហ័ន ហៅ ប៉ុន.....តែខ្ញុំអត់សូវស្និទ្ធស្នាលជាមួយ ម៉ម ណៃ ទេ ដល់ ទង់ សេងហ័ន ហ្នឹងវាសិស្សខ្ញុំ ។ រួចឥឡូវនៅរស់ទេ មនុស្ស «ប៉ុន» ហ្នឹង?

**កុសល:** ហ័ន ហៅ ប៉ុន មានតែរបាយការណ៍ប៉ុន្តែមិនដឹងថានៅរស់ឬក៏អត់ រកអត់ទាន់ឃើញ ប៉ុន្តែឯកសារមានឈ្មោះ ប៉ុន ច្រើន ជាអ្នកចារលើចម្លើយសារភាពអ្នកទោស ។





**សារុន:** ប៉ុន ជាគ្រូបង្រៀន ។ អាគៀវ នាំចេញទៅជាមួយវា ។ ប៉ុន សាច់ញាតិជាមួយខ្ញុំ អ្នកសាន់គរជាមួយគ្នា ។ ប៉ុន បងប្អូនវានៅសព្វថ្ងៃ ។ កាលណោះបងប្អូនរបស់វាគ្មានគំនិតអស់ហ្នឹងទេ ។ ប្អូនវាបង្កើតនៅរកស៊ី អាបងវានៅសាធារណការនៅភ្នំពេញ ។

**កុសល:** ប៉ុន មានបងប្អូនប៉ុន្មាននាក់?

**សារុន:** អាប៉ុន ប្រហែលបងប្អូនច្រើន បងប្អូន៨ឬ៩នាក់ ប៉ុន្តែទៅ «ខ្មែរក្រហម» តែវាមួយ ។

**កុសល:** ប៉ុន្តែសល់២នៅកំពង់ធំ? លោកគ្រូដឹងថានៅប៉ុន្មាននាក់?

**សារុន:** នៅកំពង់ធំប្រុសនៅតែមួយទេ នៅភ្នំពេញនៅជាមួយដល់តែស្រីៗមិនដឹងនៅសល់ប៉ុន្មានទេ បីបួន...ប្រុសគ្នាវាហ្នឹងអស់២ ។

**កុសល:** ប៉ុន កើតឆ្នាំអី?

**សារុន:** បើមិន មមែ វក ។ ខ្ទង់ហាសិបផ្លាយ ៥៣-៥៤ បើពី៧៩ គ្នាវាម៉ោហ្នឹងវាប្រាប់ថា អាហ័ន នៅទេ ។ វានោះថាទៅដល់ណាហើយ ថាទៅដល់ឱរ៉ាល់ហើយ ដឹងតែប៉ុណ្ណឹងទេ ។

**កុសល:** ហ័ន ហៅ ប៉ុន ចរិតយ៉ាងម៉េចដែរ?

**សារុន:** ហ័ន ហ្នឹងក៏មិនមាត់រិតតែណាស់ ។ តាមពិតឈ្មោះ ទង់ សង់ហឿន តែគេហៅថាអា ហ័ន ។ ប្អូនវាមួយនៅសព្វថ្ងៃ ទង់ គីមឡា បងនៅភ្នំពេញឈ្មោះ ទង់ គីមលាន ។ ហ័ន នៅរស់ហើយចេញទៅ ដល់ឡើងឱរ៉ាល់ កំពង់ស្ពឺ ព្រោះមានគេម៉ោពីនោះម៉ោគេជួប បបួលវាម៉ោ ។ វាម៉ោបានបន្តិចហើយ ប៉ុន្តែវាមិនទុកចិត្តវាត្រឡប់ទៅវិញ ឥឡូវស្ងាត់សូន្យ ។

**ដារ៉ា:** នៅក្នុងឯកសារចម្លើយសារភាពរបស់អ្នកទោសគឺ ប៉ុន អ្នកសរសេរ ហើយក្រោយម៉ោឯកសារដែលមានចុះឈ្មោះ ប៉ុន ច្រើនតែ ឌុច ស៊ីញ៉េពីលើទៀត ជូនទៅមេខ្មែរក្រហមដទៃទៀតដែលនេះបញ្ជាក់ថា ប៉ុន និង ឌុច ធ្វើការជាមួយគ្នា ។

**សារុន:** នៅជាមួយគ្នាប្រាកដហើយ ព្រោះកូនសិស្សខ្ញុំមួយប្រាប់ថាប្រធានអា ឌុច អនុប្រធាន ចាន់ សមាជិក ប៉ុន ។ បើខ្ញុំស្គាល់ អា ឌុច បញ្ជូន ប៉ុន ទៅមុន ហើយ ឌុច ទៅក្រោយ ហើយ ម៉ម ណៃ នៅកំពង់ធំឯណោះនៅឡើយទេពេលនោះ ។

**កុសល:** ជួប គៀវ ចុងក្រោយបំផុតនៅឆ្នាំណា?

**សារុន:** ចុង៧៣ ហ្នឹងឯង... ចុងក្រោយបំផុតខ្ញុំកំពុងរៀនបន្តវាចេញទៅគ្រាន់តែវាខ្សិបប្រាប់ខ្ញុំថាវាទៅហើយ ។

**កុសល:** ចុះដល់ពេលឃើញកាសែតដឹងថា ឌុច ត្រូវចាប់បានអ៊ីចឹងគ្រូនឹកឃើញអីខ្លះមុនដំបូង?

**សារុន:** នឹកឃើញថា ចង់មើលរូបវាមែនឬមិនមែន ដល់ឃើញមែន ប្រាកដអាហ្នឹងឯង បាននឹកឃើញថាអើវាបាបកម្ម ។ ក្រោយឆ្នាំ៧៩, ៨២, ៨៣ ខ្ញុំទៅរៀននៅភ្នំពេញទៅមើលគុក

ទួលស្លែង ខ្ញុំចេះតែអង្គុយឆ្ងល់ថា មនុស្សហ្នឹងវាទៅដល់ប៉ុណ្ណឹង ព្រោះបើវាអង្គុយវាអត់និយាយទេ បើអាណាចង់ដេរវាក៏វាធ្វើមិនពុ្រ ដល់ពេលវានិយាយ និយាយយកច្បាស់លាស់ ។ បើនិយាយពីឯកសារខ្លឹមសារដែលវាសរសេរគឺចេញពីមជ្ឈិមម៉ោ វាមិនដែលខុសគ្នាទេ តែដល់ពេលនិយាយពីការអនុវត្តគឺខុសមូលដ្ឋានថ្ងៃប្រឌិត នៅស្រុកបារាយណ៍ខ្ញុំធ្លាប់គេបំពាក់បំប៉នអាគៀវ ក៏បំពាក់បំប៉នខ្ញុំ គណៈកម្មការកុម្មុយនិស្តនៅក្រុងភ្នំពេញក៏ធ្លាប់បំពាក់បំប៉ន ពួកម៉ាកខ្ញុំមេខ្មែរក្រហមខ្លះងាប់ទៅ អាខ្លះមិនទាំងសល់កាកឆ្អឹងនៅសព្វថ្ងៃផង ។

**កុសលៈ** ពាក្យខ្មែរក្រហម គេចូលចិត្តប្រើពាក្យថា «បំពាក់បំប៉ន» តើកាលណោះពេលពុ្រពាក្យបំពាក់បំប៉នមានន័យថាយ៉ាងម៉េច?

**សារុនៈ** បំពាក់បំប៉នមានន័យថាពង្រឹងស្មារតី បំផុសបច្ចេកទេស ។

**កុសលៈ** តាមរយៈយ៉ាងម៉េច បំពាក់បំប៉ន?

**សារុនៈ** បំពាក់បំប៉ន ហៅមកបំពាក់ដូចជាស្មារតីយើងមិនទាន់យល់គេធ្វើឲ្យយើងយល់ ពន្យល់បន្ថែមហើយពន្យល់បន្ថែមទៀតមិនមែនពន្យល់តែម្តងទេ ពន្យល់ឲ្យយល់ ទាល់តែបំប៉ន បំពាក់ហើយបំប៉ន ពាក្យរបស់វាមានន័យត្រឹមត្រូវណាស់ អនុវត្តខ្លឹមសារន័យច្បាស់ ។ គឺបំពាក់ស្មារតីកុំឲ្យខ្វាចខ្វាំង កុំឲ្យស្រលាញ់បក្រពត្តិ កុំឲ្យចូលចិត្តបម្រើខុបាយកលមូលធន... រួចបានគេបំប៉នឲ្យថែមញឹកទៅយូរៗកើត ។ ហើយពាក្យបច្ចេកទេសដែលពួកខ្មែរក្រហមប្រើដូចជាពាក្យ «ស្នើ» គឺធ្វើឲ្យខ្ញុំបះសក់ ។ ពាក្យស្នើគឺលុបបំបាត់ពាក្យ «បទបញ្ជា» ពាក្យស្នើលុបបំបាត់ពាក្យ «សុំ» ព្រោះកាលណាបើ «សុំ» គឺពាក្យរបបមូលធន... អាហ្នឹងន័យអ៊ីចឹង... ឥឡូវក្មួយឯងខ្ញុំ ខ្ញុំនៅសកលវិទ្យាល័យភ្នំពេញខាងអក្សរសាស្ត្រ គ្រូដែលគាំទ្រខ្មែរក្រហមគេបកស្រាយពាក្យតាំងពី៧០មក ន័យពាក្យនីមួយៗយើងយល់ន័យឲ្យច្បាស់ប្រើឲ្យចំន័យពាក្យដែលខុសគ្នា មិនមែនដូចគ្នាទាំងអស់ទេ ។

**កុសលៈ** អូ! មានន័យថា សាស្ត្រាចារ្យជំនាន់នោះបញ្ចូលពាក្យខ្មែរក្រហមទៅក្នុងអក្សរសាស្ត្រដោយបន្តិចម្តងៗ ។

**សារុនៈ** គេយកន័យពាក្យហ្នឹងទៅបំភ្លឺរួចហើយពួកអាហ្នឹងវាឆ្លាតវាយកពាក្យហ្នឹងមកប្រើមុន ។

**កុសលៈ** ពាក្យអីខ្លះទៀតដែលសំខាន់បំផុតដែលគេប្រើដើម្បីសំដៅលុបពាក្យដែលប្រើក្នុងរបប «មូលធន» ដូចជាពាក្យ «ស្នើ» ជំនួសពាក្យ«សុំ»...សន្តិសម្ព័ន្ធ?

**សារុនៈ** អូ! អាហ្នឹងពាក្យវាសន្តិសម្ព័ន្ធ គ្រាន់វាជាប់ទាក់ទងគ្នា អាហ្នឹងមិនសូវមានន័យប៉ុន្មានទេ ។ ពាក្យដែលប្រើបំផុតដាច់ខាតគឺថាអាពាក្យខ្មែរសុទ្ធៗហ្នឹងតែម្តង ពាក្យខ្ចីពីបាលីខ្ចីពីអីមិនសូវចង់ប្រើទេ ពួកអានោះវាមានគំនិតប្រឆាំង មិនចង់ឲ្យបរទេសមកប្រើទេ ។

**កុសលៈ** ពាក្យអ្វីខ្លះដែលពូនៅចាំ ដែលពួកខ្មែរក្រហមចាប់ផ្តើមជ្រៀតចូលតាមរយៈការផ្សព្វផ្សាយតាមអក្សរសាស្ត្រ ។

**សារុនៈ** ខ្ញុំនិយាយពាក្យមួយម៉ាត់ អានោះពាក្យខ្ចី ប៉ុន្តែពាក្យហ្នឹងនរណាក៏ស្គាល់ដែរ ពាក្យ «អង្គការ» ។ «អង្គការ» បើយើងរៀន «អង្គការ» សព្វថ្ងៃយើងដឹងថា «អង្គការ» គឺក្រុមមួយដែលមានការងារ ប៉ុ ន្តែ «អង្គការ» វាប្រើក្នុងទស្សនវិជ្ជារបស់ខ្មែរក្រហមចង់និយាយថាអ្វីដែលវាប្រសិទ្ធភាពគឺអាទិទេពអ៊ីចឹង ។ អ្នកត្រូវជឿ «អង្គការ» មានន័យថាមិនជឿបុគ្គលទេ បុគ្គលតំណាងឲ្យអាទិទេពមកធ្វើការនៅហ្នឹង អ្នកមិនស្តាប់គឺងាប់តែម្តង ។

**កុសលៈ** ដូច្នោះមានន័យថា បុគ្គលខ្មែរក្រហមទាំងអស់គឺសុទ្ធតែតំណាងអង្គការមានសិទ្ធិដាច់ខាត? ចុះពាក្យ «ចាត់តាំង» យ៉ាងម៉េចដែរបាទ?

**សារុនៈ** អើ អាពាក្យ «ចាត់តាំង» ។ ពាក្យ «ចាត់តាំង» ហ្នឹងមាត់ទទេក៏បាន លិខិតក៏បាន ប៉ុន្តែពាក្យ«ចាត់តាំង»គឺបទបញ្ជាដាច់ខាត «ប្រើ» ប៉ុន្តែពាក្យ «ចាត់តាំង» មិនមែនពាក្យ «ប្រើ» ទេ លុបពាក្យ «ប្រើ» មួយចេញ ។ «ចាត់តាំង» មានន័យថាស្អីដែលបញ្ជាមកដាច់ខាតគឺអង្គការហ្នឹងតែម្តងអាទិទេព... រួចយើងប្រើជាធម្មតាកន្លងមក «ចាត់តាំង» ដូចប្រើស្រាលៗ.... តែដល់ពេលប្រធានភូមិខ្មែរក្រហម «ចាត់តាំង» ហើយអត់មានអ្នកដទៃហ៊ានប្រកែកទេ អង្គការចាត់តាំង ពួកខ្មែរក្រហមប្រើពាក្យមួយៗមិនឲ្យប្រឡូកប្រឡំគ្នាហើយច្បាស់ ។ អ្នកដែលយល់គឺយល់ អ្នកដែលមិនយល់គឺមិនយល់ ក្រវេមក្រវាមគ្រោះថ្នាក់នឹងអាហ្នឹងឯង ។ ហើយអាគៀវ នេះ អា កាំង ហ្កិចអៀវ នេះ ក្រោយមកវាទៅរៀនយកសញ្ញាប័ត្រ បរិញ្ញាប័ត្រ ហើយវិញ្ញាសាចុងក្រោយ៣ម៉ោងសរសេរ៦ទំព័រ ។ ៦ទំព័រវិញ្ញាសារបស់យើងមិនមែនធម្មតាទេ

ហើយដល់គ្រូគេកែទៅអាគៀវដាប់លេខមួយវិញ្ញសាមួយហ្នឹង ។ បើវារៀនគឺប្រាកដជារៀនតែម្រ៉ងកុំអាណាទៅកេះវា អង្គុយធ្វើគណិតវិទ្យាគិតតែធ្វើ រួចដួនកាលបើគេសួរខ្លាំងវាឆ្លើយទៅ ប៉ុន្តែដៃវានៅតែរវើរហូត ខួរក្បាលពូកែណាស់.. ចរិតវាដូចមិនដែលថាខឹងអាណាមួយទេ រឿងក្រទីក្រទើប ឬដេរអីអត់ទេ ខឹងខ្លាំងញញឹមកាន់តែខ្លាំង ស្រាប់តែដល់ពេលកាចៗទៅអីចឹង ។ ពីឆ្នាំ៨៦-៨៧ ខ្ញុំទៅដល់ស្មោងទៅសួរអាពួកម៉ាកខ្ញុំសួរថាដឹងអាគៀវទៅណាទេ ក៏ប៉ុន្តែគេលាក់ ។ ដល់ឃើញកាសែតចុះ ប៉ុស្តិ៍អាមេរិកផ្សាយថាចូលយេស៊ូចូលអី ខ្ញុំភ្ញាក់ព្រើតក៏ចាំមើលមុខអាហ្នឹងមែនឬមិនមែន ដល់ឃើញកាសែតយី អាគៀវ មែន ។

**កុសលៈ** កាំង ហ្គិចអៀវ ក៏បានអះអាងថាគាត់សោកស្ដាយនូវអ្វីដែលគាត់បានធ្វើក្នុងជំនាន់ប៉ុលពត ប៉ុន្តែគាត់ហាក់ដូចជាបានយកគ្រិស្តសាសនាដើម្បីលាងបាបកម្មរបស់គាត់ ។ តើចំពោះលោកអ៊ំដែលធ្លាប់បាននៅជាមួយគ្នាយូរ ហើយធ្លាប់បានចូលរួមសិក្សាខាងពុទ្ធសាសនា តើលោកអ៊ំយល់យ៉ាងណាដែរ?

**សារុនៈ** វាមិនមែនរួចទេ ជាគំនិតច្បាប់មិនដែលឲ្យទៅរួចកើតទេ ទស្សនវិជ្ជាយេស៊ូគ្រាន់តែប្រោសសត្វលោក ។ទស្សនវិជ្ជាព្រះពុទ្ធថានរណាធ្វើអ្នកហ្នឹងទទួលខុសត្រូវ គឺច្បាស់តែម្ដង ។ រឿងបុណ្យរឿងបាប កាលនៅជាមួយខ្ញុំគោរពលោក គោរពគ្រូអីច្បាស់លាស់របស់វា ទៅនៅកន្លែងណាក៏ធ្វើបុណ្យធ្វើទាននឹងគេដែរ ។

**កុសលៈ** ជាមនុស្សហ៊ានទទួលខុសត្រូវ?

**សារុនៈ** ហ៊ាន មនុស្សនោះប្រាកដ ។

**ដារ៉ាៈ** ឌុច មានជំនឿជឿជាក់ ហើយជាអ្នកចេះដឹងជ្រៅជ្រះ រឿងអីទៅយកព្រះយេស៊ូជាខែលលាងបាបទៅវិញ?

**សារុនៈ** ...អាហ្នឹងជានយោបាយទេ ឧទាហរណ៍ថាបើវាទៅជាអន្តរជាតិ ទៅនៅប្រទេសណាមួយក៏គេស្គាល់វាដែរ ព្រោះកាសែតចុះរូបផ្សាយរូបវាក៏គេស្គាល់ ។

**កុសលៈ** កាលពីជំនាន់នៅជាមួយអ៊ំ តើ គៀវ ធ្លាប់បាននិយាយពីរឿងចង់ចូលសាសនាគ្រិស្តដែរឬទេ?

**សារុនៈ** គ្មាន គ្មានទេ សាសនាដទៃគឺបំផ្លាញជាតិ អះអាងច្បាស់ហើយសូម្បីតែពុទ្ធសាសនាក៏ឈ្លើងជញ្ជក់ឈាមដែរ ។ គេ (ឌុច) និយាយអីចឹងថា សាសនាគឺឈ្លើងជញ្ជក់ឈាម ។

**កុសលៈ** កាលនៅជាមួយលោកពូតើរៀនភាសាបារាំងចេះហើយ?

**សារុនៈ** ចេះហើយ ។

**កុសលៈ** ចុះអង់គ្លេសដែលរៀនទេ?

**សារុនៈ** អង់គ្លេសក៏ចេះតិចតួច រៀនអាឆ្នាំជិតចេញពីគុក ។

**កុសលៈ** សង្កាតរៀនទេ?

**សារុនៈ** អូ! អានោះរៀនឆាប់ចាំ ហើយមើលទៅចេះអង់គ្លេសដែរ ពេលចេះពី៧០អីហ្នឹងមិនច្រើនទេ បើបារាំងវានិយាយបាន អានសៀវភៅសរសេររបស់ ម៉ៅ សេទុង សុទ្ធតែបារាំងទាំងអស់ ព្យាយាមរកឯកសារជាខ្មែរឲ្យខ្ញុំមើល ឯកសារបារាំងឲ្យខ្ញុំមើល សៀវភៅរឿងចិនរបស់ ម៉ៅ សេទុង បកប្រែជាបារាំង ហើយបកប្រែជាខ្មែរ ។ ឧស្សាហ៍ណាស់ ស្គាល់កន្លែងកន្ទុកកន្ទៀតមេខ្មែរក្រហមកុម្មុយនិស្តនៅក្រុងភ្នំពេញប៉ុន្មាននវាស្គាល់អស់ ។

**កុសលៈ** មួយទៀតពាក្យ«បណ្ដាញ»តើគេប្រើយ៉ាងម៉េចខ្លះ? ប្រើក្នុងកាលៈទេសៈណាខ្លះ?

**សារុនៈ** បណ្ដាញបើខ្ញុំដឹងគឺថាប្រវាក់ប្រទាក់គ្នា បើជំនាន់ខ្មែរក្រហមបណ្ដាញត្រីកោណ (គាត់ដាក់ប៊ិកធ្វើជារាងត្រីកោណជាសញ្ញាបង្ហាញ) ហើយចង្កោមដែលធ្វើការទំនាក់ទំនងគ្នាគឺបណ្ដាញគ្នាទាំងអស់ វាមានបណ្ដាញត្រីកោណ បណ្ដាញបញ្ចកោណ បណ្ដាញចតុកោណ ប៉ុន្តែភាគច្រើនត្រីកោណ ។

**កុសលៈ** មានឯកសារចម្លើយសារភាពជាច្រើន ដែលមានហត្ថលេខារបស់ ឌុច ដែលផ្ញើទៅឲ្យ សុន សេន (ខៀវ) ផ្ញើទៅឲ្យ នួន ជា (បងនួន) ទៅផ្សេងៗទៀតច្រើន ។ ឥឡូវគាត់នៅក្រោមការឃុំរបស់តុលាការយោធាខ្មែរ ហើយគេនឹងរៀបចំធ្វើការកាត់ទោស ចំពោះទស្សនៈអ៊ំផ្ទាល់ តើមនុស្សដូចគាត់គួរតែទទួលទោសបែបហ្នឹង ឬក៏ថាគួរតែសម្រាលទោស អ៊ំយល់យ៉ាងម៉េច?

**សារុនៈ** ក្នុងនាមជាមិត្តភក្តិអាណិតហើយ ក៏ប៉ុន្តែឲ្យមានទឹកចិត្តថាទៅធានាអះអាងថាឲ្យសម្រាលអីក៏ខ្ញុំទៅមិនរួច ព្រោះគ្រាន់តែឃើញគុកទួលស្លែងក្រោយឆ្នាំ៧៩មកខ្ញុំស្អែតចិត្ត ។ សំបុកខ្ញុំរាប់ទៅ១០៨នាក់ត្រូវបនប្រល័យពូជសាសន៍សម្លាប់ ឪពុកមាបង្កើត ម្ដាយមីងបង្កើត បងប្អូនជីដូនមួយអត់រាប់ដល់ជីទួតទេ ដូច្នេះទោះបីអ្នកឯងក្រុមបនជាមួយខ្ញុំក៏ខ្ញុំអត់មានស៊ីគ្នាទេ ។

**កុសលៈ** ចុះបើឧបមាថាអ៊ំមានឱកាសជួបជាមួយ ឌុច ចង់សួរ

ឌុប ពីរឿងអីខ្លះ?

**សារុន:** ចង់សួរថាឥឡូវម៉េចហ្អែង ដល់គោលដៅហ្អែងឬនៅ?

**កុសល:** គោលដៅអីទៅ?

**សារុន:** គោលគំនិតដែលធ្លាប់និយាយជាមួយគ្នា អាលទ្ធិកុម្មុយនិស្ត មិនអាចសោយរាជ្យក្នុងពិភពលោកទេ ពីព្រោះ «លទ្ធិកុម្មុយនិស្ត អត់មានខួរក្បាល» ខ្ញុំធ្លាប់បានប្រាប់វាអ៊ីចឹង ហើយម៉េចបាន អត់មានខួរក្បាល វាគ្មានជំនឿអ្វីមួយដែលសម្រាប់អប់រំ គឺមាន តែលទ្ធិផ្តាច់ការនៅក្នុងខួរក្បាល ខ្ញុំនិយាយជាមួយវាច្បាស់ដល់ ទីបំផុតវាថាឲ្យខ្ញុំ «បែបប្រតិកិរិយា» ។ ខ្ញុំថាអើហ្អែងគិតថា អញប្រតិកិរិយាគង់តែដឹងទេ ។ គួរឲ្យអាណិតវាត្រង់ថាមនុស្ស មានមនសិការស្នេហាជាតិតែដល់ចូលវាខុស ។ ខ្ញុំនិយាយទៅចុះ ទៀវ សំផន ដែលខ្ញុំធ្លាប់ស្គាល់គាត់ជាមនុស្សមួយដែលគ្មានមើល ងាយរាស្ត្រ គ្មានដែលនិយាយពីរឿងក្បត់ជាតិ តែដល់ទៅចូល ជាមួយ ប៉ុល ពត ក្លាយជាមនុស្សផ្តាច់ការ ហើយខ្ញុំយល់ថា មិនមែនតែ ប៉ុល ពត ទេ នួន ជា ហើយនិងអាដែលគេប្រុងកាត់ ទោស តាម៉ុក ក៏អ៊ីចឹងដែរ ។ បើនិយាយពីមិត្តភក្តិដែលចូល បដិវត្តន៍ ខ្ញុំខំទាញគេ តែទាញមិនឈ្នះ ហើយគេទៅងាប់អស់ អត់ មានសល់ ងាប់អស់ ។ បើក្នុងចំណោមអ្នកដែលស្គាល់គ្នាជាមួយ កាំង ហ្គិចអៀវ នៅតែខ្ញុំមួយនេះឯង ក្រៅពីនោះគ្មានសល់ទេ អស់ហើយ សព្វថ្ងៃបើទៅជួបពួកអាជើងចាស់នៅកុដិលេខ៣ គេថាម៉េចពួកម៉ាកម៉ោពីខាងណោះ គេថាខ្ញុំពួកម៉ាកនឹង អាគៀវ ប្រាកដមែន ព្រោះដេកក៏ជាមួយគ្នា រូបបើថាខ្ញុំបានអីឆាន់រូប ហើយទុកឲ្យ អាគៀវ អាណិតវា ចង់ទាញវា ប៉ុន្តែវាក៏ចង់ទាញខ្ញុំ ការពិតខ្ញុំទាញគេមិនបាន គេទាញខ្ញុំក៏អត់បាន ។

**ដារ៉ា:** ប៉ុន្តែបើសិនជាមានឱកាសល្អណាមួយអាចនឹងទៅជួប កាំង ហ្គិចអៀវ បាន លោកអ៊ំទៅជួបដែរទេ?

**សារុន:** ឲ្យតែគេឲ្យជួបទៅ ។ ខ្ញុំទៅជួបភ្លាម ។

**ចប់**



## ប្រវត្តិរូប ហ៊ី
## អនុប្រធានរបស់ ឌុច នៅមន្ទីរស-២១

ឈ្មោះដើម ឃឹម វ៉ាត ឈ្មោះបដិវត្ត ហ៊ី អាយុ២៧ឆ្នាំ ចូលបដិវត្តន៍ថ្ងៃទី១៣ ខែ៦ ឆ្នាំ១៩៦៦ ចូលបក្សថ្ងៃទី១៦ ខែ៦ ឆ្នាំ១៩៧៣ ពេញសិទ្ធិថ្ងៃទី១៦ ខែ២ ឆ្នាំ១៩៧៣ ។ ទីលំនៅដើមភូមិណោនី ឃុំត្រើយស្លា ស្រុកស្អាង ខេត្តកណ្តាល ។ ឪពុកឈ្មោះ ប៊ុន ម្តាយឈ្មោះ លី ពាក់ព័ន្ធបងពីរនាក់ ។

**ចំណារសមមិត្ត ប៊ុន**

**ម្សៀ ឡឿន,** ខ្សែអាត់របស់លោកបានជូនទៅអង្គការហើយ ។ តាមការវិភាគរបស់អង្គការតាមប្រវត្តិសាស្ត្រជាក់ស្តែង ខ្លឹមសារ ខ្សែអាត់គឺជារឿងប្រឌិត ហើយដែលមានគោលបំណងៈ ១) វាយ កម្ទាំងបដិវត្ត ២) លាក់កម្លាំងក្បត់ពិតប្រាកដរបស់ខ្លួន ។ បើប្រឌិត ធុននេះចៀសមិនរួចពីអស់ប្រស្រីភ្នែកទេ ។ ស្នើលោកសរសេរ ឈប់ប្រឌិតទៀត ។ តើលោកប្រឌិតកន្លែងណាខ្លះ? តើលាក់ សកម្មភាពបក្សពួកខ្លួនយ៉ាងម៉េចខ្លះ? សូមលោកសរសេរបញ្ជាក់ ចំណុចពីរខាងលើនេះឲ្យបានរហ័ស ។ កុំវែងពេកដូចកន្លងមកដែល វែងល្អិត តែវែងល្អិតបែបករ ។ ធ្វើបែបនេះមិនកើតទេ ។ ប្រយ័ត្ន អស់ប្រស្រីភ្នែក? ១៩ ឧសភា ៧៧ ប៊ុន ។

**ប្រវត្តិរូបសង្ខេបរបស់ ប៊ុន ធ្វើនៅឆ្នាំ១៩៧៦:** ឈ្មោះដើម ទង់ សិងហៀន ឈ្មោះបដិវត្តន៍ ប៊ុន អាយុ២៨ឆ្នាំ ភេទប្រុស ឋានៈ សមាជិកគណៈកង២១ វណ្ណភាពអនុធនកណ្តាល ចូលអង្គការថ្ងៃ ២៨ ខែ១០ ឆ្នាំ១៩៧០ អ្នកឧទ្ទេសនាម បងឌុច បងរិន ឪពុក ឈ្មោះ ទង់ ឈាង ម្តាយឈ្មោះ កែ ជីន ស្រុកកំណើត ភូមិសានគរ ឃុំសានគរ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ កម្រិតវប្បធម៌ថ្នាក់ទី២ វិទ្យាល័យកំពង់ធំ និងធ្វើជាគ្រូបង្រៀន ។

# កែ ពក និងកសិណសាក្សី ដែលនៅរស់

## ខាលពិឃាតចម្ការ ស្វាយចន្ទី



*កែ ពក មានឈ្មោះដើមកំណើត កែ វិន កើតនៅក្នុងឆ្នាំ១៩៥៣ ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ កែ ពក ជាអនុលេខាភូមិភាគឧត្តរ ។ នៅពេលដែល កុយ ធួន ជាលេខាតំបន់ត្រូវបានចាប់ខ្លួននៅក្នុងឆ្នាំ១៩៧៧ កែ ពក បានឡើងជាលេខាភូមិភាគ ហើយភូមិភាគឧត្តរពេលនោះផ្លាស់ប្តូរទៅជាភូមិភាគកណ្តាល ។ មន្ទីរភូមិភាគរបស់កែ ពក ក្នុងភូមិថ្នល់បែកកើត ឃុំស្វាយទាប ស្រុកចម្ការលើ ខេត្តកំពង់ចាម ។ នៅចម្ងាយប្រមាណជាងមួយគីឡូម៉ែត្រប៉ុណ្ណោះពីមន្ទីររបស់ កែ ពក ប្រជាជនរាប់ពាន់នាក់ត្រូវបានសម្លាប់យ៉ាងរង្គាលទាំងហ្វូងៗនៅចម្ការស្វាយចន្ទី ។ រឿងសោកនាដកម្មនៅចម្ការស្វាយចន្ទីនៅក្នុងអំឡុងពេលដែល កែ ពក គ្រប់គ្រងត្រូវបានជិតជាប់នៅក្នុងក្រសែភ្នែករបស់ជនរងគ្រោះមួយចំនួនតូចដែលមានភ័ព្វសំណាងបានរួចជីវិតពីការសម្លាប់រង្គាលនេះ ។ លោកយាយ យឹម អាយុ៧៩ឆ្នាំ បានពិពណ៌នាអំពីទិដ្ឋភាពដ៏ជិតស្និទ្ធនៃគ្រួសាររបស់ កែ ពក និងអត្តចរិតរបស់ កែ ពក ។*

យាយ យឹម បានបញ្ជាក់ប្រាប់ថា លោកយាយធ្លាប់រស់នៅបម្រើ កែ ពក ប្រពន្ធ និងកូន៤នាក់ នៅភូមិថ្នល់បែកកើត រហូតដល់ទ័ពវាយលុកមកពីប្រទេសវៀតណាមបានមកដល់ ។ ដោយត្រូវបានស្គាល់ថាជាអ្នកចាប់សរសៃលេខ១ក្នុងចំណោមអ្នកចាប់សរសៃ១០០នាក់នៅក្នុងសហករណ៍ស្វាយមាស លោកយាយត្រូវបានជ្រើសរើសជាអ្នកចាប់សរសៃ និងធ្វើជាឆ្មប

ប្រចាំគ្រួសាររបស់ កែ ពក រហូតដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។ លោកយាយ យឹម បានចាប់សរសៃឲ្យ កែ ពក ដោយដៃផ្ទាល់និងជាញឹកញាប់ ។ លោកយាយរំឭកអំពីអារម្មណ៍របស់គាត់នាពេលនោះថា គាត់ខ្លាចសែនខ្លាច កែ ពក និងប្រពន្ធរហូតដល់គាត់មិនហ៊ានមើលមុខចំទេ ។ លោកយាយមានប្រសាសន៍ថា «ប្រសិនបើខ្ញុំចាប់សរសៃ កែ ពក មិនត្រូវខ្ញុំអត់បានបាយស៊ីទេ» ។ លោកយាយរំឭកឡើងវិញថា កែ ពក ធ្លាប់បាននិយាយមកកាន់លោកយាយថា «នែ៎យាយ! ប្រសិនបើយាយចាប់សរសៃមិនត្រូវខ្ញុំបើកឡានមិនកើតទេ» ។ ក្នុងរយៈពេលដែលលោកយាយរស់នៅជាមួយគ្រួសាររបស់ កែ ពក គឺពោរពេញទៅដោយការភ័យខ្លាចបាត់បង់ជីវិតជាប្រចាំ ។ លោកយាយនិយាយទៀតថា «នៅពេលបាយថ្ងៃមួយ ខ្ញុំឃើញអ្នកដែលកំពុងតែស៊ីបាយជាមួយខ្ញុំត្រូវបានដាក់ថ្នាំបំពុលស្លាប់» ។ ហើយអ្វីដែលធ្វើឲ្យលោកយាយបិទមាត់មិនហ៊ាននិយាយនោះគឺការព្រមានដ៏គួរឲ្យញាក់សាច់ពីប្រពន្ធ កែ ពក ឈ្មោះ សឿន ថា «យាយ! នៅពេលរស់នៅជាមួយខ្ញុំកុំរវើរវាយតាមគេ.. ត្រូវក្តាប់ឲ្យជាប់ធ្វើអ្វីត្រូវធ្វើហ្នឹង ប្រសិនបើលេចពុះទៅក្រៅប្រយ័ត្នធ្លាក់ទឹក» ។ មិនយូរប៉ុន្មានមុនថ្ងៃរំដោះ លោកយាយ បានរត់គេចទៅសម្ងំលាក់ខ្លួនដើម្បីយករួចជីវិតពីការតាមចាប់ដោយទាហានរបស់ កែ ពក ។

គ្រួសាររបស់ ឌឿ យ៉ានី រួមជាមួយនឹងគ្រួសារដទៃទៀតជាច្រើនមកពីក្រុងភ្នំពេញ ត្រូវបានជម្លៀសទៅភូមិថ្នល់បែកកើត ឃុំស្វាយទាប ។ យ៉ានី បានបញ្ជាក់ប្រាប់ថា គាត់រស់នៅក្បែរមន្ទីរភូមិភាគរំលងពីរ-បីផ្ទះប៉ុណ្ណោះពីកន្លែងដែល កែ ពក រស់នៅនិងធ្វើការ ។ យ៉ានី បាននិយាយថា «យើងស្គាល់ កែ ពក ច្បាស់មែនទែន ។ ខ្ញុំដើរកាត់មុខផ្ទះ កែ ពក ស្ទើរតែជារៀងរាល់ថ្ងៃ» ។ យ៉ានី បានបញ្ជាក់ទៀតថា ប្រពន្ធរបស់ កែ ពក ឈ្មោះ សឿន បានដើរតួនាទីសំខាន់ជាមួយនឹងប្តីរបស់ខ្លួន ។ សឿន ថែមទាំងធ្លាប់ធ្វើដំណើរទៅក្រៅប្រទេសជាមួយនឹងប្រពន្ធរបស់ ប៉ុល ពត ទៀតផង ។ យាយ យឹម ក៏បានបញ្ជាក់អំពីតួនាទីដ៏សកម្មរបស់ សឿន ដោយនិយាយថា សឿន គឺជាប្រធានស្រុកចម្ការលើ ។ ទាំង យ៉ានី និងយាយ យឹម បញ្ជាក់ថា សមមិត្ត អឿន ដែលជាប្អូនថ្លៃរបស់ កែ ពក ជាប្រធានតំបន់ (តំបន់៣០៣) ។ ជាភ័ព្វសំណាង គ្រួសាររបស់ យ៉ានី និងគ្រួសាររបស់មិត្តភក្តិរបស់គាត់ រួចផុតពីការសម្លាប់រង្គាលនៅចម្ការស្វាយចន្ទីនៅក្នុងឆ្នាំ១៩៧៨ ដែលនៅពេលនោះគ្រួសារប្រជាជនថ្មីជាច្រើនមកពីភ្នំពេញត្រូវបានបញ្ជូនយកទៅសម្លាប់យ៉ាងសាហាវឃោរឃៅ ។ យ៉ានី និយាយថា «នៅក្នុងអំឡុងប្រមាណ៥ខែចុងក្រោយនៃឆ្នាំ១៩៧៨ ខ្លួនខ្ញុំនិងគ្រួសារមិត្តភក្តិរបស់ខ្ញុំពីរនាក់ទៀត ត្រូវបានពួកខ្មែរក្រហមបញ្ជូនឲ្យទៅធ្វើឥដ្ឋនៅការដ្ឋានមួយចម្ងាយប្រមាណ៦ទៅ៧គីឡូម៉ែត្រពីភូមិថ្នល់បែកកើត ។ នៅពេលខ្ញុំត្រឡប់មកវិញ ខ្ញុំរាប់ទៅឃើញសល់តែពីរគ្រួសារប៉ុណ្ណោះដែលមកពីភ្នំពេញជាមួយគ្នា គឺគ្រួសារខ្ញុំនិងគ្រួសាររបស់មិត្តខ្ញុំម្នាក់ ។ ក្នុងអំឡុង៤ទៅ៥ខែ មុនពេលទ័ពវាយលុកមកពីប្រទេសវៀតណាម ខ្ញុំប៉ាន់ស្មានថាប្រហែលពី៥០០០ទៅ១០០០០នាក់ ដោយមិនរាប់បញ្ចូលការសម្លាប់ប្រជាជនថ្មីពីលើកមុន បានស្លាប់នៅចម្ការស្វាយចន្ទី» ។ យ៉ានី ជឿថា ប្រធានភូមិស្វាយចន្ទីប្រាកដជាបានបញ្ជាឲ្យសម្លាប់ «ប្រជាជនថ្មី» ទាំងអស់ដែលរស់នៅក្បែរមន្ទីរភូមិភាគរបស់ កែ ពក ហើយយកទ្រព្យសម្បត្តិរបស់ជនរងគ្រោះទៅឲ្យ កែ ពក ដើម្បីបង្ហាញអំពីភក្តីភាពនិងការស្មោះត្រង់ចំពោះអង្គការភូមិភាគ ។

លោក ឡុង សុខៃ អាយុ៥១ឆ្នាំ គឺជាប្រជាជនមូលដ្ឋាននៅក្នុងជំនាន់ប៉ុលពត ។ គាត់រួចរស់ជីវិតដោយសារតែគាត់អត់ជាប់ឈ្មោះនៅក្នុងបញ្ជីរបស់ប្រធានក្រុមឲ្យចូលរួម «ប្រជុំ» ។ ឡុង សុខៃ និយាយថា ប្រជាជនជាច្រើនត្រូវបានពួកខ្មែរក្រហមប្រាប់ឲ្យផ្លាស់ទៅរស់នៅភូមិផ្សេង ។ នៅថ្ងៃមួយប្រហែលក្នុងខែមិថុនា ឬកក្កដា ឆ្នាំ១៩៧៨ ប្រធានក្រុមរបស់គាត់បញ្ជាឲ្យបររទេះដឹកខ្សាច់ទៅចម្ការអណ្តូងដែលជាសហករណ៍មួយទៀតនៅស្រុកចម្ការលើនេះដែរ ។ នៅតាមផ្លូវគាត់បានឃើញគ្រួសារជាច្រើនមកពីបណ្តាភូមិដទៃទៀតនៅក្នុងឃុំស្វាយទាប ធ្វើដំណើរឆ្ពោះទៅចម្ការស្វាយចន្ទី ។ គាត់មានអារម្មណ៍ចម្លែក ប៉ុន្តែមិនហ៊ានសួរទេ គាត់ក៏សម្រេចចិត្តបររទេះទៅតាមទិសដៅរបស់គាត់ ។ ដល់ពេលបររទេះត្រឡប់មកវិញគាត់ឮសំឡេងមេក្រូចាក់ខ្ទរខ្ទារនៅក្នុងចម្ការស្វាយចន្ទី សុខៃក៏មានអារម្មណ៍ចម្លែកក្នុងចិត្ត និងមានការសង្ស័យកាន់តែខ្លាំង ។



ឡុង សុខែ ចាំថា នៅយប់មួយមុនថ្ងៃនោះ កម្មាភិបាលខ្មែរក្រហម បានឲ្យគាត់ទៅយាមនៅទិសខាងលិចនៃចម្ការស្វាយចន្ទី ។ នៅពេលនោះគាត់ឮសំឡេងកាប់ដីពេញមួយយប់ ។ តាមរយៈអ្វីដែល សុខែ បានឃើញនិងឮ គាត់គិតខ្លួនឯងថា ប្រជាជនដែលគាត់បានឃើញធ្វើដំណើរឆ្ពោះទៅស្វាយចន្ទីមុខជាត្រូវយកទៅសម្លាប់ ។ តាមគាត់សន្និដ្ឋាន ប្រជាជនមិនតិចជាង១០០០០នាក់ទេដែលត្រូវបានបញ្ជូនយកទៅសម្លាប់នៅទីនោះ ។

លោក ឈុន ឡា ដែលជាប្រជាជនមូលដ្ឋាន (ឬប្រជាជនចាស់) ម្នាក់ទៀតហើយដែលបានរួចរស់មកដល់សព្វថ្ងៃនេះ បានបញ្ជាក់ប្រាប់ឲ្យដឹងកាន់តែជាក់ស្តែងថែមទៀតនូវអ្វីដែលបានកើតឡើងនៅក្នុងចម្ការស្វាយចន្ទី ។ ក្នុងខែកក្កដា ឆ្នាំ១៩៧៨ ប្រធានក្រុមរបស់ ឈុន ឡា បានបញ្ជាឲ្យគាត់ដឹកអ្នកថ្មី២នាក់ទៅចម្ការស្វាយចន្ទី នៅតាមផ្លូវ ឈុន ឡា បានឃើញរទេះគោប្រហែល៣០ទៅ ៤០ ដឹកប្រជាជនទាំងគ្រួសារៗ ។ ដល់ផ្លូវបំបែកមួយឆ្ពោះទៅភូមិស្រឡៅពកនិងមួយទៀតឆ្ពោះទៅចម្ការស្វាយចន្ទីមានឈ្លបខ្មែរក្រហមពីរនាក់ក្មេងៗអាយុប្រហែលជា ១៥ ទៅ១៦ឆ្នាំប៉ុណ្ណោះ ឈរស្ទាក់ក្បួនរទេះគោ ហើយបញ្ជាឲ្យធ្វើដំណើរឆ្ពោះទៅចម្ការស្វាយចន្ទីវិញ ។ ឈុន ឡា បានឃើញកម្មាភិបាលខ្មែរក្រហមម្នាក់ក្នុងចំណោមកម្មាភិបាលខ្មែរក្រហមពីរនាក់ដែលគាត់ធ្លាប់ស្គាល់ឈ្មោះសមមិត្ត សួន កំពុងឈរបញ្ជាឈ្លបខ្មែរក្រហមឲ្យចងប្រជាជននៅលើរទេះគោទាំងនោះ ។ បន្តិចក្រោយមកកម្មាភិបាលខ្មែរក្រហមស្រែកបញ្ជាឲ្យគាត់ទាញទម្លាក់ឥវ៉ែឥវ៉ាន់របស់ប្រជាជនទាំងនោះចេញពីរទេះ ។ ទ្រព្យរបស់ដែលកម្មាភិបាលមានតម្លៃដូចជាសារុងអាវម៉ុងតេហ្គុយខោកាណាជា ត្រូវបានកម្មាភិបាលខ្មែរក្រហមយកទាំងអស់ រីឯរបស់ផ្សេងៗទៀតដែលពួកខ្មែរក្រហមយល់ថា គ្មានតម្លៃដូចជាកេស វ៉ាលីស ត្រូវបានដាក់ជាគំនរហើយដុតកម្ទេចចោល ។ លោក ឈុន ឡា បានឃើញឈ្លបខ្មែរក្រហមម្នាក់ទៀតឈរកាន់ពូថៅមួយមានដៃវែងហើយដងខ្លី ហាក់ដូចជារង់ចាំបញ្ជាឲ្យអូសយកមនុស្សទាំងនេះទៅសម្លាប់ ។ ស្ត្រីដែលមានកូនតូចត្រូវបានស្រាយចំណងឲ្យបំបៅកូន ស្ត្រីផ្សេងទៀតត្រូវបង្ខំឲ្យនៅមួយកន្លែងរហូតដល់បន្ទំចិត្តនោមដាក់សារុង ហើយជួនពេលខ្លះពួកឈ្លបខ្មែរក្រហមយកដើងទាត់ (ឬឆ្កឹះ) គូថរបស់ស្ត្រីទាំងនោះប្រសិនបើស្ត្រីទាំងនោះនោមយូរពេក ។

លោក ឈុន ឡា បានបញ្ជាក់ថែមទៀតថា គាត់ធ្លាប់បានជួប កែ ពក ផ្ទាល់នៅឯចម្ការស្វាយចន្ទី ហើយគាត់ចាំបានថា កែ ពក មានស្លាកស្នាមនៅលើថ្ពាល់ម្ខាង ហើយធ្លាប់បានឮ កែ ពក និយាយថា «នរណាឲ្យសម្លាប់? នរណាឲ្យធ្វើអីចឹង?» ប៉ុន្តែ



ដុយទៅវិញដល់ចុងឆ្នាំ១៩៧៨ កែ ពក បានបញ្ជាកូនចៅរបស់ខ្លួនឲ្យចុះឈ្មោះអ្នកដែលចេះជិះទៅវិញ ។ លើកនេះគាត់ឮ កែ ពក និយាយថា «អ្នកចេះជិះត្រូវនៅលើគេក្នុងបញ្ជីព្រោះពួកនេះជាវណ្ណៈជិះជាន់...» ។ ឈុន ឡា មានការសង្ស័យ ហើយក៏បានជួបជាមួយនឹងយាយ យឹម ដែលរស់នៅជិតជិតនឹង កែ ពក ដែលបានជួយគាត់កុំឲ្យចុះឈ្មោះ ។ ឈុន ឡា បញ្ជាក់ថា បន្ទាប់ពីចុះឈ្មោះ ហើយក៏ទំនងជាពុំមានការសម្លាប់ទាន់ដែរ ព្រោះទ័ពវៀតណាមចូលមកដល់ ។

លោក តឹង យ៉ាត ដែលជាប្រធានឃុំស្វាយទាបនាពេលបច្ចុប្បន្ន បញ្ជាក់ប្រាប់ថា ភ្លាមៗបន្ទាប់ពីថ្ងៃរំដោះ គាត់បានឃើញមានរណ្ដៅសាកសពរួម៣ ។ រណ្ដៅមួយមានប្រវែង៣០ម៉ែត្រ ទទឹង២ម៉ែត្រ ។ រណ្ដៅ២ទៀតជាប្រភេទរណ្ដៅគ្រាប់បែក រណ្ដៅនីមួយៗមានអង្កត់ផ្ចិត១០ម៉ែត្រ និងលេណដ្ឋានទ័ពមួយទទឹង២ម៉ែត្រ បណ្ដោយ១០០ម៉ែត្រ និងជម្រៅ១ម៉ែត្រកន្លះ ។ លោក តឹង យ៉ាត ធ្វើការប៉ាន់ស្មានថា ប្រហែលជាប្រជាជន៥០០០ ទៅ៧០០០នាក់ បានស្លាប់នៅទីនេះ ហើយប្រហែលជាអដ្ឋិធាតុ១ភាគ៤ត្រូវបានគាស់និងតម្កល់ទុកនៅក្នុងខ្ទមមួយក្បែរទីនោះ ប៉ុន្តែខ្ទមនោះត្រូវបានបាត់បង់ទៅហើយដោយសារកង្វះការថែទាំជាច្រើនឆ្នាំ ។

យាយ យឹម បានពិពណ៌នាថា កែ ពក ជាមនុស្សដ៏សាហាវ ។ ឡុង សុខៃ ដែលជាអ្នកមូលដ្ឋាននៅក្នុងភូមិថ្មល់បែកកើតបានឃើញដោយផ្ទាល់ភ្នែកនូវការរៀបចំបញ្ជូនមនុស្សយកទៅសម្លាប់នៅចម្ការស្វាយចន្ទី ហើយលោក ឈុន ឡា បានឃើញកម្មាភិបាលខ្មែរក្រហមធ្វើទារុណកម្មលើស្ត្រីនិងឃើញអាវុធដែលប្រើប្រាស់សម្រាប់សម្លាប់ជនស្លូតត្រង់ទាំងនោះ ។ លោក តឹង យ៉ាត បានឃើញអដ្ឋិធាតុរបស់ជនរងគ្រោះដែលប៉ាន់ស្មានថាអាចមានចំនួនពី ៥០០០ទៅ ១០០០០នាក់ដែលបានស្លាប់នៅចម្ការស្វាយចន្ទី ។ យ៉ានី បានបញ្ជាក់ថា កែ ពក ពិតជានៅមន្ទីរភូមិភាគក្បែរចម្ការស្វាយចន្ទី ដោយគាត់បានឃើញជាញឹកញាយ គាត់ស្គាល់ កែ ពក ច្បាស់ ។ ហើយបញ្ជាក់ថា «ទោះបីជា កែ ពក និងប្អូនថ្លៃរបស់ខ្លួន សមមិត្ត អឿន បដិសេធទម្លាក់កំហុសទៅលើខ្មោច ប៉ុល ពត យ៉ាងណាក៏ដោយ សូមកុំឲ្យជឿ កែ ពក» ។ យ៉ានី បាននិយាយជាចុងក្រោយថា កែ ពក បានបញ្ជាឲ្យសម្លាប់មនុស្សច្រើនណាស់មិនត្រឹមតែនៅក្នុងភូមិរបស់គាត់ប៉ុណ្ណោះទេ ។ **ផាត កុសល**



កែ ពក

## ទំនាស់ និង វិធានការដោះស្រាយ

**១) ទំនាស់**

ទំនាស់មានពីរប្រភេទគឺទំនាស់បដិបក្ខ និងទំនាស់មិនបដិបក្ខ ។ ទំនាស់បដិបក្ខបានន័យថាជាទំនាស់ស្លាប់រស់ ឯទំនាស់មិនបដិបក្ខគឺជាទំនាស់ផ្ទៃក្នុងមិនមែនជាទំនាស់ស្លាប់រស់ទេ ។ ឧទាហរណ៍ ទំនាស់រវាងយើងនឹងភ្នាក់ងារសេ.អ៊ី.អា ជាទំនាស់ស្លាប់រស់ ។

**២) គោលជំហរនិងវិធានការដោះស្រាយទំនាស់**

វិធានការដោះស្រាយមាន៤យ៉ាងដូចតទៅ÷

ក) ត្រូវមានស្មារតីទទួលខុសត្រូវឲ្យខ្ពស់ក្នុងការវិភាគទំនាស់ ។

ខ) ត្រូវឈរលើមាគ៌ាបក្សគ្រប់ផ្នែកដើម្បីវិភាគទំនាស់ ។

គ) ត្រូវឈរលើសម្ភារនិយមបដិច្ចសមុប្បាទ គឺឈរលើការជាក់ស្តែងដើម្បីវិភាគទំនាស់ជាបដិបក្សឬជាផ្ទៃក្នុង ។

ឃ) ត្រូវឈរលើសមូហភាពដើម្បីពិនិត្យនិងដោះស្រាយទំនាស់ ។

ដកស្រង់ដោយ អៀ ម៉េងទ្រី ចេញពីសៀវភៅរៀនសូត្រនយោបាយឆ្នាំ១៩៧៧ របស់សមមិត្ត ឆេង ប៉ោ កម្មាភិបាលពេទ្យនៅមន្ទីរស-២១ដែលមានចំណងជើងថា «លទ្ធិម៉ាក្ស-លេនីន» ។



# សមមិត្ត គង់ ឬ សួង ស៊ីគឿន

## (ភក់ក្រោតាមសំណៅដើមទាំងស្រុង)

ប្រវត្តិរូបសមមិត្ត គង់ ឬ សួង ស៊ីគឿន ជាប្រវត្តិរូបមួយក្នុងចំណោមប្រវត្តិរូបកម្មាភិបាលខ្មែរក្រហមជាង២ម៉ឺននាក់ ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងរៀបចំចងក្រងទៅក្នុងប្រព័ន្ធកុំព្យូទ័រទិន្នន័យប្រវត្តិរូប ។ តើ សួង ស៊ីគឿន ជានរណា? ប្រវត្តិរូបនេះនឹងផ្តល់នូវផ្នែកខ្លះនៃចម្លើយទាំងស្រុងមួយ ។ ផ្នែកដទៃទៀតនៃចម្លើយនេះអាចមាននៅក្នុងសៀវភៅ «៥ឆ្នាំឆ្ងាយហួសពីដើងមេឃ» និពន្ធដោយអ្នកស្រី ឡូរ៉េង់ ពិជ ដែលជាអតីតភរិយារបស់ សួង ស៊ីគឿន និងជាអតីតសមាជិកនៃរបប

កម្ពុជាប្រជាធិបតេយ្យ បម្រើការនៅក្រសួងការបរទេសក្រោមការដឹកនាំរបស់ អៀង សារី ។ សៀវភៅ «៥ឆ្នាំឆ្ងាយហួសពីដើងមេឃ» នេះសរសេរជាភាសាបារាំង ហើយត្រូវបានបកប្រែមកជាភាសាខ្មែរដោយឯកឧត្តម ខៀវ កាញារិទ្ធ រដ្ឋលេខាធិការក្រសួងពត៌មាននៃរាជរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្ន ដែលមានតម្កល់ទុកនៅបណ្ណាល័យជាតិ ។ ផ្នែកចុងក្រោយនៃចម្លើយថាតើ សួង ស៊ីគៀន ជានរណា គឺពត៌មានដែលថតនៅក្នុងកាសែ្សតវីដេអូដោយអង្គការអភិវឌ្ឍសង្គមកម្ពុជាក្នុងវេទិកាសាធារណៈអំពីបញ្ហាខ្មែរក្រហមនៅខេត្តបាត់ដំបងក្នុងឆ្នាំ២០០០នេះ ។ ពត៌មានទាំង៣ប្រភពខាងលើនេះអាចនឹងជួយឲ្យមិត្តអ្នកអានបានយល់ថាតើ សួង ស៊ីគៀន ជានរណា? **ឆាំង យុ**

## ប្រវត្តិរូបបដិវត្តន៍ សួង ស៊ីគៀន

ឈ្មោះដើម សួង ស៊ីគៀន ឈ្មោះបដិវត្តគង់ កើតនៅថ្ងៃ១០ ខែកុម្ភៈ ឆ្នាំ១៩៣៧ នៅភូមិជ្រោយអំពិល ឃុំចំបក់ ស្រុកព្រែកប្រសព្វ (បច្ចុប្បន្នក្នុងខេត្តក្រចេះ) តំបន់កំពង់ចាមលើភូមិភាគឧត្តរ ភេទប្រុស ជនជាតិខ្មែរ ។ ឪពុក នូ កាក កើតនៅភូមិឃុំឬស្សីកែវ ស្រុកព្រែកប្រសព្វ តំបន់កំពង់ចាមលើភូមិភាគឧត្តរ ។ ស្លាប់នៅឆ្នាំ១៩៣៦ ។ ខ្ញុំមិនដែលស្គាល់គាត់ទេ ព្រោះពេលឪពុកស្លាប់ ខ្ញុំទើបអាយុបានបីខែ ។ វណ្ណភាពកសិករកណ្តាល ថ្នាក់កណ្តាល ។ ជីតាខ្ញុំខាងឪពុក (តាសួង) ធ្វើអាចារ្យវត្ត ។ ម្តាយ នូ រេន នៅភូមិឃុំកំណើតខ្ញុំ ឪពុកគាត់ (ជីតាខ្ញុំខាងម្តាយ) តានូ ជាភ្នាក់ងាររដ្ឋអំណាចសក្តិភូមិជំនាន់នោះ ។ ខ្ញុំកើតក្រោយគាត់ស្លាប់ ។ ដូច្នោះខ្ញុំមិនដែលស្គាល់គាត់ទេ ។ ខ្ញុំឮតែគេហៅគាត់បាឡាត់នូៗ ។ បងបង្អូនរបស់ម្តាយខ្ញុំឈ្មោះ នូ ឈុំ ធ្វើជាមេឃុំចំបក់ បម្រើរដ្ឋអំណាចសក្តិភូមិ និងរបបអាណានិគមបារាំងនៅឆ្នាំ១៩៤៧ ហើយជាបន្តបន្ទាប់មករហូតដល់ឆ្នាំ១៩៥៥ ឪពុកធំខ្ញុំនេះឈរឈ្មោះជាបេក្ខជនរបស់បក្សសេរីភាពដែលមានអាក្បត់ សំសុង ហ្វៃណង់ដេស ជាមេក្លោង ។ ចាប់ពីឆ្នាំ១៩៤៧នោះមក គាត់ទៅជាគូបដិបក្ខជាមួយខ្ញុំ ព្រោះខ្ញុំជាសមាជិកសកម្មនៃបក្សប្រជាធិបតេយ្យ និងក្រុមប្រជាជនពេលបោះឆ្នោត (ឆ្នាំ១៩៥៥) ។

-ខ្ញុំមានតែបងស្រីមួយដែលស្លាប់១ឆ្នាំមុនឪពុកខ្ញុំ ។ ដូច្នោះខ្ញុំមិនដែលស្គាល់បងស្រីខ្ញុំទេ ។ ក្រោយពីឪពុកខ្ញុំស្លាប់ ម្តាយខ្ញុំមានការលំបាកដើម្បីរកស៊ីចិញ្ចឹមជីវិត ។ គាត់មានដីចម្ការប្រមាណ១ហិកតានៅភូមិបឹងវែ ចម្ងាយប្រហែល៥គីឡូម៉ែត្រពីភូមិខ្ញុំ ។ គាត់ក៏មានដីស្រែប្រមាណ១ហិកតាទៀតនៅភូមិស្ទឹងធំ ដែលគាត់ជួលឲ្យប្អូនស្រីជីដូនមួយគាត់ធ្វើ ។ តែកម្រៃដែលបានគ្រាន់តែបង់ពន្ធដីស្រែនេះឲ្យរដ្ឋការប៉ុណ្ណោះ ។ ជីវភាពម្តាយខ្ញុំពេលនោះចេះតែចុះថយពីមួយឆ្នាំទៅមួយឆ្នាំទប់ទល់ៗខាងស្បៀង ។ តែខាងសម្លៀកបំពាក់មានការលំបាកច្រើន ។ ជីវភាពនេះត្រូវដុនដាបទៀតដោយពេលនោះ (ឆ្នាំ១៩៤៥-១៩៥៤) មានចោរព្រៃជាដៃជើងបារាំងនិងពួកទាហានចុះរាតត្បាតរែអង្កាសព្រមទាំងពន្ធដារមានសព្វសារពើ មាន «វិភាគទានសម្រាប់កម្ចាត់អសន្តិសុខ» ។ ជាមួយនេះម្តាយត្រូវខ្ចីបុលប្រាក់គេដើម្បីចិញ្ចឹមជីវិតផងនិងដើម្បីផ្គត់ផ្គង់ឲ្យខ្ញុំរៀនផង ។ ក្នុងកុមារវ័យនេះ ម្យ៉ាងខ្ញុំភ្លឹតភ្លើនពីតំណែងនាទីជាបាឡាត់ឬមេឃុំរបស់ជីតានិងឪពុកធំខ្ញុំ ម្យ៉ាងខ្ញុំឈឺចាប់ពីជីវភាពលំបាកខ្វះមុខខ្វះក្រោយរបស់ម្តាយខ្ញុំ ។

នៅឆ្នាំ១៩៤៥ពេលពួកយោធានិយមជប៉ុនចូលឈ្លានពានប្រទេសយើង នៅភូមិខ្ញុំដាច់អង្ករប្រាំមួយខែ ។ ប្រជាជនហូបតែក្ដួចនិងពោត ហើយត្រូវពួកហ្វាស៊ីសជប៉ុនកេណ្ឌយកទៅធ្វើបន្ទាយវាយនៅទីរួមខេត្តក្រចេះ ត្រូវរងគ្រោះអាសន្នរោគស្លាប់អស់ជាច្រើន ។ គ្រួសារម្តាយខ្ញុំក៏មានស្លាប់មួយចំនួនដែរ ។ បន្ទាប់ពីជប៉ុនបរាជ័យមានកើតចលនាចោរព្រៃដែលបង្កបង្កើតអសន្តិសុខក្នុងភូមិខ្ញុំរហូតដល់ឆ្នាំ១៩៥៥ ។ ក្នុងរយៈពេលនេះបងប្រុសម្តាយខ្ញុំម្នាក់និងប្អូនប្រុសឪពុកខ្ញុំម្នាក់ ត្រូវពួកចោរព្រៃដែលជាក្រុមចាត់តាមរបបអាណានិគមបារាំងសម្លាប់ចោល ។ នៅពេលនោះខ្ញុំចូលរៀនសាលាជាលើកដំបូង(ឆ្នាំ១៩៤៥) ខ្ញុំបានចាប់អារម្មណ៍ខ្លះៗពីបញ្ហាជាតិនិងពីការជិះជាន់របស់អាណានិគមនិយមបារាំងតាមរយៈការឃោសនារបស់ពួកឈ្មួញកប្បាសដែលចុះពីទន្លេតូចព្រែកសង្ក្រានមកដល់ភូមិខ្ញុំ ។ ពួកនេះជាភ្នាក់ងារពួកប្រជាធិបតេយ្យ ។

នៅឆ្នាំ១៩៤៧ ខ្ញុំទៅរៀនសាលាបឋមសិក្សានៅទីរួមស្រុកឆ្លូងហើយបានចូលជា «ក្រុមឃោសនាចល័ត» សម្រាប់អង្កាសលុយ

ឱយបក្សប្រជាធិបតេយ្យដែលពួកគ្រូបង្រៀនចាត់តាំងឡើង ។ បក្សប្រជាធិបតេយ្យបានអប់រំឲ្យស្អប់បារាំង និងស្អប់ស្តេច ។

នៅឆ្នាំ១៩៤៩-១៩៥០ ខ្ញុំមករៀននៅអនុវិទ្យាល័យ សីហនុ នៅក្រុងកំពង់ចាម ។ ពេលយប់ ខ្ញុំច្រើនមកលេងភ្នំពេញ សំណាក់នៅផ្ទះឪពុកធំខ្ញុំដែលជាបងម្តាយខ្ញុំ ។ ក្នុងការប្រាស្រ័យ ទាក់ទងពេលនោះខ្ញុំបានទទួលឥទ្ធិពលពីពួកប្រជាចលនារបស់អា ស៊ីង ង៉ុកថាញ់ ។

នៅឆ្នាំ១៩៥១-៥២ និង១៩៥៣ មានកូដកម្មជាបន្ត បន្ទាប់ប្រឆាំងរបបអាណានិគមនិយម និងរាជាធិបតេយ្យ ខ្ញុំបាន ចូលរួមយ៉ាងសកម្មដែរ ជាពិសេសក្នុងបាតុកម្មពីរលើកនៅក្រុង កំពង់ចាមក្នុងឆ្នាំ១៩៥២ ដែលប៉ូលិសនិងទាហានរាតត្បាត ។

នៅខែធ្នូ ឆ្នាំ១៩៥៣ សីហនុ ទៅកំពង់ចាមក្រោយពី បញ្ចប់យុទ្ធនាការឃោសនាបោកប្រាសថាទាមទារឯករាជ្យពី បារាំង ។ ក្នុងឱកាសនោះ «ក្រុមប្រជាចលនា» មានរៀបចំផែនការ សម្លាប់ សីហនុ ។ ពួកវាបានចាត់តាំងក្រុមភេរវកម្មប្រដាប់ដោយ អាវុធដែលជ្រើសរើសក្នុងចំណោមសិស្សវិទ្យាល័យកំពង់ចាម ។ ខ្ញុំមិនបានចូលជាសមាជិកក្រុមនេះទេ តែក្រុមនេះបានចាត់តាំង ខ្លួនខ្ញុំឲ្យបោះខិត្តប័ណ្ណប្រឆាំង សីហនុ ក្នុងយប់មុនថ្ងៃ សីហនុ មក ដល់កំពង់ចាម ។ ក្រុមភេរវកម្មនេះបានត្រូវប៉ូលិស សីហនុ ចាប់ ទាំងអស់ព្រោះក្នុងរយៈ២-៣ថ្ងៃមុនមេក្រុមនេះបានហៅគ្នាវា ស៊ីផឹកនិយាយឡូឡា ហើយយកកាំភ្លើងទៅបាញ់សត្វពេលសម្រាក ថ្ងៃត្រង់ក្នុងសាលា នាំឲ្យបែកការណ៍ដល់ភ្នាក់ងារគិញដែលជា សិស្សដូចគ្នា ។ ក្រោយពីថ្ងៃ សីហនុ មកមួយថ្ងៃក្រុមនេះ ទាំងអស់ត្រូវប៉ូលិសចាប់ទាំងអស់ ។

ខ្ញុំក៏មានឈ្មោះក្នុងបញ្ជីអ្នកត្រូវចាប់ដែរ តែនៅពេលដែល ប៉ូលិសចូលក្នុងកន្លែងសម្រាកនៅវិទ្យាល័យកំពង់ចាមដើម្បីឆែក ឆេររកអាវុធនិងរកលុយ ខ្ញុំក៏បានគេចខ្លួនផុត ហើយព្រឹកឡើង ជិះកប៉ាល់ដឹកឥវ៉ាន់មកពួននៅភ្នំពេញ ។

ខ្ញុំរស់នៅជាសម្ងាត់ប្រាំមួយខែនៅផ្ទៃព្រែកកក់ ។ ក្នុងរយៈ ពេលនោះឪពុកមាជីដូនមួយខ្ញុំម្នាក់ដែលធ្លាប់បួសជាមួយ ស៊ីង ង៉ុកមិញ បានបបួលខ្ញុំទៅចូលក្រុមអា ច័ន្ទ រង្សី នៅត្រពាំងគិន កំពង់ស្ពឺ ជាមួយអាចន្ទោ គ្រែស ។ ពេលនោះជិតដល់សន្និសីទ ហ្សឺណែវហើយ ។ ក្នុងរយៈរស់នៅជាមួយក្រុមពួកអាចោរនេះ ខ្ញុំគ្មានការកិច្ចអ្វីទេ ។ គឺរស់នៅក្នុងសភាពរង់ចាំ ។ ខ្ញុំក៏បានស្គាល់ អាសក្តិ៣ជប៉ុនដែលជាទីប្រឹក្សាអា ច័ន្ទ រង្សី ។ អាជប៉ុននេះពេល ក្រោយរដ្ឋប្រហាររបស់អា លន់ ណុល ជាមេចារកម្មរបស់ជប៉ុន និងសេ.អ៊ី.អា ។ នៅពេលនោះខ្ញុំគ្មានបានទទួលការអប់រំជាវគ្គ ឬ ជាសាលាទេ ។ ដល់សន្និសីទហ្សឺណែវ បានចុះហត្ថលេខាហើយ ខ្ញុំ ក៏ចូលមកភ្នំពេញជាមួយក្រុមអាក្បត់នេះ ។ ពេលនោះខ្ញុំធ្វើការ នៅការិយាល័យទាក់ទងរវាងក្រុមអាក្បត់នេះ និងពួករដ្ឋការ យោធារបស់ សីហនុ ។ ខ្ញុំរស់នៅកន្លែងប្រហែល៣ខែ ក៏ចេញ មករៀនសាលាកម្ពុជបុត្រ ។ ចូលមកភ្នំពេញភ្លាមខ្ញុំបានត្រូវពួក អា «ប្រជាចលនា» របស់អា ស៊ីង ង៉ុកថាញ់ ទាក់ទងឲ្យសរសេរ កាសែតរបស់វា «ខ្មែរថ្មី» ។ តែពេលនោះខ្ញុំមិនព្រមព្រោះកាសែត នេះចុះផ្សាយអត្ថបទជាបន្តបន្ទាប់និយាយពី «វិវាទស្តាលីន-ទីតូ» ហើយកាន់ជើងទីតូប្រឆាំងនឹងស្តាលីន ដោយខ្ញុំស្រឡាញ់និងគោរព ស្តាលីន ខ្ញុំមិនសុខចិត្តសរសេរក្នុងកាសែត «ខ្មែរថ្មី» នេះ ។ ទំនាស់រវាងក្រុមប្រឆាំងចលនានេះនិងខ្ញុំកាន់តែឡើងកម្រិតនៅ ពេលពួកវាវាយប្រហារយកឆ្វេងក្នុងបក្សប្រជាធិបតេយ្យនិង វាយប្រហារពួក «ក្រុមប្រជាជន» ។

ខ្ញុំកាត់ផ្តាច់ចេញពីក្រុមនេះនៅចុងឆ្នាំ១៩៥៥ ក្រោយ ពីដំណើរទស្សនកិច្ចរួមមួយនៅខេត្តសៀមរាបនិងឧត្តរមានជ័យ ដោយក្នុងពេលនោះខ្ញុំចាប់អារម្មណ៍អំពីឧបាយកលរបស់ពួកនេះ វាយប្រហារនិងប្រឆាំងកុម្មុយនិស្ត និងវាយប្រហារកម្លាំងជាតិ គ្មានឯង មិនឃើញគ្រោះអាសន្ននៃចក្រពត្តិអាមេរិក ។

ក្រោយពីឈប់នៅក្នុងការិយាល័យទាក់ទងរបស់ពួកអា ច័ន្ទ រង្សី មក ខ្ញុំមករស់នៅជាមួយម្តាយធំសាច់ថ្លៃខ្ញុំនៅមុខពេទ្យចិន បានមួយរយៈ ។ ដោយត្រូវគាត់ប្រើខ្ញុំខ្លាំងពេក ពិសេសឲ្យលក់ ទឹករកពេលវេលារៀនសូត្រមិនបាន ខ្ញុំក៏មកនៅជាមួយមិត្តម្នាក់ នៅរៀនថ្នាក់ទី២ទំនើបដូចគ្នាឈ្មោះ សារិល (ស្លាប់នៅឆ្នាំ១៩៦០) នៅទីស្នាក់ការសមាគមសិស្សចាស់នៃវិទ្យាល័យស៊ីសុវត្ថិ ។ ពេល នោះខ្ញុំរស់នៅជាមួយឈ្មោះ អ៊ុល ចាន់ អាក្បត់ រស់ សារិន ហើយខ្ញុំក៏បានទាក់ទងជាមួយមិត្ត ខុល ដែលរៀននៅខាងកាត់ដេរ ទើបនឹងមកពីប្រទេសបារាំង ។ ពេលនោះខ្ញុំបានចូលបង្រៀននៅ

សាលាចំរើនវិជ្ជា (ឆ្នាំ១៩៥៦) ។ នៅសាលាចំរើនវិជ្ជានេះខ្ញុំបានស្គាល់ឈ្មោះ មី អំ និងអា ម៉ែន សាន (វាធ្វើជាអគ្គអនុរក្សសាលា) និងបង សាឡុតស ដែលធ្វើសាស្ត្រាចារ្យនៅសាលានោះ ។

មួយរយៈពេលដែលខ្ញុំស្នាក់នៅទីស្នាក់ការសមាគមសិស្សចាស់វិទ្យាល័យស៊ីសុវត្ថិ ឈ្មោះ ហ៊ូ យន់ ក៏មកនៅកន្លែងនោះមួយរយៈកាលដែរ ។

ក្នុងរយៈកាលនេះខ្ញុំបានទិញសៀវភៅលោកប្រធានម៉ៅ សេទុង មើលច្រើន ហើយកាន់តែស្រឡាញ់របបសង្គមនិយម និងឧត្តមគតិកុម្មុយនិស្តនិយម ។ កាលក្នុងឆ្នាំ១៩៥០ ដល់១៩៥៥ ខ្ញុំចងកំហឹងនឹងរាជាធិបតេយ្យ ហើយឈឺចាប់ចំពោះទុក្ខវេទនានិងភាពក្រីក្រវេទនារហាមរបស់បងប្អូនកសិករពិសេសរបស់ម្តាយខ្ញុំផ្ទាល់ ។

ដល់ឆ្នាំ១៩៥៦ ខ្ញុំយល់បញ្ហាមួយកម្រិតទៀត ហើយបានប្តេជ្ញាចិត្តចូលរួមសកម្មភាពជាមួយជនបដិវត្តន៍សង្គមនិយមដែលមាននិស្សិតចំរើននិងបញ្ញាជនចំរើនទើបមកពីប្រទេសបារាំងជាតំណាង ។ កាលនៅរៀនសាលាកម្ពុជបុត្រ ខ្ញុំបានទទួលឥទ្ធិពលខាងសម្ភារនិយមបដិចូសមុប្បាទ និងសម្ភារនិយមប្រវត្តិសាស្ត្រដោយការបង្រៀននិងឃោសនារបស់ឈ្មោះ ម៉ី ម៉ាន់។ សាស្ត្រាចារ្យចំរើននៅកម្ពុជបុត្រក៏បានឃោសនាឲ្យឃើញគ្រោះថ្នាក់របស់ចក្រពត្តិអាមេរិកដែលមកផ្លាស់អាណានិគមបារាំងនៅប្រទេសយើង ។ ពេលនោះចលនាមហាជនប្រឆាំងនឹងកិច្ចព្រមព្រៀងយោធាខ្មែរ-អាមេរិក ថ្ងៃ១៦ ខែឧសភា ឆ្នាំ១៩៥៥ ផុសផុលសន្ធោសន្ធៅណាស់ ក៏ដូចជាចលនាមហាជនទាមទារឲ្យកម្ពុជាប្រកាន់យកនូវនយោបាយអព្យាក្រឹតក្រោយពីសន្និសីទបានឌុង ។

នៅចំពោះមុខចលនាមហាជនដ៏ខ្លាំងក្លាដូច្នេះ ពួកអាប្រជាចលនាមិនហ៊ានចេញមុខធ្វើការឃោសនាចំហរនៅពេលបោះឆ្នោតខែកញ្ញា ឆ្នាំ១៩៥៥ ។ នៅពេលដែលខ្ញុំកំពុងទទួលការឃោសនារបស់ពួកចំរើន ខ្ញុំក៏ទៅទាក់ទងនឹងពួកប្រជាចលនាខ្លះៗ ។ ខ្ញុំបានទៅចូលរួមក្នុងការប្រជុំរបស់ក្រុមនេះថា តើត្រូវបង្កើតជាគណបក្សមួយដំហរប្ដុបន្តនៅធ្វើការក្នុងគណបក្សប្រជាធិបតេយ្យ ។ កន្លែងប្រជុំគឺផ្ទះអាក្បត់ សាំង សាវ៉ាត ចាងហ្វាងកាសែត «ខ្មែរថ្មី» ។ តែពេលនោះពួកវាប្រជុំតែអ្នកទទួលខុសត្រូវប៉ុណ្ណោះ ។ ដល់ប្រជុំហើយបានពួកវាម្នាក់មកប្រាប់លទ្ធផលថាមិនចេញជាគណបក្សប្រជាធិបតេយ្យតទៅទៀត ។

នៅពេលបើកយុទ្ធនាការឃោសនាបោះឆ្នោតខ្ញុំបានធ្វើជាឃោសនិករបស់គណបក្សប្រជាធិបតេយ្យផង និងរបស់ក្រុមប្រជាជន ព្រោះបេក្ខជនរបស់គណបក្សប្រជាធិបតេយ្យនៅតំបន់ឆ្លូង ក្រចេះ ដែលជាតំបន់កំណើត ខ្ញុំជាសមាជិកក្រុមប្រជាជនហើយជាមិត្តភក្តិរបស់ ណុប បូផាន់ ។

ក្រោយពីបោះឆ្នោតចាញ់ ពួកគណបក្សប្រជាធិបតេយ្យបាក់ស្មារតី ខ្លះសារភាពសង្គមរាស្ត្រនិយម ខ្លះ (គឺពួកចំរើន) ក៏បន្តតស៊ូ ។ ពេលនោះខ្ញុំកាន់តែមានសមានចិត្តជាមួយពួកចំរើនជាបញ្ញាជនឆ្វេងដែលទើបមកពីបរទេសបារាំង ។ សមានចិត្តនេះជាមូលហេតុមួយដែលនាំឲ្យខ្ញុំផ្តាច់ខ្លួនពីពួកអា សឺង ង៉ុកថាញ់ ។ ក្រោយចាញ់ឆ្នោត ពួកនេះដឹកនាំដោយមី សឹម វ៉ាន់ស៊ីន បាននាំគ្នាធ្វើទស្សនកិច្ចនៅតំបន់សៀមរាបអង្គរ និងរវៀង សំរោងចុងកាល់ ។ ក្នុងពេលធ្វើដំណើរពួកវាបានជេរត្មះដៀលកុម្មុយនិស្ត ស្តាលីន និងពួកបញ្ញាជនចំរើន ។ ដោយខ្ញុំការពារពួកនេះ ពួកវាក៏ប្រទេចផ្តាសាខ្ញុំ ហើយបដិសេធខ្ញុំឲ្យឯកោជាមួយអា គង់ អ៊ិន ដែលពេលនោះវាប្រកាន់យកអាកប្បកិរិយាកណ្តាលហើយបាននិយាយថា «គ្រូខ្ញុំ អ៊ុច វ៉េន បានអប់រំខ្ញុំឲ្យស្រឡាញ់កុម្មុយនិស្ត» ។ ដល់ត្រឡប់មកវិញខ្ញុំឈប់ទាក់ទងជាមួយពួកក្រុមអាប្រជាចលនានេះ ព្រោះឃើញពួកវាកាន់តែប្រតិកិរិយាប្រឆាំងកុម្មុយនិស្តខ្លាំងឡើង ហើយធ្វើសកម្មភាពបំបែកបំបាក់ជួរអ្នកស្នេហាជាតិជួរអ្នកចំរើន ។




(នៅមានត)

# ការរៀបចំឯកសារទាក់ទងនឹងអំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា

***(តពីលេខមុន) ការប្រើប្រាស់ទិន្នន័យនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍***

*រាល់ឯកសារដែលប្រមែប្រមូលដោយកម្មវិធីស្រាវជ្រាវអំពីការប្រល័យពូជសាសន៍នៅកម្ពុជានិងមជ្ឈមណ្ឌលឯកសារកម្ពុជា កំពុងត្រូវបានដាក់ផ្សព្វផ្សាយឲ្យមានជាសាធារណៈ មិនថាឡើយក្នុងទម្រង់ដើមដែលមានតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជានៅភ្នំពេញ ឬជាទម្រង់ពត៌មានអេឡិចត្រូនិកនៅក្នុងទិន្នន័យរបស់កម្មវិធីស្រាវជ្រាវអំពីការប្រល័យពូជសាសន៍នៅកម្ពុជាដែលផ្សាយជាសាធារណៈតាមប្រព័ន្ធអ៊ីនធ័រនែតឬតាមស៊ីឌីរ៉ូម ។ គ្រប់ទិន្នន័យរបស់យើងអាចស្រាវជ្រាវរកបានតាមប្រព័ន្ធអ៊ីនធ័រនែតតាមរយៈអាសយដ្ឋានកម្មវិធីស្រាវជ្រាវអំពីការប្រល័យពូជសាសន៍នៅកម្ពុជា នៅសាកលវិទ្យាល័យយែលសហរដ្ឋអាមេរិក* (http://www.yale.edu/cgp/) *និងអាសយដ្ឋាននៅសាកលវិទ្យាល័យញូសៅវែលនៅប្រទេសអូស្ត្រាលី* (htt://www-cgp.sistm.unsw.edu.au/ or http://Welcome to Dccam *ឬមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ជាបន្ថែម ផែនទីខេត្តនីមួយៗសម្រាប់ទិន្នន័យភូមិសាស្ត្រត្រូវបានផលិតនិងបោះពុម្ពក្រោមការជួយជ្រោមជ្រែងពីមជ្ឈមណ្ឌលឃ្លាំមើលផែនដីនៃសកលវិទ្យាល័យយែល និងវិទ្យាស្ថានសិក្សាអំពីជីវសាស្ត្រនៅលើផែនដីហើយត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធអ៊ីនធ័រនែតរបស់កម្មវិធីស្រាវជ្រាវអំពីការប្រល័យពូជសាសន៍នៅកម្ពុជាដែលមានលក្ខណៈជារូបភាព បន្ថែមពីលើទិន្នន័យភូមិសាស្ត្រ ។*

*យើងក៏បានផលិតទិន្នន័យដាក់ក្នុងស៊ីឌីរ៉ូម ជាពិសេសឯកសារទាំងឡាយណាដែលមិនទាន់បានបញ្ចូលទៅក្នុងប្រព័ន្ធអ៊ីនធ័រនែត ។ ទិន្នន័យស្តីអំពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅកម្ពុជាដែលបញ្ចូលទៅក្នុងស៊ីឌីរ៉ូម អាចរកបាននៅមជ្ឈមណ្ឌលឯកសារកម្ពុជា និងសាកលវិទ្យាល័យញ៉ូសៅវែល ទីក្រុងស៊ីដនី ។ ស៊ីឌីរ៉ូមមួយតម្លៃ១០០ដុល្លារអាមេរិក ប៉ុន្តែត្រូវបានផ្តល់ដល់ក្រសួងមន្ទីររដ្ឋាភិបាលកម្ពុជា អង្គការមិនមែនរដ្ឋាភិបាលក៏ដូចជាអ្នកជំនួយការងារនៅកម្មវិធីស្រាវជ្រាវអំពីការប្រល័យពូជសាសន៍នៅកម្ពុជាដោយឥតគិតថ្លៃ ។*

*ក្រៅពីការផ្តល់លទ្ធភាពប្រើប្រាស់ទិន្នន័យក្នុងកុំព្យូទ័រកម្មវិធីស្រាវជ្រាវអំពីការប្រល័យពូជសាសន៍នៅកម្ពុជា និងមជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំកម្មវិធីបោះពុម្ពផ្សាយលទ្ធផលនៃការស្រាវជ្រាវរបស់ខ្លួនជាទម្រង់សៀវភៅពុម្ព ឬការផ្សាយតាមអ៊ីនធ័រនែត ។ មជ្ឈមណ្ឌលឯកសារកម្ពុជាទើបតែបានបោះពុម្ពផ្សាយទស្សនាវដ្តីជាលើកដំបូងរបស់ខ្លួនជាភាសាខ្មែរមានឈ្មោះថា «ស្វែងរកការពិត» ដែលត្រូវបានចែកផ្សាយទូទាំងប្រទេសកម្ពុជា ។ ច្បាប់ចេញផ្សាយជាភាសាអង់គ្លេសក៏កំពុងត្រូវបានរៀបចំដែរ ។*

*ទោះបីជាកម្មវិធីសិក្សាអំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជានិងមជ្ឈមណ្ឌលឯកសារកម្ពុជាមានសំណាងទទួលបាននូវជំនួយនិងការគាំទ្រជាច្រើនរួមទាំងជំនួយថវិកាសម្រាប់ប្រតិបត្តិការមួយភាគធំពីក្រសួងការបរទេសសហរដ្ឋអាមេរិក និងបណ្តាប្រទេសជាច្រើនទៀតនៅអឺរ៉ុប ក៏ដោយ ក៏យើងនៅតែខិតខំស្វែងរកថវិកាថែមទៀតដើម្បីបន្តនិងពង្រីកកម្មវិធីនេះឲ្យកាន់តែធំរឹងមាំថែមទៀត ។ ឯកសារដ៏សន្ធឹកសន្ធាប់កំពុងតែត្រូវបានរកឃើញជាបន្តបន្ទាប់នៅក្នុងប្រទេសកម្ពុជាហើយមួយចំនួនតូចត្រូវបានរកឃើញនៅក្នុងបណ្ណសារដ្ឋាន និងប្រព័ន្ធទិន្នន័យកុំព្យូទ័រនៅទូទាំងពិភពលោក ។ សព្វថ្ងៃនេះយើងមានបំណងផលិតរូបភាពនិងចុះបញ្ជី ឬធ្វើកាតាឡុកឯកសារដ៏ច្រើនសន្ធឹកសន្ធាប់នេះឲ្យបានច្រើនចង់ធ្វើការវិភាគលើឯកសារឲ្យលម្អិតថែមទៀត ។ ចង់ធ្វើឲ្យឯកសារទាំងនោះងាយក្នុងការប្រើប្រាស់ជាសាធារណៈនៅពេលអនាគតនិងចង់ធានាឲ្យប្រាកដថា ឯកសារពិតជាត្រូវបានថែរក្សាទុកឲ្យបានគង់វង្សយូរអង្វែងទៅមុខ ។ យើងក៏មានបំណងចង់បន្តការបណ្តុះបណ្តាលកម្មវិធីនេះតទៅមុខទៀតដោយអភិវឌ្ឍន៍បុគ្គលិកជំនាញខាងពត៌មានវិទ្យានិងអ្នករៀបចំឯកសារជាជនជាតិកម្ពុជាដោយអភិវឌ្ឍន៍ធនធានមនុស្សនិងជំនាញចាំបាច់ដើម្បីឲ្យអ្នកទាំងនោះអាចចាត់ចែងរាល់ឯកសារជាប្រវត្តិសាស្ត្ររបស់ជាតិកម្ពុជាដែលពុំទាន់មានរចនាសម្ព័ន្ធអប់រំមាំមួននៅឡើយ ។* **ចប់**

**ហេងឡុន ហ្វាទីស**

# សោកនាដកម្មនៅភូមិកោះផល



ការ «កម្ទេច» ភូមិជនជាតិចាមមួយឈ្មោះភូមិកោះផល ដោយសារជនជាតិចាមនៅក្នុងភូមិនេះមានវប្បធម៌និងការកាន់សាសនាផ្សេងដោយឡែករបស់ខ្លួន ត្រូវបានរៀបចំផែនការដោយបក្សកុម្មុយនិស្តកម្ពុជាបញ្ជាដោយ ប៉ុល ពត និងមានការដឹងឮពី នួន ជា ហើយអនុវត្តដោយសមមិត្ត ឈុន ។ អង្គហេតុនេះគឺផ្អែកជាមូលដ្ឋានទៅលើកសិណផ្ទាល់មាត់ពីជនរងគ្រោះដែលរួចជីវិតរស់នៅកោះផល ក៏ដូចជាឯកសារគោលនយោបាយមជ្ឈិមរបស់ពួកខ្មែរក្រហម និងរបាយការណ៍អំពីការអនុវត្តគោលនយោបាយទាំងនោះ ។ ជនជាតិចាមប្រមាណ១៦០០នាក់ក្នុងចំណោមប្រជាជនចាម១៨០០នាក់ បានបាត់ខ្លួនបន្ទាប់ពីការជម្លៀសប្រជាជនចេញពីកោះផលកាលពីខែកញ្ញា ឆ្នាំ១៩៧៥ គឺនៅពេលដែលទាហានខ្មែរក្រហមបានបង្ក្រាបអ្នកភូមិភ្លាមៗនៅក្នុងការបះបោរប្រឆាំងនឹងការហាមប្រាមការអនុវត្តនិងការគោរពតាមប្រពៃណីនិងសាសនារបស់ចាម ។ អ្នកភូមិទាំងមូលត្រូវបានកម្ចាត់ជាផ្លូវការឲ្យទៅរស់នៅតាមបណ្តាភូមិខ្មែរនៅខេត្តកំពង់ចាម កំពង់ធំ និងខេត្តស្ទឹងត្រែង ។ ប្រធានភូមិនៅពេលនោះឈ្មោះ វែស ទត បាននិយាយថា គាត់ត្រូវបានស្នើឲ្យប្រមែប្រមូលអ្នកភូមិមកប្រជុំនៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ១៩៧៥ ជាមួយនឹងកម្មាភិបាលខ្មែរក្រហមដែលបានប្រកាសគោលការណ៍ទាំងនេះ ដកមេដឹកនាំសាសនានិងមេដឹកនាំសហគមន៍ជាន់ខ្ពស់៤០នាក់ ហាមធ្វើសម្បាយំ (ថ្វាយបង្គំ) និងរ៉ាម៉ាដន (ខែបួស) បំបាត់ចោលនូវគម្ពីរគួរអាន ឲ្យស៊ីសាច់ជ្រូក ឲ្យស្ត្រីកាត់សក់ខ្លី និងឲ្យរៀបការរវាងចាមនិងខ្មែរ ។

ចំពោះកោះផលនិងភូមិចាមដទៃទៀតនៅតាមដងទន្លេមេគង្គ ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម ដែលទើបត្រូវបានជម្លៀសចេញ សមមិត្ត ឈុន បានរាយការណ៍ទៅឲ្យបងប៉ុល (ប៉ុល ពត) និងចម្លងជូនទៅបងនួន (នួន ជា) នៅក្នុងទូរលេខ លេខ១៥ ចុះថ្ងៃទី៣០ ខែ១១ ឆ្នាំ១៩៧៥ ដោយនិយាយថា «ដកនេះគឺជាគោលការណ៍បំបែកមតិដែលបងបានពិភាក្សាជាមួយយើងខ្ញុំរួចស្រេចហើយ» ដើម្បី «ឲ្យបរិយាកាសធូរស្រាលខ្លះ» ។ នៅក្នុងទសវត្សរ៍ឆ្នាំ៨០ មេបញ្ជាការកងទ័ពខ្មែរក្រហមម្នាក់ឈ្មោះ សុខ បានផ្តល់ឯកសារសរសេរដៃដែលមានចំនួន១០ទំព័រ ទៅឲ្យ

លោក ឆាំង យុ ដែលបច្ចុប្បន្នជានាយកមជ្ឈមណ្ឌលឯកសារកម្ពុជាទទួលខុសត្រូវក្នុងការប្រមូលឯកសារខ្មែរក្រហមទាំងឡាយ សម្រាប់បម្រើការស្វែងរកយុត្តិធម៌មួយដល់មនុស្សជាង២លាននាក់ដែលបានស្លាប់ក្នុងរបបនេះ ។ ឯកសាររបស់មេបញ្ជាការរូបនេះបានបង្ហាញពីគម្រោងខ្មែរក្រហមចាប់ផ្តើមពី ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ សម្រាប់ធ្វើកាជម្លៀសប្រជាជនទូទាំងប្រទេស និងហេតុផល៩យ៉ាងក្នុងការជម្លៀសដែលបានពន្យល់ដោយបក្សកុម្មុយនិស្តកម្ពុជា ។ ហេតុផលដំបូងពន្យល់ថា «អង្គការដាក់ចុះតាមទ្រឹស្តីប្រធានបក្សកុម្មុយនិស្តចិនម៉ៅកាំង ហើយត្រូវបោសសម្អាតខ្មាំងផ្ទៃក្នុងមុនពេលធ្វើសេចក្តីសម្រេចផ្សេងទៀត» ។ ហេតុផលផ្សេងទៀតរួមមានបក្សកុម្មុយនិស្តកម្ពុជាអាចធ្វើចំណាត់ប្រភេទប្រជាជនណាដែលត្រូវចាត់ជាប្រជាជនរបស់បក្សនិងប្រជាជនណាដែលត្រូវ «កម្ទេច» ដោយផ្អែកលើពាក្យស្លោកថា «ទុកក៏មិនចំណេញ ដកចេញក៏មិនខាត» ហើយដើម្បីឲ្យបក្សកុម្មុយនិស្តកម្ពុជាសម្លាប់ប្រភេទមនុស្សដែល «មិនគួរទុក» ដូចជាឲ្យអតីត «ទាហាន ឬក៏ជនស៊ីវិល» ឲ្យក្នុងរបបមុន ។

រដ្ឋធម្មនុញ្ញរបបកម្ពុជាប្រជាធិបតេយ្យ ឯកសារគោលនយោបាយមជ្ឈិម សៀវភៅកំណត់ហេតុនៃវគ្គសិក្សានយោបាយនិយាយថា ប្រជាជនមានសិទ្ធិប្រកាន់ជំនឿនិងសាសនាណាមួយក៏បាន ប៉ុន្តែ «ដាច់ខាត» មិនមែន «សាសនាប្រតិកិរិយាដែលបំផ្លាញរបបកម្ពុជាប្រជាធិបតេយ្យនិងកម្ពុជា» ។ បក្សកម្មុយនិស្តកម្ពុជានិងសម្ព័ន្ធយុវជនបក្សកុម្មុយនិស្តកម្ពុជា ដូចដែលបានចែងនៅក្នុងលក្ខន្តិកតម្រូវឲ្យសមាជិកមាន«សីលធម៌នយោបាយនិងសង្គមស្អាតស្អំ ហើយគ្មានជាប់ពាក់ព័ន្ធជាមួយនឹងខ្មាំង» ។ ដូច្នេះដើម្បីក្លាយជា «មនុស្សរបស់បក្ស» ឬក៏គ្រាន់តែដើម្បីក្លាយជាមនុស្សក្រោមរបបខ្មែរក្រហម មនុស្សម្នាក់ៗត្រូវតែមានគុណសម្បត្តិបែបនេះ បើមិនដូច្នោះអ្នកនោះនឹងធ្លាក់ចូលទៅក្នុងប្រភេទមនុស្ស «មិនគួរទុកឲ្យរស់នៅ» ជាស្វ័យប្រវត្តិ ហើយក៏ជាប្រភេទមនុស្ស «ទុកក៏មិនចំណេញ ដកចេញក៏មិនខាត» ។

ដោយសារតែប្រជាជននៅកោះផលបះបោរប្រឆាំងមិនព្រមបោះបង់ចោលនូវការប្រារព្ធនូវវប្បធម៌សាសនារបស់ខ្លួនតាមនៅក្នុងភូមិនេះទាំងមូលត្រូវបានចាត់ទុកថា «ប្រតិកិរិយា» តាមរដ្ឋធម្មនុញ្ញរបបកម្ពុជាប្រជាធិបតេយ្យមាន «សីលធម៌សង្គម» មិនស្អាតស្អំតាមលក្ខន្តិកៈបក្សកុម្មុយនិស្តកម្ពុជា និងក្លាយជាជនជាតិដែលពុំត្រូវការ «ដែលត្រូវកម្ទេចចោល» ។ ជនរងគ្រោះនិងប្រវត្តិវិទូស៊ុទ្ធតែបានស្គាល់និងដឹងឮថា «កោះផលក្លាយជាកោះផេះ» ដើម្បីពិពណ៌នាឲ្យបានខ្លីពីអ្វីដែលរបបខ្មែរក្រហមបានបំផ្លាញគឺមានន័យថា កោះដែលធ្លាប់តែសម្បូរដោយភោគផលកសិកម្មហូរហៀរក្លាយទៅជាកោះពោរពេញដោយកម្ទេចផេះ ។ ខ្ញុំបានចុះផ្សាយដោយសង្ខេបនៅក្នុងកាសែតរស្មីកម្ពុជាកាលពីខែវិច្ឆិកា ឆ្នាំ១៩៩៨ ពីប្រភពផ្តល់ពត៌មានដែលបានរស់នៅក្បែរកោះផលដែលធ្លាប់បានឮពីព្រឹត្តិការណ៍នៅទីនោះ ។ ខាងក្រោមនេះអ្នកអាននឹងបានស្តាប់ដោយផ្ទាល់ពីជនរងគ្រោះដែលបានឃើញព្រឹត្តិការណ៍នោះពិតជាក់ស្តែង ។

## លោក វែស ទត អាយុ៦៧ឆ្នាំ នៅភូមិកោះផល (សម្ភាសក្នុងឆ្នាំ១៩៩៩)

ខ្ញុំបានរស់នៅភូមិកោះផលរហូតដល់មានការជម្លៀសឆ្នាំ១៩៧៥ ។ នៅពេលនោះខ្ញុំមានកូន៧នាក់ ខ្ញុំជាអនុហាកឹម (ភូឈួយ) ចន្លោះឆ្នាំ១៩៧៣ និងឆ្នាំ១៩៧៥ ខ្ញុំជាប្រធានភូមិ ហើយត្រូវបានតែងតាំងដោយប្រធានស្រុកក្រូចឆ្មារឈ្មោះ «តាផា» ។ ខ្ញុំជាប់គុកអស់រយៈពេល៦ខែ និង១០ថ្ងៃ នៅគុកស្រុកក្រូចឆ្មា ចន្លោះដើមឆ្នាំ១៩៧៤ ដល់ដើមឆ្នាំ១៩៧៥ ។ ប្រធានគុកឈ្មោះតាប៊ុង ។ ខ្ញុំត្រូវបានពួកសន្តិសុខខ្មែរក្រហមចាក់មួយកាំបិត នេះគឺជាស្លាកស្នាម (លោក វែស ទត បង្អុលបង្ហាញស្លាកស្នាមរបួសនៅលើពោះរបស់គាត់) ។ ខ្ញុំត្រូវសន្តិសុខខ្មែរក្រហមវាយដោយគល់ឫស្សីអស់រយៈពេលបីថ្ងៃបីយប់ ហើយខ្ញុំបាត់បង់សមត្ថភាពក្នុងការនិយាយ និងមិនអាចស្តាប់ឮអស់រយៈពេលបីខែ ។ ខ្ញុំតែងឆ្លើយថាទេជានិច្ចនៅពេលពួកខ្មែរក្រហមសួរខ្ញុំថាគាំទ្ររបបលន់ ណុល ដែរឬទេ? ។ មុនពេលជម្លៀសខែកញ្ញា ឆ្នាំ១៩៧៥ ខ្ញុំក៏ត្រូវបានដោះលែង ។ ខ្ញុំត្រូវបានគេស្នើឲ្យប្រមែប្រមូលមនុស្សទៅប្រជុំនៅឯស៊ូរ៉ាវ (កន្លែងសម្រាប់ថ្វាយបង្គំតូចជាងព្រះវិហារ) នៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ១៩៧៥ ។ កម្មាភិបាលខ្មែរក្រហម៤នាក់ឈ្មោះ «តាផា» ជាគណៈស្រុកក្រូចឆ្មារ តាប៊ុង ប្រធានស្រុក គុក និងអនុប្រធានតាផា ឈ្មោះតាយូប

នៅក្នុងភូមិដំនឹក និងតាយូប មួយទៀតនៅភូមិទ្រា ហើយមានទាហានកាន់កាំភ្លើង ប្រហែល២០នាក់ទៀតនៅក្នុងពេលប្រជុំ ។ ខ្ញុំនិងអ្នកភូមិដទៃទៀតបានចូលរួមក្នុងអង្គប្រជុំនោះ ។ ពួកទាហានខ្មែរក្រហមឈរនៅគ្រប់បង្អួចទាំងអស់នៃអគារស៊ូរ៉ាវ ។ តាផា បានប្រកាសនៅក្នុងអង្គប្រជុំនូវគោលការណ៍ពីរថា ជនជាតិចាមត្រូវតែអនុវត្តតាមគោលការណ៍ទី១គឺថា ចាមថ្នាក់លើ៤០នាក់នឹងត្រូវដកចេញ ។ គោលការណ៍ទី២រួមមានប្រាំចំណុចៈ ចំណុចទី១ ស្ត្រីត្រូវកាត់សក់ខ្លី ត្រូវអនុវត្តការរៀបការរវាងចាមនិងខ្មែរ ចំណុចទី២ គម្ពីរគួរអានទាំងអស់ត្រូវប្រមែប្រមូលឲ្យកម្មាភិបាលខ្មែរក្រហមដើម្បី «កម្ទេច» ចោល ចំណុចទី៣ ចាមត្រូវចិញ្ចឹមនិងបរិភោគសាច់ជ្រូក ។ នៅពេលដែល តាផា កំពុងនិយាយចំណុចនេះកូន ក្នុងអាយុប្រហែល៦ឆ្នាំម្នាក់បានទះមាត់ តាផា ។ តាផា និយាយថា ក្មេងនេះកាចមែនទែន ហើយថាក្មេងនេះធំឡើងអាចក្លាយជាទាហានហំហ្វង (ដ៏ល្អ) ។) ចំណុចទី៤ ចាមត្រូវតែឈប់ថ្វាយ ង្គព្រះ ។ ចំណុចទី៥ ចាមត្រូវឈប់បួសនៅក្នុងខែរ៉ាម៉ាដនជាខែបួស ។

តាផា ហ្នឹងហើយគឺជាអ្នកបញ្ជាអ្នកភូមិ និងខ្ញុំឲ្យអនុវត្តគោលការណ៍ទាំងនោះ ខ្ញុំពុំព្រមតាម តាផា ហើយខ្ញុំគ្រាន់តែព្រមតាមតែមាត់នៅពេលដែល តាផា នៅក្បែរពីព្រោះខ្ញុំខ្លាច តាផា ។ សាសនារបស់ចាមគឺផ្អែកលើគម្ពីរគួរអាន ហើយបើគម្ពីរគួរអានត្រូវបានដុតចោលអស់លែងមានសាសនាអ្វីដែលត្រូវគោរពទៀត ហើយខ្ញុំជាប្រធានភូមិដូច្នេះខ្ញុំដឹងរឿងនេះទាំងអស់ ។

ខ្ញុំនៅក្នុងភូមិនៅពេលដែលការបះបោរកើតឡើងកាលណោះ ថ្ងៃ១៣ ខែកញ្ញា ឆ្នាំ១៩៧៥ គឺជាថ្ងៃដែលទាហានខ្មែរក្រហមចូលមកចាប់អ្នកភូមិ ។ ចាមម្នាក់ឈ្មោះ ម៉ាត់ សាឡែស ត្រូវបានបាញ់ស្លាប់ ។ បុរសចាមម្នាក់ទៀតឈ្មោះ ខស្មាន ត្រូវបានចាប់ក្នុងពេលឃ្វាលគោនៅឯវាលស្រែក្រៅភូមិមួយយប់ក្រោយមកទើប ខស្មាន ត្រឡប់មកភូមិវិញ ។ ពួកខ្មែរក្រហមប្រាប់ឲ្យ ខស្មាន មកប្រាប់អ្នកភូមិវិញថា «កោះផលនឹងត្រូវបានកម្ទេចចោលចាប់ពីពេលនេះតទៅ» ។ «កម្ទេច» មានន័យថាធ្វើឲ្យខ្ទេចខ្ទីទាំងស្រុងរហូតដល់អ្វីៗ «ក្លាយជាផេះ» ពេលនោះការបះបោរក៏ចាប់ផ្តើមឡើងអ្នកដែលបះបោរច្រើនតែជាប្រុសៗវ័យក្មេង ហើយគ្មាននរណាម្នាក់ប្រាប់ឲ្យបះបោរដូច្នោះទេ ។ ប្រុសចាមទាំងអស់នោះបានស្រែកថា «សាសនារបស់យើងបាត់អស់ហើយ!» អស់រយៈពេលបីថ្ងៃជាប់ៗគ្នា ចាមវ័យចំណាស់ៗមានការភ័យខ្លាច ហើយចេះតែយំ ។ បុរសៗចាមវ័យក្មេងៗនិយាយថា «តស៊ូសាបឺឡាស់» មានន័យថា យើងត្រូវតែតស៊ូសង្គ្រាមដើម្បីសាសនា ។ ចលនាបះបោរនេះបានបន្តរហូតដល់ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧៥ ។ នៅខែកញ្ញា ឆ្នាំ១៩៧៥ គឺជាខែត្រណមរ៉ាម៉ាដនសម្រាប់អ្នកកាន់សាសនាមូស្លីម ។ បន្ទាប់ពីកិច្ចប្រជុំថ្ងៃ១២ ខែកញ្ញា តាផា និងកម្មាភិបាលខ្មែរក្រហមដទៃទៀតឈប់មកទាក់ទងជាមួយខ្ញុំ ឬក៏ភូមិកោះផលទៀតហើយ ។ កម្មាភិបាលខ្មែរក្រហមទាំងនោះឈប់មកទាក់ទងយើង គឺចង់កម្ទេចយើង ។ នៅថ្ងៃ២២ ខែកញ្ញា ឆ្នាំ១៩៧៥ ទាហានខ្មែរក្រហមបានដាក់ពង្រាយពីទិសទាំងបួន ខទាហរណ៍មកពីទិសខាងកើតដាក់ពង្រាយកាំភ្លើងធំប្រហែល៧០០ម៉ែត្រពីភូមិ ។ មិនតែប៉ុណ្ណោះកាំភ្លើងធំក៏បានដាក់នៅលើកប៉ាល់ពីទិសខាងទន្លេ ។ ខ្ញុំបានឃើញការដាក់ពង្រាយនេះ ពីរថ្ងៃក្រោយមកការផ្លោងផ្តក់ក៏បានចាប់ផ្តើមឥតមានឈប់មួយនាទីណាឡើយ ។សំឡេងព្រួយ៉ាំងខ្លាំងហ៊ុំងត្រចៀករហូតយើងមិនអាចនិយាយយល់គ្នាទៅវិញទៅមក ។ គ្រាប់ផ្លោងទាំងនោះពុំត្រូវធ្លាក់ចំភូមិទេ ហើយវាផ្ទុះលើមេឃ ឬក៏ធ្លាក់ឆ្ងាយពីភូមិ (លោក វែស ទត ចង់មានន័យថា អ្នកភូមិនេះចេះសីលធំ «សីលបញ្ចៀសគ្រាប់») ។ ខ្ញុំមិនដឹងជាទាហាននិងកាំភ្លើងទាំងនោះចេញមកពីណាទេ ខ្ញុំមិនអាចមើលឃើញថាអ្នកទាំងនោះចេញមកពីទីណាទេ ។ អ្នកភូមិមានកាន់កាំបិតបានមកជួបជុំគ្នានៅជុំវិញជាយភូមិ ។ យើងអាចនាំយកសាកសពចាម៤៦នាក់មកកប់ ។ ខ្ញុំមិនដឹងថាប៉ុន្មាននាក់ទៀតដែលស្លាប់ហើយពុំអាចយកចូលភូមិនោះទេ ការប្រយុទ្ធគ្នាបានបន្តអស់រយៈពេលបីថ្ងៃ ។ ប៉ុន្មានយប់បន្ទាប់នោះ ខ្ញុំក៏ភៀសខ្លួនទៅវៀតណាម ហើយការជម្លៀសក៏ចាប់ផ្តើម ។ ការជម្លៀសគឺទៅកាន់គ្រប់ទីកន្លែង ។ មានប្រជាជន ១៨៦៤នាក់រស់នៅក្នុងភូមិរបស់ខ្ញុំមុនការបះបោរក្នុងឆ្នាំ១៩៧៥ ហើយឆ្នាំ១៩៧៩នៅសល់ប្រមាណ១៨៣នាក់ប៉ុណ្ណោះ ។ នៅបច្ចុប្បន្នមានចាមប្រហែលជា៣០០នាក់ប៉ុណ្ណោះមិនជាកើនប៉ុន្មានទេ ពីព្រោះភូមិនេះក្រណាស់ ។ **(នៅមានត)** **សឹម សុរិយ៉ា**

**(តពីលេខមុន)** កិច្ចការសន្តិបាលត្រូវបានផ្ទេរនិងផ្លាស់មកកាន់រដ្ឋធានីភ្នំពេញបន្ទាប់ពីខ្មែរក្រហមទទួលបានជ័យជម្នះក្នុងខែមេសា ឆ្នាំ១៩៧៥ ប៉ុន្តែអស់រយៈពេលជាច្រើនខែក្រោយមក អង្គភាពនេះបានស្ថិតនៅក្រោមឈ្មោះមន្ទីរ១៥ ។ ចំណាររបស់ ឌុច ទំនងជាមាននៅលើឯកសារជាច្រើនដែលមានប្រភពចេញមកពីមន្ទីរនេះ ។ ឯកសារដំបូងបំផុតដែលភ្ជាប់ ឌុច ទៅនឹងមន្ទីរ ស-២១ចុះកាលបរិច្ឆេទខែតុលា ឆ្នាំ១៩៧៥ តរហូតមក ។ នៅក្នុងរយៈពេល៦ខែបន្ទាប់មកទៀត ឌុច បានចែករំលែកពេលវេលារបស់ខ្លួនដើម្បីធ្វើការគ្រប់គ្រងគុកសន្តិបាលមួយនៅតាខ្មៅភាគខាងត្បូងទីក្រុងភ្នំពេញ និងមណ្ឌលសួរចម្លើយជាច្រើនទៀតដែលរាយពាសពេញទូទាំងទីក្រុងភ្នំពេញ ។ សន្តិបាលនៅតាខ្មៅឈ្មោះថា ស-២១ខ មានទីតាំងនៅលើបរិវេណមន្ទីរពេទ្យវិកលចរិត (ពេទ្យឆ្កួត) តែមួយគត់របស់ប្រទេសកម្ពុជា ។




**សម្លេងពីមន្ទីរ ស-២១**

**វគ្គទី១: ការរកឃើញមន្ទីរ ស-២១**

**ដោយសាស្ត្រាចារ្យ ដេវីដ ឆេនដល័រ**

ជាអ្នកគ្រប់គ្រងមន្ទីរស-២១ ឌុច បានខំប្រឹងប្រែងធ្វើការយ៉ាងសកម្មដើម្បីគ្រប់គ្រងរាល់កិច្ចការទាំងអស់របស់មន្ទីរនេះ ។បទពិសោធន៍និងសភាវគតិឈ្លៀសវៃដែលបានបណ្តុះតាមរយៈការបង្រៀន បានជួយកិច្ចការរបស់ ឌុច យ៉ាងខ្លាំង ។ ឌុច ធ្លាប់ធ្វើកិច្ចការចុះបញ្ជីកត់ត្រាផ្សេងៗ ដាក់ចេញនូវចម្លើយ ដោះស្រាយបញ្ហាផ្សេងៗ ទទួលការគោរព និងដាក់វិន័យអប់រំមនុស្សជាច្រើនក្រុម ។ ឌុច បានដាក់ខ្លួនឯងនិងអ្នកនៅក្រោមបង្គាប់ឲ្យប្រឹងធ្វើការយ៉ាងខ្លាំង ។ ហ៊ឹម ហ៊ុយ ដែលជាអតីតអ្នកយាមនៅមន្ទីរស-២១បានរំឭកឡើងវិញថា «ឌុច ខ្លាំង ច្បាស់លាស់ និយាយអីធ្វើហ្នឹង ។ ជារឿយៗ ឌុច ធ្វើឲ្យបុគ្គលិកនៅក្នុងមន្ទីរស-២១មានការភ័យខ្លាចញ័រខ្លួន ។» នៅពេលដែលសួរថាតើ ឌុច ជាមនុស្សមានចរិតយ៉ាងដូចម្តេចនោះ កងការពារម្នាក់បានឆ្លើយថា «មនុស្សយ៉ាងម៉េចអ្នេស? ឌុច គឺជ្រុលហួសហេតុតែម្តង» ។ នៅក្នុងគំនិតរបស់កងការពាររូបនេះ ភាពសាហាវឃោរឃៅបំផុតនៃឧក្រិដ្ឋកម្មរបស់ ឌុច គឺមិនមែនដោយសារ ឌុចជាអ្នកនៅពីលើបញ្ជាឲ្យយកអ្នកទោសចំនួនប្រមាណ ១៨០០០នាក់ ទៅម្ជាប់នោះទេ ប៉ុន្តែភាពដ៏សាហាវបំផុតគឺពេលដែល ឌុច អនុញ្ញាតឲ្យគេយកប្អូនថ្លៃរបស់ខ្លួន២នាក់ទៅដាក់គុកមន្ទីរស-២១ និងឲ្យយកទៅសម្លាប់ចោល ។ អតីតកងការពារគុកនេះបានរំឭកឡើងវិញថា «ឌុច មិនដែលសម្លាប់អ្នកណាដោយផ្ទាល់ទេ ប៉ុន្តែជួនពេលខ្លះ ឌុច បើកឡានទៅវាលពិឃាតនៅជើងឯក ដើម្បីពិនិត្យមើលការប្រហារជីវិតនៅទីនោះដោយផ្ទាល់» ។

សំណួរនិងចំណារជាច្រើនដែលសរសេរយ៉ាងស្អាតដោយ ឌុច ជារឿយៗសរសេរប៊ិកពណ៌ក្រហម ត្រូវបានឃើញនៅលើចម្លើយសារភាព ។ ជាញឹកញយចំណារនិងការចោទសួរដែល ឌុច ធ្វើឡើង ច្រើនតែកែតម្រូវឬបញ្ជាក់ការសង្ស័យទៅលើអ្វីដែលអ្នកទោសបានសារភាព ជូនយោបល់ឲ្យវាយដំ និងធ្វើទារុណកម្ម និងជំរុញឲ្យអ្នកសួរចម្លើយជីកឫសជីកគល់រក «ការពិត» ដែលអ្នកទោសបានលាក់ ។ មិនតែប៉ុណ្ណោះ ឌុច បានធ្វើសេចក្តីសង្ខេបលើឯកសារចម្លើយសារភាពមួយចំនួនដោយបានចង្អុលបង្ហាញពីខ្សែបណ្តាញដែល ឌុច ក្តាប់បានពីចម្លើយសារភាពមុនៗ ហើយជូនយោបល់ឲ្យធ្វើការតាមដានខ្សែបណ្តាញ ។ សេចក្តីសង្ខេបរៀបរាប់ដែលត្រូវបានសរសេរឡើងនៅក្នុងឆ្នាំ១៩៧៨ មានចំណងជើងថា «ផែនការចុងក្រោយ» ប៉ុនប៉ងចងក្រងនូវចម្លើយសារភាពក្នុងរយៈកាល៧ឆ្នាំកន្លងមក ដើម្បីបង្ហាញអំពីការសមគំនិតក្នុងទ្រង់ទ្រាយធំ និងយូរអង្វែងដែលពាក់ព័ន្ធទៅនឹងសហរដ្ឋអាមេរិក សហភាពសូវៀត តៃវ៉ាន់និងវៀតណាម ។ ដូចក្នុងករណីលោក ជេម ជេស៊ីស អាន់គ្លេថុន នៃក្រុមសេ.អ៊ី.អា

ឌុច ព្យាយាមតាំងខ្លួនប្រើប្រាស់គំនិតនេះក្នុងការស្រាវជ្រាវរកជនបង្កប់ក្នុងអង្គការ ។ ជាអ្នកគណិតវិទ្យា ឌុច ចូលចិត្តយកគំរូនូវអ្វីដែលខ្លួនគិតជាសមហេតុផល ។ «ផែនការចុងក្រោយ» គឺជាសៀវភៅគំរូមួយរបស់ ឌុច ។

ឌុច រស់នៅក្បែរមន្ទីរស-២១ ជាមួយនឹងប្រពន្ធនិងកូនតូច១២នាក់ ។ ឌុច នៅគុកមន្ទីរស-២១ រហូតដល់ល្ងាចថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ នៅពេលដែល ឌុច ដើរចេញពីក្រុងភ្នំពេញ ហើយក៏បាត់ស្រមោលរហូតដល់ពេលថ្មីៗនេះ ។ ក្នុងឆ្នាំ១៩៩៦ ឌុច លែងនៅក្នុងចលនាខ្មែរក្រហមតទៅទៀតហើយ ។ ឌុច បានជួបជាមួយនឹងក្រុមផ្សព្វផ្សាយសាសនាគ្រិស្តជនជាតិអាមេរិក នៅភាគពាយ័ព្យនៃប្រទេសកម្ពុជា ហើយក៏ក្លាយខ្លួនជាអ្នកប្រតិបត្តិសាសនាគ្រិស្ត ។ ឌុច ធ្វើការជាអ្នករៀបចំសណ្តាប់ធ្នាប់នៅមន្ទីរពេទ្យមួយកាលពីខែមេសា ឆ្នាំ១៩៩៩ នៅពេលដែលអ្នកកាសែតម្នាក់បានរកឃើញអត្តសញ្ញាណកម្មពីអតីតកាលរបស់គាត់ ។ ក្រោយមក ឌុច ត្រូវបានសម្ភាសដោយអ្នកកាសែតអាមេរិកាំង នេត ថេយ័រ ហើយក៏បាននិយាយដោយចំហអំពីអតីតកាលរបស់ខ្លួនមុនពេលត្រូវបានចាប់ខ្លួនដោយកងកម្លាំងប៉ូលិសកម្ពុជា និងដាក់ពន្ធនាគារនៅទីក្រុងភ្នំពេញ ។

## ជំនួយការរបស់ ឌុច

អនុប្រធានរបស់ ឌុច នៅមន្ទីរស-២១គឺ ឃឹម វ៉ាត (ហៅ ហ៊ី) ជាទាហានក្នុងអាយុប្រហែលជា២៥ឆ្នាំ ដែលបានបម្រើជាប្រធានអង្គភាពការពាររបស់មន្ទីរស-២១ស្របពេលដែល ឌុច ជាប្រធាននៃស្ថាប័ននេះ ។ ហ៊ី បានកើតនិងធំដឹងក្តីនៅព្រែកតូច ភាគខាងត្បូងនៃរាជធានីភ្នំពេញ ហើយបានចូលបដិវត្តន៍តាំងពីវ័យជំទង់នៅក្នុងឆ្នាំ១៩៦៦ ។ នៅក្នុងកងពលទី១១ (ក្រោយមកប្រែក្លាយទៅជាកងពល៧០៣) ហ៊ី បានបាត់បង់ភ្នែកម្ខាងនៅក្នុងការប្រយុទ្ធ ។ ហត្ថលេខារបស់ ហ៊ី ត្រូវបានឃើញនៅលើបញ្ជីចូលនិងបញ្ជីយកទោសម្លាប់ជាច្រើន ។ ក្នុងឆ្នាំ១៩៧៨ ជារឿយៗ ហ៊ី បានធ្វើការរួមគ្នាជាមួយនឹង ចាន់ ដើម្បីសួរចម្លើយឈ្លើយសឹកសង្គ្រាមជាជនជាតិវៀតណាម ។ ហ៊ី ជាមនុស្សកាចសាហាវដែលធ្វើឲ្យអ្នកនៅក្រោមបង្គាប់របស់ខ្លួនមានការខ្លាចរអាជាខ្លាំង ។ គុក ស្រស់ ដែលជាអតីតអ្នកយាមម្នាក់ក្នុងចំណោមអ្នកយាមនៅមន្ទីរស-២១ បានរំឭកថាៈ

ខ្ញុំមានការភ័យខ្លាច ហ៊ី យ៉ាងខ្លាំង ។ នៅពេលដែលខ្ញុំមើលមុខវា ហ៊ី មើលទៅកាចមែនទែន ។ ហើយប្រសិនបើ ហ៊ី ចេញសេចក្តីណែនាំដល់យើងហើយយើងធ្វើខុស ហ៊ី មកវាយតប់យើងតែម្តង ។ ប្រសិនបើយើងនិយាយអ្វីខុស វានឹងវាយយើង ។ យើងត្រូវតែប្រយ័ត្ននៅពេលដែលយើងនិយាយអ្វីដែលយើងនិយាយត្រូវតែនិយាយចំចំណុច ។ ខ្ញុំដឹងថា ហ៊ី គឺរឹងរូសខ្លាំងណាស់ ដូច្នេះខ្ញុំតែងតែមានការប្រយ័ត្នប្រយែង ។

គ្មានឯកសារបញ្ជាក់អំពីការផ្លាស់ប្តូរនិងមុខនាទីរបស់ ហ៊ី បន្ទាប់ពីឆ្នាំ១៩៧៩ទេ ។ អនុរបស់ ហ៊ី ឈ្មោះ ប៉េង ក៏ចេញមកពីស្រុកដូចគ្នាជាមួយនឹង ហ៊ី ដែរ ហើយបានធ្វើជាទាហានជាមួយនឹង ហ៊ី នៅក្នុងកងពល៧០៣ ។ ប៉េង ជាកូនកាត់ខ្មែរ-ចិន កើតនៅក្នុងឆ្នាំ១៩៥០ ។ នៅមន្ទីរស-២១ ប៉េង ជាបញ្ជាការលើអ្នកយាម ។ មិនតែប៉ុណ្ណោះ ប៉េង កត់ត្រាចំនួនអ្នកទោសចេញចូល បញ្ជូនទៅបន្ទប់តូច-ធំនៅក្នុងគុក ។ ដោយយោងទៅតាម ខៀវ ឡ អតីតអ្នកយាម ប៉េង «កាន់សោរគ្រប់បន្ទប់ទាំងអស់» ។ ប៉េង ធ្វើរបាយការណ៍ទៅឲ្យ ឌុច ដែលជាអ្នកសម្រេចថាតើត្រូវសួរចម្លើយ ធ្វើមិនដឹងមិនឮ ឬក៏យកទោសម្លាប់ចោល ។ ប៉េង រួមដំណើរជាមួយ ឌុច នៅក្នុងពេលដែល ឌុច ដើរមើលគុក ហើយបំពេញនាទីជាអង្គរក្សរបស់ ឌុច ទៀតផង ។ វ៉ាន់ ណាត ខ្លាច ប៉េង យ៉ាងខ្លាំង ។ វ៉ាន់ ណាត ហៅ ប៉េង ថាជា «មេឃាតករវ័យក្មេងដ៏សាហាវ» រហូតដល់គាត់ពុំហ៊ានមើលមុខរបស់ ប៉េង ។ នៅក្នុងកសិណរបស់ អ៊ឹង ប៉ិច នៅក្នុងតុលាការកាត់ទោស ប៉ុល ពត អៀង សារី នៅក្នុងឆ្នាំ១៩៧៩ បានហៅ ប៉េង ថាជាមនុស្ស «សាហាវព្រៃផ្សៃ» ដែលជាពាក្យពុំដែលបានប្រើសម្រាប់និយាយដល់បុគ្គលិកដទៃទៀតនៃមន្ទីរស-២១ នៅក្នុងតុលាការនេះទេ ។ ប៉េងហាក់ដូចជាត្រូវបានបញ្ចុះឋានៈនៅក្នុងឆ្នាំ១៩៧៨ នៅពេលដែលការកិច្ចរបស់ ប៉េង ត្រូវប្រគល់ទៅ ហ៊ឹម ហ៊ុយ ។ ប៉ុន្តែយោងទៅតាម គុក ស្រស់, ប៉េង រួចរស់ជីវិតផុតពីការវាយលុករបស់កងទ័ពវៀតណាម ហើយបានស្លាប់នៅភាគនិរតីនៃប្រទេសកម្ពុជានៅទសវត្សរ៍ឆ្នាំ៨០ ។

បន្ទាប់ពី ឌុច, ហ៊ី និង ប៉េង មនុស្សដ៏សំខាន់បំផុតនៅមន្ទីរស-២១ប្រហែលជា ចាន់ ដែលជាប្រធានអង្គភាពសួរចម្លើយ ។ ក្រៅពីកិច្ចការជាគ្រូបង្រៀនរបស់ ចាន់ នៅក្នុងទសវត្សរ៍ឆ្នាំ៥០ យើងពុំដឹងអ្វីផ្សេងទៀតអំពីជីវិតរបស់ ចាន់ មុនពេលនេះឡើយ ។ ការដែល ចាន់ និយាយភាសាវៀតណាមបានរអិលដែលកម្រនឹងមាននៅក្នុងចំណោមជនកម្ពុជាបង្ហាញថា ចាន់ កើតនិងធំដឹងក្តីនៅប្រទេសវៀតណាម ។ ចាន់ មកដល់មន្ទីរស-២១ជាមួយនឹង ឌុច នៅក្នុងឆ្នាំ១៩៧៥ ហើយធ្វើការនៅទីនោះរហូតដល់ទ័ពវៀតណាមលុកលុយចូលមក ។ ឆ្នាំ១៩៩០ ចាន់ នៅធ្វើការជាមួយនឹងខ្មែរក្រហមជាអ្នកសួរចម្លើយ ។ អ្នកកាសែតឈ្មោះ នេត ថេយ័រ ដែលបានឃើញ ចាន់ សួរចម្លើយអ្នកទោសនៅពេលនោះរំឭកថា ចាន់ «មានចរិតមើលទៅគួរឲ្យខ្លាចបំផុត» ដែលគាត់មិនដែលបានជួបប្រទះពីមុនមក ។ មន្ត្រីអង្គការសហប្រជាជាតិបានប្រទះឃើញ ចាន់ ម្តងទៀតនៅក្នុងឆ្នាំ១៩៩៦ ។ ពេលនោះ ចាន់ ធ្វើការដូចជាពាក់កណ្តាលចូលនិវត្តន៍ មាននាទីជាអ្នកថែសួននៅផ្សារមួយ ។

អនុប្រធានរបស់ ចាន់ គឺជាអតីតគ្រូបង្រៀនគណិតវិទ្យា ឈ្មោះ ទង់ សេងហ័ន ហៅ ប៉ុន ជាកូនខ្មែរកាត់ចិន មកពីតំបន់២៥ ដែលធ្វើការនៅក្រោម ឌុច នៅក្នុងអំឡុងសង្គ្រាមស៊ីវិល ។ ទង់ សេងហ័ន បានធ្វើការបម្រើឲ្យសន្តិបាលតាំងតែពីខែកក្កដា ឆ្នាំ១៩៧៥ មកម្ល៉េះ ។ នៅក្នុងអង្គប្រជុំស៊ុយទិតៀនមួយនៅឯគុកមន្ទីរស-២១កាលពីខែធ្នូ ឆ្នាំ១៩៧៦ ប៉ុន បានថ្លែងពីការស្អប់ខ្ពើមជីវប្រវត្តិវណ្ណៈ «អនុធនកណ្តាល» របស់ខ្លួនហើយសារភាពថា ជារឿយៗគាត់តែងតែ «អត្តទត្ថបុគ្គល» នៅក្នុងការគិតគូរ ហើយសារភាពទៀតថាដោយសារតែខ្លួនប្រឹងប្រែងធ្វើការលើបញ្ហាសន្តិបាលច្រើនពេករហូតដល់ពុំបាន«កសាងខ្លួន» ឬក៏រៀនសូត្រឲ្យបានច្រើនពី «មហាជន» ។ ឯកសារនោះបញ្ចប់ទៅវិញដោយមានកសិណសាក្សីដ៏កក់ក្តៅអំពីការងាររបស់ ប៉ុន នៅឯមន្ទីរស-២១ ពីសំណាក់ ចាន់ និង ឌុច ។

ប៉ុន ជាអ្នកសួរចម្លើយអ្នកទោសសំខាន់ៗជាច្រើនរួមមាន កែវ មាស, នៃ សារ៉ន, ហ៊ូ នឹម, ទីវ អុល និង ភោគ ឆាយ ។ ឯកសារជាច្រើនទៀតដែលចុះហត្ថលេខាដោយ ប៉ុន ភ្ជាប់ជាមួយនឹងការសួរចម្លើយទាំងនេះស្នើសុំឲ្យធ្វើទារុណកម្មឲ្យបានខ្លាំង ។ នៅក្នុងកិច្ចប្រជុំស៊ុយទិតៀនជារៀងរាល់ពីរសប្តាហ៍ម្តងដែលធ្វើឡើងនៅក្នុងគុកមន្ទីរស-២១ នៅក្នុងឆ្នាំ១៩៧៨ បុគ្គលិកនៅទីនេះអះអាងថា «ខ្លួនខ្លាច» ប៉ុន ដែលបានរិះគន់ខ្លួនឯងពីមូលហេតុដែលពុំបាន «ដើរតាមមហាជន» ។ ពាក្យ «មហាជន» នេះប្រហែលជាពាក្យប្រើជំនួសឲ្យរបៀបផ្តាច់ការពីថ្នាក់លើមកថ្នាក់ក្រោមរបស់ ប៉ុន ។ ក្រុមឯកសារមានការពាក់ព័ន្ធយ៉ាងជិតស្និទ្ធជាមួយនឹងក្រុមសួរចម្លើយក្រោមការដឹកនាំរបស់ សួស ធី ជាអតីតទាហានដែលមានអាយុប្រមាណ២៥ឆ្នាំប្លាយ នៅក្នុងឆ្នាំ១៩៧៧ និង ១៩៧៨ ។ សួស ធី មកពីស្រុកដូចគ្នាជាមួយនឹង ហ៊ី និង ប៉េង ដែរ ។ សួស ធី បាន «ចូលបដិវត្តន៍» នៅក្នុងខែសីហា ឆ្នាំ១៩៧១ ។ សួស ធី បានធ្វើការជាមួយ ហ៊ី នៅក្នុងកងពលលេខ៧០៣ មុនពេលចូលមកធ្វើការនៅមន្ទីរស-២១ នៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៥ ។ នៅក្នុងប្រវត្តិរូបស៊ុយទិតៀនផ្ទាល់ខ្លួន សួស ធី បានអះអាងថាខ្លួនបានក្លាយជាជនបដិវត្តន៍មួយរូបក៏ដោយសារខ្លួន «ខឹងសម្បាចំពោះពួកចក្រពត្តិ ពួកមានអភ័យឯកសិទ្ធិ និងពួកមូលធន ដែលបានជិះជាន់កេងប្រវ័ញ្ចប្រជាជនក្រីក្រ» ។ សួស ធី បានសារភាពថាក្នុងចំណោម «កង្វះខាតរបស់ខ្លួនគឺ សួស ធី ចូលចិត្តទៅមើលកុន ចូលចិត្តសើច ឈ្លោះជាមួយបងប្អូន និងឆាប់ខឹង» ប៉ុន្តែ សួស ធី និយាយថាគុណធម៌របស់ខ្លួនគឺ «មានសុឆន្ទៈធ្វើគ្រប់កិច្ចការទាំងអស់ដើម្បីបម្រើបក្ស» ។ សួស ធី បានរួចរស់ជីវិតរហូតមកដល់ទសវត្សរ៍ឆ្នាំ៩០ ។ ក្នុងឆ្នាំ១៩៩០ អ្នកកាសែតបានជួបសម្ភាសជាមួយ សួស ធី ចំនួនពីរដង ។ នៅពេលដែលត្រូវសួរថា មានការ «សោកស្តាយ» ឬទេ ដែលមកធ្វើការនៅមន្ទីរស-២១ សួស ធី ឆ្លើយថាខ្លួនមានការសោកស្តាយជាខ្លាំងចំពោះការកាប់សម្លាប់ច្រើនទូវកុមារនិងស្ត្រី ។ តាមពិតមនុស្សមួយចំនួនពុំមានកំហុសអ្វីទាល់តែសោះ» ។ ចំណុចមួយទៀតនៅក្នុងបទសម្ភាសន៍នោះ សួស ធី និយាយខ្ទីៗជាងបទសម្ភាសន៍លើកមុន ។ សួស ធី និយាយថា «នៅពេលដែលគេឲ្យការងារអ្នកឯងធ្វើ អ្នកឯងត្រូវតែធ្វើ» ។ នៅក្នុងចំណាត់ប្រភេទ «ដាច់ដោយឡែក» នៅក្នុងសៀវភៅទូរស័ព្ទមានឈ្មោះ «បងហ៊ុយ» ត្រូវបានចុះនៅក្នុងបញ្ជីនៅសៀវភៅទូរស័ព្ទនោះរួម

ជាមួយនឹង ឌុប ប៊ុន និង ចាន់ ។ បុរសពីរនាក់មានឈ្មោះដូចគ្នាគឺ «ហ៊ុយ» ធ្វើការនៅមន្ទីរស-២១ ក្នុងឆ្នាំ១៩៧៨ ។ ហ៊ុយ ដែលនៅក្នុងសៀវភៅទូរស័ព្ទនេះប្រហែលជា ហ៊ឹម ហ៊ុយ ដែលជាកសិករ «ថ្នាក់កណ្ដាលក្រោម» ដែល ហ៊ឹម ហ៊ុយ បានពិពណ៌នាដោយខ្លួនឯងមកពីតំបន់២៥ ដែលបានក្លាយជាទាហានខ្មែរក្រហមនៅក្នុងឆ្នាំ១៩៧២ ។ ការសន្និដ្ឋានបែបនេះដោយសារ ហ៊ឹម ហ៊ុយ បានសរសេរនៅក្នុងប្រវត្តិរូបសុយទិតៀនរបស់គាត់ផ្ទាល់ថា «ខ្លួនខ្ញើមរអើមមូលធននិយម និងពួកមានអភ័យឯកសិទ្ធិ» ។ ដោយធ្វើការនៅក្រោម ហ៊ិ, ហ៊ឹម ហ៊ុយ បានទទួលរងរបួសនៅក្នុងការប្រយុទ្ធចុងក្រោយមកលើក្រុងភ្នំពេញ ។ ហ៊ឹម ហ៊ុយ បានចូលមកធ្វើការនៅមន្ទីរស-២១ ក្នុងដើមឆ្នាំ១៩៧៧ ជាកងការពារ ហើយនៅក្នុងឆ្នាំ១៩៧៨ ហ៊ឹម ហ៊ុយ ទទួលខុសត្រូវក្នុងការកត់ត្រាឯកសារអ្នកទោសចូលទៅក្នុងមន្ទីរស-២១ និងអ្នកទោសដែលយកទៅសម្លាប់នៅជើងឯកដែលពីមុនជាភារកិច្ចរបស់ ប៉េង។ នៅចុងឆ្នាំ១៩៧៨ ហ៊ុយ ទទួលខុសត្រូវបញ្ហាសន្តិសុខនៅក្នុងគុកក្នុងលំដាប់ទី៥ ឬទី៦ នៅក្នុងខ្សែសង្វាក់នៃបទបញ្ជា ។ ហ៊ឹម ហ៊ុយ ធ្លាប់បានប្រាប់លោក ភីធ័រ ម៉ាគៀ (ដែលជាអ្នកស្រាវជ្រាវម្នាក់) ថា «គេសម្លាប់ប្រធានៗធំដទៃទៀត ហើយគេដំឡើងឋានៈខ្ញុំ» ។

នៅក្នុងបទសម្ភាសន៍ជាច្រើនជាមួយនឹងអ្នកកាសែតនិងអ្នកស្រាវជ្រាវជាន់ខ្ពស់ចាប់តាំងពីឆ្នាំ១៩៨៥មក ហ៊ឹម ហ៊ុយ បានសារភាពថា ខ្លួនបានដឹកអ្នកទោសជាច្រើនឡានទៅកាន់ជើងឯកហើយក៏បានសម្លាប់អ្នកទោសមួយចំនួន (នៅទីនោះ) ។ ហ៊ឹម ហ៊ុយ អះអាងថាខ្លួនត្រូវបានចាប់ដាក់គុក បន្ទាប់ពីឆ្នាំ១៩៧៩ អស់រយៈពេល «១ឆ្នាំ» ពីបទល្មើសទាំងអស់នេះ ក៏ប៉ុន្តែ វ៉ាន់ ណាត ជាជនរងគ្រោះដែលរួចរស់ជីវិតពីមន្ទីរស-២១បានចាំថា ហ៊ុយ ជាសមាជិកដ៏ «សាហាវខ្លាំងណាស់» នៅក្នុងក្រុមប្រហារជីវិតដែលអមដំណើរតាមអ្នកទោសទៅកាន់ជើងឯក ។ ជនរងគ្រោះដែលរួចរស់ជីវិតម្នាក់ទៀតនិយាយថា ហ៊ុយ ទទួលខុសត្រូវចំពោះការស្លាប់របស់អ្នកទោស «រាប់រយនាក់» ។ ការយល់ឃើញបែបនេះត្រូវបានបន្ទរដោយ ញ៉ែម អេន និងបុគ្គលិកដទៃទៀតនៃមន្ទីរស-២១ ដែលបានជួបសម្ភាសជាមួយអ្នកកាសែតអង់គ្លេសម្នាក់នៅក្នុងទីក្រុងភ្នំពេញ កាលពីឆ្នាំ១៩៩៧ ។ នៅក្នុងបទសម្ភាសន៍ជាច្រើនជារឿយៗ ហ៊ុយ សង្កត់បញ្ជាក់អំពីវិប្បដិសាររបស់ខ្លួនដោយនិយាយថា «ខ្ញុំពុំមានអារម្មណ៍ថាធ្វើការនៅមន្ទីស-២១គឺជាអ្វីដែលឪពុកម្ដាយរបស់ខ្ញុំចង់ឲ្យខ្ញុំធ្វើនោះទេ» ។ **(នៅមានត)**



អ៊ឹង ប៊ិច អតីតអ្នកទោសគុកទួលស្លែង ដែលរស់រានមានជីវិតក្រោយថ្ងៃ៧ មករា ១៩៧៩ ក្រោយមកលោក អ៊ឹង ប៊ិច ធ្វើជាប្រធានសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែងពីឆ្នាំ១៩៨០ ដល់ ១៩៨៤។ លោក អ៊ឹង ប៊ិច ទទួលមរណភាពក្នុងទសវត្សរ៍ឆ្នាំ៩០ នៅសហរដ្ឋអាមេរិក ។

# គំរូមួយនៃភស្តុតាងឯកសារដែលធ្លាប់មេដឹកនាំជាន់ខ្ពស់នៃបក្សកុម្មុយនិស្តកម្ពុជា ដែលនៅរស់ ទៅនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (ភាគ២)

***(តពីលេខមុន) កែ ពក***

*ជាឧទាហរណ៍ «ចម្លើយសារភាព» មួយដែលបានបញ្ជូនទៅឲ្យលេខាភូមិភាគកណ្តាលដែលពាក់ព័ន្ធ កែ ពក ចំពោះការដឹងឮអំពីការកាប់សម្លាប់ដែលនាំឲ្យមានពិរុទ្ធភាព គឺចម្លើយសារភាពរបស់សមាជិកគណៈស្រុកបារាយណ៍ក្នុងតំបន់៤២ ភូមិភាគកណ្តាលឈ្មោះ អែម មិន ហៅ សែន ដែលក្នុងពេលស្របជាមួយគ្នានោះជាអនុប្រធានទទួលបន្ទុកកិច្ចការសន្តិសុខស្រុកបារាយណ៍ ។*

*ក្នុងការពិពណ៌នាអំពីគោលនយោបាយរបស់បក្សកុម្មុយនិស្តកម្ពុជាក្នុងខែមេសា ឆ្នាំ១៩៧៥ «ចម្លើយសារភាព» របស់ សែន និយាយថាៈ*

> *យោងតាមផែនការរបស់បក្សត្រូវរៀបចំទទួលប្រជាជនដែលជម្លៀសចេញពីទីក្រុងភ្នំពេញ និងទីរួមខេត្តនានាទុកប្រជាជនទាំងនេះក្នុងកន្លែងមួយដោយឲ្យរស់នៅក្នុងភូមិនិងឃុំរបស់ប្រជាជន ហើយចំពោះអ្នកដែលបានបង្កប់ខ្លួនក្នុងចំណោមប្រជាជនចាំបាច់ ត្រូវដកចេញយកទៅដាក់កន្លែងមួយ ហើយបន្ទាប់មកធ្វើការវាយតម្លៃ ស៊ើបអង្កេតពួកនេះឲ្យបានច្បាស់ ។ ប្រសិនបើមានរកឃើញថានរណាជាមន្ត្រីត្រូវកម្ទេចម្តងមួយៗ ។*

*ក្រោយមកទៀតៈ*

> *បក្ស...បានធ្វើសេចក្តីណែនាំជាលើកទី២មួយ បក្សបានឲ្យយើងផ្តែកឆេររកចាប់មន្ត្រីបណ្តាសក្តិចុងក្រោយដែលបង្កប់ខ្លួននៅតាមបណ្តាភូមិនិងឃុំរបស់ប្រជាជន ហើយចាប់ពួកនេះដាក់នៅក្នុងមន្ទីរសន្តិសុខ ។ នៅទីនោះត្រូវឃុំពួកទាំងនេះសម្រាប់ធ្វើការវាយតម្លៃឲ្យបានច្បាស់លាស់ដើម្បីរកឲ្យឃើញនរណាជាមន្ត្រីហើយនរណាមិនមែនជាមន្ត្រី ។ បន្ទាប់មកវែកមុខម្តងមួយៗ ទៅតាមភាពពិតជាក់ស្តែង ។*

*«ចម្លើយសារភាព» របស់ សែន ក៏បាននិយាយថាសមាជិកទាំងអស់របស់ «ក្រុមដែលនៅរស់បង្កប់ក្នុងឃុំគគីធំ ស្រុកបារាយណ៍ តំបន់៤២ កាលពីខែធ្នូ ឆ្នាំ១៩៧៦ ក្រោយមកត្រូវបាន «កម្ទេចដោយបក្ស» ។ យោងទៅតាម «ចម្លើយសារភាព» របស់ សែន, សែន និង «ជនក្បត់» ជាបក្ខពួករបស់ខ្លួននៅក្នុងស្រុករបស់ សែន បានរំលោភបំពានគោលនយោបាយរបស់បក្សកាលពីខែមេសា ឆ្នាំ១៩៧៥ ដោយបញ្ជូនជនដែលត្រូវបានជម្លៀស «មួយចំនួន» ដែលជាមន្ត្រីបណ្តាសក្តិដែលត្រូវបានកំណត់អត្តសញ្ញាណថាជាខ្មាំងរស់នៅដូច «ប្រជាជនថ្មី» ដទៃទៀតនៅក្នុងសហករណ៍ក្នុងស្រុក ។ បន្ទាប់ពីការណែនាំរបស់បក្សលើកទី២ សៀន និង «ខ្សែស.អ៊ី.អា» ដទៃទៀតបានរំលោភបំពានគោលនយោបាយបក្សជាថ្មីទៀត ។ សែន និងបក្ខពួករបស់ខ្លួនបាន «ចេញមកជាចំហចាប់ចងមន្ត្រីបណ្តាសក្តិទាំងនោះដែលបង្កប់ខ្លួននៅក្នុងភូមិនិងឃុំនានារបស់ប្រជាជន» ហើយដូច្នេះ «បានធ្វើការចាប់ចងជាចំហដោយពុំបានរក្សាការសម្ងាត់ផ្ទុយទៅនឹងគោលនយោបាយរបស់បក្ស ដែលណែនាំថាយើងចាប់មន្ត្រីបណ្តាសក្តិនៅតាមវាលស្រែចម្ការ ការដ្ឋាន និងក្នុងភូមិឃុំ ។ ការធ្វើដូច្នេះអនុញ្ញាតឲ្យប្រជាជនថ្មីនិងចាស់មើលឃើញសកម្មភាពយើង...» ។*

*លទ្ធផលគឺថា «អ្នកដែលមានបុណ្យសក្តិ» មានការភ័យខ្លាច ហើយអាចរស់បានយ៉ាងហោចណាស់បណ្តោះអាសន្នដោយរត់គៀសខ្លួនទៅក្នុងព្រៃ ។ បន្ទាប់មកមនុស្សប្រមាណ៤០នាក់ដែល «ត្រូវបានចាប់ខ្លួន ហើយនាំយកទៅឃុំខ្លួននៅមន្ទីរសន្តិសុខស្រុកបារាយណ៍ តំបន់៤២ ដោយសង្ស័យថាមានឋានៈជាមន្ត្រី» ត្រូវបានពួកក្បត់ដោះលែងបន្ទាប់ពីធ្វើការវាយតម្លៃនិងស៊ើបអង្កេតអស់រយៈពេល២ខែ ដែលក្នុងករណីជាច្រើនបញ្ជាក់អំពីការសង្ស័យទាំងនោះ ។ ដោយយោងតាម «ចម្លើយសារភាព»*




របស់ សែន បញ្ហានេះកើតឡើងពីព្រោះ «ជនក្បត់» ឈ្មោះ ចាន់ ដែលជាលេខាស្រុកបារាយណ៍ បានណែនាំ «ឲ្យបន្ធូរដៃចំពោះអ្នកទោសមួយចំនួន» ដោយនិយាយថា «អ្នកទោសទាំងនេះគឺគ្មាននរណាម្នាក់ក្រៅពីសាច់ឈាមរបស់ខ្លួនយើងផ្ទាល់ ដូច្នេះយើងត្រូវមេត្តាដល់អ្នកទាំងនេះដោះលែង ហើយអនុញ្ញាតឲ្យពួកគេទៅធ្វើការចុះហើយប្រសិនបើពួកនេះគេចខ្លួនទុកឲ្យគេចចុះ» ។

ចំពោះការចាប់ខ្លួនចម្លើយសារភាពរបស់ សៀន មាន «តារាងរាយឈ្មោះជនក្បត់ពាក់ព័ន្ធនឹងប្រវត្តិ អែម មិន ហៅ សែន» បញ្ជីឈ្មោះនោះមានរាយ៦៨ឈ្មោះ ១០ឈ្មោះត្រូវបានឯកសារនោះនិយាយថា «បានចាប់ខ្លួនហើយ» អ្នកដែលនៅសល់ទាំងប៉ុន្មានមិនត្រឹមតែជា «ខ្សែសេ.អ៊ី.អា» នៅក្នុងបក្សប៉ុន្តែជាអតីតមន្ត្រីយោធារបបសាធារណរដ្ឋខ្មែរដែល សែន «សារភាពថាអ្នកទាំងនេះត្រូវបានពួកក្បត់អនុញ្ញាតឲ្យរស់នៅ» ។ ចំពោះ នួន ជា ក៏ដូចជា កែ ពក មាន «ចម្លើយសារភាព»ដទៃទៀតដែលមានពត៌មានអំពីការចាប់ខ្លួនដែលហាក់ដូចជាសេចក្តីណែនាំឲ្យចាត់វិធានការ ។ ចម្លើយសារភាពទាំងនេះរួមមានចម្លើយសារភាពដែលធ្វើឡើងកាលពីខែឧសភា ឆ្នាំ១៩៧៧ ដោយ លី ហាក់ ប្រធានសាលាបច្ចេកទេសមួយនៅជាយក្រុងភ្នំពេញ ដែលមានចំណារចុះថ្ងៃ៨ ខែមិថុនា ដែលមិនត្រឹមតែនិយាយថា «មួយច្បាប់ផ្ញើទៅឲ្យសមមិត្ត ពក» ប៉ុន្តែបន្ថែមថា «ពាក់ព័ន្ធជាមួយនឹងមិត្ត ជន ដែលជាប្តីមិត្ត ស៊ិន និងឈ្មោះអ្នកដទៃទៀតជាច្រើននៅភូមិភាគឧត្តរ» ។ បញ្ជីឈ្មោះចុះឈ្មោះ៨៥ ដែលក្នុងនោះ ១០ឈ្មោះត្រូវបានបញ្ជាក់ថាបានចាប់ខ្លួនហើយ ។ ជាបន្ថែមឈ្មោះមួយចំនួនត្រូវបានគូសសញ្ញាខ្វែង «X» នៅក្បែរឈ្មោះទាំងនោះ ប្រអប់ត្រូវបានគូសជុំវិញឈ្មោះទាំងនោះ ឬគូសបន្ទាត់នៅពីក្រោមប្រហែលជាបញ្ជាក់ថាឈ្មោះទាំងនោះត្រូវតាមចាប់ខ្លួន៥ឈ្មោះក្នុងចំណោមឈ្មោះទាំងនេះគឺជាកម្មាភិបាលនៅក្នុងភូមិភាគឧត្តរ ឬតំបន់១០៦ ជាតំបន់នៅជិតនឹងភូមិភាគនេះ ។ មិនតែប៉ុណ្ណោះ មានចំណារមួយទៀតនៅលើតារាងឈ្មោះដែលអានថា «បញ្ជីនេះពុំស្រង់ឈ្មោះទាំងអស់ទេ សូមអានឯកសារបន្ថែម» ។

## តាម៉ុក

ឧទាហរណ៍នៃ «ចម្លើយសារភាព» ដែលចង្អុលបង្ហាញអំពីការដឹងឮអំពីការប្រហារជីវិតនិងការចាប់ខ្លួនដែលនាំឲ្យមានពិរុទ្ធភាពចំពោះ តាម៉ុក រួមមានចម្លើយសារភាពរបស់ ទឹម សេន ហៅ ស៊ិត លេខាស្រុកនៅតំបន់២៥ ភូមិភាគនិរតីដែលត្រូវបានចារថា បាន «ផ្ញើជូនទៅបង ម៉ុក រួចហើយ ថ្ងៃ១២ ខែវិច្ឆិកា ឆ្នាំ១៩៧៧» ហើយមិនតែប៉ុណ្ណោះមានចំណារពីលើដាក់ថា «និរតី» ។ ចម្លើយសារភាពទាំងនេះពិពណ៌នាអំពីការធ្វើបាតុកម្មរបស់កសិករនៅក្នុងតំបន់ដែលត្រូវបានបង្ក្រាប «ដោយចាប់ខ្លួនអ្នកធ្វើបាតុកម្ម ហើយយកទៅសម្លាប់ចោល» កងកម្លាំងប្រដាប់អាវុធនៅតាមមូលដ្ឋានបានចាប់បាតុករចំនួន៥០នាក់ «ហើយបន្ទាប់មកយកបាតុករ១០នាក់យកទៅសម្លាប់» ។

ចម្លើយសារភាពកាលពីខែមីនា ឆ្នាំ១៩៧៨ របស់

សោម ជា ហៅ ស្តើង ត្រូវបានចារជាក់ថា «សមមិត្ត ម៉ុក បានអានរួចហើយ ប្រគល់ជូននៅថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៨។ សោម ជា គឺជាលេខាតំបន់២៥ ភូមិភាគនិរតី រហូតដល់ថ្ងៃអង្គការចាប់ខ្លួន។ សោម ជា បានពិពណ៌នាការប្រជុំកាលពីខែឧសភា ឆ្នាំ១៩៧៥ រវាងអ្នកស្នងតំណែងរបស់គាត់ជាលេខាតំបន់២៥ ឈ្មោះ ជ័យ សួន ហៅ តាជ័យ (ហៅ សេង) និងលេខាតំបន់២៤ ដែលជាតំបន់ជាប់នឹងភូមិភាគបូព៌ា ឈ្មោះ សួស នៅ ហៅ ឈូក ក៏ត្រូវបានចាប់ខ្លួនហើយដែរ ។ នៅក្នុងកិច្ចប្រជុំនោះៈ

> តាជ័យ គូសបញ្ជាក់ថាសព្វថ្ងៃនេះមានទំនាស់យ៉ាងខ្លាំងក្លា .....នៅក្នុងជួរបក្ស ។ ដោយយោងទៅតាមទំនាស់នោះ ចាប់ពីពេលនេះតទៅយើងចាំបាច់ត្រូវបន្តដំណើរទៅមុខ ហើយមានកម្មាភិបាលដឹកនាំភាគច្រើនដែលមិនឯកភាពជាមួយបក្សលើអត្ថន័យនេះពីព្រោះផ្លូវធ្វើបដិវត្តន៍សង្គមនិយមថ្មីដែលយើងកំពុងដើរ គឺមានលក្ខណៈតាបសង្កត់ប្រតិកិរិយា ហើយរឹតត្បិតសិទ្ធិនិងសេរីភាពរបស់មនុស្សគ្រប់គ្នា ជាពិសេសសិទ្ធិរបស់កម្មាភិបាលដើងចាស់ដែលបានចូលប្រឡូកក្នុងការតស៊ូអស់រយៈពេលយ៉ាងយូរមកហើយ ជាអ្នកដែលត្រូវដកដោយសារពួកប្រភេទនេះកំពុងត្រូវបានលាបពណ៌ថា ជាអ្នកមានគំនិតហួសហេតុនិយម ជាអ្នកយកអ្វីៗពីសង្គមចាស់ ជាអ្នកមិនអាចដើរត្រូវនឹងអ្នកដែលធ្វើបដិវត្តន៍សង្គមនិយម ជាអ្នកដែលត្រូវបោសសម្អាត ។

ដោយយោងទៅតាម «ចម្លើយសារភាព» ទាំងនេះ តាជ័យ គាំទ្រចលនាមួយ «ដើម្បីប្រឆាំងនឹងបក្សកុម្មុយនិស្តដែលកំពុងតាបសង្កត់កាប់សម្លាប់ប្រជាជនយ៉ាងអយុត្តិធម៌» ជាចលនាមួយដែល «មានមាគ៌ាត្រឹមត្រូវជួយរំដោះប្រទេសជាតិ រំដោះប្រជាជនពីរបបកុម្មុយនិស្តមួយដែលកំពុងតាបសង្កត់ កាប់សម្លាប់ប្រជាជន និងបង្ខំប្រជាជនឲ្យធ្វើការដូចសត្វគោ ក្របី ដោយគ្មានសិទ្ធិសេរីភាពអ្វីទាំងអស់» ។ ក៏ប៉ុន្តែយោងទៅតាមការរៀបរាប់នេះអ្នកទាំងឡាយដែលសង្ឃឹមថានឹងមានចលនាមួយបែបនេះ

> ទាំងនៅក្នុងមូលដ្ឋាននិងនៅក្នុងយោធា កំពុងត្រូវបានដកនិងបោសសម្អាតជាប្រចាំ ។ កម្រិតនៃការបោសសម្អាតរបស់អង្គការ គឺជានិច្ចកាលកំពុងកើនឡើងជាប្រចាំចាប់ផ្តើមពីដើមឆ្នាំ១៩៧៦ រហូតដល់ឆ្នាំ១៩៧៧ ។ ហេតុដូច្នោះអ្វីដែលគ្រប់គ្នាអាចគិតដល់គឺការភ័យខ្លាច និងការព្រួយបារម្ភរបស់ខ្លួន ។

ចម្លើយសារភាពរបស់ គង់ គាន ហៅ អ៊ីង វេត ដូចដែលបានពិពណ៌នាពីខាងលើមក ដោយសារចម្លើយសារភាពទាំងនេះពាក់ព័ន្ធទៅនឹង នួន (នួន ជា) ដែលបានដឹងអំពីការប្រហារជីវិតដែលនាំឲ្យមានពិរុទ្ធភាព ក៏មានចំណារនៅពីលើក្របនៃចម្លើយសារភាពថា «ការដកស្រង់ពត៌មានមួយចំនួនបានប្រគល់ជូនសមមិត្ត ម៉ុក រួចហើយ ខែឧសភា ឆ្នាំ១៩៧៧» ។ ចំណារនៅខាងក្រោមនៃចម្លើយសារភាពដែលជាអក្សរដៃរបស់ ឌុច ប្រកាសថា... «អា តាន់ម៉េង ត្រូវបានកម្ទេចរួចហើយ» បានបញ្ជាក់ថា តាន់ ម៉េង ត្រូវបានកម្ទេច «ដោយបង១៥» ដែលជារហស្សនាមរបស់ តាម៉ុក ។ ជាបន្ថែម ចំណារនៅលើក្របនៃចម្លើយសារភាពក៏បានធ្វើការកត់សម្គាល់ថា មនុស្សមួយចំនួនដែល «ចម្លើយសារភាព» ចោទប្រកាន់គឺ «មានការពាក់ព័ន្ធ» នៅក្នុងសកម្មភាពក្បត់ «អ្នកទាំងនោះមកពីតំបន់៣៣និង៣៥» តំបន់ទាំងពីរនេះគឺជាផ្នែកនៃភូមិភាគនិរតី ។ ចម្លើយសារភាពទាំងនេះត្រូវបានផ្ញើទៅឲ្យ តាម៉ុក ទំនងជាបង្កប់ន័យឲ្យ តាម៉ុក ធ្វើសកម្មភាពតាមដាន ហើយសេចក្តីបង្កប់នេះត្រូវបានបង្ហាញបន្ថែមដោយចំណារនៅខាងក្រោមទំព័រចម្លើយសារភាពជាច្រើនរាប់មិនអស់ ការគូសបន្ទាត់ដៅ ការខ្វែងអក្សរ «X» និងការគូសប្រអប់ព័ទ្ធជុំវិញឈ្មោះដែលនៅរាយពាសពេញក្នុងអត្ថបទចម្លើយសារភាព ។

ហេតុដូច្នេះ ចំណារនៅខាងជាយក្រដាសនៃចម្លើយសារភាពមួយដែលបញ្ជាក់ថា «សំ ត្រូវបានកម្ទេចដោយមូលដ្ឋាន» គឺស្របគ្នាទៅនឹងចំណារមួយទៀតដែលដាក់នៅក្បែរនឹងបញ្ជីឈ្មោះមនុស្ស១៦នាក់ ត្រូវបានពណ៌នាថាជា «ខ្សែរបស់សំ ដែលពាក់ព័ន្ធទៅក្នុងបទអុកឡុកប្រជាជនដើម្បីបង្កឲ្យមានទំនាស់ជាមួយអង្គការបដិវត្តន៍» ។ ចំណារនោះសរសេរថា «សូមកំណត់ទីតាំង» នៅខាងក្រោមបំផុតបន្ទាប់ពីឈ្មោះមនុស្ស៤នាក់

ទៀតដែលត្រូវបានចោទថាពាក់ព័ន្ធជា «ជនក្បត់» មានចំណារនៅជាយសន្លឹកក្រដាសសរសេរថា «តាមរក» ។ នៅក្នុងចំណុចមួយនៃចម្លើយសារភាពរបស់ វេត ដែលសរសេរអំពីកម្មាភិបាលម្នាក់ វេត បាននិយាយថា «អង្គការបានចាប់ខ្លួនហើយ» និងកម្មាភិបាលម្នាក់ទៀត វេត សរសេរថា «បច្ចុប្បន្ននៅស-២១» ចម្លើយសារភាពនោះបានចុះបញ្ជីនូវមនុស្ស៤នាក់ទៀតដែល «បានអនុវត្តសកម្មភាពផ្ទុយទៅនឹងមាគ៌ា» ហើយសញ្ញា «X» ត្រូវបានដាក់ក្បែរឈ្មោះមួយក្នុងចំណោមឈ្មោះទាំង៤ ។ បន្ទាប់មកមានអក្សរមួយឃ្លា ក្នុងនោះ វេត បានរាយឈ្មោះមនុស្ស៦នាក់ទៀតដែលគាត់បាន «សារភាព» ថាធ្វើមិនអើពើទៅនឹងមាគ៌ាបក្ស និងបន្ទាប់ពីឈ្មោះ២ចុងក្រោយមានសេចក្តីណែនាំមួយទៀតសរសេរថា «សូមរកឲ្យឃើញ» ។ នៅខាងក្រោមមកទៀត វេត បាននិយាយដល់កម្មាភិបាលម្នាក់ទៀតឈ្មោះ សង្គម អតីតគណៈស្រុកស្រែចាម ដែលសន្មតថាមានការពាក់ព័ន្ធនៅក្នុងការសមគំនិតប្រឆាំងបក្ស ហើយនៅត្រង់នេះមានគូសប្រអប់មួយនៅជុំវិញឈ្មោះ សង្គម ។ មិនតែប៉ុណ្ណោះ វេត បាន «សារភាព» ថាបន្ទាប់ពីខែមេសា ឆ្នាំ១៩៧៥ ភ្លាម មានម្នាក់ឈ្មោះ «ស្រស់ បានចាត់តាំង រុន ហើយនិងខ្ញុំឲ្យយកសំបុត្រទៅឲ្យ ឆោម ដែលជាគណៈស្រុកក្នុងតំបន់៣៥ នៅឯកោះតូច» ។ ប្រអប់មួយត្រូវបានគូសនៅជុំវិញឈ្មោះ ឆោម និងទីកន្លែងរបស់គាត់ ។ បន្ទាប់មកទៀត វេត បាន «សារភាព» ថាមានមនុស្សម្នាក់ក្នុងចំណោមមនុស្ស៧នាក់ដែលមានវត្តមាននៅក្នុងអង្គប្រជុំបានសមគំនិតប្រឆាំងដែរ ។ ឈ្មោះរបស់អ្នក៦នាក់ទៀតត្រូវបានគូសបន្ទាត់ពីក្រោម បន្ទាប់ពីនោះមានឃ្លាជាច្រើនទៀតដែលមានឈ្មោះមនុស្សជាប់ពាក់ព័ន្ធនៅក្នុងចម្លើយសារភាពរបស់ វេត ត្រូវបានគូសបន្ទាត់ពីក្រោម ឬមានប្រអប់ព័ទ្ធជុំវិញឈ្មោះទាំងនោះ វេត បានសរសេរអំពីការចូលរួមប្រជុំរបស់កម្មាភិបាលយោធានៅភ្នំពេញពីខែតុលាដល់ខែវិច្ឆិកា ឆ្នាំ១៩៧៥ៈ

> *នៅក្នុងពេលនោះខ្ញុំបានជួបជាមួយនឹង សឿន (វរសេនាតូចនៅកោះកុង) និង ផាត (វរសេនាតូចនៅកោះកុង) ...អ្នកទាំងពីរនេះនិយាយថា បណ្តាញមួយដែលបានមករស់នៅក្នុងកោះកុងគឺ ឃី (វរសេនាតូច) ដែលបាននៅជាមួយនឹងអ្នកទាំងពីរនេះដែរ ។*

ត្រង់ចំណុចនេះមានចំណារជាយក្រដាសថា «កោះកុង» ជាមួយនឹងសញ្ញា «X» ហើយប្រអប់ត្រូវបានគូសជុំវិញឈ្មោះទាំងបីនេះ ហើយនៅខាងលើនៃអត្ថបទមានសេចក្តីណែនាំថា «សូមបញ្ជាក់ទីកន្លែង» ។ ច្រើនឃ្លាបន្ទាប់មកទៀត ដែលក្នុងនោះឈ្មោះមួយចំនួនត្រូវបានគូសបន្ទាត់ឬគូសប្រអប់ព័ទ្ធជុំវិញ ចម្លើយសារភាពរបស់ វេត ឆ្លើយបញ្ជាក់ថាជាជនក្បត់ឈ្មោះ «សំណាង លេខាកងពលតូចដែលបានទៅរៀននៅប្រទេសចិន» ដែល វេត បាន «សារភាព» ថាគាត់បានប្រាប់ឈ្មោះនេះឲ្យ «ចងសម្ព័ន្ធ» ជាមួយនឹងខ្មែរក្បត់ពីរទៀត «ហន និង អ៊ួច» នៅត្រង់នេះចំណារនោះសរសេរថា «សំខាន់» ហើយឈ្មោះ ហន និង អ៊ួច ត្រូវបានគូសប្រអប់ ។

នៅទីបញ្ចប់ «ចម្លើយសារភាព» របស់ វេត បញ្ចប់ជាមួយនឹងតារាងបញ្ជីឈ្មោះដែលមានចំណងជើងថា «ស្តីអំពីបញ្ជីកម្លាំងក្បត់នៅក្នុងបណ្តាញរបស់ខ្ញុំ» ។ បញ្ជីនេះមានឈ្មោះចំនួន៦៥ ឈ្មោះចំនួន៤ចារថា «បានចាប់ហើយ» ឈ្មោះ១២ចារថា «អង្គការដក» ហើយឈ្មោះ៣ទៀតចារថា «អង្គការដកទៅក្រៅប្រទេស» ។ ឈ្មោះនៅសល់២៦ មានសញ្ញា «X» នៅក្បែរឈ្មោះទាំងនោះ ឬក៏មានគូសបន្ទាត់ពីក្រោម ។

ចម្លើយសារភាពមួយទៀតផ្ញើជូនទៅ តាម៉ុក ដែលបាននិយាយអំពីការចាប់ និងទំនងបក្ខពួកថា តាម៉ុក កំពុងត្រូវបានសុំឲ្យអនុវត្តបន្ថែមទៀត គឺជាចម្លើយសារភាពរបស់ ធូ ហៃ ចុះខែកុម្ភៈ ឆ្នាំ១៩៧៨ ។ ចម្លើយសារភាពទាំងពីរនេះចារថា «ទុកសម្រាប់ផ្ញើជូនសមមិត្ត ម៉ុក ទាក់ទងទៅនឹងតំបន់២៥ និង៣៣ និរតី» ហើយមានចំណារបន្ថែមទៀតសរសេរថា «ទាក់ទងហើយនៅថ្ងៃ២៨ ខែមីនា ឆ្នាំ១៩៧៨» ។ ចម្លើយសារភាពទាំងពីរនេះបានបញ្ចប់ដោយមានបញ្ជីមួយដែលមានចំណងជើងថា «ឈ្មោះចម្រុះនៅក្នុងប្រវត្តិរូប ធូ ហៃ» ដែលផ្តល់ឈ្មោះមនុស្ស៤នាក់ត្រូវបានចាប់ខ្លួនហើយ ។ ឈ្មោះនីមួយៗក្នុងចំណោមឈ្មោះ១៨នាក់ទៀតទាំងអស់នៅក្នុងតំបន់២៥ ភូមិភាគនិរតីមានសញ្ញា «X» នៅក្បែរ ។

***(នៅមានត)***

**ស្ទីវ ហេឌ័រ**

## ជាតិពន្ធនិងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍

# កម្ពុជា និង រ្វ៉ាន់ដា

### សេចក្តីផ្តើម

អត្ថបទនេះផ្ដើការពិនិត្យពិចារណាលើទំនាក់ទំនងរវាងជាតិពន្ធនិងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅក្នុងរឿងក្តី២នៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ៈ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅប្រទេសកម្ពុជាពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅប្រទេសរ្វ៉ាន់ដានាឆ្នាំ១៩៩៤ ។ ហេតុផលចម្បងដែលអត្ថបទនេះលើកឡើងអំពីជាតិពន្ធ ពីព្រោះថាតួនាទីនៃធាតុផ្សំ «ជាតិពន្ធ» (ក្រុមជនជាតិ ក្រុមពូជសាសន៍ ឬក្រុមកុលសម្ព័ន្ធដែលមានទំនៀមទម្លាប់វប្បធម៌រួមមួយរៀងៗខ្លួន) ត្រូវបានយល់ខុសជាញឹកញាប់ក្នុងរឿងក្តីទាំងពីរនេះ ។ ទោះបីជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅកម្ពុជាត្រូវបានចាត់ទុកថាជាកំហុសនៃការអនុវត្តបដិវត្តន៍ដែលពឹងពាក់លើកសិកម្មមួយនៅក្នុងប្រទេសនេះក៏ដោយ ក៏តាមពិតមានការពាក់ព័ន្ធនឹងការសម្លាប់ជាតិពន្ធក្នុងចំនួនដ៏ច្រើនសន្ធឹកសន្ធាប់ ។ ចំណែកឯឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅរ្វ៉ាន់ដាវិញ ទោះបីជានិច្ចកាលបង្ហាញឲ្យយើងឃើញថា ការប្រល័យពូជសាសន៍ក្នុងប្រទេសនេះបណ្តាលពីការស្អប់ និងការប៉ុនប៉ងបំផ្លាញឲ្យសាបសូន្យនៃជាតិពន្ធក៏ដោយ ក៏បញ្ហានយោបាយសំខាន់ៗជាច្រើននៅបង្កប់ពីក្រោមទស្សនៈដែលមជ្ឈដ្ឋានភាគច្រើនយល់ឃើញជាទូទៅ ។

### កម្ពុជា

ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ត្រូវបានឲ្យនិយមន័យក្នុងអនុសញ្ញាប្រល័យពូជសាសន៍ឆ្នាំ១៩៥៣ ថាជា «..ចេតនាបំផ្លាញក្រុមជនជាតិ ក្រុមពូជសាសន៍ ក្រុមជាតិពន្ធ ឬក្រុមសាសនាមួយផ្នែក ឬទាំងស្រុង» ។ និយមន័យនេះបានដកក្រុមនយោបាយនិងសង្គមចេញពីក្រុមរងគ្រោះនៃឧក្រិដ្ឋកម្មដែលមានឈ្មោះថា «ប្រល័យពូជសាសន៍» នេះ ។ ចំពោះករណីប្រទេសកម្ពុជា ២១ ភាគរយនៃប្រជាជនសរុបត្រូវបានប៉ាន់ស្មានថាបានបាត់បង់ជីវិតក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ៨០ភាគរយនៃជនរងគ្រោះទាំងនោះគឺជាតិពន្ធខ្មែរ ។ ជនដែលដល់ ប៉ុល ពត និងរបបកម្ពុជាប្រជាធិបតេយ្យរបស់ខ្លួន គឺជាជាតិពន្ធខ្មែរដ៏លើសលប់ ។ តួលេខទាំងនេះបាននាំទៅដល់ការជជែកពិភាក្សាអំពីថាតើរបបវាលពិឃាតរបស់ ប៉ុល ពត អាចត្រូវបានចាត់ទុកយ៉ាងពិតប្រាកដថាជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដែរឬទេ ។ ក្នុងពេលប៉ុន្មានឆ្នាំថ្មីៗនេះអ្នកជំនាញជាន់ខ្ពស់ផ្នែកឧក្រិដ្ឋកម្មប្រល័យពូជសាសន៍កម្ពុជា



និងអ្នកជំនាញច្បាប់អន្តរជាតិជាច្រើនបានដោះស្រាយការពិភាក្សានោះដោយចង្អុលទៅលើនយោបាយប្រល័យពូជសាសន៍របស់កម្ពុជាប្រជាធិបតេយ្យទាក់ទិនទៅនឹងព្រះពុទ្ធសាសនាជនជាតិចាមចិន ថៃ និងវៀតណាម ព្រមទាំងជនជាតិភាគតិចផ្សេងទៀត ។

ទោះបីជាយ៉ាងនេះក្តី យើងទុកបញ្ហានិយមន័យច្បាប់នេះមួយកន្លែងសិនហើយត្រឡប់មកពិនិត្យមើលទំហំនៃ «ជាតិពន្ធ» ក្នុងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅកម្ពុជាដែលនៅតែជាប្រធាន

បទនៃការពិភាក្សា ។ តើការកាន់អំណាច៣ឆ្នាំ ៨ខែ និង២០ថ្ងៃ របស់ខ្មែរក្រហមជាឧទាហរណ៍មួយនៃ «ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ឯង» ដែលក្នុងនោះ «ជាតិពន្ធុ» ពុំបានដើរតួសំខាន់ (ពីព្រោះតែខ្មែរសម្លាប់ខ្មែរគ្នាឯងប្ញយ៉ាងណា ។ តើទស្សនៈរបស់ ប៉ុល ពត អំពីការកសាងកម្ពុជាឡើងវិញទាំងប្ញសគល់ បានផ្អែកច្រើនទៅលើមនោគមន៍វិជ្ជាកុម្មុយនិស្តជាងគំនិតប្រកាន់ពូជសាសន៍ថា អ្នកណាជាពូជសាសន៍ខ្លួន ប្ញមិនមែន? សំណួរទាំងនេះនៅតែបន្តត្រូវបានពិភាក្សា ប៉ុន្តែវាជាការមានតម្លៃក្នុងការបង្ហាញនូវចំណុចមួយចំនួនខាងក្រោមនេះ ។ ថ្វីបើជាតិពន្ធុខ្មែរជាច្រើនបានស្លាប់បាត់បង់ជីវិតក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ច្រើនជាងជាតិពន្ធុវៀតណាម ចិន ឡាវ ប្ញ ចាម ក្នុងចំនួនដ៏ច្រើនក៏ពិតមែន ប៉ុន្តែសមាជិកនៃក្រុមជនជាតិភាគតិចទាំងនេះបានស្លាប់បាត់បង់ជីវិតក្នុងចំនួនភាគរយច្រើនជាងជាតិពន្ធុខ្មែរ ។ ជាតិពន្ធុខ្មែរបានស្លាប់បាត់បង់ក្នុងសម័យនោះត្រឹមតែ១៨-១៩ ភាគរយប៉ុណ្ណោះ ក៏ប៉ុន្តែជាតិពន្ធុចាម បាត់បង់ប្រហែល៣៦ ភាគរយ ជាតិពន្ធុចិន៥០ភាគរយ និងជាតិពន្ធុវៀតណាមរហូតដល់ជិត១០០ភាគរយឯណោះ ។ តួលេខនេះពុំមែនជាបច្ច័យនៃការបែងន្យ ប្ញក៏ដោយកាលៈទេសៈពិសេសណាមួយទេ ។ ឯកសារការិយាធិបតេយ្យផ្ទាល់បែបនេះបានបង្ហាញឲ្យដឹងថា ការធ្វើទុក្ខបុកម្នេញក្រុមខាងលើបែបនេះជានយោបាយរបស់កម្ពុជាប្រជាធិបតេយ្យដែលត្រូវបានកំណត់នៅការិយាល័យមជ្ឈិម ហើយត្រូវបានអនុវត្តពេញទូទាំងប្រទេស ។ ដោយសារគោលនយោបាយចំហបែបនេះ សមាជិកក្រុមទាំងនេះមិនត្រឹមតែត្រូវបានសម្លាប់ និងក្នុងករណីខ្លះត្រូវបានកម្ទេចចោលទាំងស្រុងប៉ុណ្ណោះទេ ភាសារបស់ក្រុមទាំងនេះថែមទាំងត្រូវបានហាមឃាត់ពុំឲ្យប្រើប្រាស់និងត្រូវបានបង្ខំឲ្យក្បត់នឹងជំនឿនិងប្រពៃណីរបស់ខ្លួន ជាតួយ៉ាងដូចជាករណីពួកចាមត្រូវបានបង្ខំឲ្យបរិភោគសាច់ជ្រូកជាដើម ។ ដូច្នេះជនដែលប្រព្រឹត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅកម្ពុជាបានដាក់ជាគោលការណ៍កម្ទេចប្រជាជនពុំមែនត្រឹមតែជាខ្មាំងរបស់សង្គមប្ញខ្មាំងនយោបាយប៉ុណ្ណោះទេ ប៉ុន្តែដោយសារខ្មាំងទាំងនោះមានជាតិពន្ធុផ្សេង ។ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅរ៉ាន់ដា នាឆ្នាំ១៩៩៤ បង្ហាញឲ្យឃើញពីស្ថានភាពតាមរូបភាពជាច្រើន ។




ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដែលមជ្ឈដ្ឋានជាច្រើនបានកំណត់ថាជាលទ្ធផលនៃការបែងចែកនិងការស្អប់ជាតិពន្ធុនោះ គឺជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មួយដែលវិវាទសង្គមនិងនយោបាយបានឡើងដល់ចំណុចកំពូល ។ ក្នុងរយៈពេលប្រហែល ១០០ថ្ងៃនាពាក់កណ្តាលឆ្នាំ១៩៩៤ ភាគីជ្រុលនិយមក្នុងរដ្ឋាភិបាលរ៉ាន់ដាបានដាក់ចេញនូវផែនការមួយដើម្បីសម្លាប់អ្នកដែលខ្លួនយល់ថាជា «ខ្មាំង» របស់ខ្លួន ។ ជាលទ្ធផល មនុស្សពី ៨០០ ០០០ ទៅ ១ ០០០ ០០០នាក់ ត្រូវបានសម្លាប់ ។ ភាគច្រើនលើសលប់នៃជនរងគ្រោះទាំងនេះជាជនស្លូតត្រង់ ហើយជាជនស៊ីវិលដែលពុំមានអ៊ីការពារខ្លួនគ្រប់គ្រាន់ ។ រ៉ាន់ដាមានក្រុមជាតិពន្ធុសំខាន់ៗបីៈ

១) ហ៊ូទូ ជាតិពន្ធុដែលមានចំនួនច្រើនជាងគេ

២) ទុតស៊ី មានចំនួនតិចតួច និង

៣) ត្វា មានចំនួនតិចជាងគេបំផុត ។

តាមការយល់ឃើញរបស់មជ្ឈដ្ឋានភាគច្រើន ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅរ៉ាន់ដា គឺគ្រាន់តែជាហេតុការណ៍សាមញ្ញ

មួយនៃការសម្លាប់ពួកទុតស៊ីដោយពួកហ៊ូទូ ។ ហើយបើតាមការពិត គឺអ៊ីចឹងមែន គឺថាជនដៃដល់ក្នុងការសម្លាប់ភាគច្រើនលើសលប់ និងអ្នកដែលបានរួមចំណែកក្នុងការកាប់សម្លាប់នេះគឺពួកហ៊ូទូ ចំណែកឯភាគច្រើននៃជនរងគ្រោះវិញគឺពួកទុតស៊ី ។ ទោះបីជាយ៉ាងនេះក្តី បញ្ហាដាក់ឈ្មោះថាជា «ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍លើជាតិពន្ធុទុតស៊ី» គឺនៅមិនទាន់ដាច់ស្រេចនៅឡើយទេ ។

ប្រសិនបើនិយមន័យនៃភាពខុសគ្នារវាងជាតិពន្ធុមួយទៅជាតិពន្ធុមួយទៀត គឺផ្អែកទៅលើភាសា វប្បធម៌ ឬសាសនាផ្សេងគ្នានោះ ព្រំដែនបែងចែករវាងពួកហ៊ូទូ និងទុតស៊ី មានភាពស្រពេចស្រពិល ។ សមាជិកនៃក្រុមទាំងពីរនេះនិយាយភាសាឃិនយ៉ា វ៉ាន់ដា ជាភាសាទី១របស់ខ្លួនដូចគ្នា ។ ដូចគ្នានេះដែរ ហ៊ូទូ និងទុតស៊ី មានវប្បធម៌និងសាសនាដូចគ្នា ។ តាមពិតទៅមានភ័ស្តុតាងបង្ហាញឲ្យដឹងថាក្នុងសម័យមុនអាណានិគម ប្រជាជនអាចផ្លាស់ប្តូរពីប្រភេទជាតិពន្ធុមួយទៅប្រទេសមួយបានយ៉ាងស្រួល ហើយការកំណត់ថា «ហ៊ូទូ» ឬ «ទុតស៊ី» គឺសំដៅលើឋានៈសេដ្ឋកិច្ចសង្គមជាងលក្ខណៈពីកំណើតទៅវិញក្នុងជំនាន់នោះ ។ ទោះបីជាយ៉ាងនេះក្តីមួយរយៈកាលក្រោយមកចំណាត់ប្រភេទនៃជាតិពន្ធុទាំងពីរត្រូវបានកំណត់ច្បាស់ ហើយសមាជិកភាពនៅក្នុងក្រុមជាតិពន្ធុណាមួយត្រូវបានតម្រូវឲ្យមាន ។ ទោះជាមានការរៀបអាពាហ៍ពិពាហ៍រវាងជាតិពន្ធុទាំងពីរនេះជាទូទៅក្តី កូនដែលកើតមកពុំអាចទាមទារថាខ្លួនជា ហ៊ូទូ ផង ទុតស៊ីផងនោះឡើយ ។ ចាប់ពីទសវត្សរ៍ឆ្នាំ៣០មក ពលរដ្ឋរ៉ាន់ដាទាំងអស់ត្រូវបានតម្រូវឲ្យកាន់អត្តសញ្ញាណប័ណ្ណដែលបញ្ជាក់អំពីជាតិពន្ធុរបស់ខ្លួន ។ ពេលនោះជាតិពន្ធុនៅក្នុងប្រទេសរ៉ាន់ដាបានក្លាយជាអត្តសញ្ញាណនយោបាយ ក៏ដូចជាអត្តសញ្ញាណវប្បធម៌និងសង្គមដែរ ។ ការកំណត់បែងចែកជាតិពន្ធុបានក្លាយជាការបែងចែករវាង «គ្នាយើង» និង «អ្នកដទៃ» ឬ «អ្នកខាងក្នុង» និង «អ្នកខាងក្រៅ» នៅក្នុងប្រទេសនេះ ។ គំនិតទាំងនេះត្រូវបានប្រកាន់យកយ៉ាងខ្លាំងក្លាបំផុតក្នុងឆ្នាំ១៩៩៤ ហើយអ្នកដែលត្រូវបានចាត់ទុកជា «អ្នកដទៃ» ត្រូវបានចាប់ខ្លួន និងសម្លាប់ចោល ។

វាជាការសំខាន់ក្នុងការកត់សម្គាល់ថា ទុតស៊ីពុំមែនជាគោលដៅដែលត្រូវសម្លាប់តែមួយគត់ក្នុងអំឡុងពេលប្រល័យពូជសាសន៍ទេ គឺមានពួកនិយមនយោបាយកណ្តាលហ៊ូទូខ្លួនឯងដែលត្រូវបានចាត់ទុកថាជាការគំរាមកំហែង និងមិនអាចឲ្យទុកចិត្តបានពីសំណាក់របបប្រល័យពូជសាសន៍របស់ហ៊ូទូដែរ ។ នេះបង្ហាញឲ្យឃើញពីការកាប់សម្លាប់ដែលស្តែងចេញនូវលក្ខណៈនយោបាយជាចំហ ។ បន្ថែមពីលើនេះជាតិសាសន៍ត្វាពាក់ព័ន្ធជាមួយភាគីទាំងសងខាងក្នុងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ គឺពួកនេះជាជនដៃដល់ផង និងជាជនរងគ្រោះផង ។ សមាជិកក្រុមនេះចូលរួមជាមួយភាគីណាមួយដោយអាស្រ័យទៅតាមជំនឿនយោបាយរបស់ខ្លួន ។ អ្នកដែលចូលរួមជាមួយពួកដែលមានអំណាចហ៊ូទូ ក្លាយជាអ្នកសម្លាប់ រីឯអ្នកដែលចូលរួមជាមួយពួកទុតស៊ីឬពួកហ៊ូទូដែលរងនូវការធ្វើទុក្ខម្នេញត្រូវបានសម្លាប់ ។ ដូច្នេះការចាត់ទុកថារូបភាពនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅរ៉ាន់ដា ជាករណីដ៏ច្បាស់លាស់មួយនៃការសម្លាប់បំបាត់ជាតិពន្ធុគឺមិនត្រឹមត្រូវឡើយ ។ អំណាចនិងនយោបាយយ៉ាងហោចណាស់ក៏ជាកត្តាសំខាន់ក្នុងការកំណត់ថានរណាជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដូចជាការផ្សារភ្ជាប់ធាតុផ្សំ «ជាតិពន្ធុ» ពីដំបូងទៅនឹងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដែរ ។

តួនាទីនៃជាតិពន្ធុក្នុងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ត្រូវបានយល់ខុសដោយហេតុផលជាច្រើន ។ ក្នុងករណីនៃ «ឧក្រិដ្ឋកម្មប្រល័យជាតិពន្ធុ» ដូចក្នុងប្រទេសរ៉ាន់ដា អ្នកខាងក្រៅគួរពិនិត្យមើលជាសំខាន់លើសោកនាដកម្មកើតឡើងដោយសារ «ការស្អប់គ្នារវាងកុលសម្ព័ន្ធពីរ» ជាជាងយល់ថាជាលទ្ធផលនៃប្រវត្តិសាស្ត្រ និងហេតុផលនយោបាយដ៏ស្មុគស្មាញដែលហែកហួរប្រទេសនេះរាប់ទសវត្សរ៍មកនោះ ។ ការស្អប់គ្នារវាងជាតិពន្ធុ ឬកុលសម្ព័ន្ធហាក់ដូចជារឿងចាស់តាំងពីបរមបុរាណមួយ ជារឿងកើតជាហូរហែតរៀងមក ហើយចំពោះប្រទេសនៅអាហ្វ្រិកវិញវាជារឿងធម្មជាតិទៀតផង ។ អ្នកខាងក្រៅច្រើនមានអារម្មណ៍ថាខ្លួនពុំអាចធ្វើអ្វីបានច្រើនដើម្បី (ឬគួរ) ធ្វើការផ្លាស់ប្តូរបញ្ហានេះបានទេ ។ ទោះបីជាយ៉ាងណាក៏ដោយ នៅពេលដែលស្ថានការណ៍ត្រូវបានលាតត្រដាងថាជាការប៉ុនប៉ងនាសម័យកាលថ្មីមួយ ដើម្បីកម្ចាត់សត្រូវនយោបាយដែលពុំមានការការពារគ្រប់គ្រាន់ឲ្យវិនាសសាបសូន្យពិភពលោកត្រូវរ៉ាប់រងនូវការទទួលខុសត្រូវដើម្បីធ្វើ

អន្តរាគមន៍ និងបញ្ឈប់ការកាប់សម្លាប់ ។

ហេតុផលដែលតួនាទីនៃជាតិពន្ធក្នុងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅកម្ពុជាជាញឹកញាប់ត្រូវបានវាយតម្លៃទាប គឺខុសគ្នាពីករណីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅរ៉្វាន់ដា ។ ដោយផ្អែកលើកត្តាសង្គមនិងនយោបាយ វាជាការលំបាកក្នុងការដាក់ឈ្មោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តលើជនរងគ្រោះ៨០ភាគរយថាជា «ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ» ផ្ទុយទៅវិញក្រុមជនរងគ្រោះដែលមានទំហំតូចៗដូចជាព្រះសង្ឃ ចាម ចិន ទំនងជាត្រូវបានចាត់ទុកថាជាជនរងគ្រោះដោយឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដែលជាឧក្រិដ្ឋកម្មធ្ងន់ធ្ងរជាងទៅវិញ ។ ជាពិសេសនៅក្នុងប្រទេសកម្ពុជាដែលគំនិតប្រកាន់ពូជសាសន៍ចំពោះជាតិពន្ធមួយចំនួនដូចជាវៀតណាមដែលជាជនជាតិភាគតិចជាដើមស្ថិតនៅខ្លាំងក្លានៅឡើយ ។ បញ្ហាធាតុផ្សំជាតិពន្ធនៅក្នុងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ក៏ដូចជាការពាក់ព័ន្ធផ្នែកច្បាប់របស់វាពុំមែនជាបញ្ហាសាមញ្ញនិងងាយស្រួលឡើយ ។ តាមពិតក្នុងអំឡុងពេល និងក្រោយសង្គ្រាមត្រជាក់ពួកកុម្មុយនិស្តត្រូវបានមើលឃើញថាជាក្រុមនយោបាយដ៏គ្រោះថ្នាក់បំផុតពីសំណាក់ប្រទេសលោកខាងលិចជាច្រើន ។ ដូច្នេះសោកនាដកម្មដែលមានទំហំធំធេងស្រដៀងគ្នានេះ ដូចជាបដិវត្តន៍វប្បធម៌ក្នុងប្រទេសចិន ឬដែនការសមូហភាវូបនីយកម្មក្នុងប្រទេសរុស្ស៊ីអាចត្រូវបានទម្លាក់កំហុសទៅលើសេដ្ឋកិច្ចសង្គមនិយម ឬរបបកុម្មុយនិស្តនៃប្រទេសទាំងពីរនេះ ។ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅកម្ពុជាក៏ប្រហែលជាសោកនាដកម្មផ្នែកនយោបាយមួយផ្សេងទៀតដែលអ្នកវិភាគនៃប្រទេសលោកខាងលិចបន្ទុទម្លាក់កំហុសទៅលើពួកកុម្មុយនិស្តទាំងស្រុងតែមួយគត់ដោយពុំបានគិតពីមូលហេតុ ឬមនោគមន៍វិជ្ជាផ្សេងទៀតនោះឡើយ ។

**ស៊ូសាន់ឃុក**

# ប្រទេសសេរ៉ាឡេអូន

## សុំអង្គការសហប្រជាជាតិឱ្យខ្លួនមានតួនាទីក្នុងតុលាការសង្គ្រាម

ប្រទេសសេរ៉ាឡេអូន នាពេលថ្មីៗកន្លងមកនេះបានផ្ញើសេចក្តីស្នើសុំឲ្យអង្គការសហប្រជាជាតិបង្កើតតុលាការឧក្រិដ្ឋកម្មសង្គ្រាមមួយដើម្បីកាត់ទោសក្រុមមេដឹកនាំឧទ្ទាម ដោយសារកងទ័ពរបស់ក្រុមនេះបានបង្កឲ្យមានការរងរបួសនិងបានកាប់សម្លាប់ប្រជាពលរដ្ឋសេរ៉ាឡេអូនអស់ជាច្រើននាក់ ហើយថែមទាំងបានចាប់ពង្រត់ក្រុមទាហានរក្សាសន្តិសុខចំនួន៥០០នាក់ទៀត ។ ប៉ុន្តែតុលាការដែលប្រទេសសេរ៉ាឡេអូនបានស្នើសុំនោះដូចដែលគ្រោងបញ្ជាក់នៅក្នុងសារលិខិតរបស់លោក អាម៉ាត់ តេហ្សង់ កាបាស់ ប្រធានាធិបតីប្រទេសសេរ៉ាឡេអូន ផ្ញើជូនលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ កូហ្វី អាណាន់ គឺមានលក្ខណៈខុសគ្នាយ៉ាងឆ្ងាយពីតុលាការអន្តរជាតិដែលបានបង្កើតឡើងក្នុងទសវត្សរ៍ឆ្នាំ១៩៩០ សម្រាប់តំបន់បាល់កង់ «តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី» និងប្រទេសរ៉្វាន់ដា ។ តែផ្ទុយទៅវិញ តុលាការដែលប្រទេសសេរ៉ាឡេអូនស្នើសុំឲ្យបង្កើតឡើងនេះបែរជាមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងតុលាការដែលកំពុងរៀបចំបង្កើតឡើងដើម្បីកាត់ទោសក្រុមមេដឹកនាំខ្មែរក្រហមនៅក្នុងប្រទេសកម្ពុជាទៅវិញ ដែលក្នុងនោះរដ្ឋាភិបាលកម្ពុជាជាអ្នកមានសិទ្ធិអំណាចយ៉ាងច្រើនក្នុងបញ្ហានេះ ។ ក្រុមសុភាចារបុរសនិងចៅក្រមដែលត្រូវបង្កើតឡើងគឺចំណុះទៅដោយសញ្ជាតិសេរ៉ាឡេអូនផង និងបរទេសផង ដូចក្នុងករណីប្រទេសកម្ពុជាដែរ ។ តុលាការចម្រុះដែលប្រទេសសេរ៉ាឡេអូនស្នើសុំនោះនឹងត្រូវមានអសនៈនៅក្នុងប្រទេសសេរ៉ាឡេអូន ហើយមានដែនសមត្ថកិច្ចកំណត់ឲ្យបើកសវនាការកាត់ក្តីតែចំពោះគណបក្សមួយប៉ុណ្ណោះ គឺគណបក្សរណសិរ្សបង្រួបបង្រួមបដិវត្តន៍របស់លោកហ្វូដាយ សាន់កោះ ។ ក្នុងរដូវដើមឆ្នាំនេះលោក សាន់កោះ បានរំលោភបំពានលើកិច្ចព្រមព្រៀងសន្តិភាពដែលបានចូលជាធរមានអស់រយៈពេលមួយឆ្នាំមកហើយដែលកិច្ចព្រមព្រៀងនោះបានផ្តល់ឲ្យគាត់នូវតួនាទីមួយក្នុងជួររដ្ឋាភិបាល ហើយកន្លងមកថ្មីៗនេះបានដឹកនាំទាហានរបស់ខ្លួនប្រឆាំងនឹងកងទ័ពរបស់លោក កាបាស់ និងកងកម្លាំងរក្សាសន្តិភាព របស់អង្គការសហប្រជាជាតិទៀត ។ ឥឡូវនេះលោក សាន់កោះ កំពុងស្ថិតនៅក្នុងការឃុំខ្លួន ។ តាមប្រភពព័ត៌មានពីអ្នកការទូតបានឲ្យដឹងថាប្រទេសអង់គ្លេសដែលកាលពីខែមុនបានបញ្ជូនទាហានរបស់ខ្លួនទៅប្រទេសសេរ៉ាឡេអូនបានជួយប្រទេសនេះក្នុងការធ្វើពង្រាងសុំបង្កើតតុលាការបែបនេះ ។ តុលាការនោះនឹងត្រូវបង្កើតឡើងក្រោមសេចក្តីសម្រេចមួយក្នុងចំណោមសេចក្តីសម្រេចដែលអាចមានទាំងអស់ចំនួនបីរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិស្តីពីប្រទេសសេរ៉ាឡេអូនដែលនឹងត្រូវលើកយកមកពិភាក្សានៅក្នុងប៉ុន្មានសប្តាហ៍ខាងមុខនេះ ។ **បាបារ៉ា ក្រូសសេត**

ប្រែសម្រួលដោយៈ **ឡាយ ពុទ្ធារ៉ា**

# ការខិតខំថ្មីៗជុំវិញច្បាប់ជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម

**កត់ត្រាដោយ ផាត កុសល**

***ទូរទស្សន៍ប៉ុស្តិ៍ ញូវអេស៊ា ថ្ងៃសុក្រ ទី១៦ ខែមិថុនា ឆ្នាំ២០០០***

នៅក្នុងកិច្ចជួបសំណេះសំណាលជាមួយនឹងនាយករដ្ឋមន្ត្រីថៃ ឯកឧត្តម ឈួន លីកផៃ នៅថ្ងៃទីពីរនៃដំណើរទស្សនកិច្ចរបស់មេដឹកនាំកំពូលរបស់ប្រទេសថៃនាពេលថ្មីៗនេះ (ពីថ្ងៃទី១៤ដល់ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០០) សម្តេចក្រុមព្រះទ្រង់មានបន្ទូលបញ្ជាក់ជាថ្មីអំពីសេចក្តីត្រូវការឲ្យមានការពិភាក្សាលម្អិតដើម្បីឲ្យពង្រាងច្បាប់ជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមនេះអាចត្រូវបានអនុម័ត ។ ទ្រង់មានបន្ទូលទៀតថា «យើង (យើងទីនេះខ្ញុំចង់មានន័យថាគណៈកម្មការជាន់ខ្ពស់ពិសេស) បានត្រៀមខ្លួនគ្រប់ពេលវេលាក្នុងការបន្តកិច្ចពិភាក្សាជាមួយនឹងរដ្ឋាភិបាល ហើយនៅពេលដែលគណៈកម្មការ និងរដ្ឋាភិបាលបានបញ្ចប់ការពិភាក្សាទាំងនោះហើយ ខ្ញុំនឹងត្រៀមខ្លួនស្នើសុំឲ្យរដ្ឋសភាជាតិពិនិត្យជាអត្តិភាពលើពង្រាងច្បាប់នេះ ។»

ទ្រង់មានបន្ទូលទៀតថា ទ្រង់មានព្រះទ័យសោមនស្សរីករាយដែលសម្តេច ហ៊ុន សែន និងអង្គការសហប្រជាជាតិបានឯកភាពគ្នាក្នុងការបង្កើតឡើងនូវអង្គចៅក្រមមួយ ដើម្បីដោះស្រាយនូវភាពទ័លច្រកនានានៅក្នុងដំណើរការជំនុំជម្រះក្តីដោយរដ្ឋាភិបាលកម្ពុជាឥឡូវនេះមានសេរីភាពក្នុងការចរចាជាមួយនឹងរដ្ឋសភាជាតិ ។

***ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០០***

សម្តេច ជា ស៊ីម ប្រធានគណបក្សប្រជាជនបានថ្លែងនៅក្នុងសុន្ទរកថាប្រារព្ធបុណ្យខួបទី៤៩ នៃការបង្កើតគណបក្សប្រជាជនកម្ពុជាថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៥១-ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០០ ថា គណបក្សប្រជាជនកម្ពុជាសូមសម្តែងនូវការគាំទ្រចំពោះរាជរដ្ឋាភិបាលកម្ពុជាក្នុងការនាំយកមេដឹកនាំខ្មែរក្រហមមកកាត់ទោស នៅក្នុងពេលអនាគតដ៏ឆាប់ខាងមុខនេះ ហើយពង្រាងច្បាប់សម្រាប់កាត់ទោសខ្មែរក្រហមក៏ត្រូវបានរាជរដ្ឋាភិបាលដាក់ជូនរដ្ឋសភាជាតិរួចហើយដែរ ។

***ថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០០០***

លោក ហែន កូរ៉ែល បានថ្លែងប្រាប់ឲ្យដឹងបន្ទាប់ពីលោកបានធ្វើដំណើរមកដល់ព្រលានយន្តហោះអន្តរជាតិពោធិចិនតុងថា «ប្រសិនបើអ្នកធ្វើច្បាប់សម្រេចកំណត់យកទ្រង់ទ្រាយតុលាការណាមួយតាមបែបដែលខ្លួនគិតនោះលោកអគ្គលេខាធិការអង្គការសហប្រជាជាតិនឹងអាចទាញសេចក្តីសន្និដ្ឋានជាចុងក្រោយដែលជាការបញ្ចប់នូវបញ្ហាទាំងមូល» ។ ព្រមជាមួយគ្នានេះដែរលោកក៏បានសង្កត់ធ្ងន់អំពីលក្ខណៈបច្ចេកទេសដែលជាគោលដៅដ៏សំខាន់ក្នុងដំណើរទស្សនកិច្ចរបស់លោកចុងសប្តាហ៍នេះ ហើយបានថ្លែងបញ្ជាក់ប្រាប់ថា លោកមកទីនេះគឺដើម្បីដោះស្រាយជាចុងក្រោយលើចំណុចពិស្តារអំពីរបៀបនិងវិធីសាស្ត្រក្នុងការរៀបចំបើកតុលាការមួយបែបនេះដែលពុំដែលមានពីមុនមក ។

លោក កូរ៉ែល បានជ្រើសរើសស្រង់យកនូវភារកិច្ចចាំបាច់មួយចំនួនដែលត្រូវធ្វើនៅខណៈពេលដែលមានការព្រមព្រៀងគ្នាជាផ្លូវការមួយរវាងរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ ហើយក៏បានបញ្ជាក់ឲ្យដឹងដែរថា ការដែលយើងរៀបរាប់អំពីពេលវេលាដ៏ជាក់លាក់ណាមួយសម្រាប់កំណត់ថាតើតុលាការនឹងត្រូវចាប់ផ្តើមដំណើរការក្នុងពេលដ៏ឆាប់ខាងមុខត្រឹមណានោះគឺជាប្រធានមួយដែលអាចធ្វើឲ្យមានការថ្វោះធ្វោយបាន ។ លោកបានធ្វើការបញ្ជាក់ថា លុះត្រាតែដល់ពេលដែលកិច្ចព្រមព្រៀងដែលមិនទាន់បានចុះជាលាយលក្ខណ៍អក្សររវាងលោកជាមួយនឹងសម្តេច ហ៊ុន សែន កាលពីក្នុងខែឧសភានោះ បានទទួលការយល់ព្រមពីសភា ព្រឹទ្ធសភា ក្រុមប្រឹក្សាធម្មនុញ្ញ និងព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាសិន ទើបអង្គការសហប្រជាជាតិអាចចូលខ្លួនក្នុងដំណើរការនេះជាផ្លូវការ ។ «ទាំងនេះគឺប្រៀបបាននឹងមហាសាគរដែលពុំទាន់មានព្រំប្រទល់កំណត់ច្បាស់លាស់ ។ នេះគឺជាទង្វើមួយដែលពុំមានរណាម្នាក់បានធ្វើទេពីមុនៗមក» ។

នៅក្នុងសេចក្តីថ្លែងការណ៍មួយដែលមានលក្ខណៈប្រយោល

បន្តិចសម័យប្រជុំពេញអង្គរបស់ក្រុមថ្នាក់ដឹកនាំគណបក្សប្រជាជនកម្ពុជាកាលពីថ្ងៃអង្គារ៍ ទី៤ ខែកក្កដា បានគាំទ្រផែនការរៀបចំតុលាការនេះ ប៉ុន្តែពុំបាននិយាយអំពីអង្គការសហប្រជាជាតិទេ ។

## ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០០

សេចក្តីថ្លែងការរបស់លោក ហែន កូរែល អគ្គលេខាធិការរងទទួលបន្ទុកផ្នែកច្បាប់របស់អង្គការសហប្រជាជាតិនៅព្រលានយន្តហោះពោធិចិនតុង

លោក លោកស្រីជាអ្នកសារព័ត៌មាននៅទីនេះជាទីមេត្រី ខ្ញុំអរគុណច្រើនដែលលោក លោកស្រី បានអញ្ជើញមកទីនេះនៅថ្ងៃនេះ ។ ខ្ញុំក៏មានសេចក្តីរីករាយនឹងសូមរាយការណ៍ថា នឹងចាកចេញពីប្រទេសកម្ពុជាលើកនេះដោយមានភាពជឿជាក់ក្នុងចិត្តថា គណៈប្រតិភូរបស់ខ្ញុំនិងរូបខ្ញុំផ្ទាល់បានសម្រេចបានរួមជាមួយនឹងសមភាគី ឯកឧត្តមរដ្ឋមន្ត្រី សុខ អាន និងគណៈប្រតិភូរបស់ឯកឧត្តម នូវគោលដៅទាំងឡាយដែលយើងបានកំណត់ដើម្បីសម្រេចឲ្យបាន ។បន្ទាប់ពីការពិភាក្សាក្នុងបរិយាកាសស្មោះត្រង់ជាវិជ្ជមាននិងយ៉ាងទូលំទូលាយអស់រយៈពេល២ថ្ងៃពេញ រដ្ឋមន្ត្រី សុខ អាន និងខ្ញុំសម្រេចបាននូវការ យោគយល់គ្នាមួយលើកម្រិតទំនាក់ទំនងជាមូលដ្ឋានរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិនៅក្នុងកិច្ចខិតខំប្រឹងប្រែងដែលមិនធ្លាប់មានពីមុនមក គឺអង្គជំនុំជម្រះក្តីវិសាមញ្ញនៅក្នុងតុលាការកម្ពុជាសម្រាប់ការកាត់ទោសឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ដើម្បីចងចាំនូវការយល់គ្នារវាងភាគីទាំងសងខាង ខ្ញុំបានប្រគល់ជូនឯកឧត្តមរដ្ឋមន្ត្រី សុខ អាន នូវពង្រាងអនុសារណៈនៃការយល់គ្នាដែលនឹងគ្រប់គ្រងកិច្ចសហប្រតិបត្តិការរបស់អង្គការសហប្រជាជាតិនៅក្នុងការបង្កើតនិងកិច្ចដំណើរការនៃតុលាការនេះ ។

ខ្ញុំបានបញ្ជាក់ជូនឯកឧត្តមរដ្ឋមន្ត្រីយ៉ាងច្បាស់ថាអង្គការសហប្រជាជាតិនឹងពុំអាចបន្តដំណើរការនេះទៀតទេ ប្រសិនណាបើច្បាប់បង្កើតតុលាការនេះ (ដូចដែលត្រូវបានអនុម័តដោយរដ្ឋសភាកម្ពុជា) ខុសប្លែកពីអនុសារណៈនៃការយល់គ្នានេះ ។ ខ្ញុំដឹងថា បញ្ហានេះគឺជាការព្រួយបារម្ភ ជាពិសេសរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

អង្គការសហប្រជាជាតិបានសម្រេចបាននូវភារកិច្ចនានារបស់ខ្លួនក្នុងការជួយ ធ្វើពង្រាងនិងការចរចារឲ្យមានអនុសារណៈនៃការយល់គ្នាមួយជាមួយរដ្ឋាភិបាលកម្ពុជា សំណើរបស់ឯកឧត្តមរដ្ឋមន្ត្រី សុខ អាន ឲ្យផ្តល់ដំបូន្មានលើ «៦» ប្រការទាំងឡាយនៃពង្រាងច្បាប់នេះ ។ ឥឡូវនេះគឺជាការទទួលខុសត្រូវរបស់រដ្ឋាភិបាលដើម្បីធានាឲ្យប្រាកដថាសភាជាតិអនុម័តច្បាប់ឲ្យបានទាន់ពេលវេលាក្នុងទម្រង់មួយដែលស្របទៅតាមស្មារតីនៃការយល់គ្នា ភាគីកម្ពុជានិងភាគីអង្គការសហប្រជាជាតិសម្រេចបានជាលទ្ធផលនៃការពិភាក្សាជាច្រើនកន្លងមក ។ ដូចដែលឯកឧត្តមរដ្ឋមន្ត្រី សុខ អាន បានបញ្ជាក់កាលពីម្សិលមិញ ភារកិច្ចនេះអាស្រ័យលើរដ្ឋាភិបាលតែមួយគត់ ហើយភារកិច្ចនេះមានសារៈសំខាន់ដើម្បីធ្វើឲ្យដំណើរការមានចលនាឆ្ពោះទៅការបញ្ចប់ពេញលេញទៅបាន ។

ខ្ញុំសូមថ្លែងអំណរគុណដល់ឯកឧត្តមរដ្ឋមន្ត្រី សុខ អាន និងគណៈប្រតិភូរបស់ឯកឧត្តម ដែលបានធ្វើការងារជាមួយគណៈប្រតិភូរបស់ខ្ញុំនៅក្នុងស្មារតីកិច្ចសហប្រតិបត្តិការមួយ ។ ខ្ញុំសូមជូនពររាជរដ្ឋាភិបាលកម្ពុជាឲ្យទទួលបានជោគជ័យ នៅក្នុងភារកិច្ចដ៏មានសារៈសំខាន់របស់ខ្លួនក្នុងការជូនព័ត៌មានដល់រដ្ឋសភាជាតិនូវខ្លឹមសារនៃការយល់គ្នារបស់យើងនិងពង្រាងច្បាប់នេះ ។ អង្គការសហប្រជាជាតិត្រៀមខ្លួនជាស្រេចប្រសិនបើលក្ខខណ្ឌចាំបាច់ត្រូវបានឆ្លើយតបនឹងបន្តធ្វើការជាមួយរដ្ឋាភិបាលកម្ពុជាដើម្បីនាំយកជនដៃដល់នៃឧក្រិដ្ឋកម្មដ៏សាហាវឃោរឃៅដែលប្រព្រឹត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យមកកាត់ទោស ។


ហែន កូរែល



# មន្ទ អស្ចារ្យពីរប្រភេទ

**(តពីលេខមុន)** ទន្ទឹមគ្នានឹងក្រុមប្រាសាទអង្គរវត្តដែលបានស្ថិតនៅជាភ័ស្តុតាងតំណាងអរិយធម៌ដ៏ខ្ពង់ខ្ពស់របស់ខ្មែរសម័យមហានគរ ទួលស្លែងក៏បានកើតឡើងជាតំណាងភាពងងឹតសូន្យសុងនៃប្រាជ្ញាខ្មែរ និងភាពឃោរឃៅដែលមានស្ថិតនៅក្នុងចរិតខ្មែរបច្ចុប្បន្ន ។ ការកាប់សម្លាប់យ៉ាងរង្គាលដែល ប៉ុល ពត បានប្រព្រឹត្តលើប្រជាពលរដ្ឋខ្មែរគ្នាឯង ក៏មិនមែនជាការកាប់សម្លាប់មនុស្សគ្នាឯងយ៉ាងរង្គាលជាលើកទីមួយនោះទេ ។ ទោះបីមនុស្សលោកបានកសាងអរិយធម៌បានខ្ពង់ខ្ពស់ហើយយ៉ាងណាក៏ដោយ ក៏មនុស្សលោកនៅតែរកលេសប្រើឧត្តមគតិសម្រាប់បញ្ឆេះកំហឹងសម្លាប់ស៊ីសាច់ហុតឈាមមនុស្សដូចគ្នារាប់លាននាក់ ។

យើងតែងបានធ្លាប់ឮអំពីការកាប់សម្លាប់ពួកជ្វីហ្វដោយហ៊ីត្លែរនៅប្រទេសអាល្លឺម៉ង់ និងនៅប្រទេសឯទៀតក្នុងទ្វីបអឺរ៉ុប ។ តាមពិតពួកជ្វីហ្វមិនមែនជា«ជនជាតិ»ទេ តែជាអ្នកកាន់សាសនាជុដាអ៊ីស្មជាមួយគ្នា មានទំនៀមទម្លាប់ជាមួយគ្នា មានឈ្មោះដើមកំណើតជាជួរស្រឡាយជាប់គ្នា ប៉ុន្តែរស់នៅរាត់រាយក្នុងប្រទេសជាច្រើន ។ នៅចុងក្រោយ ពួកជ្វីហ្វនេះក៏បានផ្តុំគ្នាបង្កើតជារដ្ឋអ៊ីស្រាអែលក្នុងឆ្នាំ១៩៤៨ថ្មីៗនេះ ។ នៅមុនសង្គ្រាមលោកលើកទី២ (១៩៣៩-៤៥) បន្តិច ហ៊ីត្លែរដែលជាប្រមុខរដ្ឋអាល្លឺម៉ង់មានចិត្តស្អប់ខ្ពើមពួកជ្វីហ្វណាស់ ហើយក៏បានបង្កើតកម្មវិធីនយោបាយរដ្ឋាភិបាលជាតិរបស់ខ្លួនដើម្បីសម្លាប់ពួកជ្វីហ្វឲ្យអស់ផុតពូជចេញពីពិភពលោក ។ មុនពេលបញ្ចប់សង្គ្រាមលោកលើកទី២ ហ៊ីត្លែរបានសម្លាប់ជ្វីហ្វអស់ចំនួន៦លាននាក់ក្នុងចំណោមជ្វីហ្វ២០លាននាក់ ដោយរបៀបយ៉ាងឃោរឃៅក្រៃលែង រួមមាន៖ ការបាញ់សម្លាប់ចោលភ្លាមៗនៅមុខប្តី ប្រពន្ធ មុខកូន ឬមុខឪពុកម្តាយ ដេញបាញ់ឲ្យរត់ផ្តុំគ្នា រួចចាប់ចងស្លាបសេកអូសយកទៅញាត់គរដើងគ្នាក្នុងជរំមុននឹងបញ្ចេញយកទៅបាញ់ចោលទៅព្រែក ឬអារ-កសម្លាប់ ឬធ្វើទារុណកម្មកប់ទាំងរស់ ខ្លះដឹកចេញពីក្នុងរថភ្លើងយកទៅវាយបញ្ច្រកទឹក ញាត់ក្នុងឡឧស្ម័ន រួចបើកផ្សែងពុលសម្លាប់ ឬដុតសម្លាប់ក្នុងឡទាំងរស់ ទាំងក្មេងតូចៗ ទាំងស្រីទាំងប្រុស ដោយសម្រាតខោអាវនិងដោះស្បែកជើងចេញឲ្យងូតទឹកលាងខ្លួនស្អាតបាតជាមុនសិន ។

សព្វថ្ងៃនេះ ក្រោយពីហ៊ីត្លែរបានចាញ់សង្គ្រាមទៅ អ្នកស្រាវជ្រាវបានរកឃើញកន្លែងសម្លាប់ធំៗរបៀបនេះជាច្រើនកន្លែង ជាពិសេសនៅជំរំពីរនៅអូស្វីត្សនិងនៅដាកខាវនៅក្នុងប្រទេសអាល្លឺម៉ង់ ហើយបានកសាងសារមន្ទីរយ៉ាងប្រណីតនៅកន្លែងទាំងពីរនេះ រក្សាទុកមិនឲ្យបាត់នូវវត្ថុជាភ័ស្តុតាងទាំងឡាយដែលបានរកឃើញស្តីពីការកាប់សម្លាប់នេះសូម្បីតែសក់មួយសរសៃ ឬខ្សែអាវមួយ ក៏បានរក្សាទុកឲ្យបានគង់វង្សមកដែរ ។ បន្ថែមលើសារមន្ទីរទាំងពីរខាងលើនេះ អ្នកស្រាវជ្រាវទើបបានសម្ពោធនូវសារមន្ទីរថ្មីយ៉ាងទំនើបមួយនៅក្រុងវ៉ាស៊ីនតោនសហរដ្ឋអាមេរិក ដើម្បីរំឭកការចងចាំជានិច្ចនូវអំពើអមនុស្សធម៌ដែលមនុស្សលោកបានប្រព្រឹត្តលើមនុស្សគ្នាឯង ។

ប៉ុន្តែការកាប់សម្លាប់មនុស្សដោយមនុស្សគ្នាឯងធំជាងគេបំផុតនៅលើពិភពលោកបានកើតឡើងនៅក្នុងប្រទេសចិននិងនៅក្នុងប្រទេសរុស្ស៊ីឯណោះទៅវិញទេ ។ នៅក្នុងប្រវត្តិសាស្ត្រ

ប្រទេសចិន អធិរាជចិនទាំងឡាយតែងសម្លាប់ប្រជាជនរបស់ខ្លួនចោលរាប់លាននាក់ជាញឹកញយដោយហេតុផលផ្សេងៗ ។ នាសម័យបច្ចុប្បន្ន ប្រធាន ម៉ៅ សេទុង គឺជាមេឃាតករធំជាងគេបង្អស់ ។ ទាំងនៅក្នុងបដិវត្តន៍វប្បធម៌ និងទាំងនៅក្នុងចលនាមហាលោតផ្លោះ ប្រធាន ម៉ៅ បានសម្លាប់មនុស្សទាំងអស់ចំនួនមួយរយលាននាក់ក្នុងទសវត្សរ៍ឆ្នាំ៦០ និង ៧០ ។ នៅប្រទេសរុស្ស៊ី ប្រធានាធិបតី ស៊្វីសែហ្វ ស្តាលីន តែងបាននិយាយអះអាងថា «បើមានមនុស្សស្លាប់ពីរ–បីនាក់នេះជាសោកនាដកម្មគួរឲ្យព្រួយបារម្ភមែន តែបើមានមនុស្សស្លាប់រាប់លាននាក់ទៅហើយនេះគ្រាន់តែជាលេខកត់សម្គាល់តែប៉ុណ្ណោះ» ។ របៀបគ្នានឹងប៉ុលពតនៅទួលស្លែង ស្តាលីន បានធ្វើឲ្យមនុស្សស្លាប់អស់ចំនួនយ៉ាងតិច១៥លាននាក់ ដោយបង្ខំឲ្យធ្វើកសិកម្មសមូហភាពក្នុងឆ្នាំ១៩៣៧ ។ ក្រោយមក ស្តាលីន បានចាប់ធ្វើការ «បោសសម្អាតបក្ស» សម្លាប់មនុស្សគ្នាឯងចោលអស់២០លាននាក់ថែមទៀត ។

នៅក្នុងទ្វីបអាហ្វ្រិក នៅដើមទសវត្សរ៍ឆ្នាំ១៩៧០ ប្រធានាធិបតី អេឌី អាមីន នៃប្រទេសយូគ័រណា បានសម្លាប់មនុស្សចោលអស់ចំនួន២០ភាគរយនៃប្រជាជនប្រទេសរបស់ខ្លួនដោយចាប់មនុស្សខ្លះមកវះយកថ្លើមស៊ីទាំងឆៅដោយខ្លួនឯងតែម្តង ។ ឯចំណែកអ្នកផ្តាច់ការ បូកាស្សា ដែលតាំងខ្លួនឯងជាអធិរាជនៅប្រទេសអាហ្វ្រិកកណ្តាលដូច ណាប៉ូឡេអុង ក៏បានសម្លាប់មនុស្សអស់ជាច្រើនសែននាក់ដោយរុញទម្លាក់ពីលើកំពូលភ្នំ ឬរុញច្រានចូលទ្រុងឲ្យខ្លាស៊ី ។ យើងមិនត្រូវភ្លេចទេថារដ្ឋាភិបាលប្រទេសអេត្យូពីនិងប្រទេសស៊ូដានក៏បានស្តុកអង្ករនិងគ្រឿងអាហារឯទៀតៗចោលក្នុងឃ្លាំងមិនព្រមចែកចាយឲ្យប្រជាជនដែលអត់ឃ្លានដោយរដូវរាំងស្ងួត បណ្តាលឲ្យប្រជាជនរបស់ប្រទេសទាំងពីរនេះស្លាប់យ៉ាងរន្ធាលអស់២លាននាក់ ។

នៅក្នុងសង្គ្រាមអ៊ីរ៉ាក់–អ៊ីរ៉ង់ ពីឆ្នាំ១៩៨០ ដល់ឆ្នាំ១៩៨៥ រដ្ឋាភិបាលប្រទេសទាំងពីរបានប្រើទាហានឲ្យដេញបាញ់ប្រជាជនស្លូតត្រង់រត់ចូលក្នុងចំការមីនផ្ទុះស្លាប់អស់ជាងមួយលាននាក់ ។ រីឯក្នុងអតីតប្រទេសយូហ្គោស្លាវី ពួកស៊ែបបានសម្លាប់អ្នកកាន់សាសនាអ៊ីស្លាមអស់ច្រើនសែននាក់ ។ នៅមជ្ឈិមបូព៌ា ពួកទួរគីបានសម្លាប់ប្រជាជនអារម៉េនៀនអស់ចំនួន១លាននាក់ក្នុងឆ្នាំ១៩២៤ ។ ចំណែកនៅទ្វីបអាហ្វ្រិកខាងត្បូងវិញ សង្គ្រាមក្តាប់អំណាចរបស់រដ្ឋាភិបាលដែលបានកើតឡើងបន្តបន្ទាប់គ្នាតាំងពីឆ្នាំ១៩៧៤ នៅប្រទេសអាហ្សង់ទីន ប្រទេសអែលសាវ៉ាដ័រ និងប្រទេសហ្គាតេម៉ាឡា បានធ្វើឲ្យប្រជាជនទាំងបីប្រទេសនេះស្លាប់យ៉ាងហោចណាស់អស់ចំនួន១លាននាក់ក្នុងប្រទេសនីមួយៗ ។ នៅទ្វីបអាមេរិកខាងជើង យើងមិនត្រូវបំភ្លេចចោលទេថានៅពេលដែលពួកស្បែកសកំពុងរៀបចំដីអាណានិគមរៀបចំរដ្ឋ រួចរៀបចំសហរដ្ឋអាមេរិកទាំងមូលក្នុងចន្លោះឆ្នាំ១៧០០ដល់ឆ្នាំ១៨៨០ អ្នកតាំងទីលំនៅថ្មីនេះបានសម្លាប់ប្រជាជនមូលដ្ឋានចាស់អស់ចំនួនជាង១លាននាក់ ។ ប្រជាជនមូលដ្ឋានចាស់នេះគឺជាប្រជាជនដែលធ្លាប់ហៅថា «ពួកសាសន៍ស្បែកក្រហម» ។ សព្វថ្ងៃនេះ សហរដ្ឋអាមេរិកបានទទួលស្គាល់ជនទាំងនេះថាជា «ប្រជាជនអាមេរិកាំងដើម» ។

ក្នុងន័យធ្វើឲ្យមនុស្សបាត់បង់ជីវិតដើម្បីក្តាប់អំណាចបញ្ចេញឥទ្ធិពល យើងត្រូវកត់សម្គាល់ជាជំនួយស្មារតីបន្ថែមទៀតថា មហាប្រាសាទស្អឹមស្អៃទាំងអស់នៅក្នុងពិភពលោកសុទ្ធសឹងបានត្រូវមនុស្សលោកកសាងឡើងដោយចំណាយអាយុជីវិតរាប់មិនអស់របស់ប្រជាជនដែលចាប់កេណ្ឌទៅជាឈ្លើយបង្ខំឲ្យធ្វើការយ៉ាងទម្ងន់ដោយឥតមានផ្តល់រង្វាន់ជាបៀវត្សរ៍អ្វីសោះឡើយ ។ មហាប្រាសាទទាំងនេះមានប្រាសាទពីរ៉ាមីដនៅប្រទេសអេហ្ស៊ីប, នៅប្រទេសប៉េរូ, នៅប្រទេសម៉ិចស៊ិក, មហាប្រាសាទតាស្ហមាហាល់នៅប្រទេសឥណ្ឌាខាងជើង, មហាប្រាសាទប៉េក្ហ័ននៅប្រទេសភូមា និងមហាប្រាសាទអង្គរវត្តនៅកម្ពុជា ។

ការកាប់សម្លាប់របស់ខ្មែរក្រហមខុសប្លែកពីការកាប់សម្លាប់យ៉ាងរន្ធាលដែលពិភពលោកបានឆ្លងកាត់មកហើយ ។ តាមការពិតការប្រើពាក្យ «ប្រល័យពូជសាសន៍» ដែលប្រែជាពាក្យអង់គ្លេសថា Genocide សម្រាប់សម្គាល់ការកាប់សម្លាប់ដែលខ្មែរក្រហមបានប្រព្រឹត្តឡើងនៅកម្ពុជាមានន័យត្រូវចំពោះតែពួកអន្តោប្រវេសន៍យួន និងជនជាតិភាគតិចចាមនៅកម្ពុជាតែប៉ុណ្ណោះ ។ ពាក្យនេះមានន័យដើមថា «ការកាប់សម្លាប់បំផ្លាញឲ្យអស់នូវសាសន៍ណាមួយឬជាតិណាមួយដោយសាសន៍ណាមួយ

ផ្សេងទៀតដែលមានសាសន៍ឬសាសនាផ្សេងគ្នា» ។

ផ្ទុយទៅវិញ ការកាប់សម្លាប់របស់ខ្មែរក្រហមគឺជាការសម្លាប់ខ្មែរដោយខ្មែរគ្នាឯងដោយឥតរើសមុខ ចាប់ផ្តើមពីអ្នករដ្ឋការ និងនាយទាហានថ្នាក់អ្នកដឹកនាំ បញ្ញវន្ត ដែលបានដាក់អាវុធលើកទង់សជាសញ្ញាចុះចាញ់ទៅហើយ រហូតដល់កម្មករ កសិករ យុវជន យុវនារី និងកុមារតូចៗស្លូតត្រង់ ។ ទីបំផុត ខ្មែរក្រហម «សម្អាតបក្ស» របស់ខ្លួនដោយសម្លាប់សមាជិកបក្ស កម្មាភិបាលជួរដឹកនាំ រហូតដល់ប្រជាជនមូលដ្ឋានរបស់ចលនាខ្មែរក្រហមខ្លួនឯង ។ អ្នករងគ្រោះមួយភាគធំនៅទួលស្លែងគឺជាអតីតកម្មាភិបាលខ្មែរក្រហមជួរដឹកនាំដែលបានបម្រើ ប៉ុល ពត យ៉ាងស្មោះត្រង់ តែទីបំផុតត្រូវ ប៉ុល ពត ចោទថាជា «អ្នកក្បត់បក្ស» ជា «អ្នកសេរីនិយម» ចាប់បញ្ជូនទៅទួលស្លែង ដាក់គុកធ្វើទារុណកម្មយកចម្លើយ រួចសម្លាប់ចោលយ៉ាងវេទនា ។ បដិវត្តន៍ខ្មែរក្រហមគឺសម្លាប់ដើម្បីសម្លាប់ ។

មិនតែប៉ុណ្ណោះ ចលនាខ្មែរក្រហមទាំងមូលជាចលនាបំផ្លាញខ្លួនឯង រំលាយកម្ពុជា ។ អ្វីៗដែលខ្មែរក្រហមបានលត់ដំកសាងឡើងក្នុងនាមអង្គការបដិវត្តន៍កម្ពុជា សុទ្ធសឹងមានបង្កប់ «គន្លឹះ» សម្រាប់ធ្វើឲ្យផ្ទុះបំផ្លាញខ្លួនឯង ។ ទំនប់ទឹក ភ្លឺស្រែ ប្រឡាយទឹកស្ពាន ថ្នល់ សុទ្ធតែជាការសង់ខុសពីរបៀបវិស្វកម្ម សំណង់ទប់ទឹកបង្ហូរទឹកខុសទំនងសង់ឡើងគ្រាន់តែសម្រាប់តែឲ្យបាក់ជន់លិចស្រូវ ពោត សណ្តែក និងភោគផលដំណាំឯទៀតដែលប្រជាជនបានដាំដុះ រហូតទៅដល់ត្រៀមពង្រីងទឹកបំបាក់ទំនប់ឲ្យខូចចោលដើម្បីបង្កើតការរាំងស្ងួត ខ្វះទឹក បង្អត់បាយប្រជាជន ។

នៅពេលថ្មីៗនេះ បញ្ញវន្តម្នាក់ជាថ្នាក់ដឹកនាំដែលមានឥទ្ធិពលក្នុងនយោបាយកម្ពុជា បានពន្យល់ប្រាប់ខ្ញុំយ៉ាងម៉ឺងម៉ាត់ ហើយតឹងសរសៃកថា ឆ្អឹងនៅទួលស្លែងត្រូវតែយកទៅដុតធ្វើបុណ្យដើម្បីរំដោះព្រលឹងអ្នករងគ្រោះទាំងនោះឲ្យទៅចាប់ជាតិថ្មី ។ បើយើងមិនដុតឆ្អឹងទាំងនោះទេ ព្រលឹងនៃអ្នកទាំងនោះនឹងនៅវិលវល់ទៅចាប់ជាតិឯណាទៀតមិនបានឡើយ ។ បញ្ញវន្តរូបនេះបានបន្ថែមថា នេះគឺជាទំនៀមទម្លាប់ពុទ្ធសាសនាខ្មែរ ហើយគេមិនត្រូវទុកឆ្អឹងទាំងនេះឲ្យនៅព្យួររណេងរណោង ឬគរគ្នាធ្វើជាដែនទីស្រុកខ្មែរនោះទេ ។ លុះខ្ញុំជម្រាបលោកថា យើងគួរតែរក្សាអដ្ឋិធាតុទាំងនេះទុកជាភស្តុតាងប្រវត្តិសាស្ត្រខ្មែរ បញ្ញវន្តរូបនេះក៏ឡើងមុខក្រហមងាំងហើយចោទសួរខ្ញុំវិញថាៈ «ចុះបើលោកដឹងថាឆ្អឹងណាមួយជាឆ្អឹងម៉ែលោក តើលោកបណ្តោយឲ្យពួកអាអស់នេះព្យួរទុករណេងរណោងចោលទុកមើលជាសាធារណៈទៅទៀត ឬមួយក៏លោកតវ៉ាសុំយកឆ្អឹងម៉ែលោកទៅធ្វើបុណ្យ?» ។ ខ្ញុំទឹមទើមមឹងមាំងឆ្លើយមិនរួច ។

លុះខ្ញុំចង្អុលជម្រាបបញ្ញវន្តថ្នាក់ដឹកនាំនេះថា បើធ្វើដូច្នោះហាក់ដូចជាមានន័យថាយើងប៉ុនប៉ងបំបាត់ភស្តុតាងប្រវត្តិសាស្ត្រស្តីអំពីការកាប់សម្លាប់យ៉ាងរង្គាលនៅកម្ពុជា ។ បញ្ញវន្តរូបនេះក៏បញ្ជាក់ប្រាប់វិញថា គេគ្រាន់តែដុតឆ្អឹងទេ ។ របស់ឯទៀតដូចជាខ្នោះឃ្នាង ខោអាវ ស្នាមឈាមនៅលើជញ្ជាំង ត្រូវទុកទាំងអស់ដោយធ្វើឆ្អឹងប្លាស្ទិកដាក់កន្លែងដើមជំនួសឆ្អឹងមែនទែន ។

ខ្ញុំនៅតែសង្ស័យមិនអស់ចិត្តខ្លាចថ្ងៃក្រោយខ្មែរយើងក្តីពិភពលោកក្តី នាំគ្នាឈប់ជឿថាមានការសម្លាប់នេះមែន ខ្ញុំក៏សួរលោកបញ្ញវន្តតទៅទៀតថា ចុះធ្វើម្តេចឲ្យខ្មែរយើងនៅចងចាំអំពីព្រឹត្តិការណ៍នេះតជានិច្ចទៅថ្ងៃក្រោយ ដើម្បីជាការរាំងស្កាត់កុំឲ្យខ្មែរក្រហមត្រឡប់មកវិញបានរួចសម្លាប់ទាំងឯកឧត្តម ទាំងខ្ញុំ បញ្ញវន្តរូបនេះក៏និយាយសង្ក្រុកដាក់ខ្ញុំខ្លាំងៗដូចជាការធ្វើសុន្ទរកថាឥតមេក្រូថាៈ «ខ្មែរភ្លេច? ខ្មែរមិនភ្លេចជាដាច់ខាត! ខ្មែរក្រហមត្រឡប់មកវិញមិនបានជាដាច់ខាត!» ។

អ្នកស្រីពាណិជ្ជករម្នាក់បានឆ្លើយប្រាប់ខ្ញុំវិញថា រឿងនេះជារឿងឃាតកម្មបំផ្លាញបន្ថែមទៅលើឃាតកម្មដែលមានមកហើយ ។

ប៉ុន្តែសាធារណជនភាគច្រើនដែលខ្ញុំបានពិភាក្សាជាមួយអំពីបញ្ហាទួលស្លែង និងព្រះភិក្ខុសង្ឃ បានបញ្ចេញប្រតិកម្មយ៉ាងខ្លាំងប្រឆាំងនឹងការប៉ុនប៉ងដុតបូជាធ្វើបុណ្យអដ្ឋិធាតុនៅទួលស្លែង រហូតដល់មានការធ្វើការកត់សម្គាល់ខ្លាំងៗខ្លះដែលខ្ញុំមិនអាចសរសេរផ្សាយជាសាធារណៈបាន ។

ជាទូទៅ សាធារណជនខ្មែរចាត់ទុកសារមន្ទីរទួលស្លែងនិងឆ្អឹងអ្នករងគ្រោះទាំងឡាយក្នុងរបបខ្មែរក្រហមដែលបានរក្សាទុកមកជាភស្តុតាងប្រវត្តិសាស្ត្ររបស់កម្ពុជាទាំងមូល តំណាងការឈឺចុកចាប់យ៉ាងទារុណនៃប្រជាជនទូទាំងប្រទេស ។ សាធារណជនភាគច្រើនយល់ថា រាជរដ្ឋាភិបាលគ្មានច្បាប់ គ្មានសិទ្ធិសម្រេចជា

អត្ថនោម័តិយកវត្ថុប្រវត្តិសាស្ត្រនេះទៅដុតបូជាធ្វើបុណ្យដោយសំអាងទៅលើជំនឿផ្តេសផ្តាសក្រៅសាសនាជាតិឡើយ ។ ភាគច្រើនចោទថានេះជាអំពើបំបាត់ភ័ស្តុតាងនៃឃាតកម្មមួយដ៏ធំធេង ។

មានអ្នកខ្លះបានចោទថា គម្រោងការនេះសឲ្យឃើញមានការប៉ុនប៉ងផ្លាស់ប្តូរប្រវត្តិសាស្ត្រកម្ពុជា ។ អ្នកខ្លះទៀតចោទបន្ថែមថាច្បាស់ជាមានការរៀបចំគម្រោងការនយោបាយថ្មីណាមួយប៉ុនប៉ងបិទមុខប្រជាជនខ្មែរបិទភ្នែកមតិអន្តរជាតិ ហើយទីបំផុតនឹងមានការបញ្ចូលខ្មែរក្រហមឲ្យត្រឡប់មកត្រួតត្រាធ្វើទារុណកម្មលើប្រជាជនដដែលដូចមុន ដោយប្រើលេសយ៉ាងគួរអាម៉ាស់ណាមួយថ្មីទៀត ។ មានអ្នកខ្លះទៀតបានចោទថាធ្វើនេះគឺដើម្បីបំភ្លេចកុំឲ្យគេយកភ័ស្តុតាងយ៉ាងស្កឹមស្កៃទាំងនេះទៅប្តឹងតវ៉ាទារយកជំងឺចិត្តពីមេដឹកនាំខ្មែរក្រហមលើប្រាក់រាប់រយលានដុល្លារដែលពួកអស់ទាំងនេះបានដាក់នៅធនាគារដោយការលក់ត្បូងនិងព្រៃឈើ ។ ប្រជាជនមួយចំនួនតូចភាគច្រើនជានិស្សិតបាននិយាយប្រាប់ខ្ញុំថាគេបម្រុងដុតឆ្អឹងនៅទួលស្លែងចោលដើម្បីបំបាត់ភ័ស្តុតាង រួចបំបាត់ចោលនូវការខំប្រឹងប្រែងទាំងឡាយដែលរៀបចំយកពួកមេដឹកនាំខ្មែរក្រហមទៅឲ្យតុលាការអន្តរជាតិជំនុំជម្រះទោស ។

អ្នកខ្លះទៀតបាននិយាយថា ការប្រញាប់ប្រញាល់ដុតឆ្អឹងនៅទួលស្លែងពីព្រោះអ្នកដើមគំនិតមានប្រឡាក់ប្រឡូសទាក់ទិននឹងខ្មែរក្រហមដែរ ហើយគេប្រញាប់បំបាត់ភ័ស្តុតាងទាំងនេះឲ្យបានមុនការិយាល័យស៊ើបអង្កេតឯកសារអាមេរិកាំងនិងអង្គការសហប្រជាជាតិស្នើយកពួកមេខ្មែរក្រហមទៅជូនតុលាការអន្តរជាតិជំនុំជម្រះទោស ។

តែភាគច្រើនលើសលប់នៃប្រជាជនខ្មែរដែលខ្ញុំបានលើកបញ្ហាទួលស្លែងទៅពិភាក្សាជាមួយបានមានយោបល់ថា សព្វថ្ងៃរាជរដ្ឋាភិបាលកម្ពុជាកំពុងបំពេញការសំខាន់ៗក្នុងការកសាងជាតិជាច្រើនណាស់ហើយ ។ ស្ងៀមមិនស្ងៀមទៅជានាំគ្នាគាស់កកាយរឿងនេះ បញ្ឆេះកំហឹងប្រជាជន បំបែកបំបាក់សាមគ្គីភាពជាតិថែមទៀត ។ យើងគួរតែរក្សាទួលស្លែងទុកជាទីសក្ការបូជាដូចដើមតទៅទៀត ។

គួរឲ្យឆ្ងល់ណាស់ថាហេតុដូចម្តេចបានជាខ្មែរដែលជាសាសន៍រម្យទម ធ្លាប់មានចរិតញញឹមប្រិមប្រិយ មានឥរិយាបថទន់ភ្លន់ប្រតិបត្តិព្រះពុទ្ធសាសនាថេរវាទ សន្តិភាពអហិង្សា ធ្លាប់មានធម៌មេត្តា សូម្បីតែអាយុជីវិតសត្វតូចតាចក៏មិនហ៊ានប៉ះពាល់ ធ្លាប់កសាងអរិយធម៌មួយដ៏រុងរឿង ស្រាប់តែខ្មែរបែរជាសាបព្រោះអំពើសម្លាប់រង្គាលបង្ហូរឈាមក្រហមឆ្អៅទូទាំងប្រទេសទៅវិញ ។

បើយើងសិក្សារូបចម្លាក់នៅលើកំផែងជញ្ជាំងប្រាសាទអង្គរវត្ត យើងនឹងឃើញមានចារឹកការទន់ភ្លន់តែចំពោះរូបអប្សរាប៉ុណ្ណោះ ។ ផ្ទុយទៅវិញរូបចម្លាក់ស្ទើរតែទាំងអស់សុទ្ធតែនិទានពីរឿងចម្បាំងរាំងជល់យ៉ាងសាហាវៗមានទ័ពសេះ ទ័ពដំរី ប្រយុទ្ធគ្នា ទន្ទ្រាំគ្នាយកចាញ់យកឈ្នះមានទាហាន ជើងគោក ជើងទឹក កាប់ចាក់គ្នានឹងពូថៅ និងលំពែង បាញ់គ្នានឹងស្នា នឹងព្រួញ ។ អ្នកចាញ់ត្រូវបានខ្ទុះច្រមុះ ចោះត្រចៀក ទាញសក់ យកទៅចងស្លាបសេក កៀរបណ្តើរទាំងហ្វូងៗទៅសម្លាប់ចោល ឬទៅធ្វើជាឈ្លើយឲ្យធ្វើការយ៉ាងទម្ងន់មិនខុសគ្នាពីរបបខ្មែរក្រហម ។

រីឯចលនាខ្មែរក្រហមទៀតក៏មិនមែនជាចលនាព្រៃផ្សៃបង្កើតឡើងដោយ «ពួកអាវខ្មៅចោរព្រៃឥតសាសនា» ដោយកំហឹងប្រជាជនវណ្ណៈអធនប៉ុណ្ណោះទេ ។ អ្នកដឹកនាំចលនាខ្មែរក្រហមសុទ្ធសឹងជាបញ្ញវន្តមានសញ្ញាប័ត្រខ្ពស់រហូតដល់ថ្នាក់បណ្ឌិតក៏មានមកពីមហាវិទ្យាល័យបារាំងធ្លាប់ធ្វើជាសាស្ត្រាចារ្យមន្ត្រីជាន់ខ្ពស់ក្នុងរាជរដ្ឋាភិបាល ដូចជា ខៀវ សំផន, ហ៊ូ យន់, ហ៊ូ នឹម, សុន សេន, សាឡុត ស, អៀង សារី, ខៀវ ប៉ុណ្ណារី ជាដើម ។ តាម៉ុក ដែលពួកបស្ចិមប្រទេសខ្លះស្មានថាជាអនក្ខរជន ហើយដែលជាមេឃាតករខ្មែរក្រហមយ៉ាងសាហាវបំផុតមានឈ្មោះដើមថា «ព្រះអាចារ្យជឿន» មកពីស្រុកអង្គតាសោម ខេត្តតាកែវ ធ្លាប់បានបួសជាភិក្ខុសង្ឃយ៉ាងយូរធ្វើជាសាស្ត្រាចារ្យសាលាបាលីយ៉ាងល្បីល្បាញមុននឹងសឹកចូលព្រៃធ្វើថៅកែឈើ លួចឈើយកទៅលក់នៅប្រទេសថៃមុននឹងធ្វើជាខ្មែរក្រហម ។ **ឆាំង សុខ**

## ទ្រឹស្តីម៉ាក្ស-លេនីន

◆ **ការប្រៀបធៀបកំហឹង មិនមែនប្រៀបធៀបកម្លាំងសឹកនិងសេដ្ឋកិច្ចទេ គឺប្រៀបធៀបដោយកម្លាំងមនុស្សនិងស្មារតី គឺគេត្រូវមនុស្សសម្រេចដឹកនាំសេដ្ឋកិច្ច និងដឹកនាំកម្លាំងសឹក។**

(ដកស្រង់ចេញពីសៀវភៅរបស់សមមិត្តញុក សារុន ទំព័រ៦០)

# ការទាមទាររកយុត្តិធម៌សាស្ត្រកម្ពុជាមកវិញ

## គណៈកម្មការស្វែងរកការពិត

### (តពីលេខមុន) ប្រព័ន្ធនៃការទទួលខុសត្រូវ

តាមសម្តីរបស់ ចូស ហ្សាឡាគេត «គោលនយោបាយមួយចំពោះដំណោះស្រាយការរំលោភសិទ្ធិមនុស្សនាអតីតកាលត្រូវមានកម្មវត្ថុជារួមពីរៈ ទប់ស្កាត់ការកើតមានឡើងវិញនៃការរំលោភបែបនេះជាថ្មីម្តងទៀតនិងការជួសជុលនូវការខូចខាតដែលបន្តឡើងដោយការរំលោភបំពានបែបនោះតាមកម្រិតមួយដែលអាចធ្វើទៅបាន» ។ មធ្យោបាយក្នុងការការជួសជុលការរំលោភសិទ្ធិមនុស្សតាមការអនុវត្តកន្លងមកត្រូវជាមួយនឹងប្រភេទមួយក្នុងចំណោមប្រភេទទាំងបីនេះៈ តុលាការអន្តរជាតិ តុលាការក្នុងស្រុក និងគណៈកម្មការស្វែងរកការពិត ។ តុលាការអន្តរជាតិដូចជាតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីត្រូវបានបង្កើតឡើងដោយអង្គការសហប្រជាជាតិ ឬក៏ស្ថាប័នអន្តរជាតិប្រហាក់ប្រហែល ហើយមានចៅក្រមនិងសុភាចារបុរសមកពីបណ្តាប្រទេសផ្សេងៗ ។ តុលាការក្នុងស្រុកដូចជាតុលាការជំនុំជម្រះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅរ៉្វាន់ដានាពេលបច្ចុប្បន្នធ្វើឡើងនៅក្នុងសាលាជម្រះក្តីនៃប្រទេសរបស់ជនជាប់ចោទ ហើយយកច្បាប់ក្នុងស្រុកធ្វើជាមូលដ្ឋាននៃការកាត់សេចក្តី ។ ចំណែកឯគណៈកម្មការស្វែងរកការពិត ដូចជាគណៈកម្មការស្វែងរកការពិតនិងបង្រួបបង្រួមនៅអាហ្វ្រិកខាងត្បូង ផ្តល់នូវវេទិកាមួយដើម្បីស្តាប់រឿងរបស់ជនរងគ្រោះនិងរឿងរបស់ជនឧក្រិដ្ឋដោយពុំមានអំណាចផ្តន្ទាទោសដូចជាតុលាការឡើយ ។




តុលាការអន្តរជាតិនាំយកមកជំនុំជម្រះទោសនូវជនជាប់ចោទពីបទប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងរដែលមានចែងក្នុងច្បាប់អន្តរជាតិនិងធ្វើឲ្យចងចាំព្រឹត្តិការណ៍នៃអំពើហិង្សាដ៏សន្ធឹកសន្ធាប់ ។ លក្ខណៈនៃតុលាការអន្តរជាតិគឺការទទួលខុសត្រូវជាបុគ្គល និងការផ្តន្ទាទោស ។ តុលាការទាំងនេះផ្តោតតែទៅលើអំពើរបស់ឧក្រិដ្ឋជនម្នាក់ៗដែលជានិច្ចកាលជាមេដឹកនាំនយោបាយនិងយោធា (តាមទ្រឹស្តីនៃខ្សែសង្វាក់នៃបទបញ្ជា) និងដាក់ទោសព្រហ្មទណ្ឌមកលើមេដឹកនាំទាំងឡាយណាដែលរកឃើញថាមានទោសដូចដែលខ្លួនធ្លាប់អនុវត្តកន្លងមក ។ ប្រហែលជាចំណុចសំខាន់បំផុតគឺតុលាការអន្តរជាតិជំរុញលើកម្ពស់បទដ្ឋានអន្តរជាតិ ដូចជាការហាមឃាត់អំពើប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលបទដ្ឋានទាំងនេះនឹងអស់តម្លៃប្រសិនបើពុំមានការរំលោភណាមួយត្រូវបានផ្តន្ទាទោសទេនោះ ។ តុលាការនូរិមប៊ឺក តុលាការតូក្យូ និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី និងរ៉្វាន់ដាទាំងអស់ គឺជាឧទាហរណ៍នៃការជំនុំជម្រះក្តីជាអន្តរជាតិ ។ គោលបំណងនៃការជំនុំជម្រះក្តីគឺជាសំណងដល់ជនរងគ្រោះ ចំណែកឯការកសាងសង្គមឡើងវិញ ការធ្វើឲ្យជនឧក្រិដ្ឋមានទីតិសម្បទាឡើងវិញ និងការកែលម្អតវិយាបថ គឺគ្រាន់តែជាផលប្រយោលប៉ុណ្ណោះ ។

ការទិតៀនតុលាការអន្តរជាតិជាញឹកញាប់បំផុតចាប់

ផ្តើមដោយការតវ៉ាថា តុលាការនេះបង្កើតទម្រង់មួយនៃ «យុត្តិធម៌សម្រាប់អ្នកឈ្នះ» គឺមានន័យថា តុលាការនេះមានភាពមិនលម្អៀង ហើយក៏មិនអព្យាក្រឹត ។ តុលាការអន្តរជាតិទាមទារឲ្យមានការចំណាយថវិកាដ៏ច្រើនសន្ធឹកសន្ធាប់ ហើយការគាបសង្កត់ផ្នែកហិរញ្ញវត្ថុនិងនយោបាយតែងតែធ្វើឲ្យតុលាការនេះពុំអាចធ្វើការចាប់ខ្លួន ទោះបីជាឧក្រិដ្ឋជនត្រូវបានផ្តន្ទាទោសហើយក៏ដោយ ។ ជាលទ្ធផល អ្នករំលោភសិទ្ធិមនុស្សដែលត្រូវបានចោទប្រកាន់ជាច្រើនត្រូវបានដោះលែងឲ្យរួចខ្លួន




យ៉ាងបំពាន នេះបង្កើតឲ្យមានបញ្ហាទម្លាក់ទោសដល់អ្នកដទៃ និងភាពរួចទោសទៅវិញ ។ ការផ្តោតទៅលើឧក្រិដ្ឋជនម្នាក់ៗរបស់តុលាការធ្វើឲ្យតុលាការពុំអាចគិតគូរអំពីកត្តាស្មុគស្មាញទាំងអស់ដែលអាចមានចំណែកក្នុងការប្រព្រឹត្តអំពើហិង្សាទៅលើហ្វូងមនុស្ស ហើយដូច្នេះពុំអាចផ្តោតទៅលើការដោះស្រាយឧក្រិដ្ឋកម្មបែបនេះបានពេញលេញឡើយ ។

ទោះបីជាតុលាការអន្តរជាតិអាចមានប្រសិទ្ធភាពក្នុងការសងការខូចខាត ការផ្តន្ទាទោស និងទប់ស្កាត់ ព្រោះតុលាការនេះមានអំណាចក្នុងការផ្តន្ទាទោសដែលមានកម្រិតធ្ងន់ធ្ងរក៏ដោយ ក៏តុលាការនេះពុំរួមចំណែកបានច្រើនក្នុងការស្តារឲ្យសង្គមមានភាពប្រសើរឡើងវិញ ដែលជាបញ្ហាដ៏សំខាន់ចំពោះការងើបពីអំពើហិង្សាទ្រង់ទ្រាយធំដូចគណៈកម្មការស្វែងរកការពិតឡើយ ។ តុលាការព្រហ្មទណ្ឌអន្តរជាតិអាចដាក់ឲ្យមានការគំរាមកំហែងដល់របនាសម្ព័ន្ធប្រជាធិបតេយ្យដែលនៅផុយស្រួយក្នុងបណ្តាប្រទេសដែលកំពុងតែបោះជំហានចេញពីរបបដែលមានការគាបសង្កត់មួយ ។ ករណីដោយឡែកនៃប្រទេសកម្ពុជា ឧក្រិដ្ឋកម្មរបស់ខ្មែរក្រហមគឺមានទំហំធំធេងណាស់ ដែលការទាមទារនេះធ្វើឲ្យមានការចំណាយដ៏ច្រើនលើសលប់សម្រាប់តុលាការឯករាជ្យមួយពិនិត្យគ្រប់ហេតុការណ៍ដែលកើតមានឡើងជុំវិញរបបនោះ ។

សំខាន់បំផុតនោះតុលាការ «សន្មតជាមុនថាឧក្រិដ្ឋជនដែលត្រូវផ្តន្ទាទោសគឺសុទ្ធតែមានសេរីភាពក្នុងការជ្រើសរើសថាគួរប្រព្រឹត្តឬមិនប្រព្រឹត្ត» ។ ចំពោះប្រទេសកម្ពុជា ឧក្រិដ្ឋជនដែលពុំមែនជាមេដឹកនាំកំពូលត្រូវបានរបបខ្មែរក្រហមធ្វើឲ្យមានសេចក្តីភ័យខ្លាចយ៉ាងខ្លាំងថែមទាំងត្រូវបានដុសខាត់ខួរក្បាលដោយរបបខ្មែរក្រហមដែលធ្វើឲ្យពួកគេពុំមានផ្លូវជ្រើសរើសទៀតឡើយ ។

ដូចតុលាការអន្តរជាតិដែរ តុលាការក្នុងស្រុកតែងតែបកស្រាយបទដ្ឋានសិទ្ធិមនុស្ស ។ តុលាការក្នុងស្រុកកំណត់ថាជនណាជាអ្នករំលោភបំពានសិទ្ធិមនុស្ស មានតួនាទីអនុវត្តច្បាប់ក្នុងស្រុកដែលជនល្មើសបានរំលោភបំពាន ហើយផ្តន្ទាទោសជនទាំងនោះ ។ តុលាការក្នុងស្រុកផ្តោតទៅលើឧក្រិដ្ឋជននិងអនុវត្តគោលការណ៍ទទួលខុសត្រូវជាបុគ្គល ។ តុលាការនេះគឺស្ថិតក្នុងប្រព័ន្ធតុលាការក្នុងស្រុកតែម្តង ហើយទទួលបានអំណាចពីច្បាប់បញ្ញត្តិ ដែលមានពីមុនមកនៅក្នុងប្រទេស ។ ជាលទ្ធផលតុលាការក្នុងស្រុកអាចជួយបង្កើតឡើងវិញនូវភាពស្របច្បាប់នៃប្រព័ន្ធច្បាប់ក្នុងស្រុកបន្ទាប់ពីមានអំពើហិង្សាទ្រង់ទ្រាយធំមួយ ។

ទោះជាយ៉ាងនេះក្តី តុលាការក្នុងស្រុកក៏ប្រឈមមុខនឹង

បញ្ហាដូចគ្នានឹងតុលាការអន្តរជាតិដែរ  គឺរួមបញ្ចូលទាំងលទ្ធភាពពុំគ្រប់គ្រាន់របស់វាក្នុងការកាត់ទោសជនដែលដល់ច្រើនក្នុងរបបខ្មែរក្រហម ។  បញ្ហានេះកាន់តែធ្ងន់ធ្ងរថែមទៀតដោយប្រព័ន្ធតុលាការក្នុងប្រទេសកម្ពុជាក៏ដូចជាបណ្តាប្រទេសផ្សេងៗទៀតដែលទើបរួចផុតពីអំពើហិង្សាដ៏ឃោរឃៅក្នុងទ្រង់ទ្រាយយ៉ាងធំ  ហើយខិតខំប្រឹងងើបឈរយ៉ាងយឺតចេញពីការបំផ្លិចបំផ្លាញគ្រប់វិស័យសឹងតែខ្ទេចខ្ទីគ្មានសល់អ្វី ។ តុលាការក្នុងស្រុកពឹងផ្អែកយ៉ាងច្បាស់ក្រឡែតទៅលើវិស័យច្បាប់មួយដែលដំណើរការល្អនិងមិនលម្អៀង ។ កម្ពុជាពុំដែលបានស្គាល់តុលាការឯករាជ្យនិងមិនលម្អៀងម្តងណាឡើយ  ហើយអ្នកជំនាញច្បាប់ជាច្រើនត្រូវបានខ្មែរក្រហមសម្លាប់ ។  ការហ៊ឹកហ៊ឺនផ្នែកច្បាប់បានចាប់ផ្តើមក្នុងប្រទេសកម្ពុជា  ប៉ុន្តែតុលាការដ៏ក្មេងខ្ចីនេះពុំទាន់មានឯករាជ្យភាព  ឬបទពិសោធន៍ដែលត្រូវការចាំបាច់ក្នុងការកាត់ទោសខ្មែរក្រហមដែលអាចទទួលរងឥទ្ធិពលនយោបាយនិងមានការបម្រូងបម្រាស់ ។  ក្នុងការសម្តែងឡើងជាឯកច្ឆ័នដែលធ្វើឲ្យមានការចាប់អារម្មណ៍ជាខ្លាំង  អ្នកដែលត្រូវបានសម្ភាសគ្រប់គ្នាថ្លែងឲ្យដឹងថា តុលាការពុំអាចប្រព្រឹត្តទៅក្នុងប្រទេសកម្ពុជាបានទេ ពីព្រោះតុលាការកម្ពុជាពុករលួយហើយខ្សោយណាស់ ។

លទ្ធភាពមួយទៀតគឺតុលាការនៅក្នុងប្រទេសផ្សេង ។ នៅពេលដែលសហគមន៍អន្តរជាតិពោរពេញដោយក្តីសង្ឃឹមថា ប៉ុល  ពត  នឹងត្រូវបានចាប់ខ្លួននៅរដូវក្តៅឆ្នាំ១៩៩៧ សំណើបត្យាប័នទៅកាន់ប្រទេសកាណាដាទទួលបាននូវការពេញចិត្តជាទូទៅ ។  នៅក្នុងប្រទេសកាណាដា  ប៉ុល  ពត  អាចត្រូវបានកាត់ទោសដោយច្បាប់កាណាដាដែលអនុញ្ញាតយ៉ាងច្បាស់ឲ្យមានដែនសមត្ថកិច្ចសកលក្នុងការជំនុំជម្រះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ។ មរណភាពរបស់  ប៉ុល  ពត  បានបញ្ចប់ការប៉ាន់ស្មានទាំងនេះប៉ុន្តែមេដឹកនាំខ្មែរក្រហមផ្សេងទៀតប្រហែលជាប្រឈមមុខនឹងការកាត់ទោសបែបនេះ ។

ជម្រើសចុងក្រោយគឺគណៈកម្មការស្វែងរកការពិត ។ គណៈកម្មការស្វែងរកការពិតអាចប្រមូលនិងផ្សព្វផ្សាយឯកសារប្រវត្តិសាស្ត្រដែលមានលក្ខណៈឯករាជ្យនិងមានភាពពេញលេញនៃការរំលោភបំពានសិទ្ធិមនុស្សក្នុងប្រទេសណាមួយ  គឺគណៈកម្មការនេះបំពេញនាទីស្វែងយល់ដឹងហេតុការណ៍ដែលផ្សេងពីនាទីរបស់តុលាការ ។ ឯកសារនេះត្រូវបានធ្វើឡើងដើម្បីបម្រើទាំងគោលដៅបង្ការទុកជាមុន  និងគោលដៅកែលម្អស្ថាបនាសង្គមជាតិឡើងវិញគឺ  ដោយជួយធ្វើឲ្យសង្គមបានរៀនសូត្រពីកំហុសនាអតីតកាលរបស់ខ្លួន ជួយបង្ការការកើតសាឡើងវិញនៃប្រវត្តិសាស្ត្រ  និងការបដិសេធឧក្រិដ្ឋកម្មដែលកើតឡើងក្នុងអតីតកាល ។  គណៈកម្មការស្វែងរកការពិតជាទូទៅផ្តោតទៅលើជនរងគ្រោះ  គឺគណៈកម្មការទាំងនេះពិនិត្យជុំវិញរឿងរ៉ាវរបស់ជនរងគ្រោះច្រើនជាងចម្លើយរបស់ជនល្មើស ។  គោលបំណងផ្នែកចិត្តសាស្ត្រនៃគណៈកម្មការស្វែងរកការពិតគឺការទទួលស្គាល់ជាផ្លូវការនៃការពិតនិងការជ្រួតជ្រាបក្នុងផ្នត់គំនិតរបស់ប្រជាជននាពេលបន្ទាប់របស់វា ។

គណៈកម្មការស្វែងរកការពិតពុំមានអំណាចកាត់ទោសនិងពុំបំពេញតួនាទីដូចតុលាការដែលអាចប្រកាសអំពីទោសកំហុសនោះទេ ។ គណៈកម្មការស្វែងរកការពិតកាន់តែមានលក្ខណៈលំបាកក្នុងការឲ្យនិយមន័យជាងតុលាការក្នុងស្រុកនិងតុលាការអន្តរជាតិពីព្រោះថាគណៈកម្មការស្វែងរកការពិតមាននិន្នាការទៅរកភាពអាចបត់បែនបានច្រើនជាង  និងសម្របទៅនឹងសេចក្តីត្រូវការនិងការចាំបាច់នៃស្ថានភាពនីមួយៗ ។ លោក ព្រីស៊ីឡា ហេណើ បានគូសបញ្ជាក់ខ្លីៗអំពីលក្ខណៈទូទៅ៤យ៉ាងរបស់គណៈកម្មការស្វែងរកការពិតៈ  ការផ្តោតទៅលើអតីតកាល  ការប៉ុនប៉ងផ្តល់នូវរូបភាពធំទូលំទូលាយមួយអំពីការរំលោភបំពានច្រើនជាងការសង្កត់ធ្ងន់ទៅលើព្រឹត្តិការណ៍ជាច់ដោយឡែកនីមួយៗមានអាណត្តិមួយដែលមានកម្រិតនិងបានកំណត់ជាមុនច្បាស់លាស់  និងមានអំណាចអនុញ្ញាតឲ្យទទួលបានព័ត៌មាននិងសន្តិសុខច្រើនជាង ។  របាយការណ៍ដែលត្រូវបានធ្វើឡើងដោយគណៈកម្មការនេះកម្រនឹងនាំទៅដល់ការកាត់ទោសដោយតុលាការណាស់ ។  គណៈកម្មការស្វែងរកការពិតមានគុណសម្បត្តិត្រង់ថាអនុញ្ញាតឲ្យមានការចូលរួមច្រើននិងមានគុណវិបត្តិត្រង់គណៈកម្មការនេះខ្វះលទ្ធភាពក្នុងការជំរុញការអនុវត្តសេចក្តីសម្រេចរបស់ខ្លួន ។ រដ្ឋាភិបាលថ្មី អង្គការតំបន់ ឬអង្គការសហប្រជាជាតិអាចបង្កើតគណៈកម្មការស្វែងរកការពិតមួយ ។

ការទិតៀនយ៉ាងជាក់ស្តែងបំផុតចំពោះគណៈកម្មការស្វែងរកការពិតគឺពាក់ព័ន្ធនឹងការពុំមានអំណាចគ្រប់គ្រាន់ក្នុងការផ្តន្ទាទោស ។  ប៉ុន្តែនេះអាស្រ័យទៅលើគណៈកម្មការនីមួយៗ  និង

និយមន័យនៃការផ្តន្ទាទោសរបស់មនុស្សម្នាក់ ។ អំណាចរបស់គណៈកម្មការគឺជាប់ទាក់ទងជាមួយនឹងទណ្ឌកម្មដែលពុំមានលក្ខណៈដូចការដែលបានធ្វើជាប្រពៃណី ឧទាហរណ៍សេចក្តីអៀនខ្មាស និងការបណ្តេញចេញពីសហគមន៍របស់ខ្លួន ។ ទម្រង់នៃការផ្តន្ទាទោសនេះអាចមានអំណាចដូចទណ្ឌកម្ម ព្រហ្មទណ្ឌក្នុងការលើកស្ទួយតម្លៃវិធានច្បាប់ខណៈដែលវាជំរុញឲ្យមានការចូលរួមដោយចិត្តបរិសុទ្ធពីសំណាក់ជនឧក្រិដ្ឋ ។ ទោះបីជាយ៉ាងនេះក្តី គណៈកម្មការអាចបង្កឲ្យមានបញ្ហាលើនីតិវិធីត្រឹមត្រូវដោយសារថាគណៈកម្មការទាំងនេះបង្ហាញឈ្មោះ និងផ្តន្ទាទោសជនទាំងឡាយណាដែលរកឃើញថាមានទោស ប៉ុន្តែតែងតែពុំបានបំពេញតម្រូវការនៃតុលាការមួយទេដែលជាផលវិបាកមួយដែលបង្ហាញអំពីភាពពុំគ្រប់គ្រាន់សម្រាប់ជនរងគ្រោះនិងអាចត្រូវបានចោទប្រកាន់ថារំលោភបំពានសិទ្ធិអ្នកដែលត្រូវបានចោទប្រកាន់ ។

ដោយផ្អែកទៅលើសមត្ថភាពដែលមានកម្រិតរបស់តុលាការក្នុងស្រុករបស់កម្ពុជា គណៈកម្មការស្វែងរកការពិត ឬតុលាការអន្តរជាតិ គឺជាយន្តការនៃការដាក់ឲ្យទទួលខុសត្រូវដ៏សមស្របបំផុត ។ ការរំលោភបំពានសិទ្ធិមនុស្សដ៏សាហាវឃោរឃៅរបស់ខ្មែរក្រហមត្រូវតែយកមកពិនិត្យពិចារណានិងបង្ហាញឲ្យបានដឹងឮ ។ ទោះបីជាយ៉ាងនេះក្តី ភាពតានតឹងរវាង «ការកិច្ចកាត់ទោស» ដើម្បីធ្វើឲ្យជនរងគ្រោះអស់ការសង្ស័យ និងការលើកស្ទួយច្បាប់ព្រហ្មទណ្ឌអន្តរជាតិជាមួយសេចក្តីត្រូវការធ្វើឲ្យមានតុល្យភាពរវាងការទទួលខុសត្រូវជាមួយនឹងភាពផុយស្រួយនៃប្រជាធិបតេយ្យថ្មីថ្មោង គឺមានលក្ខណៈសាំញ៉ាំខ្លាំងណាស់ ។ ខណៈដែលអ្នកប្រាជ្ញច្បាប់អន្តរជាតិលើកឡើងថាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ត្រូវតែផ្តន្ទាទោសតាមច្បាប់ វាជាការសំខាន់ដែលត្រូវចងចាំថា តុលាការនិងគណៈកម្មការស្វែងរកការពិតពុំមែនមានលក្ខណៈដាច់ដោយឡែកពីគ្នាយ៉ាងដាច់ខាតនោះឡើយ ។ ក្នុងករណីប្រទេសកម្ពុជា គណៈកម្មការស្វែងរកការពិតចាំបាច់សម្រាប់បង្ហាញឲ្យឃើញរូបភាពនៃប្រវត្តិសាស្ត្រកម្ពុជាពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ដែលតុលាការតែឯងពុំអាចដឹងបាន ។ គណៈកម្មការស្វែងរកការពិតជាមួយនឹងការចោទប្រកាន់ដោយមានដែនកំណត់អាចជាវិធីមួយដ៏មានប្រសិទ្ធភាពសម្រាប់ដោះស្រាយឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម ។

## ប្រធានបទ

ប្រធានបទចំនួន៧បានលើកឡើងនៅពេលដែលការសម្ភាសត្រូវបានធ្វើឡើង ។ ដំបូងបំផុតប្រជារាស្ត្រកម្ពុជាចង់បានសន្តិភាព ។ បន្ទាប់ពីសង្គ្រាមជាច្រើនទសវត្សរ៍ អ្នកដែលត្រូវបានសម្ភាសជាច្រើននឹងមិនគាំទ្រឲ្យមានតុលាការទេប្រសិនបើវានាំទៅរកអស្ថិរភាពនិងភាពជ្រួលច្របល់ចលាចលតទៅទៀត ។ ទី២ អ្នកដែលបានផ្តល់បទសម្ភាសន៍ចង់ដឹងអំពីការពិតដ៏ពេញលេញអំពីសម័យកាលខ្មែរក្រហម ។ របបខ្មែរក្រហមមានភាពសម្ងាត់រហូតទាល់តែប្រជាជនកម្ពុជាជាច្រើនពុំដឹងថាចុងក្រោយនរណាជាអ្នកទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍ ហេតុការណ៍ទាំងនេះត្រូវតែបានបង្កើតឡើងដើម្បីឲ្យប្រជាជនកម្ពុជាអាចទុកអតីតកាលនៅពីក្រោយខ្នងរបស់ខ្លួន ។ ទី៣ ជាសំណួរអំពីការទទួលខុសត្រូវនៃឧក្រិដ្ឋកម្មហិង្សាដែលបានប្រព្រឹត្តឡើងក្រោមបញ្ជា ឬការបង្ខិតបង្ខំដែលត្រូវបានលើកឡើងមកសំអាងជាបន្តបន្ទាប់ ។ ទី៤ អ្នកដែលបានផ្តល់បទសម្ភាសន៍ចង់ដឹងថា តើនរណានៅពីក្រោយខ្នងខ្មែរក្រហម ពោលគឺជនណាឬប្រទេសណាដែលគាំទ្ររបបនោះដោយផ្ទាល់ឬដោយប្រយោលក្តី ។ ទី៥ ពាក់ព័ន្ធនឹងបញ្ហាលើកលែងទោសអ្នកដែលបានផ្តល់បទសម្ភាសន៍បានផ្តល់នូវគំនិតផ្សេងៗគ្នា ។ មួយចំនួនផ្អែកទៅលើព្រះពុទ្ធសាសនានិងការផ្សះផ្សាជាតិបានស្នើឲ្យមានការអត់ឱនទោស ។ មួយចំនួនទៀតដែលយល់ថាឧក្រិដ្ឋជននោះសាហាវយង់ឃ្នងណាស់ ជឿថាខ្មែរក្រហមត្រូវតែផ្តន្ទាទោស ។ ទី៦ នីតិរដ្ឋត្រូវតែបានបង្កើតឡើងនៅលើទឹកដីអង្គរ ។ ចុងបញ្ចប់ ការអប់រំមានតម្លៃជាអាយុជីវិតមិនអាចប្រកែកបានសម្រាប់ប្រទេសកម្ពុជាដើម្បីធ្វើដំណើរទៅកាន់គោលដៅដែលបានលើកឡើងរបស់ខ្លួន ។

**(នៅមានត)** **ចាយ៉ា រ៉ាមជី**

## សេចក្តីកែតម្រូវ

ទស្សនាវដ្តីស្វែងរកការពិតលេខ៦ ទំព័រទី៣២ អត្ថបទដែលមានចំណងជើងថា «ការទាមទារប្រវត្តិសាស្ត្រកម្ពុជាមកវិញ» ក្នុង «ផ្នែកប្រវត្តិសាស្ត្រ» សូមកែតម្រូវមកជា «ផ្នែកវេទិកាពិភាក្សាជាសាធារណៈ» វិញ ។

# ប្រវត្តិរណ្តៅសាកសពក្រោយគុកទួលស្លែង
## កិច្ចខិតខំប្រឹងប្រែងរបស់គ្រួសារជនរងគ្រោះជនជាតិអាមេរិកាំង

លោក ជ័យ សុភារ៉ា អាយុ៥១ឆ្នាំ បច្ចុប្បន្នជាប្រធានសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង បានបញ្ជាក់ថា ការគាស់រណ្តៅសាកសពនាពេលថ្មីៗកន្លងមក នៅជាប់របងទួលស្លែងប៉ែកខាងលិច ពិតជាមានការជាប់ពាក់ព័ន្ធទៅនឹងអ្វីដែលកើតឡើងនៅក្នុងសារមន្ទីរជាតិទួលស្លែង ។

លោក សុភារ៉ា ជាអ្នកនាំភ្ញៀវនៅសារមន្ទីរទួលស្លែងក្នុងចន្លោះឆ្នាំ១៩៧៩-៨០ ពេលដែលរដ្ឋ (សាធារណរដ្ឋប្រជាមានិតកម្ពុជា) បានបង្កើតតុលាការប្រជាជនមួយដើម្បីកាត់ទោសរបបខ្មែរក្រហម ហើយពេលនោះក៏មានគណៈប្រតិភូជាច្រើនចូលរួមជាពិសេសមកពីប្រទេសសង្គមនិយម ។

បន្ទាប់មក ក្រុមរបស់លោក ជ័យ សុភារ៉ា បានជីករណ្តៅមួយនៅខាងក្រោយរបងទួលស្លែង ព្រោះគាត់ត្រូវបានប្រាប់ដោយទាហានម្នាក់ដែលអះអាងថាខ្លួនបានរួចផុតពីមន្ទីរស-២១ នៅក្រោយថ្ងៃរំដោះឆ្នាំ១៩៧៩ ។ ក្រុមរបស់លោក សុភារ៉ា បានជ្រើសរើសមុខផ្ទះលោក អាយស៊ី សុផល ជាជាងដេរស្បែកជើង ដើម្បីជីកបង្ហាញឲ្យគណៈប្រតិភូអន្តរជាតិដែលបានមកចូលរួមក្នុងការកាត់ទោសខ្មែរក្រហមឆ្នាំ១៩៧៩-៨០ បានឃើញ ។ ពេលនោះមិនទាន់មានផ្ទះប្រជាជនសង់នៅខាងក្រោយរបងសារមន្ទីរទួលស្លែងដូចសព្វថ្ងៃនេះទេ ។ មានតែសំណង់បាក់បែកកំពុកកំបាក់ស្ថិតនៅជាប់នឹងរណ្តៅព្រមទាំងមានដើមចេកមួយចំនួនស្ថិតនៅខាងក្រោយសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង(ស-២១) ។

ពេលជីកក៏ស្រាប់ឃើញក្នុងរណ្តៅនោះមានខ្សែចំណងដៃ មានឆ្អឹងលលាដ៍ក្បាលច្រើន... ។ ក្រសួងសុខាភិបាលពេលនោះក៏បានចុះទៅពិនិត្យជាមួយក្រុមរបស់លោក សុភារ៉ា ព្រមទាំងមានការចូលរួមពីគ្រប់សមត្ថកិច្ចទាំងអស់ដែរ ។ ពេលជីករណ្តៅបានបន្តិច ក៏ផ្អាកទៅវិញដោយមានក្លិនស្អុយជះខ្លាំងពេកពីសាកសពក្នុងរណ្តៅដែលបានជីកនោះ ។

លោក សុភារ៉ា បាននិយាយថាគាត់បាននាំយកឆ្អឹងពីកន្លែងផ្សេងៗដូចជាយកមកពីខេត្តស្វាយរៀង ទួលគោកខ្លះ ទៅដាក់នៅក្នុងរណ្តៅនោះមួយចំនួន និងមួយចំនួនទៀតយកទៅលាងស្ងោរដាក់ក្នុងខ្ទះដើម្បីយកមកធ្វើផែនទីប្រទេសកម្ពុជាដែលត្រូវបានតម្រៀបភាគច្រើនជាលលាដ៍ក្បាល និងកំពុងត្រូវបានដាក់បង្ហាញក្នុងបន្ទប់មួយនៃអគារទួលស្លែងសព្វថ្ងៃនេះ ។ ពេលលាងឆ្អឹងទាំងនោះលោក សុភារ៉ា សង្កេតឃើញពិសេសឆ្អឹងលលាដ៍ក្បាលមានជាប់ស្បែកនិងសក់ខ្លះៗផង ។

លោក សុភារ៉ា បាននិយាយបន្តថា ប្រជាជនខ្មែរយើងនៅតែមានការសង្ស័យទៅលើឆ្អឹងលលាដ៍ក្បាលដ៏ធំមួយ និងឆ្អឹងស្មងជើងដ៏វែងថាជាឆ្អឹងរបស់ជនជាតិបរទេស ។ យោងតាមសម្តីរបស់គាត់ ខ្មែរយើងខ្លះក៏មានកម្ពស់ដូចបរទេសដែរ ដូច្នេះរឿងនេះយើងមិនអាចធ្វើការសន្និដ្ឋានបានឡើយ ។ បន្ទាប់មកលោក សុភារ៉ា បានប្រាប់ថាក្នុងមួយរណ្តៅនេះមានសាកសពជាង១០នាក់ ។



រណ្តៅនោះត្រូវបានគ្របដោយកញ្ចក់មួយផ្ទាំងធំរួចក៏បានធ្វើជារបងដាក់ខ្សែព័ទ្ធជុំវិញដើម្បីទុកឲ្យគណៈប្រតិភូនិងអ្នកកាសែតមកទស្សនា ។ គាត់បានអះអាងថាការគ្របកញ្ចក់មួយផ្ទាំងនេះក៏ជាវិធីមួយល្អសម្រាប់ការពារកុំឲ្យសត្វផ្សេងៗស៊ី និងកុំឲ្យដីធ្លាក់ចូល ។

រណ្តៅនេះត្រូវបានលប់ដីវិញបន្ទាប់ពីស្ថានភាពនយោបាយមានការផ្លាស់ប្តូរនៅឆ្នាំ១៩៩៣ ហើយរបងក៏ត្រូវវាយបំបែកអស់ដែរ ។ កញ្ចក់ដែលពាសពីលើ

រណ្ដៅនោះមិនត្រូវបានគាស់ចេញឡើយ នៅពេលដែលលប់ដីពីលើ ។ នៅខែមិថុនា ឆ្នាំ២០០០ម្ចាស់ផ្ទះឈ្មោះ អាយស៊ី សុផល បំណងសង់ផ្ទះក៏គាស់រណ្ដៅនោះរួចក៏យកឆ្អឹងទាំងនោះទៅតម្កល់នៅវត្តទៅ ។ លោក សុភារ៉ា បានបញ្ជាក់ថា អ្នកដែលបានសាងសង់ផ្ទះជុំវិញរបងទួលស្លែងប្រាកដជាមានប៉ះចំលើរណ្ដៅហើយ ។ គាត់ក៏បានបន្ថែមថា អ្នកខ្លះដឹងថាប៉ះចំរណ្ដៅហើយ ប៉ុន្តែចេះតែសម្ងំស្ងៀមដឹងតែពីបន្តការសាងសង់និងរស់នៅតទៅទៀត ។

លោក សុភារ៉ា បានបញ្ជាក់ថា ការរកឃើញរណ្ដៅសាកសពនាពេលថ្មីៗនេះនៅជាប់របងសារមន្ទីរទួលស្លែងជារឿងកន្លងយូរមកហើយ មិនមែនជារឿងថ្មីទេ ។ ម្ចាស់ផ្ទះ ឈ្មោះ អាយស៊ី សុផល ក៏បានដឹងរឿងឆ្អឹងកប់ត្រង់នេះដែរ ។ ទើបតែពេលនេះគាត់បានសម្រេចចិត្តធ្វើផ្ទះពីលើរណ្ដៅនោះ ហើយក៏បានគាស់យកឆ្អឹងទាំងនោះចេញដើម្បីយកទៅធ្វើបុណ្យព្រមទាំងបានបួងសួងនិងខ្ទិសសុំសេចក្ដីសុខសប្បាយក្នុងការសាងសង់ផ្ទះរបស់គាត់ព្រោះនេះជាប្រពៃណីខ្មែរយើង ។

ការគាស់ប៉ះចំរណ្ដៅសាកសពនេះបានលេចឮដល់អ្នកកាសែតអ្នកស្រាវជ្រាវ និងស្ថានទូតបស្ចិមប្រទេសស្ទុះស្ទារឈ្ងូសរមកពិនិត្យមើលរណ្ដៅជនរងគ្រោះនេះ ក៏ប៉ុន្តែអ្វីដែលទាក់ទាញការយកចិត្តទុកដាក់បំផុតលើទំព័រកាសែតជាភាសាបរទេសគឺអំពីឆ្អឹងដែលមានប្រវែងវែងដែលត្រូវបានសង្ស័យថាជាឆ្អឹងជនជាតិអាមេរិកម្នាក់ឈ្មោះ ម៉ៃឃើល ស្កត់ឌីត ។ សារពត៌មានអេភីបានចេញ អត្ថបទមួយក្រោមចំណងជើងថា «រកឃើញរណ្ដៅសាកសពរួមថ្មីមួយៈ អដ្ឋិធាតុមួយចំនួនអាចជាអដ្ឋិធាតុរបស់នាវិកជនជាតិអាមេរិក» ។

អត្ថបទនោះសរសេរថា មន្ត្រីស្ថានទូតអាមេរិក និងអ្នកស្រាវជ្រាវមួយចំនួនបានទៅពិនិត្យមើលរណ្ដៅសាកសពភ្លាមៗបន្ទាប់ពីបានដំណឹងអំពីអដ្ឋិធាតុដ៏វែងចម្លែកដែលគាស់ចេញពីរណ្ដៅនេះ ហើយប្រឹងប្រែងរកដានភ័ស្តុតាងបង្ហាញថាឆ្អឹងវែងៗទាំងនោះគឺជាឆ្អឹងរបស់លោក ម៉ៃឃើល ដែលត្រូវទាហានខ្មែរក្រហម ចាប់បានក្នុងឆ្នាំ១៩៧៦ ក្នុងខណៈដែលលោក ម៉ៃឃើល កំពុងបញ្ជាកប៉ាល់របស់ខ្លួននៅក្នុងឈូងសមុទ្រថៃ ។

លោក ហ៊ីល ប្រ៊ុគ ដែរី ជាមន្ត្រីយោធាសហរដ្ឋអាមេរិកប្រចាំនៅស្ថានទូតអាមេរិកថា «ម៉ៃឃើលស្កតឌីត បានបាត់ខ្លួននៅទីនេះ (កម្ពុជា) ។ យើងមានការចាប់អារម្មណ៍អំពីបញ្ហានេះ» ។ លោក ដែរី បន្ថែមទៀតថា គាត់នឹងស្នើសុំឲ្យយកគំរូឆ្អឹងដែលសង្ស័យមួយចំនួនទៅធ្វើកោសល្យវិច័យនៅមន្ទីរពិសោធន៍របស់យោធាសហរដ្ឋអាមេរិកនៅរដ្ឋហាវ៉ៃ ។

លោក ម៉ៃឃើល កើតនៅឆ្នាំ១៩៨៦ នៅក្រុងឡុងប៊ិច



ជាកូនទី៤ក្នុងគ្រួសារដែលមានកម្រិតជីវភាពខ្ពស់គួរសមនៅភាគខាងត្បូងនៃរដ្ឋកាលីហ្វ័រញ៉ា ។

ក្នុងឆ្នាំ១៩៧៩ ម៉ៃឃើល បានធ្វើដំណើរមកទ្វីបអាស៊ី ពេលនោះ ម៉ៃឃើល បម្រើក្នុងអង្គភាពទាហានជើងទឹកសហរដ្ឋអាមេរិក ឈរជើងនៅជំរំដែនដេតុន ។ ប្រហែល៦ខែ ក្រោយមកក្នុងខែធ្នូ ឆ្នាំ១៩៧៨ គ្រួសាររបស់ ម៉ៃឃើល សង្ស័យថាមានរឿងហេតុមិនល្អកើតឡើងចំពោះ ម៉ៃឃើល ព្រោះបាត់ដំណឹងសូន្យ ។ ពេលនោះគ្រួសាររបស់ ម៉ៃឃើល ទាក់ទងទៅក្រសួងការបរទេសសហរដ្ឋអាមេរិកនៃរដ្ឋបាលរបស់ប្រធានាធិបតី ជីមីខាតធ័រ ។ នៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៩ ក្រសួងការបរទេស

បានទាក់ទងមកគ្រួសាររបស់ ម៉ៃឃើល វិញហើយប្រាប់ថា ម៉ៃឃើល និងមិត្តភក្តិឈ្មោះ គ្រីស ដេលែន បានឡើងជិះកប៉ាល់មួយហើយត្រូវបានចាប់ខ្លួនដោយទាហានខ្មែរក្រហម ។ នៅខែធ្នូ ឆ្នាំ១៩៧៩ លោក ខាល ស្កត់ឌីត បងប្រុសរបស់ ម៉ៃឃើល បានធ្វើដំណើរមកកាន់មូលដ្ឋានកងទ័ពអាកាសឈ្មោះក្លាក នៅប្រជុំកោះហ្វីលីពីន ដើម្បីស្រាវជ្រាវអំពីការបាត់ខ្លួនរបស់ប្អូនប្រុសរបស់ខ្លួន ។ នាល្ងាចមួយក្នុងខណៈដែល ខាល កំពុងមើលពត៌មានទូរទស្សន៍ អេ.ប៊ី.ស៊ី (ទូរទស្សន៍សហរដ្ឋអាមេរិក) ដែលកំពុងបញ្ចាំងរូបភាពគុកទួលស្លែង ខាល បានពើបប្រទះនឹងពត៌មានដ៏រំជួលចិត្តមួយ ។ ខាល រំលឹកថា «ពេលខ្ញុំកំពុងតែតាមដានពត៌មាន នោះស្រាប់តែលោក ជីម ឡូរី ដែលជាអ្នកកំពុងផ្សាយពត៌មាននិយាយអំពីឈ្មោះប្អូនរបស់ខ្ញុំ ម៉ៃឃើល និង គ្រីស ដេឌលែន ហើយពេលនោះខ្ញុំតក់ស្លុតជាខ្លាំងចំពោះពត៌មានដ៏អាក្រក់នេះ» ។ មិនតែប៉ុណ្ណោះគ្រួសារ ម៉ៃឃើល បានទាក់ទងក្រសួងការបរទេសសហរដ្ឋអាមេរិក និងស្នើសុំឯកសារទាក់ទងនឹងព្រឹត្តិការណ៍នេះក្រោមច្បាប់មួយហៅថា ច្បាប់សេរីភាពសារពត៌មានរបស់អាមេរិក ក៏ប៉ុន្តែការស្នើសុំនេះត្រូវបានបដិសេធដែល ខាល ជឿថាដោយសារតែគោលនយោបាយរបស់រដ្ឋបាលប្រធានាធិបតីខាតធ័រ ដែលទទួលស្គាល់របបខ្មែរក្រហមនាពេលនោះ...។ ខាល បញ្ជាក់ថា «រដ្ឋាភិបាលអាមេរិកនិយាយថា ប្រទេសវៀតណាមគឺជាសត្រូវមួយនៅក្នុងបញ្ជី ហើយគ្រួសារខ្ញុំមិនអាចទៅប្រទេសនេះបានទេ» ។ អស់រយៈពេលជាច្រើនឆ្នាំ ខាល បន្តរកច្រកចូលមកប្រទេសកម្ពុជាដើម្បីឲ្យអស់សង្ស័យនិងដឹងជាក់ច្បាស់អំពីជោគវាសនារបស់ ម៉ៃឃើល ជាប្អូនរបស់ខ្លួន ក៏ប៉ុន្តែពុំបានសម្រេចដូចបំណងឡើយ ។ ឪពុករបស់គាត់នៅតែជឿថា ម៉ៃឃើល នៅរស់ដោយមិនព្រមទទួលយកនូវពត៌មានទាំងអម្បាលម៉ាន់ដែលគាត់បានឮ ។

ដល់ឆ្នាំ១៩៨៧ គ្រួសារនេះនៅតែមិនអស់ចិត្ត និងមិនអាចដោះស្រាយនូវចម្ងល់នេះ ។ ក្នុងឆ្នាំដដែលនោះ ខាល កើតជម្ងឺមហារីកម្យ៉ាង ហើយគាត់ចង់ធ្វើអ្វីមួយសម្រាប់ជីវិតចុងក្រោយរបស់គាត់ ។ គាត់បានស្តាប់វិទ្យុឮថា រដ្ឋាភិបាលសហរដ្ឋអាមេរិកពេលនោះពុំអាចរាំងស្កាត់ប្រជាជនអាមេរិកមិនឲ្យទៅប្រទេសទាំងនេះ (កម្ពុជា និងវៀតណាម) តទៅទៀតទេ ។ ខាល បានសរសេរលិខិតជាច្រើនទៅកាន់គណៈប្រតិភូវៀតណាមប្រចាំនៅអង្គការសហប្រជាជាតិ ទីបំផុតគាត់ទទួលបាននូវការអញ្ជើញទៅប្រទេសវៀតណាម ។ ខាល បានជិះយន្តហោះកាត់តាមប្រទេសថៃចូលមកដល់វៀតណាម រួចទាក់ទងកុងស៊ុលកម្ពុជានៅក្រុងហូជីមិញ ។ ទីបំផុតក៏បានសម្រេចដូចបំណង ។



លោក ខាល បានធ្វើដំណើរមកកាន់ក្រុងភ្នំពេញតាមរថយន្តពីក្រុងហូជីមិញ ។ ខាល បានមកមើលគុកទួលស្លែងទាំងអារម្មណ៍ចង់ដឹងយ៉ាងតក់ក្រហល់ពីជោគវាសនារបស់ ម៉ៃឃើល ។ គាត់ស្ទើរតែបាត់បង់វិញ្ញាណនៅពេលដែលកំពុងដើរមើលបន្ទប់

ស្ទួរចម្លើយ និងធ្វើទារុណកម្ម ។ ឆ្លងពីបន្ទប់មួយទៅបន្ទប់មួយ ខាល ហាក់ដូចជាកំពុងបានឃើញពួកខ្មែរក្រហមធ្វើទារុណកម្មប្អូនប្រុសរបស់គាត់នៅនឹងមុខ និងសម្រែកដ៏ឈឺចាប់របស់ប្អូនប្រុសគាត់ ។ ប៉ុន្តែគាត់ព្យាយាមទប់ចិត្តដោយគិតថាព្រលឹងប្អូនរបស់គាត់ពិតជាបានធូរស្បើយពីការឈឺចាប់ដោយវត្តមានរបស់គាត់នៅគុកទួលស្លែងនេះ ។ ខាល បានជួបជាមួយអតីតអ្នកទោស



មួយចំនួនតូចដែលរួចរស់ជីវិតពីគុកដ៏ទុយ៌សនេះ ក្នុងនោះមាន លោក វ៉ាន់ ណាត ។ លោក វ៉ាន់ ណាត ធ្លាប់ប្រាប់ថា «ពេលនោះខ្មែរក្រហមឲ្យគាត់ឆ្លាក់អក្សរក្បែរបង្អួចនៃបន្ទប់តូចៗខណ្ឌដាច់ពីគ្នាដោយជញ្ជាំងឥដ្ឋ ហើយគាត់ក្រឡេកឃើញពួកគេ «ម៉ែឃឹល និងគ្រីស» កំពុងត្រូវបានបណ្តើរទៅបន្ទប់ស្ទួរចម្លើយ» ។ ខាល បានរកឃើញចម្លើយសារភាពរបស់ ម៉ែឃឹល ដែលមិនមានជាច្រើនទំព័រដូចចម្លើយសារភាពដទៃទៀតនោះទេ ។ ម៉ែឃឹល ត្រូវបានពួកខ្មែរក្រហមចោទថាជា «ភ្នាក់ងារសេ.អ៊ី.អា» ។ ខាល បានបដិសេធការចោទប្រកាន់នេះ ។ ខាល និង វ៉ាន់ ណាត ចាប់ផ្តើមគាស់រណ្តៅរកអដ្ឋិធាតុនៅលើទីធ្លាគុកទួលស្លែងដោយជឿថាពួកខ្មែរក្រហមអាចសម្លាប់ ម៉ែឃឹល នៅទីនោះ មុនពេលកងទ័ពវៀតណាមវាយរុញច្រានយ៉ាងសន្ធាប់ចូលក្រុងភ្នំពេញ ។ ខាល ធ្វើដូច្នោះដោយឈរលើហេតុផលថា «ចម្លើយសារភាពរបស់ ម៉ែឃឹល ចុះថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។ ពួកខ្មែរក្រហមពុំមានពេលគ្រប់គ្រាន់ដើម្បីយក «អ្នកទោស» ចុងក្រោយទៅសម្លាប់នៅជើងឯកនោះទេ ។ ប្រសិនបើខ្មែរក្រហមសម្លាប់ មុខជាសម្លាប់នៅទួលស្លែង» ។ នៅថ្ងៃចុងក្រោយ ខាល រកឃើញឆ្អឹងរបស់ជនរងគ្រោះ២នាក់ ដែលសង្ស័យថាជាឆ្អឹងរបស់ ម៉ែឃឹល និង គ្រីស ក៏ប៉ុន្តែក្រោយមកទទួលពត៌មានថា មិនមែនទេវិញ ។ ខាល វិលត្រឡប់ទៅអាមេរិកវិញ ។ ក្នុងឆ្នាំ១៩៨៩ ខាល ត្រឡប់មកកម្ពុជាម្តងទៀត អដ្ឋិធាតុរបស់ ម៉ែឃឹល ក៏នៅតែរកពុំឃើញ ។ ខាល បានស្លាប់ដោយជម្ងឺមហារីក នា ខែវិច្ឆិកា ឆ្នាំ១៩៩៩ ។

មុនពេល ខាល ស្លាប់ ខាល បានពឹងមិត្តភក្តិគឺលោក ក្រេក អ៊ិចឆេសាន់ និង ឆាំង យុ ។ ឲ្យរៀបចំពិធីបុណ្យបង្សុកូលនៅវត្តខណ្ឌលោម ដោយជឿថា អារម្មណ៍របស់ ម៉ែឃឹល បានទៅកាន់សុគតិភព ។ **ផេង ពង្សរ៉ាស៊ី**

(រាយការណ៍បន្ថែមដោយ ភីតធ័រ ម៉ាឃៀរ)

## ពាក្យស្លោកខ្មែរក្រហម

◆ ប្តេជ្ញាជម្រុះ និងកម្ទេចរបបសក្តិភូមិ អភិជន និងចក្រពត្តិ ដែលសុទ្ធតែជាប្រតិកិរិយា!

◆ ប្តេជ្ញាកម្ទេចឱ្យអស់ខ្មាំងស៊ីរូងផ្ទៃក្នុង សេ.អ៊ី.អា កា.សេ.បេ!

◆ ប្តេជ្ញាពលីជីវិតបំពេញពលកម្មជូនអង្គការ!

◆ អង្គការចម្រាញ់យក តែជនមិនចេះឡើយហត់!

◆ គ្រាន់តែឮឈ្មោះអង្គការញាក់សាច់!

# ជីវិតខ្ញុំក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

ស្វាយឃ្លាំងគឺជាភូមិកំណើតរបស់ខ្ញុំ ស្ថិតក្នុងទឹកដីស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម មានប្រជាជនរស់នៅ១២៤០គ្រួសារ នៅមុនឆ្នាំ១៩៧៣ ។ ប៉ុន្តែជាអកុសល ចាប់ពីឆ្នាំ១៩៧៣មក ភូមិនេះបានរងនូវគ្រោះវិនាសកម្មយ៉ាងធ្ងន់ធ្ងរ ព្រោះកិច្ចការនយោបាយនៃក្រុមមួយបានចូលជ្រៀតជ្រែករំខានដល់សេចក្ដីសុខក្សេមក្សាន្តរបស់អ្នកភូមិ ។ ពេលនោះអ្នកភូមិទូទៅស្គាល់ថា «រណសិរ្សរំដោះជាតិ» ហើយក្រោយមកទើបដឹងថានោះជា «ខ្មែរក្រហម» ទៅវិញ ។ ដើម្បីបម្រើនយោបាយព្រៃផ្សៃរបស់ក្រុមនេះធ្វើឲ្យជីវិតអ្នកភូមិរាប់រយនាក់បានស្លាប់យ៉ាងវេទនា ផ្ទះសម្បែងរាប់សិបខ្នងត្រូវបាត់បង់ វិហារធំៗពីរនៅសល់ត្រឹមតែខឿនទទេនិងប៉មមួយ ហើយសាលារៀនស៊ូរ៉ាវ (ទីកន្លែងសម្រាប់ថ្វាយបង្គំព្រះមានទំហំតូចជាងវិហារ) ត្រូវបាត់បង់ទាំងស្រុង ។

សព្វថ្ងៃនេះ ពេលសម្រាកបុណ្យទានម្ដងៗខ្ញុំបានទៅលេងស្រុកកំណើត ហើយធ្វើដំណើរកាត់តាមខឿនវិហារដែលមានប៉មមួយនៅសល់នេះ ។ ខ្ញុំតែងតែនឹកឃើញអំពីអតីតកាលដ៏រុងរឿងនៃភូមិកំណើតរបស់ខ្ញុំដែលអ្នកណាក៏ធ្លាប់ទទួលដឹងថា ស្វាយឃ្លាំងគឺជាភូមិសំបូរសប្បាយ មានអ្នកចេះដឹងច្រើន និងមានសភាពអ៊ូអរគួរឲ្យចង់រស់នៅ ។

នៅឆ្នាំ១៩៨៦ មានរឿងមួយដែលធ្វើឲ្យខ្ញុំស្ដុតអារម្មណ៍ គឺនៅពេលដែលខ្ញុំកំពុងជីកដីលើកធ្វើខឿនវិហារថ្មី ខ្ញុំបានប្រទះឃើញឆ្អឹងខ្មោចជាច្រើននៅកប់ក្នុងដី គ្មានអ្នកណាម្នាក់ដឹងថានៅទីនោះជាកន្លែងកប់ខ្មោចឡើយ ។ ភ្លាមនោះខ្ញុំក៏បាននឹកឃើញដល់សម្ដីឪពុកម្ដាយខ្ញុំធ្លាប់និយាយប្រាប់ខ្ញុំថា មិនដឹងជាជីដូន ជីតា និងអ៊ំពូរបស់ខ្ញុំស្លាប់នៅកន្លែងណាទេនៅពេលបះបោរក្នុងភូមិនេះ ។ ខ្ញុំនឹកឆ្ងល់ក្នុងចិត្តថា តើឆ្អឹងនេះជាឆ្អឹងរបស់យាយតាខ្ញុំ អ៊ំពូខ្ញុំ ឬក៏ជាឆ្អឹងរបស់អ្នកណា ។ គ្មានអ្នកណាម្នាក់អាចប្រាប់ខ្ញុំបានទេ ប៉ុន្តែខ្ញុំគ្រាន់តែនឹកក្នុងចិត្តទាំងក្ដុកក្ដួលថា គ្មានអ្នកណាក្រៅពីអ្នកភូមិខ្ញុំទេ ដែលបានស្លាប់ចោលឆ្អឹងទីនេះនៅពេលបះបោរ ។ ចលនានៃការងើបតស៊ូប្រឆាំងនឹងពួកខ្មែរក្រហម នៅភូមិស្វាយឃ្លាំងជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដែលអ្នកភូមិស្វាយឃ្លាំងស្ទើរតែគ្រប់ៗរូបបានចងចាំនិងដឹងច្បាស់ ហើយជានិច្ចកាលតែងតែដំណាលប្រាប់ខ្ញុំជាហូរហែ ទើបខ្ញុំយល់ថា មិនមែនតែកន្លែងនោះមួយទេដែលមានឆ្អឹងខ្មោច ប៉ុន្តែស្ទើរតែពាសពេញផ្ទៃដីនៃភូមិស្វាយឃ្លាំងទាំងមូលសុទ្ធតែជាផ្នូរសម្រាប់កប់សាកសពអ្នកតស៊ូដែលត្រូវយោធាខ្មែរក្រហមបាញ់សម្លាប់ចោលអស់រាប់រយនាក់ ។

អំពីមូលហេតុនៃការបះបោរក្នុងភូមិស្វាយឃ្លាំង ខ្ញុំបានឮឪពុកម្ដាយ និងអ្នកភូមិនិយាយប្រាប់ខ្ញុំថា «នៅថ្ងៃទី៨ ខែតុលា ឆ្នាំ១៩៧៥ វេលាម៉ោង៦ល្ងាច ពួកខ្មែរក្រហមបានចាប់ផ្ដើមធ្វើសកម្មភាពចាប់ប្រជាជន ពួកវាចាប់ប្រជាជនបានពីរនាក់ ហើយពេលនោះប្រជាជនមានការជ្រួលច្របល់យ៉ាងខ្លាំង ហើយបានក្រោកឡើងធ្វើការតបតនឹងពួកខ្មែរក្រហម ។ ពេលកម្លាំងបះបោរកាប់មេខ្មែរក្រហមស្លាប់ម្នាក់ហើយរើសបានបញ្ជីវាមួយ ក្នុងបញ្ជីនោះឃើញមានឈ្មោះអ្នកភូមិចំនួន៨៥នាក់ សម្រាប់ផែនការចាប់ក្នុងយប់នោះ ។ ការចាប់មនុស្សនេះមិនមែនជាលើកទីមួយទេ ប៉ុន្តែតាំងពីឆ្នាំ១៩៧៣ ដល់ខែតុលា ឆ្នាំ១៩៧៥ នេះមានអ្នកភូមិចំនួន៩៥នាក់ហើយដែលត្រូវពួកវាចាប់យកទៅហើយមិនដែលឃើញត្រឡប់មកវិញសោះ ។ ម្យ៉ាងទៀត មុនថ្ងៃបះបោរនេះបន្តិចក៏មានការប្រមូលគម្ពីគូរអានយកទៅដុតចោល បង្ខំឲ្យបិទទ្វារវិហារ សាលារៀន និងបង្ខំឲ្យនារីកាត់សក់ខ្លី ។

ថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ជាថ្ងៃដែលពួកខ្មែរក្រហមវាយដណ្ដើមបានទីក្រុងភ្នំពេញ ហើយចាប់ផ្ដើមជម្លៀសប្រជាជនចេញពីទីក្រុងឲ្យទៅតាមជនបទ ។ ប៉ុន្តែក្នុងភូមិស្វាយឃ្លាំងឯណោះវិញ នៅថ្ងៃនោះពុំមានសភាពអ្វីខុសពីប្រក្រតីទេ រហូតដល់ថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៧៥ ទើបមានការជម្លៀសប្រជាជនចេញពីភូមិ ពោលគឺការជម្លៀសនេះចាប់ផ្ដើមនៅពេលដែលកម្លាំងបះបោរក្នុងភូមិផ្ទុះឡើង ហើយត្រូវបរាជ័យទៅវិញ ។ ករណីនេះបានធ្វើឲ្យជនជាតិចាមជាច្រើននាក់បានយល់ឃើញថា

មូលហេតុនៃការជម្លៀសជនជាតិចាមក្នុងប្រទេសកម្ពុជាទាំងមូល គឺបណ្តាលមកពីមានការបះបោរនៅភូមិស្វាយឃ្លាំងនិងនៅភូមិជិតខាងគឺភូមិកោះផលនេះឯង ។

ខ្ញុំបានជួបអ្នកភូមិខ្ញុំជាច្រើនដែលនៅសេសសល់ពីស្លាប់ អ្នកខ្លះនិយាយប្រាប់ខ្ញុំថាគាត់បានជម្លៀសទៅដល់ខេត្តកំពង់ធំ ខ្លះថាគាត់ត្រូវបានបញ្ជូនដល់ខេត្តព្រះវិហារ ហើយអ្នកខ្លះទៀតប្រាប់ខ្ញុំថាគាត់ត្រូវពួកខ្មែរក្រហមឲ្យទៅរស់នៅក្នុងតំបន់គ្រនចាញ់ ស្រុកតំបែ ខេត្តកំពង់ចាម ។ គ្រួសារខ្ញុំត្រូវដឹកតាមកបាល់មួយរួមជាមួយអ្នកភូមិបួនប្រាំគ្រួសារទៀត ទៅចតនៅទីរួមខេត្តក្រចេះ រួចមានឡានមួយដឹកបន្តឆ្ពោះទៅកាន់តំបន់ព្រៃភ្នំ ។ ទៅដល់ទីកន្លែងមួយក្នុងព្រៃដ៏សែនស្ងាត់ដែលខ្ញុំនៅចាំថាគេហៅថា «ព្រៃអាប៉ោយ» ខ្ញុំឃើញមានខ្ទមតូចៗប្រក់ស្បូវប្រមាណជាងដប់ខ្ទម ។ ឡាននោះបានឈប់នៅទីនោះ មានយោធាក្នុងឯកសណ្ឋានខ្មៅបានបញ្ជាឲ្យមនុស្សនៅលើឡានទាំងអស់ចុះ និងឲ្យស្នាក់នៅក្នុងខ្ទមតូចៗកណ្តាលព្រៃនោះ មើលទៅហាក់ដូចជាហ្វូងមនុស្សដែលត្រូវគេយកទៅបំបរបង់ចោលរង់ចាំសេចក្តីស្លាប់ ។ នៅជុំវិញខ្ទម ខ្ញុំបានឃើញសុទ្ធតែផ្នូរខ្មោចថ្មីៗ ។ ខ្ញុំនៅចាំច្បាស់ជាងគេគឺខ្ញុំឃើញមនុស្សចាស់ៗ ទាំងឪពុកម្តាយខ្ញុំ ទាំងអ្នកផ្សេងទៀត ហាក់ដូចជាមានការព្រួយបារម្ភយ៉ាងខ្លាំង ប៉ុន្តែកាលណោះខ្ញុំនៅតូច ខ្ញុំពុំបានយល់អ្វីសោះ ការពិតគ្រប់ៗគ្នាកំពុងនឹកគិតអំពីជោគវាសនារបស់ខ្លួនពេលឃើញផ្នូរខ្មោចនេះព្រោះគិតថាអ្នកដែលស្លាប់ហើយកប់ក្នុងផ្នូរនេះប្រហែលជាអ្នកដែលបានមករស់នៅលើខ្ទមនេះមុនយើង ។ រួចក៏គិតថាមិនយូរមិនឆាប់ ខ្មែរក្រហមនឹងសម្លាប់ពួកយើងចោលព្រោះយើងសុទ្ធតែជាឈ្លើយសឹក ហើយសាកសពយើងក៏ត្រូវកប់នៅទីនេះដូចផ្នូរដែលយើងបានឃើញស្រាប់នេះហើយ ។

បន្តិចក្រោយមក ទាំងអស់គ្នាហាក់ដូចជាមានអារម្មណ៍ល្អឡើងវិញ ព្រោះក្រោយពីស្នាក់នៅទីនោះបានប្រហែលកន្លះខែ ពួកខ្មែរក្រហមបានបំបែកទៅតាមភូមិផ្សេងៗទៀតដោយបែងចែកគ្នាក្នុងមួយភូមិបញ្ចូលគ្រួសារចាមមួយគ្រួសារ ហើយចំណែកគ្រួសារខ្ញុំត្រូវដើរទៅនៅក្នុងភូមិមួយឆ្ងាយពីទីនោះប្រហែល ៧គីឡូម៉ែត្រ ។ ភូមិនោះ ឈ្មោះភូមិ «កំបោរ» ។ រស់នៅទីនោះមួយរយៈទើបដឹងថា ប្រជាជនដែលរស់នៅក្នុងភូមិនោះក៏សុទ្ធតែជាអ្នកជម្លៀសមកពីភ្នំពេញដែរ ។


អ៊ីសា ខស្មាន

នៅភូមិកំបោរ ឪពុកខ្ញុំត្រូវបានបញ្ជូនទៅឲ្យនេសាទនៅ «ពាមទេ» ជិតទីរួមខេត្តក្រចេះ បងប្រុសខ្ញុំពីរនាក់ឲ្យទៅនៅកងចល័ត ម្តាយខ្ញុំត្រូវទៅធ្វើស្រែទាំងយប់ទាំងថ្ងៃ ហើយខ្ញុំត្រូវបានប្រើឲ្យទៅកាប់ដើមទន្ទ្រានខែត្រ និងសែងអាចម៍គោ ចំណែកប្អូនស្រីតូចរបស់ខ្ញុំដែលមានអាយុមិនទាន់បានមួយឆ្នាំផងត្រូវទុកនៅជាមួយយាយចាស់ៗក្នុងរោងបាយ ។ ពេលនោះជាលើកដំបូងហើយក្នុងជីវិតរបស់ខ្ញុំដែលត្រូវព្រាត់ប្រាសពីគ្រួសារដ៏កក់ក្តៅ ដែលពីមុនមកមិនធ្លាប់បែកឆ្ងាយពីគាត់បន្តិចសោះ

ហើយក៏ជាពេលវេលាដែលធ្វើឲ្យខ្ញុំដឹងថាខ្ញុំស្រលាញ់ឪពុកម្តាយ



ប៉ុនណានោះ ។ ពេលសម្រាកម្តងៗខ្ញុំរត់ទៅមើលប្អូនតូចរបស់ខ្ញុំ ពេលវាយំឃ្លានបៅខ្ញុំឃើញយាយចាស់ៗដួសទឹកបបរបញ្ចុកប្អូន ខ្ញុំជំនួសទឹកដោះម្តាយ ជួនកាលសូម្បីតែទឹកបបរនោះក៏គ្មានទៀតផង ។ ខ្ញុំអាណិតប្អូនតូចខ្ញុំណាស់ ពេលនោះខ្ញុំដឹងថា ខ្ញុំបាត់អស់ទាំងស្រុងនូវសេចក្តីសុខទាំងប៉ុន្មាន ព្រោះឪពុកម្តាយជាមនុស្សដែលខ្ញុំស្រលាញ់ទុកចិត្តជាងគេបំផុតក៏ត្រូវព្រាត់ប្រាសទាំងអស់ ។ ខ្ញុំទន្ទឹងចាំមើលផ្លូវម្តាយត្រឡប់មកពីធ្វើការវិញយ៉ាងអន្ទះអន្ទែង ខ្ញុំខំសម្លឹងតាមភ្លឺស្រែដែលគាត់ដើរទៅកាលពីព្រឹកមិញនេះ ប៉ុន្តែបានឃើញត្រឹមតែហ្វូងក្មេងតូចៗ កំពុងសែងបង្គីយ៉ាងញាប់ដៃញាប់ជើង ។ រាល់ពេលយប់ស្ងាត់ហើយមានភ្លៀងធ្លាក់ធំៗ ខ្ញុំតែងតែលួចឃើញម្តាយខ្ញុំយំ គាត់ស្ទាបក្បាលខ្ញុំហើយនិយាយប្រាប់ខ្ញុំថា «ពេលភ្លៀងធំថ្មើណេះហើយ បងឯងនៅកងចល័តកំពុងលើកទំនប់ទាំងកណ្តាលភ្លៀង ឪពុកឯងកំពុងផ្សងគ្រោះថ្នាក់នឹងទឹករលកភ្លៀងខ្យល់កណ្តាលទន្លេ» ។ នៅឆ្នាំ១៩៧៦ ប្អូនស្រីតូចរបស់ខ្ញុំត្រូវស្លាប់ដោយខ្វះទឹកដោះម្តាយ បងប្រុសទីពីរខ្ញុំត្រូវស្លាប់ដោយទុរ្ភិក្សទុរាធ្វើការហួសកម្លាំង ។ **អ៊ីសា ឧស្មាន**

**ជូនចំពោះលោកប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជា**

តាងនាមឲ្យថ្នាក់ដឹកនាំនៃគណបក្សប្រជាជនកម្ពុជា និងក្នុងនាមខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះលោកប្រធានដែលបានផ្តល់នូវទស្សនាវដ្តីមួយចំនួននៃមជ្ឈមណ្ឌលឯកសារកម្ពុជាក្រោមចំណងជើងថា «ស្វែងរកការពិត» ដល់គណបក្សប្រជាជនកម្ពុជានិងរូបខ្ញុំផ្ទាល់ ។

ខ្ញុំសូមកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះស្នាដៃរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានតស៊ូព្យាយាមចងក្រងបាននូវឯកសារដ៏មានប្រយោជន៍នេះហើយខ្ញុំសង្ឃឹមថាលោកប្រធាននឹងមេត្តាបន្តផ្តល់ដល់យើងខ្ញុំនូវឯកសារសំខាន់ៗថ្មីៗទៀតជាពុំខាន ។

ខ្ញុំសូមប្រសិទ្ធិពរជូនលោកប្រធាន និងសហការីទាំងអស់ សូមមានសុខភាពល្អ និងទទួលជោគជ័យជានិច្ចក្នុងបេសកកម្មរបស់ខ្លួន ។ សូមលោកប្រធានទទួលនូវមនោសញ្ចេតនារាប់អានដ៏ស្មោះស្ម័គ្រពីខ្ញុំ ។

ប្រធានគណៈប្រចាំការគណៈអចិន្ត្រៃយ៍
គណៈកម្មាធិការកណ្តាល
**សាយ ឈុំ**

**លិខិតពីលោកជំទាវ ស៊ីង ស៊ីយុត**
**ជម្រាបជូនលោកប្អូន យុ**

អរគុណចំពោះអ្វីៗដែលបានផ្តល់មកឲ្យបង ។ បងនៅជាមួយប្អូនៗជានិច្ច ។ សូមសរសើរដោយស្មោះចំពោះការងារជាប្រវត្តិសាស្ត្រនេះ ។ អ្នកដែលបានចាកស្ថានទៅ ស្ងប់ចិត្តនៅពេលដែលការកាត់ទោសដំណើរការបាន ។

ជាកិច្ចតបវិញ បងសូមជូនវត្ថុធម្មនុញ្ញកែប្រែថ្មីនេះជូនប្អូននិងសហការីទុកជាឯកសារត្រិះរិះ ពិចារណានិងជាជំនួយស្មារតី ។

សូមប្អូនៗនិងសហការីបានទទួលជោគជ័យជានិច្ច ។

ពីបង ៥-៦-២០០០

សូមសរសេរលិខិត
ឬអត្ថបទពិភាក្សាជុំវិញបញ្ហាខ្មែរក្រហមមកកាន់
**ទស្សនាវដ្តី «ស្វែងរកការពិត»**
ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ឬតាមទូរសារលេខៈ (៨៥៥) (២៣) ២១០៣៥៨
ឬ Email: dccam@bigpond.com.kh

## គោរពជូន លោកនាយកមជ្ឈមណ្ឌលឯកសារកម្ពុជា «ស្វែងរកការពិត»

ខ្ញុំសូមអរគុណជាអនេកដែលលោកនាយកបានផ្ញើទស្សនាវដ្ដី «ស្វែងរកការពិត» ចំនួន៥លេខមកខ្ញុំ ។

ទោះជាខ្ញុំមានការរវល់មមាញឹកក្នុងភារកិច្ចរបស់ខ្ញុំយ៉ាងណាក៏ខ្ញុំបានឆ្លៀតឱកាសមើលអត្ថបទមួយចំនួនរបស់ទស្សនាវដ្ដី «ស្វែងរកការពិត» ដែរ ។ រាល់ពេលដែលខ្ញុំបើកមើលម្ដងៗ ខ្ញុំហាក់ដូចជាស្រមៃឃើញឡើងវិញនូវសម័យកាលដ៏សែនលំបាកវេទនាដែលខ្ញុំរស់នៅក្រោមរបបប៉ុលពតនេះ ។ ខ្ញុំបានវិលមកដល់ព្រលានយន្តហោះពោធិចិនតុងថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៧៦ ។ ខ្ញុំត្រូវបានអង្គការដកលិខិតឆ្លងដែនទុកហើយបញ្ជូនតាមរថយន្តបឺសមកដល់សាលា Institut Technique Khmère-Soviétique ។ បន្ទាប់មកខ្ញុំត្រូវមករៀបចំមន្ទីរសាងខ្លួននៅបឹងត្របែក ហៅថា «ប ៣០» ។ ខ្ញុំធ្លាប់ត្រូវអង្គការបញ្ជូនឲ្យទៅធ្វើស្រែនៅភូមិតាឡីជាប់នឹងជើងឯក និងនៅខាងជើងប្រាំងចំរេះ ។ ទន្ទឹមនឹងនេះក្រៅពីការងារដ៏មហាសែនលំបាកវេទនា ខ្ញុំត្រូវអង្គការឲ្យធ្វើផែនទីកម្ពុជាប្រជាធិបតេយ្យ ព្រោះអង្គការដឹងថាខ្ញុំជា Ingénieur des Géomètres ។ អត្ថបទដែលលោកបានស្រាវជ្រាវនោះមានអត្ថបទខ្លះខ្ញុំក៏បានដឹងដូចគ្នាដែរ ព្រោះក្រោយពីរដ្ឋប្រហារឆ្នាំ១៩៧០ ខ្ញុំបានចូលជាសមាជិករណសិរ្ស FUNK ។ ខ្ញុំបានរៀនសូត្រវគ្គនយោបាយច្រើនលើកច្រើនសាជាមួយថ្នាក់ដឹកនាំអង្គការ ក្នុងពេលដែលខ្ញុំរស់នៅទីក្រុងភ្នំពេញពីឆ្នាំ១៩៧៦ ដល់១៩៧៩ ។ តាំងពី ឆ្នាំ១៩៨២ ខ្ញុំធ្លាប់បានធ្វើជាអគ្គរដ្ឋទូតនិងទូតគោចរនៅអាមេរិកឡាទីននិងអាហ្វ្រិក ហើយខ្ញុំក៏ធ្លាប់ដើរនិយាយពន្យល់សកលលោកពីរបបប្រល័យពូជសាសន៍នេះដែរ ។ ខ្ញុំសូមអរគុណលោកនាយកជាថ្មីម្ដងទៀតដែលបាននាំអារម្មណ៍ខ្ញុំឲ្យដើរតាមអត្ថបទរបស់ទស្សនាវដ្ដី «ស្វែងរកការពិត» ហើយបានស្រមៃឃើញជីវិតខ្ញុំក្នុងរបបប្រល័យពូជសាសន៍នោះហាក់ដូចជានៅថ្មីៗសោះ ។ សូមលោកនាយកទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រពីខ្ញុំ ។

ភ្នំពេញ, ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០០

**ឡុង វិសាលោ** *(អនុរដ្ឋលេខាធិការក្រសួងការបរទេសនិងកិច្ចសហប្រតិបត្តិការអន្តរជាតិ)*



ចម្រៀងខ្មែរក្រហម

# រដូវវស្សាហើយយើងប្រមូលកម្លាំងសម្រុកធ្វើស្រែ

ផ្គរលាន់ដើមឆ្នាំ
ប្រញាប់ប្រញាល់
ផ្គរលាន់គ្រឹមៗ
យើងខ្ញុំយុវ៌ន
រដូវវស្សាហើយ
សម្រុកធ្វើស្រែ
យើងខ្ញុំនារី
ទាំងពូជទាំងដី
យើងខ្ញុំយុវ៌ន
ភ្ជួររាស់ឲ្យសព្វ
ស្រែយើងអស់ទឹក
មានស្មឹងមានបឹង
យើងបន្តភ្ជួរ
សន្ទូងយើងដុះ
យើងខ្ញុំរើសពូជ
ដើម្បីបង្កើន
ប្តេជ្ញាៗ
ធ្វើស្រែឆ្នាំនេះ

រណ្តំមេឃា
ឱបងប្អូនអើយ
រលឹមតក់ៗ
ស្រវ៉ានង្គ័ល
មិត្តអើយខំប្រឹង
ឲ្យបានផលទ្វេ
មូលមីរញាប់ដៃ
រីករាយកន្ទង
ដៃកាន់នង្គ័ល
សសុសអស់ដី
ប្រញឹកដោះស្រាយ
ទន្លេហូរកាត់
រាស់អស់ដីយើង
យើងខ្ញុំប្រឹងថែ
បាចជីរជាមួយ
ផលឲ្យបានច្រើន
ប្រមូលកម្លាំង
ឲ្យបានផលា

ជាសញ្ញាថា
ធ្វើពីដើមដៃ
ភ្លៀងធ្លាក់ទឹកដក់
រនាស់ខ្វាយខ្វល់
យើងផ្តុំកម្លាំង
ក្នុង១ហិកតា
កញ្ជើនិងល្អី
សំណាបបំព្រង
ប្តេជ្ញាយកផល
ប្រព័ន្ធភ្លឺថ្មី
យើងមានប្រឡាយ
យើងជាន់រហាត់
យើងដកស្ទូងផង
ជនបទយើងប្រែ
យើងខ្ញុំលើកស្ទួយ
ផលិតកម្មយើងកើន
វាយសម្រុកខ្លាំង
រួមសាងកម្ពុជា

វស្សាដល់ហើយ
ស្រូវយើងហុចផល ។
នៅសព្វមណ្ឌល
ភ្ជួររាស់ទាន់ពេល ។
ឥតបីទំនេរ
លើសពីពដង ។
សាបផងបាចផង
លាស់ឡើងខៀវខ្ចី ។
ឲ្យច្រើនក្រាស់ក្រៃ
ចាំងចែងពីកើត ។
ភ្លឺត្រង់ខ្វែងខ្វាត់
បញ្ចូលទឹកស្រែ ។
ជាប់ជាហូរហៃ
ខៀវស្រស់បំព្រង ។
គុណភាពដីយើង
ជីវភាពធូរធារ ។
មហាអស្ចារ្យ
មហាលោតផ្លោះ ។

**កត់ត្រាចងក្រងជាឯកសារ**

**កញ្ញា សើ សាយ្យាណា**


***ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុក និងឃុំ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ទស្សនាវដ្តីចំនួន១០០០ក្បាលជារៀងរាល់លេខនឹងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ មួយច្បាប់ក្នុងតម្លៃ ៧០០០រៀល***

*មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្តីនេះទៅតាមលទ្ធភាពដែលអាចធ្វើបានៗ ព័ត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្តីស្វែងរកការពិត សូមមេត្តាទាក់ទងមកកាន់នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!*

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of Searching for the Truth!. For contribution, please contact (855) 23 211 875 or By Email: dccam@bigpond.com.kh. Thank you.



A magazine of the Documentation Center of Cambodia: Searching for the Truth! Number 7, July 2000
Funded by the Royal Ministry of Foreign Affairs, Oslo, Norway, Section for the Human Rights and Humanitarian Assistance; and the Canada Funds, Canadian Embassy, Phnom Penh, Cambodia